# ពាក្យបរិយាយដើមនៃរឿងសាមកុក

# របស់

# ឃ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

រឿងសាមកុកនេះ ជារឿងរ៉ាវផ្នែក១ កាលពីក្នុងរវាងខាងចុងសតវត្សរ៍ទីពីរ និងខាងដើមសតវត្សរ៍ទីបីនៃគ្រិស្តសករាជ។ កាលចាប់ផ្ដើមកើតរឿងឡើង គេមិនបានកត់ត្រាជាអក្សរទុកមកតាំងពីដំបូងទេ គ្រាន់តែជារឿងនិយាយតំណាលតៗគ្នាមក។ ដល់សម័យតមកក្រោយទៀត ប្រជាជនចិននិយមយករឿងសាមកុកនេះទៅលេងល្ខោន ដែលយើងហៅថាលេងហី ទើបនាំឲ្យរឿងសាមកុកនេះសាយភាយចេញទៅ មានអ្នកចេះដឹងរឿងរ៉ាវនេះកាន់តែច្រើនឡើងៗ ទើបអ្នកប្រាជ្ញចិនរួបរួមចងក្រងកត់ត្រាទុកជាអក្សរតមក។ ដល់សម័យស្រុកចិនចេះឆ្លាក់ពុម្ពអក្សរហើយ គេបានបោះពុម្ពផ្សាយរឿងសាមកុកនេះជាសៀវភៅឡើង ជាដើមហេតុនាំឲ្យរឿងសាមកុកសាយភាយទូទៅក្នុងប្រទេសចិន រហូតដល់នានាប្រទេសផង។

បើយើងពិគ្រោះមើលសេចក្ដីផ្ទៃរឿងនៃសាមកុកនេះ នឹងយល់ថា អ្នកនិពន្ធរឿងនេះមានបំណងចង់ចងក្រងផ្ទៃរឿង ឲ្យទៅជាតម្រាសិក្សាខាងផ្លូវនយោបាយស្រុកទេសផង ខាងផ្លូវកិច្ចកលក្នុងសឹកសង្គ្រាមផង ហើយតែងបានល្អហូរហែគួរឲ្យសរសើរដល់គំនិត និងសេចក្ដីព្យាយាមរបស់អ្នកនិពន្ធរឿងសាមកុកនេះណាស់។ ហេតុនេះហើយបានជារឿងសាមកុកនេះបានផ្សាយចេញក្រៅ មិនត្រឹមតែក្នុងស្រុកចិន រហូតដល់នានាប្រទេសផង។

ចំពោះប្រទេសសៀម គេបានប្រែរឿងសាមកុកចេញពីភាសាចិនជាលើកដំបូង កាលពី ព.ស ២៣៤៥ ក្នុងសម័យដែលមិនទាន់មានរោងពុម្ពសម្រាប់បោះពុម្ពសៀវភៅនៅឡើយ។ ដល់សម័យកើតរោងពុម្ពសៀវភៅផ្សេងៗបានហើយ គេក៏បានចាត់ការបោះពុម្ពរឿងសាមកុកនេះផ្សាយជាច្រើនលើកដែរ។ រឿងសាមកុកដែលគេបានចាត់ការបោះពុម្ពលើកក្រោយបង្អស់ក្នុង ព.ស ២៤៧០ ប្រហែលជាច្បាប់បោះពុម្ពលើកក្រោយនេះហើយ ដែល**អ្នកឧកញ៉ាវិបុលរាជសេនា** “**កន**” តំណាងរាស្ត្រ បានប្រែចេញជាខេមរភាសាចប់សព្វគ្រប់ តែគ្មានឱកាសនឹងបោះពុម្ពផ្សាយរឿងនេះ តមកជាច្រើនឆ្នាំ ។ ក្រោយបំផុតលោកបានយកសំណៅប្រែរឿងសាមកុក មកប្រគល់ឲ្យពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យចាត់ការបោះពុម្ពផ្សាយតាមត្រូវការ។ យើងសូមពោលជាតំណាងតាងនាមពុទ្ធសាសនបណ្ឌិត្យ សូមសម្តែងអំណរអរគុណចំពោះអ្នកឧកញ៉ាវិបុលរាជសេនា “កន” ហើយសូមសរសើរសេចក្តីព្យាយាម ដែលបានខំខ្វល់ខ្វាយប្រែរឿងដ៏វែងនេះត្រាតែចប់សព្វគ្រប់។ ប៉ុន្តែក្នុងឱកាសសព្វថ្ងៃនេះ ពុទ្ធសាសនបណ្ឌិត្យ មិនអាចចាត់ការបោះពុម្ពផ្សាយជាសៀវភៅដាច់ដោយឡែកទៅបាន ទើបនាំយករឿងនេះមកចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយា នេះជាបណ្តើរៗទៅសិន។

ឯផ្ទៃរឿងសាមកុកនេះ បើសរុបសេចក្តីឲ្យខ្លីតាមអត្ថាធិប្បាយរបស់ក្រុមព្រះដាំរ៉ុងរាជានុភាព អ្នកប្រាជ្ញប្រវត្តិសាស្ត្រជាតិថៃ ដូចមានសេចក្តីតទៅនេះ៖

“រឿងសាមកុកនេះ ចាប់ផ្តើមមានរឿងកើតឡើង ក្នុងរជ្ជកាលព្រះបាទ**ឡេនតេ** កាលពី ព.ស ៧១១ (រវាង គ.ស ១៥៨) ដែលជាបឋមហេតុបណ្តាលឲ្យព្រះរាជាណាចក្រចិនបែកខ្ញែកចេញទៅជាបីភាគ ដែលចិនហៅថា “**សាមកុក**”។ ព្រះមហាក្សត្រព្រះអង្គនេះ ឥតសមត្ថភាព ទ្រង់ជឿស្តាប់ពាក្យទូលញុះញង់របស់ពួកខន្ទី (ពួក

មនុស្សប្រុសកម្រៀវក្នុងព្រះរាជដំណាក់) ពួកមន្ត្រីតូចធំក្នុងក្រុងក៏គ្មានអ្នកណាមួយខ្លាំងពូកែ ល្មមជាទីគោរពកោតក្រែងរបស់ជនទូទៅ រាជការផែនដីក៏ល្អៀងឃ្លៀងឃ្លាតចាកផ្លូវសុចរិតយុត្តិធម៌ ពួកចោរកំណាចក៏ឡើងចាង ទូទៅ ដរាបដល់ទ្រង់ទិវង្គតទៅ។ ក្សត្រព្រះអង្គនេះទ្រង់មានព្រះរាជបុត្រពីរព្រះអង្គ ព្រះអង្គច្បងព្រះនាម **ហង់ជូពៀន** ទ្រង់ទទួលគ្រងរាជ្យជាតំណព្រះរាជវង្ស តែព្រះនាង**ហ្វូហៅ** ជាព្រះវរជននីស្តីរាជការផែនដីជំនួស ព្រោះព្រះរាជបុត្រនៅកុមារណាស់។ ព្រះរាជបុត្រអនុជព្រះនាម **ហង់ជូហៀប** កំព្រាព្រះជននី នាង**តាំងថៃហ** ជាអយ្យិកាចិញ្ចឹមតាំងពីនៅជាទារក ហើយក៏ខ្វល់ខ្វាយចង់ឲ្យចៅបានរាជសម្បត្តិ ទើបនាងទាំងពីរទៅជាអរិនឹងគ្នា។ ក្រោយព្រះបាទ**ឡេនតេ**ទិវង្គតទៅនោះ **ហ្វូជិន**ជាបងព្រះនាង**ហ្វូហៅ** បានធ្វើជាមន្ត្រីធំក្នុងព្រះរាជវាំង ធ្វើកលឧបាយឲ្យគេសម្លាប់នាង**តាំងថៃហ** ហើយគិតកម្ចាត់ពួកខន្ទីចេញទៀត ប៉ុន្តែព្រះនាង**ហ្វូហៅ**រារាំងការពារពួកខន្ទី។ តមក **ហ្វូជិន** លបមានចុតហ្មាយសម្ងាត់ទៅដល់**តាំងតុះ** ចៅហ្វាយស្រុក**ឈើឡុង** ឲ្យលើកទ័ពទៅបង្ក្រាបពួកខន្ទីៗបានដឹងរឿង ក៏ធ្វើកលល្បួងឲ្យ**ហ្វូជិន**ចូលទៅក្នុងវាំង ព្រួតដៃគ្នាចាប់**ហ្វូជិន**សម្លាប់ទៅ។ ពួកខាង**ហ្វូជិន**បានដឹង ខឹងណាស់ក៏នាំគ្នាដុតព្រះរាជវាំងហើយលើកគ្នាចូលលុកលុយកាប់សម្លាប់ពួកខន្ទីជាចលាចល។ ក្សត្រគ្រងរាជ្យទ្រង់គេចរត់ទៅស្នាក់នៅទីដទៃ។ ឯ**តាំងតុះ** កាលបានឱកាសជាប្រយោជន៍ដល់ខ្លួន ក៏លើកទ័ពចូលក្រុងបង្ក្រាបការចលាចលរាបទាបហើយ ទើបដកព្រះមហាក្សត្រ និងព្រះនាង**ហ្វូហៅ**ជាព្រះវរជននីចេញចាករាជសម្បត្តិ លើក**ហង់ជូហៀប**ជាព្រះអនុជឡើងគ្រងរាជ្យ ទ្រង់ព្រះនាមព្រះបាទ**ហៀនតេ**។ **តាំងតុះ** ក៏តាំងខ្លួនឯងជា "**សៀងកុក**" (តំណែងអគ្គមហាសេនាបតី) សម្រេចរាជការផែនដី។ កាល**តាំងតុះ**បានឡើងជា**សៀងកុក**ហើយ ក៏តាំងប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗ។ ពួកមន្ត្រីនៅក្រុង គ្មានអ្នក

ណាមួយអាចកម្ចាត់**តាំងតុះ**ចេញ ក៏នាំគ្នារត់ចេញទៅនៅខេត្តក្រៅអស់ជាច្រើន។ ក្នុងចំណោមពួកដែលរត់ទៅនោះមានមន្ត្រីពូកែម្នាក់ឈ្មោះ**ចូឆ្វ** បានបបួលចៅហ្វាយស្រុកជាច្រើនស្រុកលើកទ័ពទៅបង្ក្រាប**តាំងតុះ** ប៉ុន្តែធ្វើការមិនសម្រេច ព្រោះមិនរួមសាមគ្គីគ្នា ដោយចៅហ្វាយស្រុកអស់នោះគិតតែចង់បានប្រយោជន៍ និងអំណាចតែសព្វៗខ្លួន ម្ល៉ោះហើយទៅជាទាស់ទែងច្បាំងតែគ្នាឯង។

តមកមិនយូរប៉ុន្មាន **អងអ៊ុន**ជាមន្ត្រីធំនៅទីក្រុងក៏គិតធ្វើកលឧបាយកម្ចាត់**តាំងតុះ**ចេញបានសម្រេច ដោយយកស្ត្រីរូបឆោមឆើតធ្វើជានុយ ប៉ុន្តែ**អងអ៊ុន**មិនអាចចាត់ការស្រុកទេសឲ្យរៀបរយទៅបាន ថែមទាំងក្សត្រទ្រង់រាជ្យក៏ឥតមានសមត្ថភាព ទើបជាហេតុឲ្យពួករបស់**តាំងតុះ** មាន**លីឈុយ**, **គុយគី** ជាដើម ធ្វើការសងសឹកសម្លាប់**អងអ៊ុន**ទៅទៀត ហើយបង្ខំឲ្យព្រះបាទ**ហៀនតេ** តាំងពួកខ្លួនឲ្យធ្វើជាធំក្នុងទីក្រុង។ នៅទីបំផុតពួកនេះគិតកម្ចាត់ព្រះបាទ**ហៀនតេ**ចេញ។ ទ្រង់គេចរត់ចោលទីក្រុងទៅ ទ្រង់បានសេចក្តីលំបាកវេទនាជាអនេក ហើយមានព្រះរាជឱង្ការឲ្យហៅ**ចូឆ្វ**ចូលមកជួយទំនុកបម្រុងទ្រង់ក្នុងឱកាសនោះ។ **ចូឆ្វ**លើកទ័ពចូលទៅបង្ក្រាបពួកក្បត់បានរាបទាបនៅទីក្រុង ហើយបានទទួលតំណែងជា**សៀងកុក**សម្រេចរាជការផែនដី តែបណ្តាខេត្តក្រៅនៅតែបះបោររឹងទទឹងតាំងពីកាល**តាំងតុះ**, **លីឈុយ**, **គុយគី**មកនោះ។ ឯពួកមន្ត្រីដែលរត់ចោលក្រុងទៅក្នុងសម័យ**តាំងតុះ** ក៏បានត្រឡប់ចូលមកទីក្រុងវិញ ក្នុងពេលដែល**ចូឆ្វ**បានធ្វើ**សៀងកុក** ដោយស្ម័គ្រចិត្តចុះចូលនឹង**ចូឆ្វ**ក៏មាន ដែលនៅស្ងៀមៗ ចាំមើលបំណាំក៏មាន ដែលនៅរឹងទទឹងក៏នៅមាន។

ឯ**ចូឆ្វ**នោះ ជាមនុស្សមានសតិបញ្ញាវាងវៃ ជាមេទ័ពមានសមត្ថភាព ជាអ្នកអាចគ្រប់គ្រងបង្គាប់បញ្ជាខេត្តក្រៅនានា អាចធ្វើឲ្យទីក្រុងមានអំណាចមានកម្លាំង

កើនចម្រើនឡើងជាងកាលជាន់មុននោះ។ ប៉ុន្តែ **ចូឆ្វ** ច្រើនធ្វើការតាមតែទំនើងចិត្តខ្លួន ពួកនាម៉ឺនដែលមិនមែនជាបក្សពួក**ចូឆ្វ**ច្រើនស្អប់ គិតកម្ចាត់ចេញ តែគ្មានអ្នកណាហ៊ានកម្ចាត់ចេញទេ ព្រោះពួកនៅក្រុងស្រឡាញ់**ចូឆ្វ**ដោយភាគច្រើន។ **ចូឆ្វ**ប្រើអំណាចមុខក្រសួងជ្រុលហួសពេក ជាហេតុឲ្យព្រះបាទ**ហៀនតេ**ទ្រង់ក្រំព្រះទ័យយ៉ាងខ្លាំង ដល់ទៅទ្រង់យកព្រះលោហិតសរសេរព្រះឱង្ការសម្ងាត់ ហៅរកអ្នកស្វាមីភក្តិឲ្យគិតកម្ចាត់**ចូឆ្វ**ចេញ។ ដំណឹងនេះផ្សាយដល់ខេត្តក្រៅ បណ្ដាពួកចៅហ្វាយស្រុកដែលមានកម្លាំង មិនមែនជាបក្សពួកខាង**ចូឆ្វ** ក៏យល់ថា**ចូឆ្វ**ជាសត្រូវនឹងផែនដីដូចជា**តាំងតុះ**ដែរ ទើបនាំគ្នារឹងទទឹងឡើង។ ឯ**ចូឆ្វ**ដែលប្រកាន់សក្តិខ្លួនជា **សៀងកុក** ក៏យល់ថាត្រូវតែបង្ក្រាបខេត្តក្រៅដែលរឹងទទឹងជាសត្រូវនឹងផែនដី ទើបជាហេតុឲ្យកើតជាចម្បាំងឡើង ដោយទាំងសងខាងអាងថាច្បាំងបង្ក្រាបពួកក្បត់ផែនដី។ ផលនៃការច្បាំងគ្នាជាយូរអង្វែងនោះ ប៉ែកខាងកងទ័ព**ចូឆ្វ**ច្បាំងបង្ក្រាបខេត្តក្រៅបានចំនួនច្រើន បង្ក្រាបមិនបានតែបណ្ដាខេត្តដែលនៅក្រោមឱវាទ**ស៊ុនគួន** និង **ឡៅពី** ប៉ុណ្ណោះ។

**ស៊ុនគួន** ជាម្ចាស់ស្រុកកន្តាំង ជាខេត្តធំៗតាំងនៅទិសខាងកើត ជាអ្នកគ្រប់គ្រងស្រុកទេសបានល្អតាំងនៅក្នុងសីលធម៌ មានមនុស្សនិយមរាប់អានច្រើន ត្រាតែមានកម្លាំងខ្លាំងពូកែឡើងច្រើន។ ឯ**ឡៅពី**នោះ ដំបូងជាមនុស្សអនាថា តែមានត្រកូលខ្ពស់ជាប់សែស្រឡាយក្នុងរាជវង្ស**ហ័ន** ជាអ្នកមានអធ្យាស្រ័យល្អ ហើយគាប់ចួនបានមនុស្សពូកែមានថ្វីដៃមកចូលធ្វើជានាយទាហានច្រើននាក់ ទើបមានកេរ្តិ៍ឈ្មោះល្បីឡើង តមកបាន**ខុងមេង**ជាទីប្រឹក្សាខាងសឹកសង្គ្រាម បានណែនាំឲ្យចងមិត្តនឹង**ស៊ុនគួន** ព្រួតដៃគ្នាតស៊ូនឹង**ចូឆ្វ**ទើបរក្សាខ្លួនបានសុខ ហើយគាប់ចួនបានខេត្ត**សេឆួន** តាំងនៅទិសខាងលិចជាបង្អែក ទើបតាំងឡាក់ឋានបានមាំមួន។ ឯព្រះបាទ

**ហៀនតេ**ជាព្រះមហាក្សត្រប្រទេសចិន តែព្រះនាមដូចរូបអ្នកតា តែពង្សាវតារចិននៅរាប់ថា ជាព្រះមហាក្សត្រប្រទេសចិនទាំងមូល។

លុះ**ចូឆ្វូ**អនិច្ចកម្មទៅ **ចូភី**ជាកូន**ចូឆ្វូ**បានទទួលតំណែងជា**សៀងកុក**តំណមកជំនួសបិតា រួចបានដកព្រះបាទ**ហៀនតេ**ចេញពីរាជសម្បត្តិ ហើយប្រកាសតាំងខ្លួនឯងឡើងជាព្រះមហាក្សត្រប្រទេសចិន ផ្លាស់រាជវង្សថ្មីហៅថា **រាជវង្សវុប** កាលពី ព.ស ៧៦៣។ ប៉ែកខាង**ឡៅពី** ក៏បានតាំងខ្លួនជាក្សត្រឡើងដែរ ចាត់តាំង**រាជវង្សហ័ន**ឡើងថ្មីទៀតនៅខេត្តដែន**សេឆួន**។ ខាង**ស៊ុនគួន** មិនចង់នៅចំណុះ**ចូភី** ឬ**ឡៅពី** ក៏តាំងជាឯករាជ្យឡើងនៅខេត្តដែនកន្តាំង។ តាំងអំពីកាលនោះមក ប្រទេសចិនទាំងមូលក៏បែកខ្ញែកចេញជាសាមកុក គឺបែកចេញជាបីអាណាចក្រសឹងមានឥស្សរៈដាច់ដោយឡែកពីគ្នា។ អាណាខេត្តរបស់ព្រះបាទ**ចូភី** ហៅថា **វុយកុក**។ អាណាខេត្តរបស់**ឡៅពី**ហៅថា **ចុកកុក**។ អាណាខេត្តរបស់ព្រះបាទ**ស៊ុនគួន**ហៅថា **ង៉កុក**។ អំណឹះកាលតមក កាលអស់បុណ្យព្រះបាទ**ឡៅពី, ចូភី, ស៊ុនគួន** ហើយអ្នកគ្រប់គ្រងប្រទេសជាតំណមក ជាអ្នកឥតសមត្ថភាពទាំងបីកុក ទើប**ស៊ុម៉ាចៀវ** ដែលជាអ្នកសម្រេចរាជការផែនដីខាង**វុយកុក**បង្ក្រាបចុកកុកបានមុន រួចតមក **សុម៉ាអៀន** បុត្រ**ស៊ុម៉ាចៀវ** ដណ្តើមរាជសម្បត្តិ**វុយកុក**បានផ្លាស់រាជវង្សថ្មីហៅថា**រាជវង្សជិន** ហើយបង្ក្រាប**ង៉កុក**បានមួយកុកទៀត ទើបមហាអាណាចក្រចិនត្រឡប់ចូលរួបរួមគ្នាមូលតែមួយបានឡើងវិញ។ ចប់រឿងសាមកុកដោយសង្ខេបខ្លីត្រឹមប៉ុណ្ណោះ”។

(សង្ខេបរយៈសម័យក្នុងរឿងសាមកុកនេះ ដូច្នេះគឺសម័យ**រាជវង្សហ័ន**រៀវរោយ ក្នុងរជ្ជកាលព្រះបាទ**ហៀនតេ** ២១ឆ្នាំ ក្នុងសម័យ**តាំងតុះ** ក្នុងរជ្ជកាលព្រះបាទ**ហៀនតេ** ៣០ឆ្នាំ សម័យសាមកុក ៦០ឆ្នាំ ប្រមូលសម័យកាលក្នុងរឿងសាមកុកនេះជារយៈ ១១១ ឆ្នាំ)។

នៅទីបំផុត យើងមានសេចក្តីសង្ឃឹមថាអស់លោកអ្នកអានរឿងសាមកុក ដែលជាសេចក្តីប្រែរបស់អ្នកឧកញ៉ាវិបុលរាជសេនា “កន” តំណាងរាស្ត្រ គង់មានសេចក្តីពេញចិត្តដោយច្រើនមិនខាន ដ្បិតរឿងនេះមានសេចក្តីផ្ទៃរឿងជាប់ទាក់ទងគ្នាហូរហែ គួរឲ្យចង់មើលចង់ដឹង។ ឯអក្ខរាវិរុទ្ធ និងពាក្យពេជន៍ខ្លះ យើងបានពិនិត្យកែសម្រួលទៅតាមសម័យនិយម ដែលលោកអ្នកប្រែបានអនុញ្ញាតឲ្យកែបានតាមតម្រូវការ ដូចមានសេចក្តីបញ្ជាក់ក្នុងអារម្ភកថារបស់លោកស្រាប់។

# អារម្ភកថា

វីសេចក្ដីនៃព្រះរាជពង្សាវតារនៃព្រះមហាក្សត្រ ដែលសោយរាជសម្បត្តិក្នុងមហាប្រទេសចិននោះ អ្នកប្រាជ្ញបុរាណគេបានសម្មតគ្នា ហៅជាភាសាចិនក្នុងរឿងនេះថា “**សាមកុក**” មានបែបផែនប្រែទុកក្នុងក្រុងទេពមហានគរជាភាសាសៀមៗ បុរាណក្សត្របានចាត់ការឲ្យផ្ទៀងផ្ទាត់តាមប្រវត្តិប្រទេស ក៏ឃើញជាក់ច្បាស់ថាក្នុងសម័យសាមកុកនោះជាជំនាន់ក្រោយពុទ្ធកាល ដែលព្រះពុទ្ធដ៏ជាអម្ចាស់នៃយើងព្រះអង្គទ្រង់បរិនិព្វានកន្លងរំលងទៅហើយបាន ៧៦៣ ព្រះវស្សា ទើបមហាប្រទេសចិនឧប្បត្តិរឿងសាមកុកនេះឡើង គិតតាំងពីពុទ្ធសករាជ ៧៦៣ រហូតដល់ ៨៦៣ ព្រះវស្សា ទើបផុតផែនដីសាមកុកនោះទៅវិញ អាយុផែនដីសាមកុកនោះ រាប់បាន ៦០ ឆ្នាំដោយគណនា។

ខ្ញុំមានសេចក្ដីប្រាថ្នាចង់ឲ្យបានរឿងនេះ ផ្សាយក្នុងក្រុងកម្ពុជាធិបតីតទៅ ទើបនៅមានចិត្តឧស្សាហ៍ប្រែមកជាភាសាខេមរៈពីដើមដល់ចប់ គម្រប់ជាសេចក្ដី ៧៨ ខ្សែ តែមករួមបញ្ចូលគ្នាជាសៀវភៅឲ្យតិចទៅវិញ គឺ៥ខ្សែជាសៀវភៅមួយ ត្រូវជា១៨ សៀវភៅ រួមទាំងសៀវភៅចុងបង្អស់ដែលមានរួមគ្នាតែ៣ខ្សែ មួយសៀវភៅនេះផង។

វីការដែលបានស្ថាបនាជាខេមរាធិប្បាយរឿងនេះ គឺសំណេះប្រើពាក្យសម្ដីតាមសម័យបច្ចុប្បន្ន របៀបពាក្យពេចន៍ក៏ពុំសូវល្អិតល្អន់ស្រួលពីរោះដូចលោកបុរាណទេ ព្រោះខ្ញុំចេះពាក្យខ្មែរពុំស្មើនឹងលោកសម័យចាស់ ចំណេះសៀមក៏ពុំទាន់ជាក់ច្បាស់មុតមាំ គ្រាន់តែផ្សំយកលំនាំល្អមឲ្យស្ដាប់បានប៉ុណ្ណោះ ទោះបីខ្វះលើសលោះខុសពុំត្រង់ក្នុងខឯណានីមួយ ក៏សូមលោក-អ្នកចេះដឹងទាំងឡាយជួយកែប្រែអធិប្បាយឲ្យត្រឹមត្រូវឡើងផងចុះ ព្រោះរឿងនេះចំពោះជាបុរាណសាស្ត្រ អាចនឹង

ញុំាងឲ្យផ្ញៀវផ្កាសនូវសតិបញ្ញា ចេះវោហារសម្ដីវែស្គាល់យល់គំនិតចិត្តមនុស្សល្អ និងអាក្រក់គ្រប់ប្រការ ហើយនិងជាទីនាំអាត្មាឲ្យប្រព្រឹត្តនាំសត្យានុម័ត្យពិតត្រង់ក្នុងវង្សជាតិ បុរសដ៏មានគំនិតមារយាទគួរសិក្សាឲ្យចេះដឹងរឿងនេះ ទុកជាគ្រឿងប្រដាប់សម្រាប់សតិប្រាជ្ញាឲ្យបាន ទើបនឹងចម្រើនមាននូវសិរីសុវត្ថិវឌ្ឍនាការជាក្រសេមសុខនិរទុក្ខាមហាប្រសើរតទៅ។

**អ្នកឧកញ៉ាឧបុលរាជសេនា កន ត្វូឈ្មួយសេនាបតីវ៉ឺត្រែត៍**

ភ្នំពេញ, នៅថ្ងៃ ២៧ ម៉េ ឆ្នាំ១៩៣៣

ត្រូវនឹងថ្ងៃ ១ កើតខែចេត្រឆ្នាំ រកា នៅជាចត្វាស័ក ព.ស ២៤៧៦។

# រឿង សាមកុក

## កណ្ឌទី ១

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

| |
|---|
| **រឿងសាមកុកទុកជាយុទ្ធសាស្ត្រ** |
| **អ្នកខាងវៃឆ្លាសបើបានអាន** |
| **នឹងចេះឧបាយកលចំណាន** |
| **ទាំងមានសន្ដានស្នេហាជាតិ ។** |

**ដើម**ឡើយផែនដីនៃមហាណាចក្រចិនទាំងមូល រាប់តាំងពីមុនជាន់សាមកុកឡើងទៅនោះ ក៏ជាសុខរៀងមកយូរណាស់ ក្រោយនោះក៏កើតជាសឹកសង្គ្រាម លុះសង្គ្រាមស្ងប់ក៏ត្រឡប់ជាសុខវិញ។ ដំណេតពីសម័យនោះមក មានព្រះមហាក្សត្រសោយរាជសម្បត្តិក្នុងមហាណាចក្រកចិន ទ្រង់ព្រះនាមព្រះចៅ**ជីវប៊ូអង** រំលងពីនោះមកមានព្រះមហាក្សត្រសោយរាជសម្បត្តិជាលំដាប់ត១មកទៀត ជាច្រើនព្រះអង្គសឹងជាសុខក្សេមក្សាន្តគណនាបាន ៧០០ឆ្នាំ មហាណាចក្រចិនក្នុងជាន់នោះមានខេត្តធំៗចំនួន ៧ មណ្ឌល ឯរាជធានីទីក្រុងដែលស្ដេចគង់នៅៗក្នុងខេត្ត**ជិនកុកហៃ**។ ព្រះចៅ**ជីវប៊ូអង**វាយយកបានមណ្ឌលទាំង ៧ មកជាចំណុះនៃព្រះអង្គរួមជាអាណាចក្រ១។ ព្រះមហាក្សត្រជាលំដាប់ជាន់ក្រោយនោះទ្រង់ព្រះនាមព្រះចៅ**ជិនអង** ទ្រង់ធ្វើសង្គ្រាមបរាជ័យនឹង**ហាន់ធ** ក្រោយនោះ**ហាន់ឆ** និង**ហាន់ចូកូ**ច្បាំងគ្នាទៀត ក៏បានរាជសម្បត្តិទៅ**ហាន់កូចូ**វិញ ហើយមានព្រះរាជវង្សជាតំណេតពីស្ដេច**ហាន់កូចូ**សោយរាជ្យជាលំដាប់តមកទៀត រាប់បានចំនួន ១២ អង្គក្សត្រ។ គ្រានោះ មាន

នាហ្មឺនធំម្នាក់ឈ្មោះ **អងម៉ាំង** ប្រែចិត្តក្បត់ដណ្តើមយករាជសម្បត្តិបានហើយ តាំងខ្លួនជាម្ចាស់ផែនដីសោយរាជ្យបាន ១៨ឆ្នាំ។ ក្រោយមកនោះមានព្រះរាជវង្សស្តេច**ហាន់កូចូ** ព្រះនាម**ហាន់កងប៊ូ**សម្លាប់**អងម៉ាំង**ចេញបាន ហើយឡើងសោយរាជសម្បត្តិតមកទៀត លំដាប់ក្សត្រសោយរាជ្យតពីស្តេច**ហាន់កងប៊ូ**មកមានចំនួន ១២ អង្គក្សត្រ ឯស្តេចដែលសោយរាជ្យទីបំផុតនោះព្រង់ព្រះនាមព្រះចៅ**ហាន់តេ** ក្នុងចុងរាជ្យនោះ ផែនដីស្រុកចិនបែកជា ៣ អន្លើ ភាសាចិនហៅថា “សាមកុក” ព្រោះមានស្តេចជាម្ចាស់ផែនដី ៣ ព្រះអង្គក្នុងមហាណាចក្រចិននោះ។

ក្នុងសម័យនោះព្រះចៅរាជាធិរាជ**ហាន់តេ** មិនមានព្រះរាជបុត្រសោះ បានសុំឈ្មោះ**ឡេនតេ**ជាវង្សរដទៃមកចិញ្ចឹមជាព្រះរាជឱរស។ ព្រះចៅ**ហាន់តេ**ទិវង្គតទៅ **ឡេនតេ**បានសោយរាជ្យមានព្រះរាជឱរសពីរព្រះអង្គ ព្រះរៀមនាម**ហង់ជូពៀន** ព្រះអនុជនាម**ហង់ជូហៀប**។ កាលក្នុងរាជព្រះចៅ**ឡេនតេ**នោះ ស្តេចនេះមិនបានតាំងនៅក្នុងផ្លូវទសពិតរាជធម៌តាមបុរាណរាជប្បវេណី ទាំងមិនបានសេពគប់នឹងអ្នកមានតម្រិះប្រាជ្ញាសុចរិតទៀតត្រង់នឹងផែនដីឡើយ គាប់ព្រះទ័យប្រមាថវង្វេងដោយល្បែងពាល បណ្តាលឲ្យជឿកាន់យកតែតាមសម្តីមនុស្សអន្ធពាលអសត្យ ប្រព្រឹត្តទៅតាមអំពើចិត្តទុច្ចរិតលាមក ផែនដីក៏កើតកលិយុគវិបរិតទៅផ្សេងៗ ។ ខណៈនោះមានពួកខន្ទី([១]) ដែលនៅគាល់បម្រើផ្ទាល់ព្រះអង្គ មានអំណាចញុំាងស្តេចឲ្យលុះទៅតាមឧបាយទុច្ចរិតផ្សេងៗបាន។ មានខន្ទីម្នាក់ឈ្មោះ**ចៅជៀក**ជាធំលើសខន្ទីដទៃ ឃើញព្រះចៅ**ឡេនតេ**ទ្វេធ្វេសស្មារតីយកព្រះទ័យទុកដាក់ស្រឡាញ់ខ្លួន ក៏កំរើបចិត្តគិតនឹងបក្សពួកតាំងធ្វើអំពើលាមកផ្សេងៗ សូម្បីកិច្ចរាជការបណ្តាដែលមាននៅ

---

[១] ជាពួកមនុស្សប្រុសកម្រៀវ ជាពួកអ្នករាជការខាងក្នុងព្រះបរមរាជវាំង តាមទំនៀមស្រុកចិនសម័យបុរាណ ។

ក្នុងព្រះរាជអាណាចក្រមណ្ឌលទាំងប៉ុន្មាន ក៏ព្រះរាជាបណ្ដោយឲ្យសម្រេចនៅលើពួកខន្ទីទាំងអស់ ព្រោះខន្ទីជាអ្នកចាំទូលពិត គិតកែតម្រូវត្រូវទៅតាមអធ្យាស្រ័យនៃខ្លួនដែលមានប្រយោជន៍។ គ្រានោះបណ្ដាអស់ពួកនាហ្មឺនសព្វមុខមន្ត្រីតូចធំខ្ញុំរាជការ អាណាប្រជានុរាស្ត្រទាសកម្មករទាំងឡាយ ក៏កើតសេចក្ដីក្ដៅក្រហាយទូទៅទាំងព្រះនគរ។

ខណៈនោះមានមន្ត្រីធំៗពីរនាក់ ដែលជាមនុស្សសុចរិតល្អនឹងផែនដីឈ្មោះ **តៅប៊ូ**១, **តាន់គួន**១ បានឃើញស្ដេចវង្វេងភ្លេចស្មារតីយកព្រះទ័យទុកដាក់ស្ម័គ្រស្រឡាញ់ពួកខន្ទីទាំងឡាយ ក៏គិតរិះរកឧបាយសម្លាប់ពួកខន្ទីទាំងនោះចោលចេញ។ ឯ**ថៅជៀក**ខន្ទីនោះដឹងខ្លួនភ្លាម ក៏ញុះញង់ឲ្យពួកខន្ទីទាំងឡាយរកឧបាយចាប់យក **តៅប៊ូ** និង**តាន់គួន**ទាំងពីរនាក់ទៅសម្លាប់ចោល។ លុះធ្វើសម្រេចកិច្ចដូចប្រាថ្នាហើយ **ថៅជៀក** និងខន្ទីទាំងនោះក៏រឹតតែខ្វល់ខ្វាយកំរើបចិត្តឥតខ្លាចអ្វីសោះឡើយ។

លុះអំណើះពីនោះមក ព្រះចៅ**ឡេនតេ**សោយរាជសម្បត្តិបាន១២ ឆ្នាំ ជាឱកាសក្នុងថ្ងៃ ១៥ កើត ខែផល្គុន ព្រះអង្គទ្រង់ចេញប្រថាប់លើព្រះទីនាំងកៅអីក្នុងទីប្រាសាទ (**អ៊ុនតុនតៀន**) នៅវេលាថ្ងៃត្រង់ជាក់ ក៏បណ្ដាលឲ្យឃើញអាភេទធ្លាក់ខ្យល់ព្យុះសង្ឃរាជាអស្ចារ្យណាស់ ឃើញមានពស់មួយធំសម្បើម សម្បុរខៀវធ្លាក់ចុះមកពីលើអាកាសនៅទីចំពោះព្រះភក្ត្រ ហើយពស់នោះគេចលូនឡើងព័ទ្ធរុំជើងព្រះកៅអីដែលស្ដេចគង់។ ព្រះអង្គទ្រង់ស្លុតព្រះទ័យភ័យតក្កមាធ្លាក់ព្រះកាយាពីលើព្រះកៅអី ដួលសន្លប់ចុះលុះបាត់ព្រះស្មារតី ពុំដឹងព្រះអង្គសោះ។ ពួកនាហ្មឺនទាំងអស់បានឃើញគ្រប់គ្នា ក៏ភ័យម៉ីម្នាស្ទុះរត់ពពាក់ពពូនខ្លះប្រះខ្លួនលូនចូលទៅលើកគ្រាហ៍ នាំព្រះរាជាចូលទៅកាន់ព្រះមន្ទីរទែនក្នុង ឯពស់នោះក៏អន្តរធានបាត់ទៅវិញមួយរំពេច។ លំដាប់នោះក៏បង្កើតជាផ្គររន្ទះអសនីបាញ់ខ្ទរខ្ទ័រញ៉័រកក្រើកអស់ទាំង

ផែនទី ស្មើរតែភ្លូកក្រឡាប់ មេឃក៏ចុះអ័ព្ទងងឹតបិទសូរ្យសែង ព្រះភិរុណក៏រំលាជាភ្លៀងធ្លាក់ជព្រុំលាយទៅដោយគ្រាប់ព្រិលធំៗ ចំមកលើផ្ទះសម្បែងមហាជនរលំរលើងដួលគរលើគ្នាជាកោលាហលពេញនគរ បណ្ដារាស្ត្រសឹងតែផ្អើលភ្លូករីករវជ្រួលច្របល់ លុះដល់ថ្ងៃរសៀលទើបស្ងប់ខ្យល់វាំងភ្លៀង។ រំលងពីនោះមក ៤ឆ្នាំ ដល់រដូវប្រាំងក្នុងខែបុស្សស្រុក**ឡុងអៀង**នោះជារាជធានី ព្រះធរណីក៏កក្រើករំពើកញាប់ញ័រឯង ទឹកទន្លេឡើងលិចអស់ភូមិករណ៍ផ្ទះសម្បែងអ្នកស្រុកដែលនៅក្បែរមាត់កំពង់ រលំរលើងរលីងយង់អណ្ដែតទៅតាមទឹកបាត់អស់ ពេលនោះប្រែខ្វៃមាន់ញីទៅជាមាន់ឈ្មោល។

លុះដល់ថ្ងៃ ១ កើត ខែពិសាខឆ្នាំនោះ កើតបុព្វនិមិតជាភ្លើងឆេះឡើង មានអណ្ដាតប្រហែល២០ព្យាម (៤០ម៉ែត្រ) បក់បោកត្រឡប់អណ្ដាត និងផ្សែងចូលទៅក្នុងល្វែងព្រះទីនាំង**អ៊ុនតុនតៀន**។ ដល់មកខែជេស្ឋ ក៏កើតបុព្វនិមិតម្ដងទៀត ជាពន្លឺរស្មីដ៏រុងរឿងធ្លាក់ចុះមកពេញព្រះរាជវាំង ឯភ្នំវ៉ាន់ស្វ ដែលមានទំហំធំហើយខ្ពស់ជាងគេនោះ ក៏បណ្ដាលទៅជាបែកធ្លាយពីកំពូលចុះមកយ៉ាងអស្ចារ្យ។ ព្រះចៅ**ឡេនតេ**ទ្រង់ពិភាល់ក្នុងព្រះទ័យពេកណាស់ ក៏ត្រាស់សួរទៅពួកនាហ្មឺនសព្វមុខមន្ត្រីតូចធំទាំងឡាយនោះថា "និមិតវិបរិតដូច្នេះ តើនឹងល្អ ឬអាក្រក់ប្រការដូចម្ដេច?" **យីឡុង** ជានាហ្មឺនធំចេះដឹង ក៏តាំងសរសេរជាសំបុត្រសម្ងាត់ទូលថា "ហេតុដែលបណ្ដាលឲ្យឃើញអស្ចារ្យដូច្នេះ មិនមកពីអ្វីទេ គឺមកពីពួកខន្ទីអប្រិយប្រព្រឹត្តទុច្ចរិតកន្លងព្រះរាជប្បវេណីគ្រប់ប្រការនោះឯង បានជាបណ្ដាលឲ្យកើតនិមិតអស្ចារ្យប្លែកដូច្នេះ ដើម្បីឲ្យព្រះអង្គទ្រង់ឃើញហើយត្រិះរិះតាមគួរនឹងការ"។ ព្រះចៅ**ឡេនតេ**ទតចប់សេចក្ដីហើយ ក៏មានព្រះទ័យបរិវិតក្កជាទុក្ខ ទ្រង់ដកដង្ហើមធំតែមិនបានមានព្រះបន្ទូលថាដូចម្ដេចឡើយ ទើបស្ដេចក្រោកចាកអាសនៈផ្លាស់ព្រះភូសាឆ្លងព្រះអង្គថ្មី។

ពេលនោះទទួល**ថៅជៀក**ខន្ទី ចូលទៅក្រាបបង្គំគាល់ពីក្រោយព្រះទីនាំងបានក្រឡេកទៅឃើញលិខិត ដែលស្ដេចកំពុងទតដឹងសេចក្ដីច្បាស់ជាលិខិតរបស់**យីឡុង** ធ្វើក្រាបបង្គំទូលដូច្នោះ ក៏ថយមកពិគ្រោះនឹងបក្សពួកវិញថា “យើងត្រូវរកឧបាយដូចម្ដេច ឲ្យបានសេចក្ដីខុសនេះធ្លាក់ទៅលើ**យីឡុង**ជាយ៉ាងសាហ័ស ដើម្បីនឹងឲ្យស្ដេចធ្វើទោស**យីឡុង**នោះ ចេញចាកអំពីស័ក្តិយសជាមន្ត្រីឲ្យបាន”។

ឯពួកខន្ទីដែលជាមេធំៗនោះមាន៩នាក់ គឺឈ្មោះ**ថៅជៀក១, តៀវតុង១, តៀវយៀង១, ហងស៊ី១, កួនគុយ១, ហៅឡាំ១, កៀនស៊ុត១, ហេហ៊ុយ១, កាំឡេង១** បើមន្ត្រីណាមិនបាននៅក្នុងឱវាទស្ដាប់បង្គាប់នៃពួកខន្ទីទាំងនោះ ក៏ឲ្យដកហូតងារចេញពីរាជការ អ្នកឯណានៅក្នុងបង្គាប់បញ្ជា ក៏តែងតាំងឲ្យលើកតម្កើងឲ្យឡើងយសស័ក្តិជាមន្ត្រីតូចធំតាមចិត្ត ឯ**ថៅជៀក** និងពួកខន្ទីទាំងនោះ ក៏តាំងឈ្មោះខ្លួនជា “**ស៊ិបសៀងស៊ី**” ព្រះថៅ**ឡេនតេ** ក៏យកព្រះទ័យទុកដាក់ជឿកាន់យកតាមពាក្យសម្ដីនៃឈ្មោះ**តៀវយៀង**ខន្ទី សន្មតហៅថា “ព្រះបិតាធម៌” រាជការនិងច្បាប់ទម្លាប់សម្រាប់ផែនដីក៏ភ័ន្តប្រែទៅ បណ្ដាអាណាប្រជារាស្ត្រទាសកម្មករទាំងឡាយ ក៏មានសេចក្ដីក្ដៅក្រហាយជាចលាចលរាល់តំបន់ កើតចោរកំណាចលួចប្លន់កាប់សម្លាប់គ្នាជារឹករវរពន់ពេកណាស់។

ប៉ែកខាងស្រុក**គីឡុកតុន**នោះ មានបុរសបងប្អូន៣នាក់ ឈ្មោះ**តៀវកុក១, តៀវប៉ូ១, តៀវលៀង១** ឯឈ្មោះ**តៀវកុក**នោះ ជាអ្នកដើរស្វែងរកថ្នាំលើកំពូលភ្នំ ហើយបានជួបប្រទះនឹងតាចាស់ម្នាក់មុខមាត់ពណ៌សម្បុរដូចជាទារក ភ្នែកលឿងដៃកាន់ឈើច្រត់ តាចាស់នោះក៏នាំ**តៀវកុក**ចូលទៅក្នុងរូងគុហាលើភ្នំ ហើយឲ្យក្បួនតម្រាបីច្បាប់ឈ្មោះ “ថៅផេងយ៉ៅស៊ុត” ហើយប្រាប់ថា “ចូរអ្នកយកតម្រានេះទៅជួយទំនុកបម្រុងមនុស្សទាំងឡាយឲ្យបានសេចក្ដីសុខសប្បាយចុះ តែបើខ្លួនអ្នកមាន

ចិត្តមិនទៀងត្រង់គិតប្រទូសរាយនឹងរាជការផែនដីវេលាណា ភ័យន្តរាយនឹងបង្កើតបានដល់ខ្លួនអ្នកវេលានោះ” **តៀវកុក**ក៏លុតជង្គង់ក្រាបសំពះហើយជម្រាបសួរថា “ខ្លួនលោកនេះអ្វី?” តាចាស់នោះឆ្លើយប្រាប់ថា “យើងជាទេវតា” ថាហើយក៏អន្តរធានបាត់ទៅ។

ឯ**តៀវកុក** លុះបានតម្រានេះហើយ ក៏ម្នីម្នាវិលត្រឡប់មកកាន់ទីលំនៅខ្លួនវិញ ខំរៀនទន្ទេញតាមតម្រានោះទាំងថ្ងៃទាំងយប់ ដរាបទាល់តែចេះចាំមាត់ស្ទាត់ អាចសូត្រហៅខ្យល់ហៅភ្លៀងបានគ្រប់ប្រការទើបតាំងខ្លួនជា “កូយិន” ប្រែជាភាសាខ្មែរថា “អ្នកចេះដឹងយ៉ាងវិសេស”។

គ្រានោះ នៅស្រុក**គីឡកគុន** ពួកអ្នកស្រុកកើតជំងឺជាច្រើន **តៀវកុក**បានដឹងហើយក៏សរសេរជាលេខយន្តមន្តគាថា តម្រាយកទៅចែកឲ្យពួកអ្នកស្រុកនោះទាំងប្រុសទាំងស្រី ដើម្បីបំបាត់ជំងឺយ៉ាងស័ក្តិសិទ្ធិឆុតឆាប់ពូកែណាស់ មនុស្សម្នាមហាជនក៏ជឿស្រឡាញ់រាប់អាន**តៀវកុក** ទុកជាគ្រូអាចារ្យប្រៀនប្រដៅចំនួនជាងរយនាក់។

ចាប់តាំងពីពេលនោះមក **តៀវកុក**ក៏ខំដើរស្វះស្វែងព្យាបាលរោគាពាធតាមស្រុកតូចស្រុកធំនិគមជនបទនានា អ្នកណាបានលេខយន្តមន្តគាថារបស់**តៀវកុក**យកទៅរក្សាទុកលើផ្ទះ ក៏បានជាជ្រះស្រឡះអស់ជំងឺតម្កាត់ឥតមានភ័យបារម្ភអ្វីឡើយ។ បណ្តាជនក្នុងស្រុកតូចធំសឹងនិយមរាប់អានមានទ្វេឡើងរាល់ៗថ្ងៃ។ **តៀវកុក**លុះកើតមានលាភសក្ការៈ និងមនុស្សម្នាមហាជនចុះចូលជាសិស្សគណច្រើនហើយ ទើបតាំងសិស្សគណទាំងនោះ ឲ្យធ្វើជាភ្នាក់ងារឃុំគ្រប់ៗអន្លើប្រហែលដប់តំបន់។ តំបន់ធំៗមានមនុស្សចំនួនពីរម៉ឺនប្លាយនាក់ ឯតំបន់តូចៗមានមនុស្សចំនួន ៦ពាន់ ឬ

៧ពាន់នាក់ មានមេកាន់កាប់រក្សាកូនស្រុកតាមលំដាប់ហើយ មានទង់ជ័យសម្រាប់ចេញច្បាំងគ្រប់តំបន់។

**តៀវកុក**តាំងខ្លួនជា**ចុងគុន** (ស្តេចត្រាញ់) ហើយក៏តែងឧបាយឲ្យវន្ទីឮទៅថា ផែនដីនឹងភ័ន្តប្រែជាចលាចលហើយ ព្រោះមានអ្នកមានបុណ្យមកគ្រងផែនដីជាថ្មី ស្រុកទេសនឹងបានសុខសប្បាយ ហើយឲ្យយកក្តារលាបពណ៌សរសេរជាអក្សរពីរតួ ទុកនៅមុខខ្លោងទ្វាផ្ទះថា "ឆ្នាំជូតស្រុកនឹងបានសុខសប្បាយ"។

គ្រានោះ ស្រុក**ឆេជីវ១, អីវជីវ១, ឈើវជីវ១, យ៉ាំងងជីវ១, គុនជីវ១, អ៊ីជីវ១, គីឡុកគុន១,** ពួកអ្នកស្រុកទាំងប្រាំបីតំបន់នេះរាប់អានសរសេរយកឈ្មោះ**តៀវកុក** ទុកជាទីសក្ការៈបូជាគ្រប់ៗផ្ទះ ទើប**តៀវកុក**ប្រើឈ្មោះ**ម៉ាអ្វូនយី**ឲ្យយកមាសប្រាក់ទៅជូន**ហង់ស៊ីុ**ខន្ទី ដែលជាកំណាន់ខេត្តនៃខ្លួន ហើយឲ្យ**ម៉ាអ្វូនយី**និយាយជម្រាបអាចិកំបាំងនឹង**ហង់ស៊ីុ**ខន្ទីថា "**តៀវកុក**ជូនរបស់នេះមក សុំឲ្យ**ហង់ស៊ី**ជួយធ្វើការជាកលសឹកក្នុងទីក្រុង" រួចហើយ **តៀវកុក**ក៏ប្រជុំបងប្អូនប្រុសទាំងពីរនាក់ពន្យល់សេចក្តីថា "បើនឹងគិតការអ្វីៗត្រូវឲ្យយកចិត្តបណ្តារាស្ត្រជាប្រមាណ ដ្បិតឥឡូវនេះ បណ្តាអ្នកស្រុកទាំងប្រាំបីមណ្ឌល គឺរាប់អានស្រឡាញ់នៅក្នុងឱវាទស្តាប់បង្គាប់យើងអស់ហើយ បើបានការព្រមព្រៀងដូច្នេះ តទៅយើងត្រូវតែគិតយកផែនដី ប្រសិនបើយើងមិនអើពើក្នុងពេលវេលានេះទេ ក៏នឹងមានសេចក្តីស្តាយទៅថ្ងៃក្រោយ"។ ប្អូនប្រុសទាំងពីរនាក់ក៏យល់ព្រមផង ទើប**តៀវកុក**ឲ្យបញ្ចុះបញ្ចូលទាហាន ព្រមដោយគ្រឿងសាស្ត្រាវុធត្រៀមប្រចាំការ ដល់កំណត់ចេញច្បាំងវេលាណានឹងបានចាត់ការដោយស្រួល។

**តៀវកុក**ប្រើសិស្សម្នាក់ឈ្មោះ**តងជីវ** ឲ្យកាន់សំបុត្រសម្ងាត់ទៅជូន**ហង់ស៊ី**ខន្ទី ឯ**តងជីវ**មិនបានយកសំបុត្រនោះទៅជូនផ្ទាល់**ហង់ស៊ីុ**ខន្ទី ក៏យកទៅជូននាហ្សឹន

ឯទៀត ឲ្យថ្វាយទៅព្រះ**ឡេនតេ**វិញ។ ព្រះចៅ**ឡេនតេ**ជ្រាបសេចក្ដី ទើបត្រាស់ប្រើឲ្យ**ហ្វូជិន**ជានាហ្មឺនធំឲ្យលើកទ័ពទៅចាប់**ម៉ាអ៊ូនយី** ដែលជាអ្នកនាំបណ្ណាការទៅជូន**ហង់ស៊ី**ខន្ទីនោះសម្លាប់ចោលទៅ ហើយចាប់ទាំង**ហង់ស៊ី**ខន្ទីដាក់គុកទៀត។ លុះ**តៀវកុក**ដឹងដំណឹងដូច្នោះ ក៏ចាត់ការត្រៀមសេនាទាហានទុកព្រម ហើយតាំងខ្លួនជា**សៀនកុងចុងគុន** (ប្រែថា ស្ដេចសួគ៌) តាំង**តៀវប៉ោ**ប្អូនបន្ទាប់ជា**តេកុងចុងគុន** (ប្រែថា ស្ដេចផែនដី) តាំង**តៀវលៀង**ជាប្អូនពៅជា**យិនគុងចុងគុន** (ប្រែថា ស្ដេចមនុស្ស) ហើយ**តៀវកុក**ក៏ស្រែកប្រកាសប្រាប់សេនាទាហាន និងបណ្ដារាស្ត្រទាំងពួងថា រាជការផែនដីនៃព្រះចៅ**ឡេនតេ**នឹងវិនាសសាបសូន្យអស់ហើយ ៗមានអ្នកមានបុណ្យមកសោយរាជសម្បត្តិជាថ្មីទៀត។ អ្នកទាំងអស់គ្នាចូរធ្វើតាមពាក្យទេវតាចុះ នឹងបានសេចក្ដីសុខសប្បាយដោយមូលមតិគ្នា។ បណ្ដារាស្ត្រទាំងពួងឮហើយ ក៏មានសេចក្ដីត្រេកអរយ៉ាងក្រៃលែង។ **តៀវកុក**ឲ្យយកសំពត់ពណ៌លឿងជូតក្បាលទាំងអស់គ្នាជាសម្គាល់ប្រមាណជាសែសិប ឬហាសិបម៉ឺននាក់ ដែលជាពួកកងរបស់**តៀវកុក** ហើយ**តៀវកុក**និងសេនាទាហានទាំងនោះ ក៏ព្រមចិត្តគ្នាធ្វើជាចោរ នឹងរកអ្នកឯណាតទល់នោះគ្មាន ក៏រឹតតែមានកម្លាំងច្រើនឡើង។

**ហ្វូជិន**ឃើញហេតុដូច្នោះ ក៏នាំយកសេចក្ដីនេះទៅក្រាបបង្គំទូលព្រះចៅ**ឡេនតេ**ៗជ្រាបហើយ ទើបត្រាស់ឲ្យយកព្រះរាជសារប្រាប់ទៅគ្រប់ខេត្តទាំងអស់ថា "បើអ្នកឯណាមានថ្វីដៃខ្លាំងពូកែចាប់ពួកចោរជូតក្បាលលឿងបាន នឹងឲ្យបំណាច់រង្វាន់ធ្វើជានាម៉ឺនមានយសស័ក្តិតាមថ្នាក់គុណានុរូប" ទើបត្រាស់ប្រើ**ចុងឡុងជៀវ**ទាហានឯក១, **ឡោជិន១**, **ហង់ហ៊្វូសុង១**, **ជូហ៊ី១** ឲ្យលើកពលចេញទៅជា៣ប៉ែក ដើម្បីព័ទ្ធចាប់ខ្លួន**តៀវកុក**ឲ្យបាន។ ឯ**តៀវកុក**ក៏លើកទាហានទៅព័ទ្ធលំនៅចុងដែនស្រុកអ៊ីវជីវ។ **ឡៅអៀន** ចៅហ្វាយស្រុកអ៊ីវជីវនោះ ជាពួកអ្នកស្រុកកាំងហៃ

លោហិតតវង្សនឹង**ហាន់ចូកូ** ជាចៅ**លាំងចុងហង់** កាលបើដឹងដំណឹងថា ពួកចោរផ្ទួតក្បាលលឿង លើកគ្នាមកវាយចុងដែនស្រុកអីវជីវដូច្នោះ ក៏ឲ្យហៅ**ចៅចេង**ជានាយទាហានមកពិគ្រោះប្រឹក្សា។ **ចៅចេង**ថា “ពួកចោរមានកម្លាំងក្លាហានណាស់ ទាហានស្រុកយើងតិច គួរឲ្យមានសំបុត្រទៅបញ្ចុះបញ្ចូលពួកអ្នកស្រុកដែលនៅចុងដែនសិន បើអ្នកឯណាខ្លាំងពូកែមានថ្វីដៃចាប់ពួកចោរទាំងនោះបាន នឹងទូលស្នើសេចក្ដីគាប់ប្រសើរនោះដល់ព្រះចៅ**ឡេនតេ**”។ **ឡៅអៀន**ក៏យល់ព្រម ទើបឲ្យធ្វើជាសំបុត្របញ្ចុះបញ្ចូលយកទៅបិទទុកនៅមុខទ្វារគ្រប់ស្រុកគ្រប់ខេត្តទាំងអស់។

នៅស្រុកទុនគួន មានបុរសម្នាក់ឈ្មោះ**ឡៅពី** កាលពីកុមារឈ្មោះ **ហៀនតិក** ជាអ្នកមិនសូវសង្វាតរៀនសំបុត្រស្នាមអ្វីនឹងគេ តែជាអ្នកមានតម្រិះប្រាជ្ញាច្រើន ចិត្តក៏ល្អ សូម្បីមានសេចក្ដីក្រោធយ៉ាងណាក៏មិនអាចនរណាដឹងបាន ព្រោះគ្មានអាការបញ្ចេញទៅខាងក្រៅឲ្យគេដឹងប្រាកដសោះ មានកិរិយាសុភាពរាបសា មានបក្សពួកច្រើន មានសន្ដានចិត្តជាអ្នកទូលាយ ទាំងរូបរាងសោតក៏ធំដំបងជាងមនុស្សទាំងពួង ប្រកបដោយលក្ខណៈរូបធំខ្ពស់ស្រឡះប្រមាណប្រាំហត្ថប្លាយ ត្រចៀកសងខាងយារដល់ស្មា ដៃវែងសំយ៉ុងចុះក្រោមយារដល់ក្បាលជង្គង់ មុខសក្បុសដូចពណ៌ថ្មកែវ បបូរមាត់ក្រហមដូចជាតិហិង្គុល ភ្នែកទាំងគូបើងាកទៅខាងមើលឃើញត្រចៀកខ្លួនឯង។

**ឡៅពី**នោះជាបុត្រ**ឡៅហេង**ៗជាពូជរាជវង្សព្រះចៅ**ហាន់កេងតេ**។ លុះ**ឡៅហេង**ជាបិតាអនិច្ចកម្មទៅ **ឡៅពី**ក៏នៅកំព្រាតែពីរនាក់នឹងមាតា។ **ឡៅពី**ជាមនុស្សមានសេចក្ដីកតញ្ញូ ចេះថែរក្សាមាតាមិនឲ្យមានហ្មង តែជាអ្នកខ្សត់ទ្រព្យសម្បត្តិ ត្បាញកន្ទេលលក់ចិញ្ចឹមជីវិត។ ទីលំនៅដែល**ឡៅពី**នៅនោះឈ្មោះភូមិ

ឡៅសងឈុន នៅជិតស្រុកទុនគួន ផ្ទះដែល**ឡៅពី**នៅៗជិតដើមមន ។ ដើមមននោះមានកម្ពស់ប្រមាណជាប្រាំបីព្យាមប្លាយ មានមែកត្រសុំសាខាដូចឆត្រ។

គ្រាមួយមានគ្រូម្នាក់ដើរមកឃើញភូមិផ្ទះ**ឡៅពី** និងដើមមនត្រូវនឹងតម្រាខ្លួន ក៏ទំនាយថា “ភូមិនេះមានអ្នកមានបុណ្យនៅ” វេលានោះ**ឡៅពី**នៅតូចនៅឡើយ ពេលដែល**ឡៅពី**លេងជាមួយនឹងក្មេងតូចៗដូចគ្នាតែងស្រដីថា “បើអញបានធ្វើស្ដេច អញនឹងយកដើមមននេះធ្វើជាស្វេតច្ឆត្របាំង”។ **ឡៅអួន** គឺជាមាបានឮ**ឡៅពី**និយាយប្លែកៗដូច្នេះ ក៏សម្គាល់**ឡៅពី**ថា “ក្មួយអញនេះប្រហែលជាមានបុណ្យប្រាកដមែន”។ ចាប់តាំងពីពេលនោះមក **ឡៅអួន** គឺជាមាក៏ទំនុកបម្រុងឲ្យមាសប្រាក់ដល់**ឡៅពី**ជារឿយៗ។ លុះកុមារ**ឡៅពី**បានអាយុ ១៥ ឆ្នាំ មាតាឲ្យទៅនៅរៀនអក្សរនឹងគ្រូម្នាក់ឈ្មោះ**តេហៀន**។ **ឡៅពី**មានសំឡាញ់ពីរនាក់ឈ្មោះ **លោទិត១** និង **ស៊ិនចាន់១** នៅរៀនអក្សរជាមួយគ្នាដរាបទាល់តែដល់អាយុ ២៥ ឆ្នាំ។

ខណៈនោះ **ឡៅពី**ដើរចេញទៅបានឃើញសំបុត្រដែលគេបិទនៅខ្លោងទ្វារស្រុក ក៏ឈរមើលៗហើយដកដង្ហើមធំ ពេលនោះមានមនុស្សម្នាក់ឈរពីក្រោយខ្នង**ឡៅពី**ពោលថា “យី! អ្នកឯងនេះជាតិជាប្រុសគ្រលាំង ម៉េចក៏មិនជួយយកអាសាផែនដី? ហេតុអ្វីហើយក៏មកឈរដកដង្ហើមធំដូច្នេះវិញ?” **ឡៅពី**បែរមុខទៅឃើញមនុស្សនោះឈរពីក្រោយ រូបរាងធំដំបង កម្ពស់ប្រាំហត្ថ ក្បាលដូចក្បាលខ្លា ភ្នែកក្រឡោតធំៗ ធ្មាមរីកធំ សំឡេងមួយដូចផ្គរ កិរិយាដូចសេះផាយ។ **ឡៅពី**ឃើញចម្លែកដូច្នោះ ក៏សួរថា “អ្នកឯងឈ្មោះអ្វី?” មនុស្សនោះឆ្លើយថា “យើងឈ្មោះ**តៀវហ៊ុយ អេកតិក** នៅស្រុកចុងគុន យើងមានទ្រព្យសម្បត្តិ និងស្រែចម្ការជាច្រើន មានទាំងរានលក់ស្រា និងសាច់ទៀតផង។ យើងគាប់ចិត្តរកគប់នឹងមិត្តភក្តិណាដែលមានសតិបញ្ញាច្រើន។ ឥឡូវនេះយើងបានមកឃើញអ្នកឈរមើលសំបុត្រ

ហើយដកដង្ហើមធំ នាំឲ្យយើងពិភាល់ក្នុងចិត្តពេលណាស់ ទើបយើងសួរអ្នកចង់ដឹងសេចក្ដីពិត!”។ **ឡៅពី**ឆ្លើយថា “យើងជាពូជព្រះវង្សព្រះចៅ**ហាន់កេងតេ** ឈ្មោះ**ឡៅពី** បានឮដំណឹងថា មានពួកចោរជូតក្បាលលឿងមកធ្វើឲ្យអន្តរាយផែនដី ទើបយើងចង់ជួយយកអាសាផែនដី ចេញទៅកម្រាបពួកចោរទាំងនោះ តែនឹងលុះទៅមិនរួច ដោយកម្លាំងតិចទ្រព្យសម្បត្តិក៏ស្ដួចស្ដើង។ យើងគិតទៅមិនសម្រេចទើបដកដង្ហើមធំដូច្នេះ”។ **តៀវហ៊ុយ**ឆ្លើយថា “ទ្រព្យសម្បត្តិយើងឯណេះមានគ្រប់គ្រាន់ល្មមហើយ ដូច្នេះយើងគិតនាំគ្នាទៅបញ្ចុះបញ្ចូលពួកអ្នកស្រុកដែលមានថ្វីដៃពូកែៗ ឲ្យលើកគ្នាទៅជួយព័ទ្ធចាប់ពួកចោរកំណាចទាំងនោះ តើអ្នកយល់ថាដូចម្ដេច?” **ឡៅពី**ឆ្លើយថា “គំនិតដែលអ្នកគិតនេះត្រូវពិតមែនហើយ គាប់ចិត្តយើងពេកណាស់ ដោយគំនិតនេះត្រូវនឹងគំនិតយើង” រួចក៏បបួលគ្នាទៅតៀមសុរាទិញសុរាផឹកជាមួយគ្នា។

ខណៈនោះ មានមនុស្សម្នាក់រូបរាងធាត់ធំសម្បើមបរទេះមកដល់នៅមុខតៀមលក់សុរា ហើយស្រែកហៅអ្នកលក់សុរាថា “ចូរអ្នកយកសុរាមកលក់ឲ្យយើងឆាប់ៗ យើងនឹងអាលផឹករួចទៅជួយយកអាសាផែនដី” **ឡៅពី**ងាកទៅឃើញមនុស្សនោះរូបរាងធំដំបងកម្ពស់ប្រាំមួយហត្ថ ពុកចង្កាប្រវែងមួយហត្ថប្លាយ មុខក្រហមដូចផ្លែពុទ្រាទុំ បបូរមាត់ក្រហមដូចជាតិហិង្គុល ចញ្ចើមដូចកូននាង (សត្វនាង) ភ្នែកវែងដូចភ្នែកសត្វករវិក កិរិយាខុសប្លែកពីមនុស្សធម្មតា។ **ឡៅពី**ឃើញដូច្នោះក៏បបួលឲ្យចូលទៅផឹកសុរាជាមួយគ្នា ហើយសួរថា “អ្នកឈ្មោះអ្វី?” មនុស្សនោះឆ្លើយថា “យើងឈ្មោះ**គួនអ៊ូ** ខ្លះហៅថា **ហ៊ុនទៀង** នៅស្រុកហាតុងកៃលៀង នៅស្រុកនោះមានមនុស្សម្នាក់មានទ្រព្យសម្បត្តិច្រើន ប៉ុន្តែកាចណាស់ តែងតែកំហែងមនុស្សទាំងពួងឲ្យគេកោតខ្លាចខ្លួន។ យើងឃើញហេតុអាក្រក់ដូច្នេះ ក៏សម្លាប់វាចោលទៅ។ យើងរត់មកនៅស្រុកនេះស្រុកនោះជាច្រើនតំបន់ហើយ ឥឡូវយើងទើប

នឹងចូលមកដល់ស្រុកនេះបានឮដំណឹងថា មានគេបិទប្រកាសបញ្ចុះបញ្ចូលពួកអ្នកស្រុកឱ្យទៅជួយយកអាសាផែនដី ចាប់ពួកចោរជូតក្បាលលឿង។ ហេតុនេះបានជាយើងមក ដើម្បីជួយយកអាសាធ្វើការនេះ។

**ឡៅពី**តបថា "មែនហើយ! យើងទាំងពីរនាក់នេះក៏កំពុងតែត្រិះរិះគិតដូចអ្នកដែរ។ បើយើងទាំងបីនាក់មានគំនិតគិតត្រូវគ្នាដូច្នេះឈ្មោះថា ជាការប្រពៃពេកណាស់" **គួនអ៊ូ**បានឮដូច្នោះ ក៏មានសេចក្ដីពេញចិត្តឥតរង្កៀស។ **តៀវហ៊ុយ**ឆ្លើយថា "យើងទាំងបីនាក់មានគំនិតគិតត្រូវគ្នាដូច្នេះ ខ្ញុំសូមអញ្ជើញអ្នកទាំងពីរទៅផ្ទះខ្ញុំ នៅក្រោយផ្ទះខ្ញុំមានសួនច្បារជាទីសប្បាយណាស់ ហើយជាកន្លែងស្ងាត់ផង ទាំងផ្កាយីថូទៀត ក៏មានរីកនៅទីនោះជាច្រើន។ យើងនឹងបានបេះបូជាព្រះនូវទេព្ដា ហើយនឹងបានឱ្យសច្ចាប្រណិធានដល់គ្នាឱ្យជាចិត្តមួយថ្លើមមួយជាមួយគ្នា នឹងបានគិតគូរការធំតទៅ។ **ឡៅពី** និង**គួនអ៊ូ** បានឮដូច្នោះត្រេកអរណាស់ ទើបបបួលគ្នាដើរតម្រង់ទៅកាន់ផ្ទះ**តៀវហ៊ុយ** ។

ព្រឹកឡើង**តៀវហ៊ុយ**ក៏រៀបចាត់ចែងយកសេះស និងក្របីខ្មៅនូវធូបទៀនមានទាំងគ្រឿងពលីការអាមិសផ្សេងៗ នាំយកទៅជាមួយផង លុះទៅដល់ទីសួនច្បារក្រោយផ្ទះ ក៏អុជទៀនធូបធ្វើសក្ការៈបូជាព្រះនូវទេព្ដា ទាំងសច្ចាប្រណិធានថា "យើងខ្ញុំឈ្មោះ **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ទាំងបីនាក់នេះនៅស្រុកទេសផ្សេងៗពីគ្នា វេលាថ្ងៃនេះបានភប់ប្រសព្វគ្នា យើងនឹងបានតាំងចិត្តឱ្យសត្យសញ្ញាដោយសច្ចាប្រណិធានស្បថស្បាន សុំយកគ្នាធ្វើជាបងប្អូនរួមឧទរ ជាមួយគ្នាជាចិត្តជីវិតមួយ សុំឱ្យមានសេចក្ដីទៀងត្រង់ដល់គ្នានឹងគ្នាត្រាតែអស់ជីវិតរៀងខ្លួន ដើម្បីនឹងបានជួយទំនុកបម្រុងផែនដីឱ្យបានសេចក្ដីសុខតទៅ បើមានភ័យអន្តរាយដោយប្រការឯណានីមួយ ត្រូវឱ្យជួយយកអាសាដល់គ្នានឹងគ្នា សូម្បីមានបរាជ័យក្នុងសឹកសង្គ្រាមក្ដី ក៏

មិនលះបង់ចោលគ្នាឡើយ គឺត្រូវតែជួយការពារគ្នាដរាបទាល់តែស្លាប់ទាំងបីនាក់ រីសេចក្តីស្បថដែលយើងខ្ញុំទាំងបីនាក់បានតាំងសច្ចាប្រណិធាននេះ យើងខ្ញុំសូមឧទ្ទិសចំពោះមុខទេព្តា សូមឲ្យទេព្តាជួយធ្វើជាសាក្សីពេជ្រញាណ បើតទៅយើងខ្ញុំទាំងបីនាក់ពុំទៀងត្រង់នឹងគ្នា សូមឲ្យទេព្តាបំផ្លាញជីវិតឲ្យឃើញពិតប្រាកដទាន់ភ្នែកនាលោកិយ។

លុះធ្វើសច្ចាប្រណិធានរួចហើយ គេក៏សន្មតហៅ**ឡៅពី**ជាបងច្បង **គួនអ៊ូ**ជាប្អូនបន្ទាប់ **តៀវហ៊ុយ**ជាប្អូនពៅ។ វេលានោះពួកអ្នកស្រុកដែលខ្លាំងពូកែ ពួកណាបានដឹងក៏នាំគ្នាទៅចុះចូលនឹងពួកនេះបានប្រមាណជា៣០នាក់។

ថ្ងៃមួយ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** បានឲ្យរៀបតុលៀងភោជនាហារ ចាត់ការរៀបចំគ្រឿងសាស្ត្រាវុធទុកជាស្រេច នៅខ្វះតែសេះជំនិះប៉ុណ្ណោះដែលមិនទាន់មាន។

ក្រោយពេលនោះបន្តិចមក ស្រាប់តែមានបុរសម្នាក់មកប្រាប់**ឡៅពី**ថា "ឥឡូវនេះមានឈ្មួញពីរនាក់នាំសេះជាច្រើនចូលមកលក់ក្នុងស្រុកនេះ" **ឡៅពី**ឮដូច្នោះក៏ស្ទុះមីម្នាចេញទៅទទួលឈ្មួញសេះទាំងពីរនាក់នោះនាំចូលមក។ ឯឈ្មួញសេះទាំងពីរនោះ ម្នាក់ឈ្មោះ**តៀវស៊ីផេង** ម្នាក់ទៀតឈ្មោះ**ឡៅសុង**។ ឈ្មួញទាំងពីរនេះបាននិយាយប្រាប់**ឡៅពី**ថា "យើងខ្ញុំទាំងពីរនាក់រកស៊ីបានសុខជាយូរឆ្នាំមកហើយ ទើបតែមកដល់ឆ្នាំនេះ នាំសេះទៅលក់ប្រទះតែនឹងពួកចោរ នៅកណ្តាលផ្លូវទៅមិនរួច ទើបយើងខ្ញុំនាំគ្នាត្រឡប់មកស្រុកនេះវិញ"។ **ឡៅពី**ស្តាប់ហើយក៏ហៅឈ្មួញទាំងពីរនាក់នោះឡើងទៅលើផ្ទះ ហើយបង្គាប់ឲ្យរៀបចំភោជនាហារបរិភោគទាំងអស់គ្នា រួចទើប**ឡៅពី**ផ្តើមនិយាយឡើងថា យើងគិតនាំគ្នាទៅចាប់ពួកចោរកំណាច ដែលវាធ្វើឲ្យចលាចលដល់ផែនដី។ **តៀវស៊ីផេង** និង**ឡៅសុង**ស្តាប់ហើយ

ឆ្លើយថា “លោកមានប្រសាសន៍នេះត្រូវនឹងបំណងរបស់យើងខ្ញុំពេកណាស់ ដូច្នេះ យើងខ្ញុំទាំងពីរនាក់សូមជូនសេះហាសិប ប្រាក់ប្រាំរយតម្លឹង និងដែកមួយរយហាប ដល់លោក ដើម្បីជាកម្លាំងធ្វើការនេះតទៅ។ ថាហើយក៏ជូនរបស់ទាំងនោះទៅឱ្យ **ឡៅពី** ។បានទទួលហើយ មានសេចក្តីត្រេកអរអរគុណដល់ឈ្មួញទាំងពីរនាក់ជាអនេក រួចទើបឱ្យរកជាងមកដំធ្វើជាគ្រប៊ីពីរសម្រាប់កាន់ខ្លួនឯង ដំធ្វើជាគ្រប៊ីមួយប្រវែងដប់មួយហត្ថ ទម្ងន់ប៉ែតសិបពីរនាឡិឱ្យ**គួនអ៊ូ**កាន់ ដំធ្វើជាលំពែងមួយប្រវែងដប់ហត្ថ ទម្ងន់ប៉ែតសិបប្រាំនាឡិឱ្យ**តៀវហ៊ុយ**កាន់ ហើយនិងឱ្យធ្វើគ្រឿងក្រោះពាក់ និងអានសេះសម្រាប់ចេញច្បាំងគ្រប់គ្នាទាំងបីនាក់។

ចាប់តាំងពីពេលនោះមក អ្នកទាំងបីនាក់ក៏បញ្ចុះបញ្ចូលពួកអ្នកស្រុកដែលមានថ្វីដៃបានចំនួន ៥០០នាក់ នាំចូលទៅរក**ចៅចេង**។ក៏នាំចូលទៅរកចៅហ្វាយស្រុក**ឡៅអៀន**។ អ្នកទាំងបីនាក់គំនាប់ចៅហ្វាយស្រុករួចហើយ ទើបនិយាយប្រាប់ឈ្មោះ និងសែខ្លួនដល់ចៅហ្វាយស្រុក**ឡៅអៀន**។ ឮថា**ឡៅពី**ជាសែជាមួយគ្នា ក៏មានសេចក្តីមេត្រីរាប់អានចំពោះ**ឡៅពី**ជាខ្លាំង ទើបទទួល**ឡៅពី**ទុកជាក្មួយប្រុស។

លុះនៅមកបានច្រើនថ្ងៃ មានបម្រើកាន់សំបុត្រចូលមកប្តឹងថា “ពួកចោរជូតក្បាលលឿង មានទាហានឯកឈ្មោះ**តៀវអួនជី** បានលើកពលចំនួនប្រាំម៉ឺននាក់ទន្ទ្រានចូលមកដល់ក្នុងដែនស្រុកទុនគួនហើយ”។ ចៅហ្វាយស្រុក**ឡៅអៀន**ឮដូច្នោះក៏ចាត់**ចៅចេង**ឱ្យហៅ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** មកប្រឹក្សាថា “អ្នកទាំងបីនាក់! ចូរអ្នកនាំគ្នាលើកកងទ័ពចំនួនប្រាំរយនាក់ ទៅព័ទ្ធចាប់ពួកអាចោរទាំងនោះឱ្យបាន”។ អ្នកទាំងបីបានឮដូច្នោះមានចិត្តត្រេកអរណាស់ ព្រមទទួលយកអាសាផែនដី ទើបលើកកងទ័ពទាំងប្រាំរយចេញមកសំដៅទៅកាន់ភ្នំថៃហៀងអាន រមិលមើលទៅក៏ឃើញពួកចោរដើរដេរដាស លើកគ្នាចូលមកជាច្រើន។ ឯពួកចោរទាំងនោះមិនប្លង

សក់ទេ សុទ្ធតែសំយាកសក់ ហើយផូតក្បាលសំពត់ពណ៌លឿងទាំងអស់គ្នា។ **ឡៅពី**ឃើញដូច្នោះ ក៏ឱ្យរៀបចំជាបន្ទាយ វាយចំរូងស្រាស់បន្លាធ្វើជាកំផែងព័ទ្ធជុំវិញ ហើយបរសេះចេញទៅឈរមុខទ័ព ឱ្យ**គួនអ៊ូ**ជិះសេះអមខាងស្តាំ ឱ្យ**តៀវហ៊ុយ**ជិះសេះអមខាងឆ្វេង **ឡៅពី**ក៏លើកស៊ែឡើងអង្គុលមុខអាចោរហើយជេរថា “នែអាពួកក្បត់!”។ មេទ័ព**តៀវអួនជីឮឡៅពី**ជេរដូច្នោះខឹងណាស់ ទើបប្រើទាហានឯកម្នាក់ឈ្មោះ**តេងម៉ៅ** ឱ្យឡើងជិះសេះចេញទៅតយុទ្ធនាកណ្តាលរណរង្គ។ **តៀវហ៊ុយ**កាន់លំពែងប្រវែងដប់ហត្ថ បរសេះចូលទៅប្រយុទ្ធនឹង**តេងម៉ៅ**ភ្លាម ពេលនោះ**តៀវហ៊ុយ**វាំភ្លែងលំពែងចាក់ត្រូវចំកណ្តាលដើមទ្រូង**តេងម៉ៅ**ធ្លាក់ពីលើខ្នងសេះស្លាប់ក្នុងខណៈនោះឯង។

**តៀវអួនជី**ខឹងខ្លាំងណាស់ ស្ទុះកាន់គ្រប៊ីឡើងសេះបរសំដៅ**តៀវហ៊ុយ**។ **គួនអ៊ូ**ឃើញដូច្នោះ ក៏ស្ទុះឡើងសេះបរទៅតាំងពីមុខ**តៀវហ៊ុយ**ចាំទទួលរង។ **តៀវអួនជី**ឃើញរូប**គួនអ៊ូ**ក៏ស្លុតស្មារតីភ័យរលះរលាំង។ **គួនអ៊ូ**ឃើញបានការក៏យកគ្រប៊ីកាប់ត្រូវខ្លួន**តៀវអួនជី**ដាច់ជាពីរកំណាត់។ ពួកចោរទាំងឡាយក៏បែកខ្ចាត់ខ្ចាយរត់ចេញទៅអស់ **ឡៅពី**ក៏បរពលចូលដេញប្រកាប់ចាក់ពួកអាចោរបានជាឈ្លើយច្រើនណាស់លុះមានជ័យជម្នះហើយ ក៏លើកពលវិលត្រឡប់មកស្រុកទុនគួនវិញ។

ឯ**ឡៅអៀន**លុះដឹងព័ត៌មាន ក៏ចេញទៅទទួល**ឡៅពី**ដល់ទ្វារស្រុក ហើយនាំត្រឡប់ចូលមក។ **ឡៅអៀន**ក៏ឱ្យបំណាច់រង្វាន់ដល់ពួកទាហានតាមសមគួរ លុះព្រឹកឡើង មានបម្រើសេះកាន់សំបុត្រ**សិបកេង**ចៅហ្វាយស្រុកឆេងជីវមកដល់ចៅហ្វាយស្រុកទុនគួនថា ឥឡូវនេះពួកចោរផូតក្បាលលឿង លើកទ័ពមកព័ទ្ធស្រុកឆេងជីវច្រើនណាស់ សុំឱ្យចៅហ្វាយស្រុកទុនគួនលើកទ័ពទៅជួយ ។ **ឡៅអៀន** ដឹងដូច្នោះក៏ឱ្យរក**ឡៅពី**មកប្រឹក្សា។ **ឡៅពី**ថា ខ្ញុំបាទនិងប្អូនពីរនាក់សុំយកអាសាចេញ

ទៅជួយស្រុកឆេងជីវឱ្យអស់ពីចិត្ត។ **ឡៅអៀន**បានស្ដាប់ក៏ចាប់ចិត្តត្រេកអរណាស់ រលះរលាំងតាំងឱ្យ**ថៅចេង**ឃុំនាំពលទាហានប្រាំពាន់ លើកចេញទៅជាមួយនឹង **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**។ **ឡៅពី** និង**ថៅចេង**លើកទាហានទៅដល់ស្រុកឆេងជីវ ពួកចោរឃើញកងទ័ពក៏លើកត្រឡប់មកចោមវាយ។

**ឡៅពី, ថៅចេង** មានពលទាហានតិច ក៏រាថយគេចមក ហើយប្រឹក្សាគ្នានឹង **គួនអ៊ូ, តៀវហ៊ុយ**ថា ពលទាហានយើងតិចជាងពួកអាចោរ យើងត្រូវគិតជាកលសឹកទើបមានជ័យជម្នះងាយ ថាហើយ**ឡៅពី**ឱ្យ**គួនអ៊ូ**ឃុំនាំពលទាហានមួយពាន់ទៅបង្កប់នៅតំបន់ភ្នំខាងស្ដាំផ្លូវ ឱ្យ**តៀវហ៊ុយ**ឃុំនាំពលទាហានមួយពាន់ទៅបង្កប់នៅខាងឆ្វេងផ្លូវ កំណត់ថាបើបានឮសំឡេងឃ្មោះវេលាណា ឱ្យលើកទាហានវាយផ្ទប់សង្កុញចូលមកទាំងសងខាង។ **គួនអ៊ូ, តៀវហ៊ុយ**ទទួលស្ដាប់**ឡៅពី**ហើយ ក៏លើកទាហានចេញទៅ លុះព្រឹកឡើង**ឡៅពី**និង**ថៅចេង** ក៏លើកទាហានទៅតាមផ្លូវដែល**គួនអ៊ូ, តៀវហ៊ុយ**បង្កប់ពលនៅនោះ។

ឯពួកចោរក៏លើកពលរុករានទន្ទ្រានដេញទ័ព**ឡៅពី** ៗក៏បរពលចូលប្រយុទ្ធហើយរាថយទ័ពមកដល់ច្រកភ្នំដែលបង្កប់ទាហាននោះ ហើយឱ្យវាយឃ្មោះជាសញ្ញាឡើង **គួនអ៊ូ, តៀវហ៊ុយ**ដែលបង្កប់ទាហានទាំងសងខាងឮហើយ ក៏បញ្ចេញទាហានបំពានវាយផ្ទប់ប្រសព្វគ្នាមក **ឡៅពី**ក៏ដេញទាហានវាយផ្ទប់ពីមុខមកវិញ។

ទ័ពចោរកោលាហលច្របល់គ្នារឹករវរសន្ធឹកណាស់ សឹងរត់បំពានទៅជើងកំផែងស្រុកឆេងជីវ ទ័ព**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏ដេញវាយប្រសព្វខ្ទប់ពួកចោរខាង**ស៊ិបកេង**ថៅហ្វាយស្រុកឆេងជីវឃើញបានការ ក៏លើកទាហានដេញតាមទ្វារស្រុកព្រួតវាយត្រសុកមួយផ្លូវទៀត គ្រប់ទាំងបួនទិស ពួកចោរទាំងនោះក៏ស្ទុះរត់

ព្រាត់ព្រាយលាយច្របល់គ្នា ត្រឹមតែត្រូវរបួសនិងស្លាប់ក៏គណនារាប់ពុំអស់ លុះអស់ពេលយុទ្ធនាការបណ្ដានាយកងទ័ពគ្រប់ខ្លួន ក៏លើកពលចូលបន្ទាយវិញ។

**ស៊ិបកេង**ចៅហ្វាយស្រុក ក៏ចែករង្វាន់ដល់ពលទាហាន**ឡៅពី**តាមសមគួរ ហើយ**ចៅចេង**និយាយថា យើងនឹងលើកទាហានត្រឡប់ទៅស្រុកទុនគួនវិញ។ **ឡៅពី**ឆ្លើយថា ខ្ញុំបានឮគេនិយាយថា **លោទិត**ជាទី **ទុងឡុងជាង**ជាទាហានឯករបស់ព្រះចៅ**ឡេនតេ** កំពុងច្បាំងនឹង**តៀវកុក**ជាចោរនៅតំបន់ស្រុកកុងចុង បើដូច្នេះខ្ញុំនឹងសុំយកអាសាលើកទាហានទៅច្បាំងនឹងពួកចោរនៅទីនោះទៀត។ **ចៅចេង**ឮដូច្នេះក៏ចាត់ទាហានឲ្យទៅ**ឡៅពី**ប្រាំរយនាក់ ឯ**ចៅចេង**លើកទាហានតម្រង់សំដៅទៅស្រុកទុនគួនវិញ។ ខណៈនោះ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លើកទាហានទៅដល់ស្រុកកុងចុង ហើយបបួលគ្នាចូលទៅរក**លោទិត** ទើបយកខរាជការ ដែលខ្លួនបានតច្បាំងនឹងពួកចោរកាលគ្រាមុននោះមកពណ៌នាឲ្យ**លោទិត**ស្ដាប់។ **លោទិត** ពេញចិត្តណាស់ក៏និយាយថា អ្នកទាំងបីនាក់ចូលទៅធ្វើរាជការជាមួយនឹងយើងចុះ។

ខាង**តៀវកុក**មានពួកចោរជាពលទាហានចំនួនដប់ប្រាំមឺន ខាងឯ**លោទិត**មានពលទាហានចំនួនប្រាំម៉ឺន ទ័ព**លោទិត** និង**តៀវកុក**តាំងបន្ទាយប្រទល់គ្នា បានតតាំងច្បាំងគ្នាមិនទាន់ចាញ់ឈ្នះនៅឡើយ។ **លោទិត**និយាយនឹង**ឡៅពី**ថា **តៀវប៉ូ**និង**តៀវលៀង**ជាប្អូន**តៀវកុក**នោះឃុំនាំពួកចោរទៅច្បាំងនឹង**ហាង់ហ៊្វូសុង** និង**ជូហ៊ី**នៅស្រុកអេងឆួន យើងនឹងបំបែកទាហានឲ្យអ្នកមួយពាន់ រួមជាមួយនឹងទាហានរបស់អ្នក ៗចូរលើកទៅជួយ**ហាង់ហ៊្វូសុង** និង**ជូហ៊ី**នៅស្រុកអេងឆួនចុះ ហើយឲ្យអ្នកជួយស៊ើបយកដំណឹងរាជការធូន់ស្រាលឲ្យដឹងផង។ **ឡៅពី**ទទួលពាក្យ**លោទិត** ហើយក៏លើកទាហានស្រូតរូតទាំងយប់ថ្ងៃតម្រង់ទៅស្រុកអេងឆួន។

ឯ**ហង់ហ៊ូសុងនិងជូហ៊ី** កំពុងបរពលចូលច្បាំងនឹងទ័ពនោះនៅមិនទាន់ចាញ់ឈ្នះអស់ពេលហើយ **តៀវប៉ូ, តៀវលៀង** ឲ្យទាហានថយទៅកាន់ទីកន្លែង ហើយឲ្យយកចំបើងធ្វើជំរំឡើងក្នុងបន្ទាយ ខាង**ហង់ហ៊ូសុង** និង**ជូហ៊ី**បានដឹង ទើបប្រឹក្សាគ្នាថា ឥឡូវនេះពួកចោរយកចំបើងទៅសង់ធ្វើជំរំក្នុងបន្ទាយ យើងនឹងគិតយកភ្លើងដុតបន្ទាយពួកចោរឲ្យបាន។ គិត**ហើយ**ឲ្យយកស្មៅទៅគរលាក់ទុកក្បែរបន្ទាយជាច្រើន លុះពេលកណ្ដាលអាធ្រាត្រយប់ស្ងាត់ ប្រហែលយាមពីរ ក៏បង្កើតខ្យល់ព្យុះជាខ្លាំងបោកបក់ត្រឡប់ ។ ពួកទាហានដែលបញ្ជូនទៅលាក់បង្កប់យល់បានការ ក៏នាំគ្នាយកភ្លើងឈ្នួលដុតស្មៅនោះឆេះឡើង ភ្លើងក៏ឆេះរាលដាលអស់ទាំងទីបន្ទាយចោរពន្លឺភ្លើងដ៏ភ្លឺសន្ធោរសន្ធៅបីដូចពេលថ្ងៃ ពួកចោរសឹងតែភិតភ័យជាចលាចលជ្រួលច្របល់ក្នុងបន្ទាយ សឹងតែស្ទុះរត់ព្រាត់ព្រាយចោលគ្រឿងប្រដាប់សម្រាប់សឹកគឺក្រោះបំពាក់និងអានសេះ ភ្លើងក៏ឆេះឡើងម៉ត់ឥតមានសេសសល់។ ពួកចោររត់ច្របល់ចេញពីបន្ទាយ **ហង់ហ៊ូសុង** និង**ជូហ៊ី**ក៏តាំងរាយរៀបពួកពលឲ្យចូលដេញចាក់កាប់សម្លាប់ ពួកចោរត្រូវរបួសពិការមរណៈស្លាប់នឹងគ្រារាប់ពុំបាន។ លុះព្រឹកឡើង**តៀវប៉ូ, តៀវលៀង**នូវអស់ពួកចោរទាំងឡាយដែលនៅសល់នោះ សឹងតែដោះរត់ឲ្យរួចជីវិតតែរៀងខ្លួន លុះរត់ទៅជួបនឹងកងទ័ពមួយកងសុទ្ធតែកាន់ទង់ក្រហមទាហានកងមុខចេញស្ទាក់កាត់ពួកចោរទុកមិនឲ្យទៅមុខរួច ឯមេទ័ពនោះឈ្មោះ**ចូឆូ**កម្ពស់ប្រហែលប្រាំហត្ថ ភ្នែកតូចពុកមាត់វែង ជាបុត្រ**ចូកូ**។ (ប្រវត្តិចូកូ) រីឯ**ចូឆូ**នោះកាលពីនៅតូចចូលចិត្តដើរលេងព្រៃរកបរបាញ់សត្វ តែងចូលចិត្តស្ដាប់ចម្រៀងរបាំតូរ្យតន្ត្រី មានសតិបញ្ញាវាងវៃរហ័ស ឈ្មោះ**ចូតិក**ជាមា កាលបានឃើញ**ចូឆូ**ជាអ្នកលេងមិនធ្វើការរកស៊ី ក៏មានចិត្តស្អប់ខ្លាំងណាស់ ទើបដើរទៅប្រាថ្នានឹងប្រាប់រឿងរ៉ាវឲ្យ**ចូកូ**ជាបងដឹង។ **ចូឆូ**ដឹងថា**ចូតិក**ជាមាស្អប់ខ្លួននាំរឿងទៅប្រាប់បិតា ក៏

ប្រើឧបាយធ្វើជាខ្យល់ចាប់ដួល មាឃើញដូច្នោះក៏ស្រែកប្រាប់**ចូក្ទូ**ថា **ចូឆ្ទូ**ខ្យល់ចាប់ដួលទៅហើយ។ **ចូក្ទូ**ភ័យណាស់ស្ទុះប្រញាប់ទៅមើល **ចូឆ្ទូ**ក៏ក្រោកឡើងលេងដូចប្រក្រតី។ **ចូក្ទូ**ក៏សួរថា “មាឯងទៅប្រាប់អញអម្បាញ់មិញថា ឯងខ្យល់ចាប់ ឥឡូវបាត់ហើយឬ? **ចូឆ្ទូ**ឆ្លើយថា “ខ្ញុំតាំងពីដើមមកមិនដែលមានឈឺអ្វីសោះឡើយ ហេតុដែលមាគាត់ស្អប់ខ្ញុំបាទណាស់ ទើបយកសេចក្ដីមិនពិតមកជម្រាបបិតាដោយក្លែងក្លាយទេ”។ តាំងពីថ្ងៃនេះតទៅ**ចូក្ទូ**ក៏ជឿពាក្យ**ចូឆ្ទូ** ទោះមានោះនឹងនាំយកហេតុអ្វីទៅនិយាយប្រាប់ ក៏**ចូក្ទូ**លែងជឿពាក្យសម្ដីប្អូនសោះ ឯ**ចូឆ្ទូ**ក៏កាន់តែកំរើបឥតកោតខ្លាចនរណា ប្រព្រឹត្តអំពើអាក្រក់ផ្សេងៗជាងមុន ពួកភៀនដែលលេងជាមួយគ្នាក៏លើកបញ្ជោរសរសើរ**ចូឆ្ទូ**ថា ផែនដីសម័យនេះកើតវឹកវរចលាចលខ្លាំងណាស់ គ្មាននរណាមួយមានសតិបញ្ញាក្លៀវក្លាហ៊ាន ប្រាបប្រាមការពារបច្ចាមិត្តឲ្យរាបទាបសោះ ។ យើងទាំងឡាយយល់ឃើញថា ខ្លួនលោកមានសតិបញ្ញា បើនឹងគិតការប្រាបប្រាមពួកអាកំណាចក៏អាចនឹងធ្វើឲ្យផែនដីប្រកបដោយសេចក្ដីសុខបាន។

ឯក្នុងស្រុកឡាំយ៉ុងនោះ មានបុរសម្នាក់ឈ្មោះ**ហ្សៅ** មានប្រាជ្ញាជ្រៅជ្រះណាស់ តែងនិយាយឲ្យអ្នកទាំងពួងបានដឹងថា ផែនដីក្រុងជារាជធានីនោះនឹងវិនាសសាបសូន្យហើយ ដែលនឹងប្រាបប្រាមពួកបច្ចាមិត្តរាជសត្រូវឲ្យរាបទាបបាន បើមានតែ**ចូឆ្ទូ**ម្នាក់។ ឯស្រុកលិឡាំនោះ មានគ្រូម្នាក់ឈ្មោះ**ខៅផៀវ**ចេះមើលលក្ខណៈមនុស្ស លុះ**ចូឆ្ទូ**ដឹងហើយក៏ស្វែងទៅរក**ខៅផៀវ** បានជួបហើយសួរទៅ**ខៅផៀវ**ថា “ខ្លួនខ្ញុំបាទនេះអំណឹះតទៅមុខតើនឹងបានជាមនុស្សល្អ ឬអាក្រក់ប្រការដូចម្ដេច?” **ខៅផៀវ**នៅស្ងៀម **ចូឆ្ទូ**ក៏សួរថែមទៅទៀត **ខៅផៀវ**ឆ្លើយថា “ខ្លួនអ្នកជាមនុស្សមានសតិបញ្ញាច្រើន តទៅមុខនឹងការពារផែនដីបាន ប៉ុន្តែមិនបានប្រកបដោយសត្យសុចរិតនឹងផែនដី គឺជាសត្រូវនឹងរាជសម្បត្តិ” **ចូឆ្ទូ**ក៏សើចដោយសេចក្ដីពេញចិត្ត។

លុះ**ចូឆ្វូ**បានអាយុម្ភៃឆ្នាំ ក៏ចូលទៅធ្វើរាជការជាទាហានក្នុងស្រុកឡុកអៀង ជាទីក្រុង **ចូឆ្វូ**ឲ្យយកឈើចំរឹងប៉ែតសិបកំណាត់ទៅដោតទុកគ្រប់ទ្វារទាំងបួនទិស ហាមមនុស្សមិនឲ្យដើរកណ្តាលយប់ បើនរណាដើរទៅមកខុសវេលា ឲ្យចាប់យកខ្លួនទៅធ្វើទោស។ លុះកណ្តាលយប់ក្នុងថ្ងៃមួយ **ចូឆ្វូ**ដើរទៅត្រួតក្រវែលប្រទះនឹងមនុស្សម្នាក់ជាពួកខន្ទី ដើរមកខុសវេលា **ចូឆ្វូ**ឲ្យចាប់ខ្លួនទៅវាយដប់ប្រាំខ្វាប់។

ឯ**ចូឆ្វូ**នោះ ធ្វើរាជការម៉ឺងម៉ាត់រឹតតែមានអំណាចឡើងរាល់ថ្ងៃ មនុស្សទាំងពួងសឹងកោតក្រែងរអែងខ្លាចជាច្រើនណាស់ ព្រះចៅ**ឡេនតេ**ទ្រង់ជ្រាបស្គាល់ក៏តាំងឲ្យឡើងយសជា "**ទុនខីវឡេង**"។ លុះពួកចោរជូតក្បាលលឿងកំរើបចលាចលពេញក្នុងស្រុកអេងឆ្វន ព្រះចៅ**ឡេនតេ**ទ្រង់តាំងឲ្យ**ចូឆ្វូ**ឡើងទីជា**គុះអ៊ុយ** ឲ្យឃុំនាំទាហានប្រាំពាន់លើកទៅជួយស្រុកអេងឆ្វន លុះទៅដល់ហើយក៏ប្រទះនឹង**តៀវប៉ូ, តៀវលៀង** និងពួកចោរដែលសល់ពីស្លាប់កាលបែកបន្ទាយរត់ទៅនោះ **ចូឆ្វូ**ក៏លើកពលស្ទាក់កាត់មុខទុក ហើយខ្ទប់សម្លាប់ពួកចោរអស់ប្រហែលមួយម៉ឺនប្លាយ ទាហាន**ចូឆ្វូ**ចាប់បានសេះ និងគ្រឿងសាស្ត្រាវុធជាច្រើនណាស់ តែខ្លួន**តៀវប៉ូ, តៀវលៀង** គេចរត់រួចទៅ។

ឯ**ចូឆ្វូ**ចូលទៅរក**ហុងហ៊ូសុង និងជូហ៊ី** ហើយដំណាលពីកិច្ចរាជការទាំងពួង ទើប**ចូឆ្វូ**សុំយកទាហានទៅតាម**តៀវប៉ូ, តៀវលៀង**ទៀត។ ខាង**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** លើកពលមកដល់ស្រុកអេងឆ្វនបានឮសំឡេងគេតតាំងច្បាំងគ្នា ឃើញមានពន្លឺភ្លើងភ្លឺស្វាងណាស់ ក៏រលះរលាំងដេញទាហានឲ្យស្រូតចូលទៅជួយ លួមចូលទៅដល់ពួកចោរក៏បែកបាក់ខ្ចាត់ខ្ចាយទៅ **ឡៅពី**ក៏នាំ**គួនអ៊ូ, តៀវហ៊ុយ** ចូលទៅរក**ហុងហ៊ូសុង** និង**ជូហ៊ី** ជួបគ្នាហើយក៏និយាយថា **ឈោទិត**ឲ្យខ្ញុំបាទមកជួយធ្វើការលោក។ **ហុងហ៊ូសុង** និង**ជូហ៊ី** ទទួលថា ខ្ញុំអរគុណណាស់ រួចនិយាយថា ឥឡូវនេះ

**តៀវប៉ូ, តៀវលៀង** និងពួកចោរបែកអស់ហើយ ខ្ញុំឃើញថា **តៀវប៉ូ, តៀវលៀង**នឹងរត់ទៅរក**តៀវកុក**ជាបងនៅស្រុកចុងកុង បើដូច្នេះចូរអ្នកលើកទាហានស្រូតរូតតាមស្ទាក់ស្កាត់ចាប់ឲ្យបានខ្លួនចុះ។ **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លាត្រឡប់លើកទាហានតាមទៅ លុះដល់ពាក់កណ្ដាលផ្លូវទទួលជួបប្រទះនឹងព្រះរាជបម្រើ ឃុំមនុស្សទោសក្នុងទ្រុងដាក់លើរទេះបរមក ក្រឡេកតាមមើលទៅស្គាល់ឃើញច្បាស់ជា**លោទិត**នៅក្នុងទ្រុងនោះ **ឡៅពី**ស្លុតចិត្តចុះពីលើខ្នងសេះស្ទុះចូលទៅសួរ**លោទិត**ថា ហេតុម្ដេចអ្នកទើបមកត្រូវទោសដូច្នេះ? **លោទិត**ថា ខ្ញុំបាទព័ទ្ធឡោម**តៀវកុក**ទុកឲ្យនៅក្នុងបន្ទាយ ទៀបនឹងចាប់ខ្លួនបានហើយ **តៀវកុក**ដឹងខ្លួនចេះតែប្រុងប្រយ័ត្ន ខ្ញុំនឹងគិតចាប់ឲ្យឆាប់ទាន់ចិត្តពុំបាន ព្រះចៅ**ឡេនតេ** ទ្រង់បានជ្រាប ទើបត្រាស់ប្រើ**ជូហុង**ក្រុមវាំងចេញមកស៊ើបការណ៍រាជការ។ **ជូហុង**ប្រាថ្នានឹងចង់បានទ្រព្យរបស់ពីខ្ញុំៗបានប្ដឹងជម្រាបថា ក្នុងកងទ័ពនេះកំពុងដាច់ស្បៀងអាហារណាស់ ខ្ញុំគ្មានរបស់អ្វីគួរសមជូនជាជំនូនទេ។ **ជូហុង**ខឹងនឹងខ្ញុំត្រឡប់ទៅក្លែងពិតទូលព្រះចៅ**ឡេនតេ**ថា ខ្ញុំមិនយកចិត្តទុកដាក់ធ្វើរាជការសឹកសង្គ្រាម ហេតុនេះបានជាយឺតយូរពុំសម្រេចការ ព្រះចៅ**ឡេនតេ**ជឿពាក្យនេះ ទើបត្រាស់ប្រើ**តាំងតុះ**ឲ្យចេញមកជាមេទ័ពជំនួសខ្ញុំ ហើយត្រាស់ឲ្យចាប់ខ្ញុំធ្វើទោសដាក់ទ្រុងនាំទៅស្រុកក្រុង។ **តៀវហ៊ុយ** បានឮដូច្នោះក៏នឹកខឹងណាស់ កន្ត្រាក់យកគ្រប៊ីលើកឡើងនឹងសម្លាប់ភូឃុំ ដណ្ដើមដោះយក**លោទិត**ចេញពីទ្រុង **ឡៅពី**ឃើញអាការដូច្នោះក៏ស្ទុះទៅរាំងរាថា កុំអាលធ្វើលើព្រះរាជអាជ្ញាសិទ្ធិ នឹងធ្វើតាមអំពើចិត្តមិនបានទេ។ **គួនអ៊ូ** ឆ្លើយថា អម្បាល**លោទិត**ហើយ គង់មានសេចក្ដីខុសដូច្នេះ ក្រៅពីនេះនរណានឹងអាចធ្វើជាមេទ័ពតទៅទៀតបាន? ឃើញថានឹងនាំគ្នារកទីពឹងពាក់អាស្រ័យគ្មានឡើង សូម្បីតែធ្វើការមានគុណគាប់ជាបំណាច់យ៉ាងណា ក៏គង់ត្រឡប់ខុសទៅបានដូច**លោទិត**ជាតួយ៉ាង។ បើដូច្នេះ

យើងត្រូវត្រឡប់ទៅស្រុកទុនគួនវិញជាជាង។ **ឡៅពី**ស្ដាប់ឃើញត្រូវ ក៏លើកទាហានត្រឡប់ទៅស្រុកទុនគួន លុះលើកទៅបានពីរបីថ្ងៃ ដល់ពាក់កណ្ដាលផ្លូវ ឮសំឡេងស្រែកហោរកញ្ជៀវខាងក្រោយភ្នំ **ឡៅពី**ក៏នាំ**គួនអ៊ូ, តៀវហ៊ុយ** បរសេះឡើងទៅមើលពីលើកំពូលភ្នំ ក្រឡេកទៅឃើញទ័ពហ្លួងបែក ឃើញទ័ពចោរជួតក្បាលលឿងលើកដេញសង្កុញមក **ឡៅពី**ឃើញទង់ជ័យស្គាល់ជាទ័ព**តៀវកុក** លើកដេញទ័ព**តាំងតុះ** ទើប**ឡៅពី គួនអ៊ូ, តៀវហ៊ុយ** ត្រឡប់ញាក់សេះចុះទៅជួយខាងទ័ពហ្លួង ទ័ព**តៀវកុក**ក៏ត្រឡប់បាក់បែកខ្ចាត់ខ្ចាយតាមផ្លូវទៅប្រមាណប្រាំរយ។ ឯ**តាំងតុះ**ក៏លើកទ័ពចូលបន្ទាយ ហើយឲ្យរក**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ទៅសួរថា អ្នកឯងជាមន្ត្រីតំណែងអ្វី? **ឡៅពី**ឆ្លើយថា ខ្ញុំបាទមិនបានជាមន្ត្រីតំណែងអ្វីទេ។ **តាំងតុះ**បានស្ដាប់ដូច្នោះ ក៏ធ្វើកិរិយាបែបមើលងាយមិនមានសេចក្ដីគួរសមរាប់អាន **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លាត្រឡប់ទៅវិញ **តៀវហ៊ុយ**ក៏និយាយថា បើបងប្អូនបីនាក់ជួយយកអាយុជីវិតវាឲ្យរួចពីសេចក្ដីស្លាប់គ្រានោះ វាមិនស្គាល់គុណយើងសោះ ត្រឡប់ជាធ្វើឫកមើលងាយយើងវិញ គួរតែសម្លាប់វាចេញទើបអស់សេចក្ដីក្ដៅចិត្ត ថាហើយក៏កន្ត្រាក់គ្រប៊ីស្ទុះវិលទៅនឹងសម្លាប់**តាំងតុះ**។ **ឡៅពី, គួនអ៊ូ** រារាំងឃាត់ថា កុំធ្វើ គេជាព្រះរាជបម្រើ។ **តៀវហ៊ុយ**តបថា បើមិនសម្លាប់វាចេញ ត្រូវការអ្វីយើងនឹងនៅធ្វើការជាមួយនឹងវា ៗនឹងមានសេចក្ដីមើលងាយប្រមាថយើងច្រើនទៅទៀត ព្រោះវាមានអាជ្ញាសិទ្ធិ។ បងទាំងពីរចង់នៅក៏នៅចុះ ខ្ញុំសូមលាទៅរកទីពឹងទៀតហើយ។ **ឡៅពី, គួនអ៊ូ** ឆ្លើយថា យើងមានបងប្អូនទាំងបីនាក់ ទោះដូចម្ដេចក៏ត្រូវតែស្លាប់រស់ជាមួយគ្នា ដែលនឹងព្រាត់ចាកគ្នានោះមិនគួរទេ នឹងទៅណាត្រូវទៅជាមួយគ្នា។ **តៀវហ៊ុយ**តបថា បើដូច្នោះចាំរសាយសេចក្ដីខឹង ថាហើយ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លើកពលទាហានត្រឡប់ទៅរក**ជូហ៊ីង**ស្រុកឆេងគួន ឲ្យទាហានស្រូត

ដើរទាំងយប់ទាំងថ្ងៃ ដល់ហើយក៏នាំគ្នាចូលទៅរក**ជូហ៊ី** ហើយពណ៌នាពីការរាជការទាំងពួងឲ្យ**ជូហ៊ី**បានស្តាប់សព្វសេចក្តី។ **ជូហ៊ី**ក៏ពេញចិត្តអាណិតស្រឡាញ់រាប់អាន**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**ពន់ពេកណាស់ សន្មតទុកជាពួកកងជាមួយគ្នា **ជូហ៊ី**និយាយថា **តាំងតុះ**នោះស្រុកកំណើតនៅក្នុងក្រុងឡាយលិមយោ ជានាហ្មឺនឈ្មោះ**ហុងតុងថាយស៊ីវ** ឯ**តាំងតុះ**នោះមិនជាអ្នកស្គាល់ការធូន់ស្រាល មិនស្គាល់មនុស្សល្អអាក្រក់ឡើយ បើជាអ្នកទៅនៅជាមួយផង ក៏នឹងរកផលប្រយោជន៍មិនបានឡើយ។

ឯទ័ព**ចូឆូ** ដែលទៅតាម**តៀវប៉ូ**, **តៀវលៀង**នោះលុះមិនបានជួបប្រទះហើយក៏លើកត្រឡប់មករក**ហ៊ុងហ៊ូសុង**នៅស្រុកអេងឆួន ចូលរួបរួមធ្វើរាជការជាមួយនឹង**ហុងហ៊ូសុង**ៗ និង**ចូឆូ**លុះដឹងដំណឹងថា **តៀវលៀង**នៅស្រុកឆ្វប៉ាងដូច្នោះ ក៏លើកទាហានទៅច្បាំងនឹង**តៀវលៀង** ឯ**តៀវប៉ូ**ទៅតាំងបន្ទាយនៅតំបន់ក្រោយភ្នំមួយមានពួកចោរជាបរិវារប្រមាណប្រាំបីម៉ឺន-ប្រាំបួនម៉ឺននាក់។

**ជូហ៊ី**លុះដឹងដំណឹងថា**តៀវប៉ូ**នៅទីនោះ ក៏ចាត់ឲ្យ**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**ជាទ័ពមុខ តួ**ជូហ៊ី**ជាទ័ពហ្លួង លើកពលទាហានទៅតតាំងច្បាំងនឹង**តៀវប៉ូ**។ ខាង**តៀវប៉ូ**ចាត់ប្រើ**កូសេង**ឃុំនាំពួកចោរចេញមកតយុទ្ធនឹងកងទ័ពមុខ នោះ**ឡៅពី**ប្រើ**តៀវហ៊ុយ**ឲ្យចេញទៅតទល់នឹង**កូសេង** ប្រយុទ្ធគ្នាមិនទាន់បានបីភ្លែង **តៀវហ៊ុយ**ចាក់នឹងលំពែងត្រូវ**កូសេង**ធ្លាក់ពីលើសេះស្លាប់។ ពួកចោរទាំងឡាយក៏បែកខ្ចាត់ខ្ចាយអស់ទៅ។ **ឡៅពី**ដេញទាហានឲ្យចូលវាយកាប់ចាក់ពួកចោរជាចលាចល។ **តៀវប៉ូ**ទាល់គំនិតគិតរកច្រករត់ទៅណាមិនរួច ក៏សេកមន្តគាថា ហើយឲ្យមេឃងងឹតបិទអស់មណ្ឌលព្រះសុរិយា បណ្តាលឲ្យអស្ចារ្យផ្គររន្ទះបាញ់ខ្ទរខ្ទារ ធ្លាក់ភ្លៀងខ្យល់ព្យុះបោកបក់គ្រប់ទិសានុទិស មានទាំងមនុស្សជិះសេះកាន់គ្រឿងអាវុធអណ្តែតចុះមកពីលើអាកាសដេរដាសប្រថពី ពលទាហានខាង**ឡៅពី**ឃើញដូច្នោះ ក៏

ស្ទុះរត់ជ្រួលច្របល់វឹកវរណាស់។ **ឡៅពី**ក៏ឲ្យថយទ័ពត្រឡប់មក ហើយប្រឹក្សានឹង **ជូហ៊ី**ៗក៏និយាយថា អាភេទអស្ចារ្យដូច្នេះ គឺគេធ្វើដោយវិជ្ជាការមន្តអាគមទេ យើងត្រូវឲ្យទាហាននាំយករបស់ស្មោគគ្រោក ឡើងទៅលាក់បង្កប់ទុកលើកំពូលភ្នំ បើគេធ្វើដូច្នេះទៀត ឲ្យទាហានបាចសាចរបស់ស្មោគគ្រោកនោះចុះមក មន្តអាគមនោះក៏នឹងសាបរលាបទៅឯង។ **ឡៅពី**ក៏ប្រើ**គួនអ៊ូ, តៀវហ៊ុយ** ឲ្យយុំនាំពលយោធាម្នាក់មួយពាន់ យករបស់ស្មោគគ្រោកឡើងទៅទុកលើកំពូលភ្នំទាំងសងខាង ត្រង់ទ័ពដែលបង្កប់ទាហានតយុទ្ធគ្នានោះ លុះព្រឹកឡើង**តៀវប៉ូ**លើកពួកចោរចេញមក **ឡៅពី**ក៏លើកពួកទាហានចេញទៅតទល់ច្បាំងគ្នា នោះ**តៀវប៉ូ**តាំងតែសេកមន្តគាថាធ្វើឲ្យមេឃងងឹត កើតផ្គររន្ទះព្យុះខ្យល់ និងមនុស្សជិះសេះកាន់អាវុធដូចកាលជាន់មុន **ឡៅពី**ឃើញដូច្នោះក៏ធ្វើជារាថយទ័ពមកខាងក្រោយ **តៀវប៉ូ**ក៏ដេញជិតប្រកិតតាមមកដល់ទីប្រចាប់ច្រកភ្នំទាំងសងខាង។ **គួនអ៊ូ, តៀវហ៊ុយ** ក៏ឲ្យទាហានបាចសាចអសុចិលាមកភក់ជ្រាំនិងឈាមជ្រូកឈាមឆ្កែពីលើកំពូលភ្នំទៅត្រូវពួកចោរ រីឯមនុស្សជិះសេះកាន់អាវុធចុះពីលើអាកាស ក៏ក្លាយទៅជាក្រដាស និងដុំស្មៅទាំងអស់ មេឃលែងងងឹត និងភ្លៀងខ្យល់ ផ្គររន្ទះក៏ស្រឡះភ្លឺស្វាងដូចធម្មតា។ **តៀវប៉ូ**ឃើញដល់កលកំបាំងផងខ្លួន ក៏ថយទ័ពត្រឡប់ទៅខាងក្រោយ **ជូហ៊ី, ឡៅពី** ក៏លើកពលទាហានទន្ទ្រានតាមប្រកិតជិតដោយ ទៅទាល់តែដល់ច្រកប្រហាកភ្នំ **គួនអ៊ូ, តៀវហ៊ុយ** ដែលនៅពីលើក៏បរពលចុះមកខ្ទប់ប្រសព្វគ្នាទាំងសងខាង គាប**តៀវប៉ូ**ឲ្យនៅជាកណ្តាល មិនដឹងនឹងរេតទល់ទៅខាងណា ក៏បែកខ្ចាត់ខ្ចាយអស់ទៅ **ឡៅពី**លើកពលទាហានតាមទៅទៀត ក្រឡេកទៅឃើញអក្សរឈ្មោះ**តៀវប៉ូ** ឯ**តៀវប៉ូ**នោះរត់ទៅក្នុងព្រៃ។ **ឡៅពី**លើកធ្នូបាញ់ទៅត្រូវស្មាឆ្វេង ព្រួញក៏ជាប់ស្មាទៅ **តៀវប៉ូ**ប្រឹងរត់ស្រូតទៅដល់ស្រុកយៀងស៊ា ចូលក្នុងកំពែងបានហើយក៏ខ្ទប់បិទទ្វារស្រុកទុក។

**ជូហ៊ី, ឡៅពី**ដេញទាហានតាមទៅក៏វាយទ័ពព័ទ្ធជុំវិញស្រុកនោះ ហើយចាត់ទាហានឲ្យចេញទៅស៊ើបស្ដាប់ដំណឹង**ហុងហ៊្វសុង** ដែលទៅច្បាំងនឹង**តៀវលៀង** ទទួលសេះបម្រើនាំសំបុត្រមកប្រាប់**ជូហ៊ី, ឡៅពី**ថា ឥឡូវនេះ**ហុងហ៊្វសុង**កាប់**តៀវលៀង**ស្លាប់ក្នុងស្រុកឆ្វយ៉ុងហើយ បណ្ដាបក្សពួក**តៀវលៀង**ទាំងប៉ុន្មានសឹងមកចុះចូលនៅជាច្រើន។ **ហុងហ៊្វសុង** បានឃុំនាំយកបក្សពួករបស់**តៀវកុក**ចូលទៅថ្វាយព្រះចៅ**ឡេនតេ** ៗទ្រង់ព្រះរាជទានឲ្យ**ហុងហ៊្វសុង**ឡើងជាទី**កុងគុន** គឺជាទាហានសម្រាប់រក្សាព្រះអង្គ ឲ្យគ្រងស្រុកប៊ុយជីវ ហើយ**ហុងហ៊្វសុង**ក្រាបបង្គំទូលព្រះចៅ**ឡេនតេ**ថា **លោទិត**មានសេចក្ដីគាប់គួរក្នុងការធ្វើសង្គ្រាមនឹងបានមានសេចក្ដីកំហុសដូច**ជូហុង**ក្រាបបង្គំទូលដូច្នោះក៏ទេ ព្រះចៅ**ឡេនតេ** ទ្រង់ជ្រាបដូច្នោះ ក៏ត្រាស់ឲ្យដោះ**លោទិត**ចេញពីទោសហើយឲ្យគង់ទីដូចដើម។ ឯ**ចូឆូ**នោះមានសេចក្ដីគាប់ប្រសើរក្នុងរាជការទ្រង់ប្រោសប្រទានឲ្យទៅឈរស្រុកចេឡាំ។

**ជូហ៊ី, ឡៅពី** ដែលឡោមព័ទ្ធស្រុកយៀងស៊ានោះដឹងថា បណ្ដាទាហានខ្ញុំរាជការតូចធំ សឹងមានសេចក្ដីគាប់ប្រសើរក្នុងរាជការ ៗចាត់ឲ្យទៅឈរខេត្តខណ្ឌជាច្រើនតំបន់ដូច្នោះ ក៏ខំស្រូតរូតដេញទាហានឲ្យចូលវាយទម្លាយស្រុកយៀងស៊ាជិតនឹងបានការហើយ ទទួល**ឡាំចេង**នាយទាហានចោរគិតគូរនឹងពួកចោរទាំងពួងលបសម្លាប់**តៀវប៉ូ**ជានាយចៅហ្វាយស្លាប់ហើយ កាត់យកក្បាលនាំទៅជូន**ជូហ៊ី, ឡៅពី**ខាងក្រៅស្រុក ហើយសុំខ្លួនចុះចូលធ្វើរាជការជាមួយតទៅ។ **ជូហ៊ី**មានចិត្តអំណរណាស់ ក៏តែងសំបុត្រវាយដំណើរពីធ្វើរាជការមានគុណគាប់បំណាច់ទាំងប៉ុន្មាន មកចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅ**ឡេនតេ**គ្រប់ប្រការ។

មានឈ្មោះ **តៀវហង, ហាន់តុង, ស៊ុនតុង** ជាសេនា**តៀវកុក** លុះ**តៀវកុក**ស្លាប់ហើយ ក៏បញ្ចុះបញ្ចូលពួកចោរបានច្រើនម៉ឺន លើកទៅប្លន់ដណ្ដើមយកទ្រព្យ

របស់អស់បណ្ដាអ្នកស្រុក ហើយដុតបំផ្លាញផ្ទះសម្បែងជាច្រើន។ សេះបម្រើក៏នាំសំបុត្របកចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅ**ឡេនតេ** ៗទ្រង់ត្រាស់ឲ្យមានសារត្រាទៅដល់**ជូហ៊ី** ឲ្យ**ជូហ៊ី**ចាត់ទាហាន ដែលមានថ្វីដៃខ្លាំងពូកែលើកទៅបង្ក្រាបពួកចោរទាំងនោះឲ្យបាន។ **ជូហ៊ី**បានទទួលព្រះតម្រាស់ហើយ ក៏ចាត់សេនាទាហានលើកទៅឡោមព័ទ្ធស្រុកអ្វួនសៀវជ្រុងខាងកើត។ **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ឡោមព័ទ្ធជ្រុងខាងលិច។ ខណៈនោះ**តៀវហង** ចាត់ឲ្យ**ហាន់តុង**ឃុំនាំពលទាហានចេញទៅតទល់ខាងទ័ព**ឡៅពី, ជូហ៊ី**ឃុំនាំពលទាហានឯកពីរពាន់ចូលខ្ទប់ប្រសព្វពីម្ខាង ឯពួកចោរតទល់លើសកម្លាំងទ្រាំពុំបាន ក៏ថយទ័ពត្រឡប់ចូលក្នុងកំផែងស្រុកវិញ។ **ឡៅពី**និងសេនាទាហានទាំងពួងក៏លើកតាមចូលទៅវាយទម្លាយទល់ដល់កំផែង ក៏ឡោមព័ទ្ធទុកពួកចោរនៅក្នុងកំផែងស្រុក ដាច់ស្បៀងអាហារខ្លាំងណាស់ ទើប**ហាន់តុង**ប្រើទាហានចេញមករក**ជូហ៊ី** សុំចំណុះចុះចូល**ជីហ៊ី**ៗមិនព្រមទទួល **ឡៅពី**ក៏និយាយថា កាលគ្រាផែនដីព្រះចៅ**ហាន់កូចូ** នឹងបានរាជសម្បត្តិនោះពីព្រោះមានមនុស្សមកសុំចំណុះចុះចូលជាច្រើន ហេតុម្ដេចទើបលោកមិនព្រមទទួលគេជាចំណុះដូច្នោះ។ **ជូហ៊ី**តបថា កាលគ្រាព្រះចៅ**ហាន់ចូកូ**នោះស្រុកទេសមិនបានប្រក្រតី កើតចម្រូងចម្រាសជាច្រើនណាស់ បានជាព្រះចៅ**ហាន់កូចូ**ទទួលមនុស្សចំណុះចុះចូលច្រើន គ្រានេះមានកើតចលាចលតែត្រឹមពួកចោរជូតក្បាលលឿងមួយពួកទេ បើនឹងទទួលពួកចោរជាចំណុះចូលទៅ មនុស្សទាំងពួងនឹងយកតម្រាប់តាមគ្នា ថាធ្វើខុសហើយ បើមានអ្នកមកបង្ក្រាបសឹមលះបង់ពុតអាក្រក់ គង់នឹងត្រឡប់ទៅជាមនុស្សល្អបាន យូរទៅនឹងធ្វើអាក្រក់បានទៀត។ **ឡៅពី**ស្ដាប់សព្វគ្រប់ ក៏ទទួលថាប្រសាសន៍នោះគួរហើយ តែថាការដែលយើងមកឡោមព័ទ្ធស្រុកទុកជុំទិសទាំងបួនទិសឲ្យនៅដូច្នេះ ពួកវាក៏ទាល់ចេញមិនរួចសោះ សូម្បីពួកនោះក៏សឹងតែជាជាតិទាហាន ឧបមាដូច

សុនខដែលទាល់ច្រក កាលណាឡើយវានឹងនៅស្ងៀមឲ្យទាហានយើងចាប់ចងដោយងាយ គង់នឹងតតាំងច្បាំងទាល់តែវិនាសម្ដងៗ ទាហានយើងក៏គង់ខាតបង់ទៅខ្លះជាធម្មតា មានឧបមាដូចយកពុំសែនទៅដូរយកអំបិល បើដូច្នេះសូមឲ្យបន្ថយទាហានជ្រុងខាងកើតចេញចុះ ដើម្បីទុកផ្លូវឲ្យពួកវារត់ចេញទៅ សឹមតាមចាប់យកដោយតម្រិះប្រាជ្ញាឃើញបានដោយងាយ។ **ជូហ៊ី**ស្ដាប់ទៅឃើញត្រូវ ក៏ឲ្យបន្ថយទាហានជ្រុងខាងកើតចេញអស់ ហើយមកព្រួតទម្លាយតែខាងទិសទាំងបី។

ឯ**ហាន់តុង** ក៏លើកទាហានរត់ចេញទៅតាមទ្វារទិសខាងកើត **ជូហ៊ី, ឡៅពី, គួនអ៊ួ, តៀវហ៊ុយ** ទាំងបួននាយក៏បរពលដេញតាមទៅបានបាញ់នឹងធ្នូត្រូវ**ហាន់តុង**ស្លាប់ ពួកទាហានចោរក៏រត់បែកខ្ចាត់ខ្ចាយទៅ។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ២

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

**ឯជូហ៊ី, ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ទាំងបួនកាយ លើកពលតាមទៅជួបប្រទះនឹង**តៀវហាង់, ស៊ុនតុង**តែជាពួក**ហាន់តុង**នោះ **តៀវហាង់, ស៊ុនតុង** ការទាហានវាទទឹងមុខតទល់នឹងទ័ព**ជូហ៊ី** ៗឃើញពល**តៀវហាង់**ច្រើនលើសលុបក្រែងទប់ពុំឈ្នះ ក៏ក្រឡាស់ថយទ័ពត្រឡប់មកវិញ។ **តៀវហាង់, ស៊ុនតុង** ក៏ដេញសង្កុញតាមទៅដណ្ដើមយកស្រុកអួនសៀវបានវិញ។ **ជូហ៊ី** ក៏ថយទៅតាំងបន្ទាយនៅឆ្ងាយនោះប្រមាណមួយរយសិន (៤ គ.ម)។ **ជូហ៊ី**គិតនឹងលើកពលចូលដណ្ដើមយកស្រុកអួនសៀវទៀត ទទួលក្រឡេកទៅឃើញទាហានមួយពួកលើកមកតាមផ្លូវទិសខាងកើត ឯនាយទាហានដែលលើកមកនោះ ឈ្មោះ **ស៊ុនកៀន** កិរិយាដូចខ្លា ថ្ងាសទូលាយ មុខវែងកើតនៅស្រុកតងង៉។ **ស៊ុនកៀន**នកាលអាយុដប់ប្រាំពីរឆ្នាំបាននៅស្រុកចៀនតងជាមួយនឹងបិតា ទៅដល់មាត់ស្ទឹងស្រុកចៀនតងប្រទះនឹងពួកចោរដប់នាក់ វាប្លន់ដណ្ដើមយកទំនិញ ហើយវាជញ្ជូនទៅគរលើគោក **ស៊ុនកៀន**ខឹងណាស់និយាយនឹងបិតាថា ចោរ**ទាំង**អស់នេះអាក្រក់ខ្លាំងណាស់ ខ្ញុំនឹងឡើងទៅចាប់ខ្លួនវាឲ្យបាន ហើយ**ស៊ុនកៀន**ក៏ដើរឡើងទៅធ្វើអាការៈបីដូចនាហ្មឺន ស្រែកហៅបាវព្រាវទាំងពួងអឹងកង ឯចោរដប់នាក់ឃើញក៏ភិតភ័យរត់ចោលរបស់ទ្រព្យអស់។ **ស៊ុនកៀន**ដេញតាមសម្លាប់ចោរបានម្នាក់ ប្រាំបួននាក់រត់រួចទៅ កិត្តិស័ព្ទទាំងនេះ ក៏ល្បីលេចឮទៅដល់ចៅហ្វាយស្រុកចៀនតង ៗឲ្យហៅយកខ្លួន**ស៊ុនកៀន**ទៅតាំងឲ្យធ្វើជានាយទាហានអំណឹះតមក **ហ៊ឺផុង**ជាមនុស្សក្បត់ឃុំនាំពលបានច្រើនម៉ឺនតាំងខ្លួនជាស្ដេច

ឈ្មោះ**យ៉ាំងបេង** នោះអ្នករក្សាស្រុក និង**ស៊ុនកៀន**ដឹងដំណឹង ក៏បញ្ចុះបញ្ចូលពលទាហានក្នុងស្រុកដែលខ្លាំងពូកែបានមួយពាន់ប្លាយ លើកទៅច្បាំងឯស្រុកហ៊ីឆុង កាប់**ហ៊ឹងឆុង** និងកូន**ហ៊ីឆុង**ស្លាប់ អ្នករក្សាស្រុកក៏បកសំបុត្រចូលទៅក្រាបបង្គំទូលព្រះចៅ**ឡេនតេ** សូមព្រះរាជទានសេចក្ដីគាប់ប្រសើរឲ្យ**ស៊ុនកៀន** លុះកើតពួកចោរផ្ទូតក្បាលលឿង លើកពួកពលរាតត្បាតកាប់សម្លាប់អ្នកស្រុកគ្រប់ខេត្តខណ្ឌកាន់តែកំរើបខ្លាំងឡើង **ស៊ុនកៀន**ដឹងដំណឹងថា **ជូហ៊ី**កំពុងបង្ក្រាបពួកចោរក៏មានសេចក្ដីត្រេកអរណាស់ ក៏តាំងបញ្ចុះបញ្ចូលពួកអ្នកស្រុក ហើយនឹងទាហានកស្រុកអួនសៀវទាំងពីរតំបន់នេះ បានពលប្រមាណមួយពាន់ប្រាំរយ ក៏លើកបណ្ដោយមកស្រុកអួនសៀវ កាលមកដល់ទល់នឹងកងទ័ព**ជូហ៊ី**ហើយក៏ចូលទៅជួបនឹង**ជូហ៊ី**ថា ខ្ញុំបាទចូលមកសូមយកអាសាបម្រាបពួកអាចោរ ។ **ជូហ៊ី**បានសេចក្ដីត្រេកអរណាស់ ទើបតាំងចាត់ចែងទាហានប្រគល់ឲ្យ**ឡៅពី**លើកទៅវាយបន្ទាយ**តៀវហង់, ស៊ុនតុង** ខាងទិសខាងជើង ឲ្យ**ស៊ុនកៀន**លើកទាហានទៅវាយទិសខាងត្បូង ក្នុងខណៈនោះ **ស៊ុនកៀន**ពារកំផែងឡើងចូលទៅក្នុងស្រុកអួនសៀវបាន ហើយដេញចាក់កាប់សម្លាប់ពួកចោរលើបន្ទាយស្លាប់ប្រហែលម្ភៃប្លាយ ពួកចោរទាំងឡាយក៏ធ្លាក់បាក់បែករត់អស់ទៅ...

**តៀវហង់**ឃើញ**ស៊ុនកៀន**ពារកំផែងស្រុកឡើងទៅកាប់សម្លាប់ពលទាហានស្លាប់ ក៏ខឹងខ្លាំងណាស់ ស្ទុះឡើងសេះកាន់គ្រប៊ីចូលប្រយុទ្ធគ្នានឹង**ស៊ុនកៀន**ដល់ជើងកំផែង **ស៊ុនកៀន**ឃើញដូច្នោះ ក៏ស្ទុះលោតចុះពីលើសើនដោយកម្លាំងដ៏រហ័ស ស្ទុះទៅដណ្ដើមយកគ្រប៊ីពី**តៀវហង់**បាន ហើយកាប់**តៀវហង់**ធ្លាក់ពីលើសេះស្លាប់ ចាប់យកសេះនោះមកជិះ ហើយបរបំផាយដេញកាប់ពួកចោរបែកធ្លាយអស់ទៅ ខាង**ស៊ុនតុង**ក្រឡេកមកឃើញថាតស៊ូនឹង**ស៊ុនកៀន**ពុំបាន ក៏បរសេះស្ទុះនាំពួកចោរទាំង

នោះចេញតម្រង់ទៅទិសឯជើង លុះក្រឡេកឃើញ**ឡៅពី**វាយទម្លាយទ័ពជាប់ចូលមក **ស៊ុនតុង**ភ័យស្លុតគិតថា អញគ្រានេះមុខជាដោះមិនរួចនឹងដៃ**ឡៅពី** ហើយត្រូវតែប្រឹងឲ្យខាងតែរួចជីវិតទៅចុះ។ **ស៊ុនតុង**ក៏វាថយក្រោយ **ឡៅពី**ក៏ទទួលយឹតធ្នូបាញ់សំដៅទៅត្រូវ**ស៊ុនតុង**ធ្លាក់ពីលើសេះស្លាប់។

**ជូហ៊ី**ឃើញបានការ ក៏ដេញសង្កុញទាហានពារទម្លាយបន្ទាយវាយយកស្រុកបាន ហើយកាប់សម្លាប់ពួកចោរស្លាប់ប្រហែលមួយម៉ឺនប្លាយ ស្រេចហើយក៏លើកចេញទៅវាយយកស្រុកជាលំដាប់ ដែលអម្បាលពួកចោរវាយយកបានពីថ្ងៃមុនប្រមាណដប់បួន ឬដប់ប្រាំស្រុកនោះ **ជូហ៊ី**ក៏យកបានវិញទាំងអស់ ឯអាណាប្រជានុរាស្ត្រទាសករ ដែលមានគ្រប់ដែនតំបន់ក៏បានក្សេមក្សាន្តសប្បាយដូចដើម ហើយ**ជូហ៊ី**ក៏លើកទ័ពត្រឡប់ចូលទៅទីក្រុងឡុកអៀង ថ្លែងការណ៍សាទុក្ខដល់សេនាបតីឲ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅ**ឡេនតេ** សូមទ្រង់ជ្រាប។ ព្រះចៅ**ឡេនតេ**ត្រាស់ឲ្យបំណាច់រង្វាន់**ជូហ៊ី** ឡើងជាទីនាយទាហានធំមានតំណែងចូលគាល់រាល់ឱកាសនិងទ្រង់តាំងឲ្យជាទីចៅហ្វាយស្រុកហោឡាំទៀត។ **ជូហ៊ី**ក៏ក្រាបបង្គំទូលស្នើសរសើរកិត្តិគុណ**ស៊ុនកៀន** និង**ឡៅពី** ដែលបានតាំងចិត្តសុចរិតជួយធ្វើរាជការកម្រាបពួកចោរកំណាចគ្រប់ប្រការ។ ព្រះចៅ**ឡេនតេ** ក៏ទ្រង់ព្រះមេត្តាប្រោសតាំង**ស៊ុនកៀន**ជាទីក្រមការខេត្ត តែ**ឡៅពី**នោះមិនបានត្រាសថាប្រការម្តេច នោះ**ឡៅពី**ក៏ថយមករង់ស្តាប់ការប្រហែលមួយខែប្លាយ មិនបានសម្រេចសេចក្តីប្រាថ្នាក៏នឹកទោមនស្សតូចចិត្តណាស់។ ថ្ងៃមួយ**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**ក៏នាំគ្នាដើរមើលរបៀបទីលំនៅផ្លូវផ្សារផ្សេងក្នុងទីក្រុង ដើម្បីឲ្យរំសាយសេចក្តីរំខាន បានដើរទៅប្រទះនឹង**តៀវគិន**ជានាហ្មឺនហ្លួងជិះរទេះមក **ឡៅពី**មានសេចក្តីត្រេកអរលើកដៃឡើងគំនាប់ហើយជម្រាបថា ខ្ញុំបាទនេះមានសេចក្តីនឿយហត់ជួយធ្វើរាជការរក្សាសេចក្តីសុខ

គ្រាដែលស្រុកកើតចលាចលនឹងពួកចោរ ប៉ុន្តែនឹងរកអ្នកឯណាទូលស្នើសរសើរគុណគាប់នោះគ្មានសោះ។ **តៀវគិន**បានស្តាប់ដូច្នោះ ក៏រំជួលចិត្តអាណិត**ឡៅពី**ណាស់ ទើបនាំ**ឡៅពី**ចូលទៅក្រាបបង្គំគាល់ ហើយទូលព្រះចៅ**ឡេនតេ**ថា កើតពួកចោរជូតក្បាលលឿងឡើងក្នុងគ្រានេះ ព្រោះហេតុព្រះអង្គទ្រង់ជឿស្តាប់ពាក្យពួកខន្ទីដប់នាក់ ខន្ទីប្រើអំណាចកាត់សេចក្តីអាណាប្រជានុរាស្ត្រទាំងឡាយដោយអស័ត្យ យកត្រូវជាខុស យកខុសជាត្រូវ បណ្តានាហ្មឺនមុខមន្ត្រីតូចធំដែលនិយមខាងផ្លូវយុត្តិធម៌ ក៏ទ្រង់លម្អៀងឲ្យដកហូតងារចេញពីរាជការ ស្រវាតែពួកសូកប៉ាន់គ្មានអៀនខ្មាស មនុស្សផ្តេសផ្តាស់ទ្រង់លើកយកមកតាំងជាមន្ត្រីគ្រប់តំណែង ហេតុនេះឯងទើបបង្កើតចលាចលរាល់ស្រុកឯបណ្តារាស្ត្រសឹងប្រាសចាកសេចក្តីសុខ មានតែទុក្ខក្តៅក្រហាយរហូតមកដល់សព្វថ្ងៃនេះ។ ទូលព្រះបង្គំជាខ្ញុំគិតថា នឹងសុំព្រះរាជទានខន្ទីទាំងដប់នាក់ទៅកាត់ក្បាលផ្តាលអាក្រោស ឲ្យអាណាប្រជានុរាស្ត្រទាំងពួងគ្រប់ខេត្តខណ្ឌដែលចំណុះស្រុកហ្លួងបានឃើញអស្ចារ្យ បើអ្នកឯណាមានប្រាជ្ញាស្មារតីប្រកបដោយសេចក្តីសត្យសុចរិតយុត្តិធម៌ គួរប្រោសតាំងជាមន្ត្រីមានយសបណ្តាស័ក្តិតាមគុណានុរូបតទៅ ទើបស្រុកទេសនឹងបាននៅដោយសេចក្តីសុខក្សេមក្សាន្ត។

ខន្ទីដប់ក៏បាននៅគាល់ក្នុងទីនោះ លុះបានឮពាក្យ**តៀវគិន**ទូលដូច្នោះ ក៏ឆ្លើយទូលទាស់ព្រះចៅ**ឡេនតេ**ថា **តៀវគិន**គ្រាន់តែជាទីមន្ត្រីថ្នាក់ទាបតូច ហេតុអ្វីពោលបង្កាច់មិនកោតខ្លាចព្រះរាជអាជ្ញា ចូលមកក្រាបបង្គំទូលព្រះករុណាជាពាក្យរំពូកប្រដៅដូច្នេះ ជាការមិនគួរណាស់។ ព្រះចៅ**ឡេនតេ**ក៏ទាស់អធ្យាស្រ័យ ទើបត្រាស់ឲ្យពេជ្ឈឃាដបណ្តេញ**តៀវគិន**ចេញចាកទីគាល់ ទើបខន្ទីដប់នាក់គិតគ្នាថា **តៀវគិន**មកក្រាបទូលពោលទោសយើងក្នុងវេលានេះជាខធំណាស់ ប្រហែលជាបានចេញ

ទៅធ្វើការបង្ក្រាបពួកចោរ មានសេចក្ដីនឿយហត់ប្រាកដដោយគុណបំណាច់ល្អមែន ហើយគ្មាននរណានឹងទូលស្នើសរសើរគុណគាប់ឲ្យ បានជានឹកតូចចិត្តអាចចូលមកទូលពិតខ្លួនឯងដូច្នេះ លុះយើងនឹងឲ្យធ្វើទោសតបគ្រានេះ សេចក្ដីនិន្ទាគង់មានដល់យើងមិនខាន បើដូច្នោះយើងត្រូវតែគិតអានដោយស្ងាត់នឹងសម្លាប់បំបាត់ជីវិតវាចេញ គង់មិនរួចនឹងដៃយើងទេ។

ព្រះចៅ**ឡេនតេ** ទើបទ្រង់ព្រះតម្រិះថា **ឡៅពី**ក៏មានសេចក្ដីគាប់ប្រសើរក្នុងរាជការ ទើបត្រាស់ឲ្យសេនាបតីឲ្យបំណាច់រង្វាន់**ឡៅពី** សេនាបតីយល់ព្រមត្រូវចាត់**ឡៅពី**ឲ្យចេញទៅធ្វើចៅហ្វាយស្រុកអាន់ហរគួន ទើប**ឡៅពី**ឲ្យទាហានដែលមកជាមួយវិលត្រឡប់ទៅស្រុកទេសវិញអស់ រើសយកទុកតែមនុស្សស្និទ្ធចំនួនម្ភៃនាក់ ហើយនាំ**គួនអ៊ូ**, **តៀវហ៊ុយ** និងមនុស្សម្ភៃនាក់ទៅឈរស្រុកអាន់ហរគួនបានប្រហែលមួយខែប្លាយ **ឡៅពី**ក៏ផ្សាយសេចក្ដីរាប់អានដល់អាណាប្រជានុរាស្ត្រថា បើអ្នកណាកើតក្ដីទាស់ទែងគ្នា មានតែផ្សះផ្សាឲ្យតិចថយចុះទៅជាលំដាប់ រាស្ត្រទាំងពួងក៏បានសេចក្ដីសុខក្សេមក្សាន្ត មានសេចក្ដីស្រឡាញ់រាប់អានលើកដៃសំពះ**ឡៅពី**សរសើរថា ល្អណាស់ដូចជាមាតាបិតា ឯ**គួនអ៊ូ** និង**តៀវហ៊ុយ** ក៏មានចិត្តភក្ដីមេត្រីស្រឡាញ់**ឡៅពី**ដោយស្មោះត្រង់ ពេលដែល**ឡៅពី**ចេញនិយាយរាជការ**គួនអ៊ូ**, **តៀវហ៊ុយ** ក៏មិនដែលឃ្លាតបាត់មុខសោះ តែងពិភ័ក្តិរក្សាគ្នា។ លុះនៅយូរមក មានសំបុត្រព្រះរាជតម្រាស់ត្រាស់ប្រើ**តុអ៊ីវ**ជាព្រះរាជបម្រើ ឲ្យនាំមកដល់**ឡៅពី**សេចក្ដីថា បើជារាស្ត្របានឡើងទីជាមន្ត្រីទីចៅហ្វាយស្រុក ហើយត្រូវនាំស្បួយសារឡើងមេកំណាន់ខាងក្នុង។ **ឡៅពី**ដឹងដំណឹងក៏ចេញទៅទទួលដល់ទ្វារស្រុក **ឡៅពី**គំនាប់ព្រះរាជតម្រាស់តាមទំនៀម ឯ**តុអ៊ីវ**អង្គុយលើទីខ្ពស់ឲ្យ**ឡៅពី**ឈរគំនាប់តាមតំណែង។ **តុអ៊ីវ**សួរ**ឡៅពី**ថា អ្នកឯងមានគុណគាប់អ្វីខ្លះ ទើបបានមកធ្វើចៅហ្វាយស្រុកនេះ?

**ឡៅពី**ឆ្លើយថា ខ្ញុំជាពូជព្រះវង្សព្រះចៅ**ហាន់កូច** តែជាបុណ្យវាសនាតិច ទើបបានជាអ្នកតូចនៅស្រុកទុនគួន កាលគ្រាកើតពួកចោរជូតក្បាលលឿងជាពួកក្បត់នោះ ខ្ញុំក៏បានយកអាសាផែនដីចេញទៅច្បាំងនឹងពួកចោរដល់ សាមសិបបួន សាមសិបប្រាំដង មានគុណបំណាច់តិចតួចណាស់ ទើបទ្រង់ប្រោសឲ្យចេញមករក្សាស្រុកនេះ។ **តុអ៊ីរ**ឮដូច្នោះក៏ស្រែកគំហកឲ្យ**ឡៅពី**ថា ឯងនេះទ្រនង់ស័ក្តិអួតអាងថា ខ្លួនជាព្រះញាតិវង្ស ហើយអួតថា ខ្លួនបានទៅច្បាំងបង្ក្រាបពួកចោរដល់ទៅសាមសិបបួន**សាម**សិបប្រាំលើកផងទៀត យើងគន់មើលរូបភាពមិនសមជាអ្នកធ្វើការសឹកទេ កុំនិយាយកុហក យើងមិនជឿខ្លួនទេ ដែលមកធ្វើជាអ្នករក្សាស្រុកនេះគួរហើយ ឥឡូវមានព្រះតម្រាស់ឲ្យយើងមកទារយកសួយសារជាជំនួសកំណាន់ខេត្តថ្មី។ **ឡៅពី**ស្តាប់ហើយ ក៏នៅស្ងៀមមិនតបសោះ ទើបលាចុះទៅកាន់ទីលំនៅ ហើយឲ្យហៅបាឡាត់ស្រុកមកប្រឹក្សាថា **តុអ៊ីរ**ជាព្រះរាជបម្រើមកបង្គាប់ដូច្នេះ យើងនឹងគិតដូចម្តេច? បាឡាត់ឆ្លើយថា **តុអ៊ីរ**ធ្វើក្អេងក្អាងដូច្នេះ ប្រាថ្នានឹងយកសំណូកជាប្រយោជន៍ខ្លួន **ឡៅពី**តបថា តាំងពីយើងមកឈរនៅស្រុកនេះ ថ្លៃទំនៀមគ្មាន យើងមិនដែលបៀតបៀនអ្នកឯណាឲ្យបានអំបោះមួយសរសៃ ម្ជុលមួយក៏ឥតអង្គឹមាន យើងមិនដែលធ្វើឲ្យបណ្តារាស្ត្រក្តៅក្រហាយសោះ បើដូច្នោះនឹងមានរបស់អ្វីមកឲ្យសំណូកដល់**តុអ៊ីរ** នោះយើងក៏ទាល់គំនិត។

លុះព្រឹកឡើង**តុអ៊ីរ**ឲ្យហៅខ្លួនបាឡាត់ស្រុកទៅផង ហើយវាយប្រាថ្នាឲ្យបាឡាត់ស្រុកឆ្លើយថា **ឡៅពី**ឆរាស្ត្រ។ បាឡាត់នឹងបានឆ្លើយតាមពាក្យ**តុអ៊ីរ**ក៏ទេ។ **ឡៅពី**ដឹងក៏រៀបនឹងចូលទៅរក**តុអ៊ីរ** អ្នកចាំទ្វាររាំងឃាត់មិនឲ្យចូលទៅ **ឡៅពី**ត្រឡប់ទៅវិញ វេលានោះ**តៀវហ៊ុយ**ផឹកស្រាស្រវឹងណាស់ ក៏ជិះសេះបរទៅលេងទៅដល់ត្រង់មាត់ទ្វារដែល**តុអ៊ីរ**នៅ ឃើញមនុស្សចាស់ៗឈរស្រែកយំប្រហែលហា

ហុកសិបនាក់ **តៀវហ៊ុយ**ងាកទៅសួរថា ហេតុអ្វីអ្នករាល់គ្នាមកឈរយំនៅទីនេះ? មនុស្សពួកនោះក៏ជម្រាបថា **តុអ៊ីវ**ឱ្យយកបាឡាត់ទៅចងវាយ ហើយបង្គាប់ឱ្យឆ្លើយថា **ឡៅពី**ឆរាស្ត្រ យើងខ្ញុំបបួលគ្នាមកសុំទោសលោកបាឡាត់ អ្នកចាំទ្វារមិនព្រមបើកឱ្យចូលទៅ ថែមទាំងវាយដំយើងខ្ញុំឡើងទៀត យើងខ្ញុំមានសេចក្ដីឈឺចាប់អៀនខ្មាសទើបស្រែកយំដូច្នេះ។

**តៀវហ៊ុយ**បានស្ដាប់ហើយ ក៏នឹកខឹងខ្លាំងណាស់ លោតចុះពីលើខ្នងសេះស្ទុះទៅច្រានទ្វារ នាយទ្វារហាមឃាត់ក៏មិនព្រមស្ដាប់ លុះ**តៀវហ៊ុយ**ចូលទៅផុតមាត់ទ្វារ ឃើញបាឡាត់ស្រុកត្រូវចំណងចងជើងដៃ ឃើញ**តុអ៊ីវ**អង្គុយលើកៅអី **តៀវហ៊ុយ**ស្រែកគំហកថា អាឯងនេះជាមនុស្សឆរាស្ត្រខ្លាំងណាស់ អាឯងស្គាល់អញដែរទេ? **តុអ៊ីវ**ភ័យស្លុតស្មារតីងើបឡើងមើលមុខ**តៀវហ៊ុយ**មិនទាន់ឆ្លើយតបថាម្ដេច **តៀវហ៊ុយ**ស្រាប់តែចាប់កន្ត្រាក់សក់ទាញទម្លាក់ពីលើកៅអី ហើយសក់រុំក្របួចនឹងដៃអូសទាញចេញមកដល់សាលាកណ្ដាល ហើយយកសក់**តុអ៊ីវ**ចងភ្ជាប់នឹងបង្គោលសសរ រួចកាត់មែកឈើស្រស់មកវាយសំពង**តុអ៊ីវ**ទាល់តែដំណំគ្រាំគ្រា។ កាល**ឡៅពី**ត្រឡប់វិលទៅផ្ទះវិញក៏អង្គុយកើតទុក្ខទោមនស្ស លុះឮសំឡេង**តុអ៊ីវ**ស្រែកឆោឡោ ក៏សួរមនុស្សម្នាថា សំឡេងនរណាស្រែកអ្វីឮខ្លាំងម្ល៉េះ? មានគេជម្រាបថា ជាសំឡេង**តៀវចុងគុន (តៀវហ៊ុយ)** ជាប្អូនលោកយកនរណាទៅវាយមិនច្បាស់ប្រាកដ។ **ឡៅពី**ពិភាល់ក្នុងចិត្តក៏ដើរចេញទៅមើល ឃើញ**តៀវហ៊ុយ**កំពុងតែវាយសំពង**តុអ៊ីវ**នៅក្នុងចំណង។ **ឡៅពី**ភ័យណាស់ស្ទុះទៅឃាត់**តៀវហ៊ុយ**ៗថា អានេះជាមនុស្សឆបោកធំណាស់ វាជាមនុស្សអាក្រក់ ទុកវាមិនបានទេ សមតែវាយឱ្យស្លាប់។ **តុអ៊ីវ**ឃើញ**ឡៅពី**មកដល់ក៏និយាយអង្វរថា សូមលោកជួយដោះជីវិតខ្ញុំផង **ឡៅពី**ឮដូច្នោះក៏មានចិត្តមេត្តាអាណិត ក៏និយាយឃាត់ហាម**តៀវហ៊ុយ**ឱ្យដើរ

ចេញ ទទួល**គួនអ៊ូ**ដើរមកដល់ទៀត ទើបនិយាយនឹង**ឡៅពី**ថា យើងបានធ្វើសេចក្ដីគាប់ប្រសើរយកអាសាផែនដីមកជាច្រើនគ្រាហើយ ក៏បានឋានន្តរត្រឹមប៉ុណ្ណោះ តែ**តុអ៊ីវ**ជាព្រះរាជបម្រើមកមើលងាយ ក្រៅពីមុខការព្រះរាជបម្រើមុខគួរឲ្យអប្បយសណាស់ ដែលយើងបងប្អូនតែបីនាក់ ឧបមាដូចជាសត្វហង្ស ដែលនឹងអាស្រ័យនៅក្នុងព្រៃនេះមិនសមរម្យសោះ បើដូច្នេះយើងត្រូវតែសម្លាប់**តុអ៊ីវ**នេះ ហើយនឹងបបួលគ្នាទៅនៅស្រុកទេសរបស់យើងវិញប្រសើរជាង ដំណាទៅមុខសឹមយើងនឹងគិតការធំតទៅ ។ **ឡៅពី**បានស្ដាប់ក៏ចាប់ចិត្ត ដ្បិតត្រូវនឹងគំនិតរបស់ខ្លួន ទើបត្រឡប់ទៅផ្ទះចូលទៅយកត្រាសម្រាប់ការងារមកចងក**តុអ៊ីវ** ហើយផ្ដាំថា ឯងជាព្រះរាជបម្រើមកធ្វើការរំលោភដោយអាការកំហែងឆបំភិតបំភ័យដូច្នេះ គួរណាស់តែយើងនឹងកាត់ក្បាលឯងចេញ ឥឡូវយើងទុកជីវិតឲ្យឯងវិញដោយចិត្តយើងល្អ យើងក៏មិនត្រូវការនឹងនៅធ្វើរាជការក្នុងទីនេះទេ ចូរឯងនាំយកត្រានេះចូលទៅស្រុកក្រុងផងចុះ យើងវិលទៅនៅស្រុកទេសទីលំនៅយើងហើយ ហើយ**ឡៅពី**ក៏នាំ**គួនអ៊ូ**, **តៀវហ៊ុយ** និងបក្សពួកទាំងម្ភៃនាក់នោះចេញពីស្រុកអាន់ហរកួនទៅ។

ឯ**តុអ៊ីវ**ក៏នាំយកត្រាសម្រាប់ងារ **ឡៅពី** និងបក្សពួកចេញទៅដល់ស្រុកតេងជីវជាទីមណ្ឌលខេត្ត។

ទាំងបីនាក់ដែលធ្វើខុសក្នុងរាជការបញ្ជូនទៅ ខណៈនោះ**ឡៅពី**ទៅដល់កណ្ដាលផ្លូវក៏ឮកិត្តិសព្ទថា ចៅហ្វាយស្រុកតេងជីវចេញសំបុត្រឲ្យស៊ើបចាប់ខ្លួន បើនឹងស្រូតទៅឲ្យដល់ស្រុកទុនគួនក្រែងមិនទាន់ **ឡៅពី**ដឹងថា **ឡៅកេង**ដែលជាចៅហ្វាយស្រុកតៃជីវជាសែជាមួយគ្នាទើបគិតថា បើដូច្នោះយើងត្រូវចូលទៅអាស្រ័យនៅនឹង**ឡៅកេង** នៅសិនចុះទើបផុតភ័យ គិតហើយក៏នាំ**គួនអ៊ូ**, **តៀវហ៊ុយ** និងបក្សពួកចូលទៅរក**ឡៅកេង**នៅស្រុកតៃជីវ ដល់ហើយក៏ពណ៌នាប្រាប់សេចក្ដីនៃ

រឿងឲ្យ**ឡៅកេង**ស្លាប់។ **ឡៅកេង**ដឹងក្នុងសំបុត្រចៅហ្វាយស្រុកតេងជីវ ត្រូវគ្នានឹងពាក្យ**ឡៅពី**ប្រាប់ដូច្នោះ ក៏នឹកអាណិត**ឡៅពី**ពន់ពេក ព្រោះជាសែជាមួយគ្នា ហើយជាពូជព្រះវង្សផង ទើប**ឡៅកេង**បំពួនខ្លួន**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**ឲ្យនៅក្នុងផ្ទះ។

និយាយពីខន្ទីដប់នាក់នោះ ព្រះចៅ**ឡេនតេ**ទ្រង់ប្រោសប្រាណណាស់ នឹងស្រដីនិយាយកិច្ចការអ្វីក៏សម្រេចដូចចិត្ត ទើប**តៀវកុង, តៀវយាង** ខន្ទីទាំងពីរនាក់ឲ្យបម្រើទៅនិយាយការដល់មន្ត្រីនាយទាហាន ដែលបានទៅកម្រាបពួកចោរជូតក្បាលលឿងនោះថា បើអ្នកឯណាមានទ្រព្យរបស់ជាមាស ឬប្រាក់ ហើយយកទៅជូននាយចៅហ្វាយយើង នោះនាយចៅហ្វាយយើងនឹងជួយក្រាបពិតទូលឲ្យបានឡើងយសស័ក្តិ តាមគុណបំណាច់ បើអ្នកឯណាមិនបានគិតគួរសមនឹងនាយចៅហ្វាយយើងទេ នឹងទូលបង្ខុសឲ្យថ្លោះយសស័ក្តិ ខានធ្វើខ្ញុំមន្ត្រីរាជការតទៅ។ ខណៈនោះ**ហងហ៊ូកូ** និង**ជូហ៊ី**ជានាយទាហានធំ បានស្តាប់សម្តីបម្រើពោលដូច្នេះ ក៏ទាស់អធ្យាស្រ័យណាស់ មិនទទួលធ្វើតាមពាក្យពន្យល់សោះ។ **តៀវកុង, តៀវយាង**ក៏រករឿងទូលញុះញង់ព្រះចៅ**ឡេនតេ**ឲ្យដកហូតងារ**ហងហ៊ូកូ** និង**ជូហ៊ី**ចេញចាកតំណែងរាជការ ព្រះចៅ**ឡេនតេ**ក៏ទ្រង់ធ្វើតាម ហើយតាំង**តៀវកុង, តៀវយាង**ឲ្យឡើងទីជាមន្ត្រីធំទាំងអស់។ វេលានោះរាជការផែនដីក៏ប្រែត្រឡប់ផ្តេសផ្តាសជាខ្លាំងណាស់ អស់អាណាប្រជានុរាស្ត្រទាសករទាំងឡាយ ក៏កើតក្តៅក្រហាយទូទាំងព្រះរាជធានី។

ឈ្មោះ**កូសេង**ពួកចោរជូតក្បាលលឿង រត់ទៅនៅស្រុកតៀងស៊ាបញ្ឆុះបញ្ឆូលបបួលពួកអ្នកស្រុក ដើរលួចប្លន់ដណ្តើមទ្រព្យ កាប់សម្លាប់អាណាប្រជានុរាស្ត្រទាំងពួងជាច្រើនតំបន់ គ្មានអ្នកណានឹងរិះគិតសង្កត់សង្កិនឲ្យរាបទាបសោះឡើយ ឈ្មោះ **តៀវគី, តៀវស៊ុន** នៅស្រុកយីយ៉ុង ក៏តាំងបញ្ឆុះបញ្ឆូលពួកបក្សជា

ច្រើន ហើយគិតក្បត់ **តៀវគី**នោះតាំងខ្លួនធ្វើជាស្ដេច **តៀវស៊ុន**ជាសេនាបតីធំធ្វើការអាក្រក់ទៅផ្សេងៗ ពួកចៅហ្វាយស្រុកទាំងពួងដឹងការណ៍ ក៏ធ្វើសំបុត្រមកប្ដឹងចូលទៅស្រុកក្រុងជាច្រើនគ្រា ខន្ទីដប់នាក់បិទសេចក្ដីនោះទុក មិនបានក្រាបបង្គំទូលព្រះចៅ**ឡេនតេ**ទ្រង់ជ្រាបសោះ។

មានការថ្ងៃមួយ ព្រះចៅ**ឡេនតេ**ស្ដេចចេញទៅប្រពាតសួនច្បារ ទ្រង់សោយសុរាជ័យនៅទីនោះ ឯខន្ទីដប់នាក់ក៏អង្គុយផឹកនៅមុខព្រះទីនាំង ។ ខណៈនោះ **ឡៀតោ**ជាភីលៀងស្ដេចដឹងថាពួកចោរកម្រើបក្បត់ឡើងទៀត ព្រះបាទ**ឡេនតេ**មិនបានទ្រង់ជ្រាប **ឡៀតោ**មានចិត្តបារម្ភណាស់ ក៏តាមស្ដេចទៅក្នុងសួន។ ព្រះចៅ**ឡេនតេ**ទ្រង់ទតឃើញក៏ត្រាស់សួរថា **ឡៀតោ**ធ្វើទឹកមុខបែបមានភ័យ ចូលមកមានការអ្វី? **ឡៀតោ**ក្រាបបង្គំទូលថា ព្រះអង្គមិនទ្រង់ជ្រាបឬទេ? ឥឡូវនេះ គ្រប់ខេត្តខណ្ឌទាំងពួងកើតចលាចលទៀតហើយ ស្រុកគង់អន្តរាយជាប្រាកដ ហេតុម្ដេចព្រះអង្គមកគង់សោយសុរាសប្បាយដូច្នេះ។ ព្រះចៅ**ឡេនតេ**ទ្រង់ត្រាស់ថា ខេត្តខណ្ឌទាំងពួងកើតចលាចល យើងប្រើសេនាទាហានទៅបង្ក្រាបរាបទាបអស់ហើយ ហេតុអ្វីក៏មកនិយាយដូច្នេះ ។ **ឡៀតោ**ក្រាបបង្គំទូលថា ខេត្តខណ្ឌទាំងពួងដែលកើតចលាចលគ្រានេះ ពីព្រោះខន្ទីដប់នាក់និយាយរាជការទាំងពួងមិនប្រកបដោយផ្លូវយុត្តិធម៌សោះ ទូលព្រះបង្គំជាខ្ញុំដឹងសេចក្ដីប្រាកដណាស់ លុះនឹងស្ងៀមមិនបានក្រាបទូល ក៏ហាក់ដូចមិនមានផ្លូវកតញ្ញូដល់ព្រះអង្គ។ វេលានោះខន្ទីដប់នាក់បានឮ**ឡៀតោ**ក្រាបបង្គំទូលដូច្នោះ ក៏ភ័យណាស់ លុះចូលទៅជិតមុខព្រះទីនាំង ធ្វើឧបាយជាដោះមួកហើយស្រែកយំទូលថា ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលបានធ្វើជាខ្ញុំក្រោមល្អងធូលីព្រះបាទសព្វថ្ងៃនេះ សឹងតាំងចិត្តជាសុចរិត ខំធ្វើរាជការរក្សាផែនដីដោយទៀងត្រង់ណាស់ តែថាអស់ពួកនាហ្មឺនធំៗ និង**ឡៀតោ**ឃើញថា ព្រះអង្គទ្រង់ប្រោសប្រាណក៏

មានចិត្តឥតថ្នាស្អប់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ទើបគិតឧបាយរករឿងឡើងមកក្រាបបង្គំទូលបង្កុស បើដូច្នេះនឹងធ្វើរាជការតទៅគង់មិនបានរួចអាយុជីវិតឡើយ ទូលព្រះបង្គំជាខ្ញុំទាំងឡាយសូមក្រាបថ្វាយបង្គំលាលែងធ្វើរាជការ ចេញទៅធ្វើសែចម្ការចិញ្ចឹមជីវិតចុះ ឯទ្រព្យរបស់ទាំងប៉ុន្មានសូមលើកថ្វាយព្រះអង្គ សូមឲ្យទ្រង់ចែករំលែកឲ្យពួកសេនាទាហានដែលធ្វើរាជការ។

ព្រះចៅ**ឡូនតេ**បានទ្រង់ព្រះសណ្ដាប់ពួកខន្ទីពិតទូលដូច្នោះ ក៏ទ្រង់ព្រះពិរោធក្រោធានឹង**ឡៅតោ**ខ្លាំងណាស់ត្រាស់ថា ខ្លួនឯងគ្រាន់តែជាទីភីលៀងប៉ុណ្ណោះ សូម្បីក្នុងទីលំនៅផ្ទះសម្បែងរបស់ឯង ក៏គង់មានបាវព្រាវល្មមប្រើប្រាស់ជាធម្មតា ខ្លួនអញជាក្សត្រសោយរាជ្យសម្បត្តិជាម្ចាស់ផែនដី ក៏គប្បីឲ្យមានមនុស្សប្រើប្រាស់នៅខ្លះ ហេតុអ្វីឯងមកប្រស្បាឲ្យអញឈឺចិត្តដូច្នេះ ដែលឯងសម្ដែងខ្លួនជាកតញ្ញូនោះអញមិនឃើញផងសោះ។ ត្រាស់ហើយ ទ្រង់បង្គាប់ពេជ្ឈឃាដខាងឆ្វេងឲ្យចាប់ខ្លួន**ឡៅតោ**ទៅសម្លាប់។ ពេជ្ឈឃាដក៏ចូលចាប់ខ្លួន**ឡៅតោ**ចេញទៅ **ឡៅតោ**ស្រែកចំពោះព្រះភក្ត្រថា ដែលទ្រង់ត្រាស់បង្គាប់ឲ្យសម្លាប់ទូលព្រះបង្គំជាខ្ញុំនោះមិនស្ដាយជីវិតទេ ទូលព្រះបង្គំជាខ្ញុំស្ដាយតែព្រះរាជសម្បត្តិព្រះចៅ**កួចូ** ដែលសាងសន្សំមកអំពីដើមបានបួនរយប្លាយឆ្នាំហើយ ស្រុកទេសមិនដែលកើតចលាចលសោះ គ្រានេះមុខជានឹងអន្តរាយសាបសូន្យប្រាកដ។ ពេជ្ឈឃាដក៏ដឹកនាំ**ឡៅតោ**ចេញទៅដល់ទីកន្លែងពិឃាដ លើកគ្រប៉ីឡើងនឹងកាប់ ទទួល**តាន់តាំ**ឃើញស្ទុះមកស្រែកឃាត់ថា កុំអាលសម្លាប់ ចាំខ្ញុំចូលទៅទូលស្នើព្រះចៅ**ឡូនតេ**ឲ្យឃើញទោសខុសត្រូវសិន។ **តាន់តាំ**ក៏ចូលទៅក្រាបបង្គំគាល់ដល់ទីសួនផ្កា ហើយទូលសួរថា **ឡៅតោ**ធ្វើខុសពីអ្វីបានជាព្រះអង្គទ្រង់ឲ្យនាំទៅសម្លាប់? ព្រះចៅ**ឡូនតេ**បានទ្រង់ព្រះសណ្ដាប់**តាន់តាំ**ទូលសួរដូច្នោះ ទើបត្រាស់ថា **ឡៅតោ**ជាមនុស្សចិត្តរហ័សពុំមានសេចក្ដីគិត យក

សេចក្ដីមិនពិតមកនិយាយញុះញង់ទម្លាយទោសមកលើខន្ទីដប់នាក់ ដែលមានយសស័ក្ដិជាធំ ហើយស្ដីទ្រគោះឲ្យយើងទៀត។ **តាន់តាំ**ទូលថា បណ្ដានាហ្មឺនតូចធំនូវអស់អាណាប្រជានុរាស្ត្រគ្រប់ខេត្តខណ្ឌទាំងអស់ សុទ្ធតែមានសេចក្ដីក្ដៅក្រហាយជាច្រើនណាស់ មានចិត្តស្អប់ចង់ស៊ីសាច់ពួកខន្ទីដប់នាក់ឲ្យអស់ទៅ ហេតុម្ដេចព្រះអង្គទ្រង់រាប់អានស្រឡាញ់ពួកខន្ទីនោះខ្លាំងម្ល៉េះ? ពួកខន្ទីនេះនឹងមានគុណបំណាច់យ៉ាងណា បានជាព្រះអង្គតាំងឲ្យធ្វើជាមន្ត្រីធំៗ? ទូលព្រះបង្គំជាខ្ញុំមិនឃើញសមគួរសោះ។ មួយទៀត **ហង់ស៊ី**ខន្ទីក៏ប្រែចិត្តក្បត់ ប្រើឧបាយកលចូលនឹងពួកចោរជូតក្បាលលឿង មានអ្នកឯទៀតចូលមកក្រាបទូលព្រះអង្គ ៗមិនចង់ជម្រះរកឲ្យឃើញវៀចត្រង់ ព្រះអង្គក្លែងធ្វើជានៅស្ងៀម ដែលព្រះអង្គធ្វើដូច្នេះ នឹងចង់ឲ្យរាជសម្បត្តិអន្តរាយឬអ្វី?

ព្រះចៅ**ឡេនតេ**ត្រាស់តបថា មានអ្នកមកក្រាបទូលថា **ហង់ស៊ី**ជាក្បត់នោះ មិនមែនសោះ ឯខន្ទីទាំងដប់នាក់នេះយើងបានទំនុកបម្រុងអស់ពីចិត្តជាប្រាកដ បើ **ហង់ស៊ី**ជាក្បត់ក៏មានប្រាំបួននាក់នៅត្រង់ល្អ ឬយ៉ាងហោចណាស់គង់មានម្នាក់ ឬពីរនាក់នៅត្រង់ល្អនឹងយើង គង់នឹងនាំព័ត៌មានឲ្យយើងដឹង។

**តាន់តាំ**ឃើញថា ព្រះចៅ**ឡេនតេ**ស្រឡាញ់រាប់អានខន្ទីដប់នាក់លើសលុប នឹងប្រារព្ធទូលនាំហេតុឲ្យវែងទៅទៀតក៏មិនជាប្រយោជន៍ជាក់ច្បាស់ **តាន់តាំ**ខឹងណាស់ យកក្បាលបោកនឹងគ្រែគំនាល់ ដែលស្ដេចគង់នោះទាល់តែបែកក្បាលហូរឈាម។ ព្រះចៅ**ឡេនតេ**ទ្រង់ព្រះក្រោធខ្លាំងណាស់ ត្រាស់ឲ្យពេជ្ឈឃាដខាងឆ្វេងចាប់យកខ្លួន**តាន់តាំ** និង**ឡៅតោ**ដែលនាំយកទោសម្ដាប់នោះ យកទៅដាក់គុកទាំងពីរនាក់វិញ លុះវេលាយប់ខន្ទីដប់នាក់គិតគ្នា ហើយហៅភូឃុំមកបង្គាប់ថា បើដល់

ពេលពាក់កណ្ដាលអាធ្រាត្រ ឲ្យលបសម្លាប់**តាន់តាំ** និង**ឡៅតោ**ចេញចុះ ភូឃុំក៏ទៅធ្វើតាមខន្ទីបង្គាប់។

ហើយខន្ទីដប់នាក់ ក៏តែងជាសំបុត្រព្រះរាជតម្រាស់ទៅដល់**ស៊ុនកៀន**ថា ត្រាស់ឲ្យ**ស៊ុនកៀន**ទៅឈរស្រុកទៀងសា ហើយឲ្យបង្ក្រាប**កូសេង** ដែលជាពួកចោរសេះចេញឲ្យរាបទាប **ស៊ុនកៀន**ដឹងក្នុងសំបុត្រព្រះរាជតម្រាស់ហើយ ក៏លើកពលទៅបង្ក្រាបពួកចោរ លុះបានរាបទាបហើយ ក៏បកសំបុត្រចូលទៅក្រាបទូលព្រះចៅ**ឡេនតេ** ៗទ្រង់ជ្រាបទើបទ្រង់ព្រះតម្រិះថា **ស៊ុនកៀន**មានសេចក្ដីគាប់ប្រសើរក្នុងរាជការស្រុកកាំងហែជាខេត្តឯក ទើបឲ្យតែងព្រះរាជតម្រាស់បង្គាប់**ស៊ុនកៀន**ឲ្យឈរស្រុកកាំងហែ ឲ្យ**ឡៅងី**ជាទីចៅហ្វាយស្រុកអ៊ីជីវឲ្យលើកទាហានទៅវាយ**តៀវគី, តៀវស៊ុន** ដែលតាំងខ្លួនជាស្ដេចយីយ៉ុង ។ ឯ**ឡៅកេង**ដឹងក្នុងព្រះរាជតម្រាស់ថា **ឡៅងី**ត្រូវទៅច្បាំងនឹង**តៀវគី, តៀវស៊ុន** ដូច្នោះ ក៏សរសេរសំបុត្រឲ្យ**ឡៅពី**កាន់ទៅរក**ឡៅងី** ក្នុងសំបុត្រនោះថា **ឡៅកេង, ឡៅពី** និង**ឡៅងី** ជាសែជាមួយគ្នា សុំឲ្យ**ឡៅពី**ធ្វើការសឹកជាមួយផង ។ **ឡៅងី**ដឹងក្នុងសំបុត្រដូច្នោះ ក៏មានសេចក្ដីត្រេកអរណាស់។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៣

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ហ្វូជិន**ទទួលសំបុត្រពី**តាំងតុះ** ហើយបិទទុកមិនឲ្យខន្ទីដប់នាក់ដឹងសេចក្តីដរាបដល់**លីយូ**ដាក់ថ្នាំបំពុលលាយនឹងស្រា យកទៅថ្វាយព្រះនាង**ហូហៅ** និង**ហង់ជូពៀន** ដែលគ្រងរាជសម្បត្តិឲ្យទ្រង់សោយដោយបង្ខំ)។*

ឯ**ហ្វូជិន**ដឹងក្នុងសេចក្តីសំបុត្រ**តាំងតុះ**ដូច្នោះ ក៏បិទបាំងមិនឲ្យខន្ទីដប់នាក់ដឹងសេចក្តី ទើបបង្គាប់ឲ្យហៅនាហ្មឺនមុខមន្ត្រីទាំងពួងមកប្រឹក្សាថា យើងនឹងឲ្យ**តាំងតុះ**ចូលមកក្រុង តើស្រួលមិនស្រួលដូចម្តេច? **តេះថាយ**ឆ្លើយថា **តាំងតុះ**នោះចិត្តថ្លើមដូចជាសត្វខ្លា បើនឹងឲ្យចូលមកក្នុងក្រុងគង់នឹងកើតអន្តរាយដល់មនុស្សទាំងពួង។ **ហ្វូជិន**តបថា អ្នកនោះនឹងគិតការធំចូលជាមួយនឹងយើងមិនបានទេ។ គ្រាន់តែឮដំណឹងមិនទាន់ឃើញខ្លួនខ្លាចមុនដូចពាក្យបុរាណថា ខ្លួនខ្លាមិនខ្លាច ទៅខ្លាចអាចម៍ខ្លាទៅវិញ។ **លោទិត**ឆ្លើយថា ខ្ញុំបានស្គាល់ចិត្ត**តាំងតុះ**មកពីដើម ប្រាកដជាមនុស្សចិត្តអាក្រក់ បើបណ្តោយឲ្យចូលមកក្នុងក្រុងហើយ គង់នឹងកើតចលាចលដូចជាពាក្យ**តេះថាយ**ជាប្រាកដ។ **ហ្វូជិន**តបថា អ្នកទាំងអស់គ្នាកុំនិយាយ យើងមិនស្តាប់ទេ។ **លោទិត** និង**តេះថាយ** និងអស់នាហ្មឺនទាំងពួង លុះបានឮសម្តី**ហ្វូជិន**និយាយដូច្នោះក៏នឹកតូចចិត្តណាស់ ខ្លះលើកត្រាសម្រាប់ងារជូនហើយក៏លាចេញលែងធ្វើរាជការ វិលទៅនៅផ្ទះសព្វខ្លួនជាច្រើន។ **ហ្វូជិន**ទើបចាត់ភ្នាក់ងារកាន់ព្រះតម្រាស់

ឲ្យចេញទៅទទួល**តាំងតុះ** ៗក៏លើកពលចូលមកតាំងនៅទីតំបន់លុតគីក្បែរកំពែងក្រុង។

ឯខន្ទីដប់នាក់ដឹងថា **តាំងតុះ**លើកទាហានចូលមកតាំងនៅជិតក្រុងហើយ ទើបគិតគ្នាថា ហេតុទាំងនេះ ពីព្រោះ**ហ្វូជិន**ជាដើមគំនិតគិតអែបព្រះតម្រាស់ឲ្យខេត្តក្រៅលើកកងទ័ពមកធ្វើអន្តរាយដល់យើង បើប្រសិនជាយើងនៅស្ងៀម សេចក្ដីអន្តរាយនោះគង់នឹងមានដល់ជីវិតយើងប្រាកដ គួរតែយើងនឹងគិតសម្លាប់**ហ្វូជិន**ចេញជាមុនសិន។ លុះគិតព្រមព្រៀងគ្នាហើយ ទើបចាត់ប្រើមនុស្សទំនុកទុកចិត្តហាសិបនាក់ កាន់គ្រឿងសាស្ត្រាវុធទៅអែបប្របទ្វារព្រះបរមរាជវាំងខាងក្នុង ហើយបង្គាប់ថា បើកាលណាបានឃើញ**ហ្វូជិន**ចូលមក ឲ្យព្រួតគ្នាចូលចាក់កាប់ចោលចុះ។ ខ្លួន**តៀវយៀង**ក៏ចូលទៅទូលព្រះនាង**ហ្វូហៅ**ថា **ហ្វូជិន**អែបព្រះតម្រាស់បង្គាប់ឲ្យខេត្តក្រៅលើកទាហានជាកងទ័ព ចូលមកនឹងចាប់ទូលព្រះបង្គំជាខ្ញុំទាំងឡាយសម្លាប់ចោល ទូលព្រះបង្គំជាខ្ញុំទាំងឡាយមិនមានទីពឹងឯទៀតសោះ ចំពោះមានតែត្រឹមព្រះអង្គ សូមព្រះអង្គទ្រង់ព្រះករុណាជួយឲ្យទូលព្រះបង្គំជាខ្ញុំទាំងឡាយរួចរស់ជីវិតក្រោមល្អងធូលីព្រះបាទតទៅ។ ព្រះនាង**ហ្វូហៅ**មានព្រះសវនីយ៍បង្គាប់ថា ឲ្យអ្នករាល់គ្នាទៅអង្វរលន់តួសុំទោស**ហ្វូជិន**ចុះ **ហ្វូជិន**គង់នឹងមានសេចក្ដីអាណិតអាសូរមិនបានធ្វើសេចក្ដីអន្តរាយទេ។ **តៀវយៀង**ទូលតបថា **ហ្វូជិន**នោះមានចិត្តស្អប់ទូលព្រះបង្គំជាខ្ញុំទាំងដប់នាក់ណាស់ ដែលទ្រង់ថាឲ្យទូលព្រះបង្គំជាខ្ញុំទាំងឡាយទៅរក**ហ្វូជិន**នោះ បីដូចយកសាច់ទៅឲ្យខ្លា នឹងមិនគង់ជីវិតវិលមកវិញបានទេ បើព្រះអង្គមេត្តាប្រោសទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមទ្រង់ឲ្យអញ្ជើញ**ហ្វូជិន**ចូលមក ត្រាស់សុំអាយុជីវិតទូលព្រះបង្គំជាខ្ញុំទាំងឡាយផ្ទាល់ព្រះឱស្ឋ បើប្រសិនជា**ហ្វូជិន**មិនមេត្តាទេ ទូលព្រះបង្គំជាខ្ញុំទាំងឡាយសូមទទួលថ្វាយជីវិតទាំង

អស់គ្នាចំពោះព្រះភក្ត្រតែម្តងទៅចុះ។ ព្រះនាង**ហូហៅ**ទ្រង់ព្រះសណ្តាប់ក៏ចាប់ព្រះទ័យមានសេចក្តីករុណាណាស់ ទើបចាត់បម្រើឲ្យទៅអញ្ជើញ**ហូជិន**ចូលមកគាល់។ ឯ**ហូជិន**កាលនឹងរៀបខ្លួនចូលទៅគាល់ព្រះនាង**ហូហៅ**នោះ **តាន់លឹម**ឃាត់ថា ដែលព្រះនាង**ហូហៅ**ឲ្យអញ្ជើញលោកទៅគាល់នោះ ខ្ញុំបាទមានសេចក្តីពិភាល់ណាស់ ក្រែងមានសេចក្តីអន្តរាយដល់ខ្លួនលោក។ **ហូជិន**តបថា ព្រះនាង**ហូហៅ**និងយើងជាបងប្អូននឹងគ្នា កាលណានឹងគប់គិតជាមិត្តទ្រុស្តចូលគំនិតនឹងពួកខន្ទីដប់នាក់នោះឡើយ។ **អួនសៀវ**ក៏ឆ្លើយថា ការដែលយើងគិតទុកនោះ ប្រហែលខន្ទីដប់នាក់ដឹងជាក់ប្រាកដ យើងនឹងចូលទៅពុំបាន។ **ចូឆូ**ឆ្លើយថា បើលោកនឹងគង់ចូលទៅក៏ទៅចុះ តែត្រូវសុំឲ្យខន្ទីដប់នាក់ចេញមកពីក្នុងព្រះបរមរាជវាំងសិន ទើបលោកមិនមានអន្តរាយ។ **ហូជិន**បានឮអ្នកទាំងបីនិយាយដូច្នោះក៏សើច ហើយតបថា យើងជាមន្ត្រីធំសម្រេចរាជការផែនដីមិនមានអ្នកណាស្មើ ខន្ទីដប់នាក់ប៉ុណ្ណោះ វាមិនមានសេចក្តីគិតឆ្លៀវឆ្លាតទៅប៉ុន្មាន វានឹងធ្វើយើងដូចម្តេចបាន។ **អួនសៀវ**ថា លោកនឹងចូលទៅក៏ទៅចុះ តែខ្ញុំបាទសុំទៅជាមួយផង។ **អួនសៀវ**ទើបឲ្យ**អួនសុត**ជាប្អូន ឃុំនាំទាហានប្រាំរយចូលទៅនៅប្រចាំត្រង់ទ្វារវាំងខាងមុខ **អួនសៀវ** និង**ចូឆូ**តែងខ្លួនពាក់ក្រោះកាន់គ្រប៉ីចូលទៅជាមួយនឹង**ហូជិន**ដល់មាត់ទ្វារខាងក្នុង **ប៉ោអ៊ី**នាយទ្វារក៏ឃាត់ហាម**អួនសៀវ** និង**ចូឆូ**មិនឲ្យចូលទៅ ឲ្យនៅខាងក្រៅ។ **ហូជិន**ក៏ដើរចូលទៅតែម្នាក់ឯង លុះដល់ស៊ុំទ្វារខាងក្នុង **តៀវយៀង**, **គួយគុន**ឃើញហូជិនដើរចូលមក ក៏វាំងផ្លូវហើយញាក់មុខឲ្យពួកហាសិបនាក់ចោមព័ទ្ធចាប់**ហូជិន**បាន ហើយ**តៀវយៀង**ស្រែកថា ខ្លួនឯងនេះពីដើមជាមនុស្សតូចទាបណាស់ យើងបានជួយទំនុកបម្រុងយកសេចក្តីពិតទូលសុំឲ្យខ្លួនឯងបានធ្វើជាទីធំដល់ទីនេះ ហេតុម្តេចឯងក៏ចិត្តធំម្ល៉េះហ៊ានប្រើមនុស្សទៅលបសម្លាប់ព្រះនាង**តាំងថៃហ**ជាព្រះមាតាព្រះចៅ**ឡេនតេ** ដែល

មិនមានសេចក្ដីខុសសោះឲ្យទិវង្គតទៅ ហើយខ្លួនឯងក្លែងអែបធ្វើព្រះតម្រាស់ចេញទៅខេត្តក្រៅ ឲ្យលើកទាហានចូលមកនឹងចាប់ខ្លួនយើង ដែលមានគុណូបការៈដល់ខ្លួននោះសម្លាប់ទៀត ខ្លួនឯងនេះជាមនុស្សគ្មានសេចក្ដីកតញ្ញូនឹងយើងសោះ ត្រឡប់ថ្កោលទោសថា យើងជាសត្រូវនឹងរាជសម្បត្តិវិញ ខ្លួនឯងគិតប្រទូសរាយនឹងយើងហើយ យើងត្រូវយកជីវិតខ្លួនចេញក្នុងវេលានេះ។

**ហូជិន**កាលជាប់ក្នុងចំណោមដ៏ពន្លឹកដូច្នោះ ក៏តក់ស្លុតរន្ធត់ស្ទើរនឹងបាត់ស្មារតីផុតនិស្ស័យ ដែលនឹងរកទីពឹងប្រឹងក្រឡេកមើលទៅទ្វារខាងក្រោយបិទជិតឈឹង ពួកទាហានហាសិបនាក់ក៏ប្រហារ**ហូជិន**អនិច្ចកម្មនៅទីនោះឯង។

ឯ**អ្នួនសៀវ**និង**ចូឆ្លូ**ឈរវេរាខាងក្រៅទ្វារចាំយូរណាស់ មិនឃើញ**ហូជិន**ចេញមក ក៏ស្រែកហៅពីក្រៅ **តៀវយៀង**បានឮសំឡេងក៏កាត់ក្បាល**ហូជិន**គ្រវែងបោះចេញមក ហើយស្រែកប្រាប់ថា **ហូជិន**គិតក្បត់ យើងសម្លាប់ចេញហើយ យកក្បាលទៅចុះ នរណាដែលមិនបានចូលដៃរួមគំនិតក្បត់ជាមួយទេ ឲ្យវិលត្រឡប់ជាប្រញាប់ទៅវិញចុះ កុំមកតវ៉ាថាអ្វីឡើយ។ **អ្នួនសៀវ** និង**ចូឆ្លូ**បានឮដូច្នោះ ក៏ស្រែកប្រកាសថា **ហូជិន**ជាសេនាបតីសម្រេចរាជការផែនដី ខន្ទីដប់នាក់រួមគំនិតគ្នាចាប់**ហូជិន**សម្លាប់ហើយ យើងត្រូវតែទម្លាយទ្វារវាំងចូលទៅសម្លាប់ខន្ទីដប់នាក់ឲ្យអស់ចេញ នរណាចូលដៃនឹងយើងខ្លះ? **ង៉ោខង**ជាទាហាន**ហូជិន**ដែលនៅជាមួយនឹង**អ្នួនសុត**ឮ**អ្នួនសៀវ**និង**ចូឆ្លូ**ស្រែកថាដូច្នោះ ក៏យកភ្លើងដុតទម្លាយទ្វារព្រះបរមរាជវាំង ហើយ**អ្នួនសុត**ក៏ដេញទាហានចូលទៅបានប្រទះនឹងខន្ទីឡេវទាំងពួង ក៏ចាប់សម្លាប់អស់។ **អ្នួនសៀវ**, **ចូឆ្លូ** ក៏ស្ទុះទៅទៀត ខណៈនោះ **តៀវតុង**, **តៀក្វង**, **ហែហ៊ុយ**, **គុយសេង** ខន្ទីទាំងបួននាក់នេះ ឃើញ**អ្នួនសៀវ**, **ចូឆ្លូ** និង**អ្នួនសុត**ទម្លាយទ្វារព្រះបរមរាជវាំងចូលទៅ ក៏ស្ទុះរត់វាងចូលទៅក្នុងសួនផ្កា **អ្នួនសៀវ**, **ចូឆ្លូ**ដេញ

ទាន់សម្លាប់នៅទីនោះ ហើយចិញ្ច្រាំសាច់ខន្ទីបួននាក់ទាល់តែល្អិតខ្ទេចខ្ទីអស់ទៅ ឯភ្លើងក៏ឆេះរាលចូលទៅដល់ដំណាក់ខាងក្នុង។ **តៀវយៀង**, **គួនគុយ**, **ថៅជៀក**, **ហៅឡាំ**ឃើញអណ្ដាតភ្លើងឆេះសន្ធោសន្ធៅ ក៏នាំព្រះនាង**ហ្វូហៅ** និង**ហង់ជូពៀន** នាង**ជូហៀប** រត់គេចទៅត្រង់កន្លែងដែលភ្លើងមិនទាន់ឆេះទៅដល់នោះ។

ខណៈនោះ **ហោទិត**ដែលចេញចាកពីតំណែងមន្ត្រីហើយនោះ លុះឃើញពន្លឺភ្លើងឆេះក្នុងព្រះបរមរាជវាំង ក៏តែងខ្លួនពាក់ក្រោះកាន់អាវុធទៅឈរអែបមាត់ទ្វារពួកព្រះស្នំនៅ លុះក្រឡេកទៅឃើញ**គួនគុយ**, **ហ្វូហៅ**គេចរត់ពីភ្លើងក៏ស្រែកសួរទៅថា អាសត្រូវរាជសម្បត្តិនាំព្រះនាងរត់ទៅណា? **គួនគុយ**បានឮសម្រែកក្រឡេកទៅឃើញ**ហោទិត** ក៏ភិតភ័យរត់គេចចេញអំពីទីនោះ ព្រះនាង**ហ្វូហៅ**ក៏ភ័យស្លុត លោតទម្លាក់ខ្លួនពីលើរបៀងដំណាក់ **ហោទិត**រត់ចូលទៅទទួលទ្រទាន់ **ង៉ោខង**ឃុំទាហានចូលទៅដល់ក្នុងវាំង ប្រទះនឹង**ហ្វូពៀវ**ក៏ស្រែកថា អានេះជាសត្រូវនឹងរាជសម្បត្តិ អាឯងរួមគំនិតនឹងខន្ទីដប់នាក់សម្លាប់**ហ្វូជិន**បងឯង អញសម្លាប់អាឯងវិញឱ្យបាន ពួកទាហានក៏ស្ទុះស្រូចូលទៅព័ទ្ធចាប់សម្លាប់**ហ្វូពៀវ**បាន។

បណ្ដានាហ្មឺនមុខមន្ត្រីខ្ញុំរាជការ និងសេនាទាហានទាំងពួង សឹងចូលទៅជាពួកក្រុមនៃ**អ្វួនសៀវ** និង**ចូឆ្វូ**ជាច្រើន ទើប**អ្វួនសៀវ**ចាត់ទាហានមួយកងតាមទៅព័ទ្ធចាប់ខន្ទីដប់នាក់ និងបក្សពួកទាំងប្រុសទាំងស្រីតូចធំសម្លាប់អស់ ហើយ**ចូឆ្វូ**ក៏ឃុំនាំទាហានចូលទៅលត់ភ្លើង ដែលឆេះក្នុងព្រះបរមរាជវាំងរលត់ស្រេច ក៏អញ្ជើញព្រះនាង**ហ្វូហៅ**ទៅស្ដីរាជការផែនដីដូចដើម។ លុះវេលាយប់**គួនគុយ**ក៏រត់ទៅជួបនឹង**តៀវយៀង** ទើបបបួលគ្នានាំ**ហង់ជូពៀន**, **ហង់ជូហៀប**ចេញទៅនៅក្រៅក្រុងលាក់ខ្លួនពួនជ្រកក្នុងព្រៃធំប្របជើងភ្នំប៉ាក់គួសាន។

ឯ**អ្នួនសៀវ** និង**ចូឆ្ក**ក៏កេណ្ឌប្រមូលពលទាហានចែកជាពីរកង កងមួយឲ្យតាមចាប់ពួកខ្មាំងប្រាំមួយនាក់ កងមួយឲ្យតាមស៊ើបរក**ហង់ជូពៀន** និង**ហង់ជូហៀប**ក្នុងព្រៃក្រៅក្រុង ខណៈដែល**គួនគុយ** និង**តៀវយៀង**បានឮស្នូរសំឡេងទាហានទន្ទ្រានតាមទៅជញ្ជាន់រកសន្ធឹកណាស់ ក៏ភ័យខ្លាចក្រែងមិនរួចពីសេចក្ដីស្លាប់ ទើបប្រញាប់ដោះវេះគេចយកតែខ្លួន ឯព្រះឱរសទាំងពីរព្រះអង្គ ក៏បោះបង់នៅក្នុងព្រៃកណ្ដាលអាធ្រាត្រស្ងាត់។ ឯ**តៀវយៀង**រត់កាត់តាមផ្លូវជើងគោកទៅដល់ស្ទឹងមួយប្រទះនឹងកងទ័ព**ប៊ិនខង**ចៅហ្វាយស្រុកហោឡាំ ពួកទាហានមិនបានឃើញខ្លួន**តៀវយៀង**ឮស្នូរតែជើងដើរក្នុងព្រៃស្រោកៗ ក៏នាំគ្នាព័ទ្ធរកក្បែរមាត់ស្ទឹងនោះ លុះដុតគប់ភ្លើងចងនឹងមែកឈើបំភ្លឺចូលទៅឃើញជាមនុស្ស **តៀវយៀង**ក៏ស្ទុះលោតទៅក្នុងស្ទឹងលង់ទឹកស្លាប់ទៅ។

ឯ**ហង់ជូពៀន** និង**ហង់ជូហៀប** ដែលខ្មាំងបោះបង់ចោលក្នុងព្រៃ លុះបានឮសំឡេងពលទាហានទន្ទ្រានព្រៃចូលមកអឹងកងដូច្នោះ ក៏ទ្រង់ភ័យណាស់។ ដល់ពេលយាមបី ទឹកសន្សើមធ្លាក់ណាស់ ក៏ប្រឹក្សាគ្នាថា យើងនឹងនៅក្នុងទីនេះមិនបានទេ ត្រូវរត់ចេញទៅទើបផុតភ័យ ថាហើយក៏នាំគ្នាយាងព្រះបាទសសុលមមុលព្រៃនៅក្នុងវេលាកណ្ដាលយប់ងងឹតមើលផ្លូវមិនឃើញសោះ មិនដឹងបើនឹងទៅខាងណាក៏យកជាយព្រះភូសាចងភ្ជាប់គ្នា លុះក្រឡេកឃើញអំពិលអំពែកហើរនាំមុខមួយហ្វូងក៏ភ្លឺស្វាងឃើញច្រកល្ហក ក៏នាំគ្នាយាងទៅតាមពន្លឺអំពិលអំពែកនោះ **ហង់ជូហៀប**ជាព្រះអនុជមានព្រះបន្ទូលថា អំពិលអំពែកនេះគឺជាទេវតាជួយនាំផ្លូវយើងប្រាកដអំណឹះទៅមុខយើងនឹងមានបុណ្យ។ លុះវេលាជិតភ្លឺស្រាងក៏យាងទៅដល់ចុងភ្នំមួយអន្លើ ព្រះបាទាព្រះរាជកុមារទាំងពីរអង្គក៏ហើមពុរពងនឹងយាងទៅមិនបាន លុះទ្រង់

ក្រឡេកមើលទៅឃើញគំនរស្មៅមួយកង ក៏នាំគ្នាចូលទៅប្រះផ្ទំលង់លក់ពុំដឹងព្រះកាយា។

ទីនោះមានចម្ការដំណាំរបស់អ្នកស្រុកម្នាក់ឈ្មោះ**ស៊ុយកុក** ក្នុងពេលយប់នោះ **ស៊ុយកុក**ដេកលក់យល់សប្តិឃើញថា មានព្រះអាទិត្យពីរដួងធ្លាក់នៅទីខាងក្រោយផ្ទះ លុះព្រឹកឡើង**ស៊ុយកុក**ភ្ញាក់ឡើងពីដេក ក៏ដើរចេញទៅលេងខាងក្រោយផ្ទះក្រឡេកទៅឃើញរស្មីភ្លឺត្រង់គំនរស្មៅ ក៏ដើរចូលទៅមើលឃើញកុមារពីរនាក់ដេកប្រឱបគ្នា **ស៊ុយកុក**ក៏ដាស់ឡើងសួរថា កុមារនេះមកពីណា? **ហង់ជូហៀប**ឆ្លើយថា នោះព្រះនាម**ហង់ជូពៀន**ដែលសោយរាជសម្បត្តិក្នុងក្រុងឡុកអៀង យើងជាព្រះអនុជឈ្មោះ**តាន់លីអង** បានជាយើងរត់មកនៅអាស្រ័យក្នុងទីនេះ ព្រោះតែខន្ទីដប់នាក់ បណ្តាលឲ្យកើតចលាចលវរវឹកក្នុងព្រះនគរ។ **ស៊ុយកុក**បានឮដូច្នោះ ក៏តក់ស្លុតលុតជង្គង់ចុះក្រាបថ្វាយបង្គំហើយទូលថា ទូលព្រះបង្គំជាខ្ញុំឈ្មោះ**ស៊ុយកុក** ពីដើមបានចូលធ្វើជាខ្ញុំរាជការក្នុងទីក្រុងដែរ តាំងតែពីផែនដីព្រះចៅ**ឡេនតេ**ជាព្រះវរបិតានៃព្រះអង្គ អាខន្ទីដប់នាក់វាធ្វើការអាក្រក់ទុច្ចរិតផ្សេងៗ ទូលព្រះបង្គំជាខ្ញុំមិនសប្បាយចិត្តមិនចង់ធ្វើរាជការ ក៏លាងារចេញមកធ្វើស្រែចម្ការរកទទួលទាននៅទីនេះ។ ទូលហើយ**ស៊ុយកុក**ក៏អញ្ជើញព្រះរាជកុមារទាំងពីរព្រះអង្គឡើងទៅគង់លើផ្ទះ ហើយក៏រៀបទឹកន្លែងប្រថាប់ និងប្រដាប់ក្រយាស្ងោយថ្វាយតាមសមគួរ ខណៈនោះព្រះរាជកុមារទាំងពីរព្រះអង្គក៏គង់សម្រាកនៅផ្ទះ**ស៊ុយកុក**។

ឯ**ប៊ិនខង**ក៏លើកទាហានផ្លូងចូលមកប្រទះនឹង**គួនគុយ**ខន្ទី ទាហានក៏ឃុំចាប់ខ្លួនបាន **ប៊ិនខង**ពិចារណាសួរថា តើចលាចលគ្រានេះព្រោះពួកឯងទាំងដប់នាក់បណ្តាលធ្វើការអាក្រក់ផ្សេងៗ ឥឡូវឯងនាំព្រះរាជកុមារទាំងពីរព្រះអង្គទៅទុកឯណា? **គួនគុយ**ឆ្លើយតបថា កាលកើតភ្លើងឆេះឡើងក្នុងព្រះបរមរាជវាំង ខ្ញុំបាននាំ

ព្រះរាជបុត្ររត់ទៅនៅក្នុងព្រៃ លុះបានឮសំឡេងគឹកកងរំពងចូលមកសឹងតែពួកទាហាន ខ្ញុំបាទក៏មានសេចក្ដីតក់ស្លុតរន្ធត់ភ័យណាស់ ក៏រត់ប្រាសយកតែខ្លួន ឯព្រះរាជកុមារពីរព្រះអង្គបងប្អូនក៏មិនដឹងខ្ចាត់ភ្លាត់ទៅទីណា។ **ប៊ិនខង**ឮដូច្នោះខឹងណាស់ ក៏ឲ្យសម្លាប់**គួនគុយ**នៅទីនោះ ហើយកាត់យកក្បាលព្យួរនឹងកសេះ លើកទាហានចេញចាកទីនោះបំបែកគ្នាជាច្រើនផ្លូវ តាមទៅរកព្រះរាជឱរសទាំងពីរព្រះអង្គ។ ឯ**ប៊ិនខង**ជិះលើខ្នងសេះតត្រុករុកព្រៃរំពៃរកព្រះរាជឱរសា ជាហេតុគឺទេវតានាំតម្រង់ត្រង់ទៅដល់មណ្ឌលផ្ទះ**ស៊ុយកុក**។

គ្រានោះ**ស៊ុយកុក**ឈរនៅមុខផ្ទះ លុះក្រឡេកឃើញ**ប៊ិនខង**ចងក្បាល**គួនគុយ**ព្យួរនឹងកសេះ គេចចូលមកជិតផ្ទះអាត្មា ក៏ម្ចីម្ចារត់ទៅជិតពិនិត្យក៏ស្គាល់បាន ទើបសួរថា លោកចាប់ខ្លួន**គួនគុយ**បានទៅទីណា ទើបកាត់ក្បាលព្យួរនឹងកសេះនាំមកនេះ? **ប៊ិនខង**ឆ្លើយឲ្យដំណឹង**ស៊ុយកុក**តាំងពីដើមដល់ចប់សព្វសេចក្ដីហើយថា ខ្ញុំស្វែងមកដល់ទីនេះដើម្បីនឹងស៊ើបរកព្រះរាជឱរសទាំងពីរព្រះអង្គ **ស៊ុយកុក**ក៏នាំតម្រង់ទៅក្រាបបង្គំគាល់ដល់ក្នុងផ្ទះ ហើយ**ស៊ុយកុក** និង**ប៊ិនខង** ក៏យកសេចក្ដីក្រាបបង្គំទូលព្រះរាជកុមារទាំងពីរថា ទំនៀមរាជប្រវេណីអំពីបុរាណមានថ្លែងចារឹកទុកមកថា ប្រទេសឯណាបើគ្មានម្ចាស់ផែនដីសោយរាជសម្បត្តិ សូម្បីតែមួយថ្ងៃ ផែនដីនោះនឹងកើតចលាចលទៅជាមានអន្តរាយមិនខាន ហេតុនេះសូមទានព្រះអង្គវិលទៅគង់ក្នុងទីក្រុងដូចដើមវិញ ទើបផែនដីនឹងបានសេចក្ដីសុខសប្បាយតទៅ។

ព្រះរាជកុមារទាំងពីរព្រះអង្គទ្រង់ព្រះសណ្ដាប់ ក៏គាប់ព្រះហឫទ័យព្រមតាមសម្ដីដែលក្រាបបង្គំទូលនោះ **ស៊ុយកុក** និង**ប៊ិនខង**ក៏រៀបចងគ្រឿងសេះព្រះទីនាំងដែលសម្រាំងទុកថ្វាយ ហើយក៏យាងស្ដេចឡើងគង់ទ្រង់យាងចេញទៅ លុះទៅដល់ផ្លូវប្រមាណបីរយសិន (១២ គ.ម) ទទួលជួបប្រទះនឹងឈ្មោះ **អងអ៊ុន១, អ៊ុរពីរ១,**

**ស៊ុនខេន១, តៀវប៉េង១, ប៉ោស៊ុន១, អ្នួនសៀវ១** ជានាហ្មឺនមានបណ្ដាសក្តិ ឃុំនាំពលទាហានប្រមាណប្រាំរយនាក់លើកតាមមាគ៌ា អ្នកទាំងនេះលុះក្រឡេកឃើញព្រះរាជកុមារទាំងពីរព្រះអង្គ ក៏តម្រង់បរសេះចុះទៅទទួលស្ដេច។ វេលានោះ**ស៊ុយកុក** និង **ប៊ិនខង**ក៏ពណ៌នាសេចក្ដី ដែលបានទៅរកឃើញព្រះរាជកុមារឱ្យស្ដាប់គ្រប់ប្រការ បណ្ដានាហ្មឺនទាំងប្រាំមួយនាក់លុះបានស្ដាប់ជាក់ហើយ ក៏ចាត់បម្រើសេះឱ្យយកក្បាល**គួនគុយ** ស្រូតរូតទៅប្រកាសឱ្យអស់បណ្ដារាស្ត្រនៅក្នុងព្រះនគរបានដឹងគ្រប់គ្នា ហើយប្រាប់ពួកក្រុមខ្ញុំរាជការចាត់ព្រះរាជរថដ៏វិចិត្ររចនាសម្រាប់ព្រះមហាក្សត្រ ចេញទៅទទួលព្រះរាជកុមារទាំងពីរព្រះអង្គ ចម្ងាយផ្លូវប្រមាណមួយរយសិន (៤ គ.ម) ស្ដេចក៏ឡើងគង់ត្រឡប់ ទទួលជួបប្រទះនឹងទាហានមួយកងច្រើនខ្នាន់ខ្នាប់ តែពុំដឹងច្បាស់ជាពួកកងទ័ពអ្នកឯណា អស់ពួកខ្ញុំរាជការទាំងឡាយក៏ភិតភ័យ **អ្នួនសៀវ**ជានាយទាហានក៏បំផាយសេះស្រូតទៅមុខព្រះរាជរថ ហើយស្រែកសួរថា ទ័ពអ្នកឯណាលើកមកនេះ **តាំងតុះ**ជាមេទ័ពក៏ប្រញាប់បរសេះជែងទៅមុខទាហាន ហើយឆ្លើយតបថា ព្រះរាជកុមារនៅឯណា ឬស្ដេចយាងមកជាមួយពួកនេះ? **ហង់ជូពៀន**ទ្រង់ព្រះសណ្ដាប់ក៏ស្ដុតព្រះទ័យស្ងៀមនៅ ចំណែក**ហង់ជូហៀប**ជាព្រះអនុជក៏ឆ្លើយឡើងថា ទ័ពអ្នកឯណាសួររកព្រះរាជកុមារ? **តាំងតុះ**ក៏ឆ្លើយថា ខ្ញុំឈ្មោះ **តាំងតុះ**ជាចៅហ្វាយស្រុកស៊ីឡុង។ **ហង់ជូហៀប**ត្រាស់សួរបញ្ជាក់ថា មកនេះជាក្បត់ឬប្រាថ្នាវត្ថុអ្វី? **តាំងតុះ**ថា ខ្ញុំមិនមែនជាក្បត់ទេ គឺមកទទួលស្ដេច។ **ហង់ជូហៀប**ត្រាស់ថា បើមកទទួលស្ដេចហេតុម្ដេចមិនចុះពីលើសេះ។ **តាំងតុះ**ឮដូច្នោះភ័យណាស់ ក៏លោតចុះពីលើខ្នងសេះ ហើយចូលទៅក្រាបថ្វាយបង្គំព្រះរាជកុមារទាំងពីរព្រះអង្គ ដែលគង់នៅលើព្រះរាជរថនោះ។ **ហង់ជូហៀប**មានព្រះបន្ទូលថា អ្នកនេះជាមនុស្សស្គាល់ខុសត្រូវ ចេះនិយាយពាក្យដើមពាក្យចុងប្រកបគ្នា មិនបង់

ប្រយោជន៍ដែលនឹងចិញ្ចឹមឲ្យធ្វើជានាហ្មឺនធំតទៅទៀត។ **តាំងតុះ**បានឮដូច្នោះក៏នឹក គិតតែក្នុងចិត្តថា **ហង់ជូហៀប**មានព្រះសតិបញ្ញាឆ្លៀវឆ្លាតដឹងបទបាទ ដែលនឹងមាន បន្ទូលក៏ស្រួលពីរោះមិនទាស់ត្រង់ណា អញនឹងគិតដោយប្រាជ្ញាទម្លាក់**ហង់ជូពៀន** ចេញ ហើយនឹងលើកយក**ហង់ជូហៀប**ឲ្យសោយរាជសម្បត្តិវិញឲ្យបាន **តាំងតុះ**គិត ដូច្នោះ ក៏ថ្វាយបង្គំនាំពលទាហានថយទៅតាំងទ័ពនៅខាងក្រៅកំពែងព្រះនគរ។

ខណៈនោះ ព្រះនាង**ហូហៅ**បានឃើញព្រះរាជបុត្រត្រឡប់មកវិញ ក៏មាន សេចក្តីសោមនស្សណាស់ ព្រះនាងបានត្រួតពិនិត្យមើលបណ្តាព្រះរាជទ្រព្យដែល មានក្នុងផ្ទៃព្រះឃ្លាំង ក៏សឹងតែសម្បូណ៌នៅដូចដើមដដែល បាត់តែត្រាព្រះសង្ហា ដែលសម្រាប់ស្តីរាជការក្នុងព្រះនគរ។

គ្រានោះ **តាំងតុះ**ដ៏មានសន្តានចិត្តក្លៀវក្លា រមែងលើកពលសេនាចូលមក លេងក្នុងព្រះនគរជារឿយៗ បណ្តាពួកពលទាំងពួងក៏សឹងតែមកដណ្តើមយករបស់ ទ្រព្យ និងចំណីអាហាររបស់បណ្តាប្រជានុរាស្ត្រទាំងឡាយជាជ្រួលច្របល់រឹករវរ មនុស្សក្នុងព្រះនគរក៏មិនមាននរណាតវ៉ាថាម្តេច ឯ**តាំងតុះ**នោះបើនឹងចូលទៅក្រាប បង្គំគាល់ ក៏ធ្វើមិនស្គាល់អស់សេនាបតីធំៗ មិនមានសេចក្តីគួរសមគំនាប់តាម ធម្មតា។ **ប៉ៅស៊ិន**បានឃើញវេលាណាក៏ប្រឹក្សានឹង**អួនសៀវ**ថា **តាំងតុះ**នេះអំណឺះយូរ ទៅគង់នឹងកំរើបចិត្តធ្វើការអាក្រក់មិនខាន យើងត្រូវតែគិតអានបំផ្លាញរំលាងវា ចេញជាមុន។ **អួនសៀវ**ឆ្លើយថា វេលានេះផែនដីទើបតែនឹងស្ងប់ បើយើងនឹងត្រឡប់ កម្រើកឡើងក្រែងមិនស្រួល។ **ប៉ៅស៊ិន**ឃើញថា **អួនសៀវ**មិនព្រមទទួលគំនិតជា មួយនឹងគ្នា ក៏ម្ខីម្ខាទៅរក**អងអ៊ុន**ហើយប្រឹក្សាដូចនិយាយនឹង**អួនសៀវ**នោះ **អងអ៊ុន** ត្រូវចិត្តដូចគំនិតរបស់ខ្លួន ក៏សុំឲ្យបង្អង់និងថយទៅត្រិះរិះរកឧបាយ។ **ប៉ៅស៊ិន**មិន

សប្បាយដោយចិត្តរូតរះ ក៏កើតទោមនស្សតែម្នាក់ឯង ទើបនាំបក្សពួកចេញទៅនៅក្នុងព្រៃ។

ឯ**តាំងតុះ**តែងតែបញ្ចុះបញ្ចូលសេនាទាហាន ដែលធ្លាប់នៅអាស្រ័យនឹង**ហួជិន**ពីមុននោះ សឹងចុះចូលទៅនៅខាងខ្លួនទាំងអស់ **តាំងតុះ**ក៏កាន់តែកំរើបចិត្តគិតនឹង**លីយូ**ថា យើងចង់នឹងទម្លាក់**ហង់ជូពៀន**ចេញចាករាជសម្បត្តិ ហើយលើក**ហង់ជូហៀប**ឲ្យសោយរាជ្យជាថ្មី រាជការផែនដីក៏គង់នឹងដាច់ស្រេចនៅលើយើងអំណឹះទៅមុខបើយើងនឹងប្រាថ្នាយ៉ាងណា ក៏គង់នឹងបានសម្រេចស្រួលដោយងាយ។ **លីយូ**តបថា សព្វថ្ងៃនេះមានស្ដេចក៏ដូចជាមិនមានស្ដេចសោះ សេនាបតីទាំងអស់ក៏សម្រេចរាជការពុំបាន ដែលមានប្រសាសន៍គិតអានដូច្នោះគួរណាស់ ព្រោះសម័យនេះផែនដីក៏ទើបនឹងស្ងប់ជាសុខក្សេមក្សាន្ត សូមគិតអានជាប្រញាប់ចុះ។ ប្រការមួយទៀត សូមឲ្យលោកប្រមូលអស់បណ្ដានាហ្មឺនមុខមន្ត្រីតូចធំទៅជួបជុំនៅទីសួនផ្កា តំបន់អ៊ុនបេងហ៊ុយ បើប្រជុំព្រមហើយឲ្យប្រកាសថា ត្រូវទម្លាក់**ហង់ជូពៀន**ចេញចាករាជសម្បត្តិ ហើយលើក**ហង់ជូហៀប**ឲ្យសោយរាជ្យវិញ បើនាហ្មឺនណាមិនយល់ព្រម ឲ្យចោមចាប់កាប់សម្លាប់ចេញមួយរំពេចឲ្យបាន លោកក៏នឹងមានអាជ្ញាសិទ្ធិដាច់ខាតតទៅ។

**តាំងតុះ**បានស្ដាប់ក៏មានចិត្តសោមនស្សត្រេកអរ មានវាចាថា ពាក្យដែលអ្នកនិយាយនោះត្រូវណាស់ **តាំងតុះ**ឲ្យរៀបអាហារភោជន ហើយឲ្យអញ្ជើញនាហ្មឺនមុខមន្ត្រីតូចធំទៅជួបជុំបរិភោគ នាហ្មឺនតូចធំសឹងនិយមកោតខ្លាចអំណាច**តាំងតុះ**ទាំងអស់គ្នា វេលាដែលបានទៅជួបជុំក៏នាំគ្នាទៅបរិភោគក្នុងសួនផ្កា លុះអង្គុយចុះព្រមគ្នាហើយ **តាំងតុះ**ក៏កាន់គ្រប៊ីចេញមកឈរកណ្ដាលតុ ហើយប្រកាសថា អស់លោកទាំងអស់គ្នាកុំអាលសេពសុរា ខ្ញុំនឹងសុំនិយាយការរាជការខមួយសិន។ នាហ្មឺនទាំង

អស់ក៏សំងំចាំស្តាប់។ ទើប**តាំងតុះ**និយាយថា សព្វថ្ងៃនេះ**ហង់ជូពៀន**បានទទួលគ្រងរាជសម្បត្តិ ឧបមាបីដូចជាសិរសា និងហឫទ័យនៃអគ្គមហាសេនាបតីនាហ្មឺនសព្វមុខមន្ត្រី នូវអស់អាណាប្រជានុរាស្ត្រទាំងពួង តែថាក្សត្រនេះមិនមានឫទ្ធានុភាពអាចនឹងកម្រាបបច្ចាមិត្តបាន ព្រោះគ្មានតបៈតេជៈឲ្យជាទីកោតខ្លាច។

ឥឡូវនេះខ្ញុំឃើញ**ហង់ជូហៀប**ជាព្រះអនុជ មានសតិបញ្ញាវាងវៃជាង ចេះវោហារក្លាហាន ខ្ញុំនឹងដកហូត**ហង់ជូពៀន**ចេញវេលានេះ ហើយលើក**ហង់ជូហៀប**ឡើងឲ្យសោយរាជសម្បត្តិវិញ ទើបផែនដីនឹងបានសេចក្តីសុខសប្បាយ អ្នកទាំងឡាយនឹងយល់ឃើញប្រការដូចម្តេច? បណ្តានាហ្មឺនតូចធំក៏សំងំនៅស្ងៀមទាំងអស់គ្នា តែ**តេងងួន**ជាចៅហ្វាយស្រុកតេងជីវព្ទដូច្នោះ ក៏ស្ទុះក្រោយឡើងឈរហើយនិយាយថា ខ្លួនអ្នកឯងគ្រាន់តែជាទីតំណែងមន្ត្រីខេត្តក្រៅ មិនត្រូវមានអំណាចនឹងដកហូតអម្ចាស់ផែនដីឡើយ ព្រោះ**ហង់ជូពៀន**ក៏ជាព្រះរាជឱរសច្បង គួរនឹងគ្រងរាជសម្បត្តិជំនួសព្រះចៅ**ឡេនតេ** តាមព្រះរាជប្រវេណីអំពីបុរាណ ព្រះអង្គក៏នឹងមានសេចក្តីខុសត្រង់ណា ដែលអ្នកឯងមានវាចាដូច្នេះ នឹងចង់ជាសត្រូវក្បត់ផែនដីឬអ្វី?

**តាំងតុះ**បានស្តាប់ដូច្នោះខឹងណាស់ ក៏ស្រែកគំហកថា យើងប្រឹក្សាជាការល្អណាស់ ចុះហេតុម្តេចខ្លួនក្រឡាស់ឆ្លើយទទឹងនឹងពាក្យរបស់យើងដូច្នោះ យើងត្រូវកាត់ក្បាលនឹងគ្របីនេះឥឡូវ ថាហើយក៏ហូតស្រោមគ្របីចេញ គិតនឹងដេញកាប់**តេងងួន**។

**លីយូ**ក្រឡេកឃើញ**លីប៉ោ**ឈរពីក្រោយខ្នង**តេងងួន** មានខ្លួនធំខ្ពស់ កាន់លំពែងនៅដៃយ៉ាងអង់អាច ក៏នឹកបារម្ភខ្លាចទើបចូលទៅសុំជម្រាបឃាត់**តាំងតុះ**ថា ថ្ងៃនេះយើងអញ្ជើញអស់លោកមកជួបជុំពិសាក្រយាហារ គួរតែនឹងស្តាប់ចម្រៀងរបាំរាំលេងសប្បាយ ម្តេចមកនិយាយប្រកួតប្រកែកជជែកគ្នា នៅមានវេលាតែថ្ងៃ

មួយនេះទេឬ? គង់មានថ្ងៃតទៅទៀតនឹងប្រឹក្សាគ្នាបាន ឬនឹងចង់តវ៉ាដល់សាលាលូកឃុនចុះ ថ្ងៃនេះអញ្ជើញពិសាឲ្យសប្បាយ។

បណ្ដានាហ្មឺនទាំងឡាយ ក៏ហាមឃាត់**តេងងួន**ៗក៏ឡើងសេះនាំ**លីប៉ោ**វិលទៅវិញ ឯ**តាំងតុះ**ក៏ពិគ្រោះនឹងនាហ្មឺនទាំងអស់ថា យើងប្រឹក្សាអម្បាញ់មិញនេះអស់លោកនឹងយល់ឃើញយ៉ាងណា ជាត្រូវឬខុស? **លោទិត**តបថា លោកប្រឹក្សាការរាជការនោះខុសណាស់ ព្រោះព្រះចៅ**ឡេនតេ**ជាព្រះវរបិតាទ្រង់ជ្រាបថា **ហង់ជូពៀន**ជាព្រះរាជបុត្រច្បងមានសតិបញ្ញាគួរនឹងឡើងសោយរាជសម្បត្តិបាន ខ្លួនលោកត្រឹមតែជាជាន់មន្ត្រីខេត្តក្រៅនៅមិនទាន់ភ្លឺច្បាស់ ព្រះរាជបញ្ញត្តិតាមសណ្ដាប់រាជប្រវេណី នឹងមកដកហូត**ហង់ជូពៀន**ដែលមិនមានសេចក្ដីខុសនោះមិនគួរ។ **តាំងតុះ**ឮដូច្នោះក៏រឹតតែខឹងណាស់ ហូតគ្រប៊ីប្រុងកាប់**លោទិត**នៅទីនោះ **ថៃប៉ិក**ក៏ស្ទុះទៅហាមឃាត់ថា **លោទិត**នេះជាមន្ត្រីធំមកពីដើម សន្ដានចិត្តក៏សុចរិតទៀងត្រង់នឹងរាជការ បណ្ដានាហ្មឺនមុខមន្ត្រីតូចធំខ្ញុំរាជការនូវអាណាប្រជានុរាស្ត្រទាំងឡាយក៏រួសរាយរាប់អានស្រឡាញ់**លោទិត**ច្រើនណាស់ បើលោកនឹងសម្លាប់**លោទិត**ចេញច្បាស់ជាក្រឡុះក្រឡាប់ទឹកដីកើតភ័យអន្តរាយមិនខាន។ **អងអ៊ុន**ក៏ឆ្លើយថ្កានថា ថ្ងៃនេះជាទីប្រជុំគ្នាបរិភោគអាហារឲ្យសប្បាយ បើនឹងប្រឹក្សាការរាជការផែនដីក៏ត្រូវបង្អង់ដល់ថ្ងៃឯមុខចុះ បណ្ដានាហ្មឺនទាំងពួងក៏គំនាប់លា**តាំងតុះ**ត្រឡប់ទៅទីលំនៅរៀងខ្លួន។

ឯ**លីប៉ោ**ស្ទុះទៅដល់ទីឋានជាមួយនឹង**តេងងួន**ហើយ ក៏កាន់លំពែងឡើងសេះវិលត្រឡប់មកចាំស្ដាប់ការក្នុងសួនផ្កាវិញ កាលនាហ្មឺនទាំងអស់វិលទៅអស់ហើយ **តាំងតុះ**ក៏កាន់គ្រប៊ីដើរទៅដល់មាត់ទ្វារសួនផ្កា ក្រឡេកឃើញ**លីប៉ោ**ជិះសេះបរចូលមកដល់ក្បែររបង ក៏សួរ**លីយូ**ថា ទាហានរបស់នរណា? **លីយូ**ឆ្លើយថា លោកថយ

មកវិញឲ្យឆាប់ ទាហាននោះឈ្មោះ**លីប៉ោ**ជាកូនចិញ្ចឹម**តេងង្វួន** មានកម្លាំងខ្លាំងពូកែណាស់។ **តាំងតុះ**ក៏ថយត្រឡប់មកវិញ។ លុះដល់ព្រឹកឡើងមានបម្រើទៅប្រាប់**តាំងតុះ**ថា ឥឡូវ**តេងង្វួន**និង**លីប៉ោ**ឃុំនាំទាហានលើកមកច្បាំងនឹងលោកហើយ។ **តាំងតុះ**ខឹងណាស់ក៏រលះរលាំងរៀបពលទាហានលើកចេញទៅ។

ពេលនោះ**តេងង្វួន**និង**លីប៉ោ**បរសេះចេញទៅឈរមុខទាហាន ហើយស្រែកថា គ្រាមុនអាពួកខន្ទីដប់នាក់វាបណ្ដាលហេតុជាចលាចលពេញផែនដី ទើបកើតភ័យអន្តរាយ ឥឡូវស្រុកទើបតែនឹងបានសុខសប្បាយបន្តិចប៉ុណ្ណោះ ខ្លួនគ្រាន់តែជាមន្ត្រីខេត្តក្រៅមិនទាន់មានគុណបំណាច់យ៉ាងណា មកគិតការតាំងខ្លួនធំសម្រេចរាជការផែនដី អាចហ៊ានចេញវាចាស្រដីថានឹងដកហូតព្រះមហាក្សត្រចេញអំពីរាជសម្បត្តិតាមចិត្តរបស់ខ្លួន ធ្វើដូច្នេះនឹងឲ្យផែនដីកើតចលាចលម្ដងទៀត ដូចកាលគ្រាពួកខន្ទីនោះឬអ្វី?

**តាំងតុះ**មិនទាន់តបសម្ដី **លីប៉ោ**ក៏បំផាយសេះគ្រវីលំពែងចូលទៅតម្រង់នឹងចាក់**តាំងតុះ** ៗឃើញដូច្នោះ ក៏បរសេះស្ទុះថយទៅក្រោយ ទាហាន**តេងង្វួន**ក៏បរពលចូលទៅចាក់កាប់សម្លាប់កងទាហាន**តាំងតុះ** ៗក៏បែកទាហានខ្ចាត់ខ្ចាយថយទៅក្រោយប្រហែលហាសិបសិន (២ គ.ម) ទើបឲ្យតាំងបន្ទាយវាយចម្រូងរូងទឹកជាស្នាមភ្លោះជុំវិញជាមាំមួន ហើយក៏ប្រឹក្សានឹងសេនាទាហានថា តាំងពីយើងបានធ្វើសឹកសង្គ្រាមរៀងមក ក៏ជាច្រើនគ្រាហើយ មិនដែលឃើញទាហាននរណាក្លាហានខ្លាំងពូកែដូច**លីប៉ោ**សោះ បើប្រសិនយើងបាន**លីប៉ោ**នោះមកជាសេនារបស់យើង ការទាំងពួងក៏នឹងបានសម្រេចតាមប្រាថ្នា **លីសុក**នាយទាហានឮហើយឆ្លើយជម្រាប**តាំងតុះ**ថា ខ្ញុំបាទនិង**លីប៉ោ**នៅស្រុកជាមួយគ្នា ជាមិត្តសំឡាញ់នឹងគ្នាតាំងពីតូច តែថា**លីប៉ោ**នោះខ្លាំងពូកែមែន ប៉ុន្តែចិត្តអាក្រក់ណាស់ មិនដឹងគុណអ្នកឯណា ប្រាថ្នា

រកតែទ្រព្យរបស់គាប់ចិត្ត បើលោកត្រូវការ ខ្ញុំបាទនឹងសូមទៅនិយាយបញ្ចុះបញ្ចូល**លីប៉ោ**ឲ្យបាននៅធ្វើការជាមួយនឹងលោក។ **តាំងតុះ**សួរថា អ្នកនឹងទៅបញ្ចុះបញ្ចូលដូចម្ដេចទើបបាន**លីប៉ោ**មកនៅនឹងយើង?

**លីសុក**ឆ្លើយថា សូមឲ្យលោករកទ្រព្យរបស់ដែលល្អមានតម្លៃ ហើយនិងសេះឈ្មោះ សឹកថៅ (សិន្ធវ:) ដ៏មានកម្លាំងបរមួយថ្ងៃបានចម្ងាយផ្លូវមួយម៉ឺនសិន (៤00 គ.ម) នោះមកឲ្យខ្ញុំបាទៗនឹងយកទៅឲ្យ**លីប៉ោ** ហើយនឹងបញ្ចុះបញ្ចូលតាមតម្រិះប្រាជ្ញាខ្ញុំឲ្យខាងតែបាន**លីប៉ោ**ចូលមកនៅនឹងលោកជាប្រាកដ។ **តាំងតុះ**មិនទាន់អស់ចិត្តក៏បែរទៅពិគ្រោះនឹង**លីយូ**ទៀតថា ដែល**លីសុក**និយាយទាំងអម្បាលនេះ តើអ្នកយល់ឃើញដូចម្ដេច?

**លីយូ**ថាខ្ញុំបាទស្ញើចនឹងលោកណាស់ លោកប្រាថ្នាគិតការធំប៉ុណ្ណេះ ហើយមិនគួរឡើយនឹងស្ដាយទ្រព្យរបស់និងសេះមួយប៉ុណ្ណោះសោះ បើសមដូចប្រាថ្នាកាលណាទ្រព្យសម្បត្តិលើសនេះក៏គង់ហូរចូលឯងមិនខាន។

**តាំងតុះ**បានស្ដាប់ដូច្នោះហើយ ក៏ចុះចិត្តជឿជាក់អស់ពីពោះ ទើបចាត់យកទ្រព្យរបស់គឺមាសមួយពាន់តម្លឹង ត្បូងពេជ្រទាំងគ្រាប់ដប់វាយក្បាលខឹមខាត់ប្រដាប់ខ្សែក្រវាត់មួយ ហើយនិងសេះមួយឈ្មោះសឹកថៅប្រគល់ឲ្យ**លីសុក**ហើយផ្ដាំថា អ្នកចូរយកទៅឲ្យ**លីប៉ោ**តាមគំនិតអ្នកគិតនោះចុះ។ **លីសុក**ទទួលរបស់ និងសេះហើយ ក៏លា**តាំងតុះ**ទៅកាន់ទីបន្ទាយ**តេងង្គួន** លុះទៅដល់មាត់ទ្វារក៏ជួបប្រទះនឹងមនុស្សបម្រើរបស់**លីប៉ោ** ចេញមកគយល្បាត ពួកនោះក៏ចាប់ខ្លួន**លីសុក**ទុក ហើយសួរថា អ្នកឯងមានការមករកអ្វីដល់ទីនេះ? **លីសុក**ឆ្លើយថា ខ្ញុំឈ្មោះ**លីសុក**ជាមិត្តសំឡាញ់នឹង**លីប៉ោ**តាំងពីតូច ឥឡូវមានសេចក្ដីនឹករឭក**លីប៉ោ**បានជាចូលមករក អ្នកទាំងឡាយចូរនាំខ្ញុំទៅរក**លីប៉ោ**ចុះ ទាហានគយល្បាតក៏ឲ្យឃុំខ្លួន**លីសុក**ទុក ហើយ

ចូលទៅជម្រាប**លីប៉ោ** ៗបានដឹងជា**លីសុក**មករកក៏មានសេចក្ដីត្រេកអរណាស់ ទើបចេញមកទទួល**លីសុក**នាំចូលទៅក្នុងបន្ទាយ ហើយក៏និយាយថា យើងទាំងពីរនាក់ស្ម័គ្រស្រឡាញ់គ្នាតាំងពីតូចៗ ពីជួបឃ្លាតចាកគ្នាមកជាយូរណាស់ហើយ ឥឡូវអ្នកមកធ្វើរាជការនៅក្នុងទីតំណែងណា? **លីសុក**តបថា ខ្ញុំជាទី**តុងឡុងជាង**នាយទាហាន ដឹងជាអ្នកចូលធ្វើរាជការជានាយទាហានដូចគ្នា បានជួយអាសាផែនដីខ្ញុំក៏មានចិត្តត្រេកអរណាស់ វេលានេះនឹងរករបស់ផ្ញើជាគួរសមពុំបាន មានតែសេះមួយឈ្មោះសឹកថៅនៅកំពុងពេញកម្លាំង បរមួយថ្ងៃបានចម្ងាយមួយម៉ឺនសិន (៤00 គ.ម) បើឡើងភ្នំ ឬចុះឆ្លងទឹកក៏បីដូចជាដើរលើដីរាបដូចគ្នា អ្នកចូរយកទៅទុកជាជំនិះរបស់ខ្លួននឹងបានធ្វើការរាជការរក្សាផែនដីតទៅ។ **លីប៉ោ**បានស្ដាប់ដូច្នោះ ទើបដឹកសេះនោះទៅមើលលក្ខណៈ ឃើញរោមនោះក្រហមដូចរងើកភ្លើងអស់ទាំងខ្លួន គ្មានពណ៌ត្រង់ណាឲ្យខុសប្លែកគ្នា កម្ពស់បួនហត្ថប្លាយ ត្រូវលក្ខណៈជាសេះចម្បាំងខ្លាំងពូកែមែន។ **លីប៉ោ**ក៏មានសេចក្ដីសោមនស្សត្រេកអរពន់ប្រមាណ បានឱនគំនាប់ក៏និយាយថា អ្នកនាំយកសេះនេះមកឲ្យខ្ញុំៗអរគុណណាស់ ព្រោះសមប្រកបនឹងសេចក្ដីប្រាថ្នារបស់ខ្ញុំលើសដែលឲ្យទ្រព្យរបស់ទាំងពួង ខ្ញុំក៏មិនមានវត្ថុអ្វីថ្លៃត្រកាលនឹងតបស្នងសងគុណអ្នកទេ។ **លីសុក**តបថា ដែលខ្ញុំយកសេះមានថ្វីជើងខ្លាំងពូកែមកជូនអ្នកទាំងនេះ នឹងបានគិតប្រាថ្នាយករបស់ជាសំណងវិញក៏ទេសោះ ចំពោះគិតថា អ្នកជាជាតិទាហានមានចិត្តសុចរិតទៀងត្រង់ប្រុងនឹងធ្វើការយកអាសាផែនដី ទើបខ្ញុំនាំសេះនេះមកជូន។

ទើប**លីប៉ោ**ឲ្យរៀបលៀងភោជនាហារ ខណៈកាល**លីសុក**កំពុងសេពសុរា ក៏មានវាចាសួរ**លីប៉ោ**ថា លោកធំនោះឥឡូវនៅទីកន្លែងណា អាណិតនាំខ្ញុំទៅគំនាប់ ដើម្បីឲ្យលោកស្គាល់រាប់អានផង។ **លីប៉ោ**តបថា អ្នកនៅឯណាមិនដឹងជាបិតាខ្ញុំ

អនិច្ចកម្មយូហើយ? **លីសុក**តបថា ចូរអ្នកនាំខ្ញុំទៅគំនាប់**តេងងួន**ជាបិតាចិញ្ចឹមអ្នកចុះ។ **លីប៉ោ**ក៏បណ្ដេញមនុស្សទាំងអស់ឲ្យដើរចេញ ហើយខិនខ្សឹបថា អ្នកផឹកស្រាស្រវឹងទេដឹង? ខ្ញុំនិងអ្នកដឹងស្គាល់មាតាបិតាទាំងសងខាងតាំងពីតូច ហេតុដូចម្ដេចបានជានិយាយដូច្នេះ ដែលយើងមកនៅធ្វើការនឹង**តេងងួន**ហៅថាបិតានោះ ព្រោះចាំចិត្តគិតតែធ្វើខ្លួនឲ្យបានសុខប៉ុណ្ណោះទេ។ **លីសុក**ថា ខ្លួនមានថ្វីដៃល្បីឈ្មោះខ្លាំងពូកែក្នុងការសង្គ្រាមជាប្រាកដណាស់ បើនឹងគិតរករបស់អ្វី ក៏គង់សម្រេចសេចក្ដីប្រាថ្នា ហេតុម្ដេចមកចាំចិត្តនៅដូច្នេះ? **លីប៉ោ**តបថា ដែលអ្នកនិយាយនោះក៏មែនហើយ តែយើងស្វែងរកទីពឹងដែលជាបង្គោលមាំនោះនៅមិនទាន់បាន។ **លីសុក**ញញឹមហើយឆ្លើយថា ធម្មតាសត្វបក្សីតែងពឹងព្រៃព្រឹក្សា ដែលមានផល្លានុផលទើបបានសេចក្ដីសុខសប្បាយ ប្រវេណីនាហ្មឺនខ្ញុំរាជការទាំងឡាយ បើព្រះមហាក្សត្រទ្រង់ទសពិតរាជធម៌ដ៏ប្រពៃ ក៏រមែងបានសេចក្ដីសុខក្រោមម្លប់ព្រះបរមពោធិសម្ភារជាដរាប ដែលអ្នកថាចាំចិត្តនៅធ្វើរាជការជាមួយនឹង**តេងងួន**នេះ នឹងប្រាថ្នាប្រយោជន៍អ្វី អំណើះទៅខាងមុខអ្នកគង់នឹងបានសេចក្ដីខុស និងបានទុក្ខភ័យអន្តរាយ គួរខ្វល់ខ្វាយរកនាយចៅហ្វាយជាថ្មីទៀតជាជាង។

**លីប៉ោ**ឮដូច្នោះ ក៏សាកសួរ**លីសុក**ថា អ្នកធ្វើរាជការក្នុងស្រុកក្រុង គង់បានដឹងឮថា នាហ្មឺនណាមានបុណ្យអំណាចអាចតាំងនៅក្នុងផ្លូវសុចរិតយុត្តិធម៌ នឹងនិយាយការរាជការក៏ស្រេចដាច់ខាតបាន។ **លីសុក**ឆ្លើយថា ខ្ញុំសម្លឹងរកមើលបណ្ដានាហ្មឺនមុខមន្ត្រីក្នុងដីក្រុងនោះ ដែលនឹងឲ្យមានសតិបញ្ញាក្លាហាន មានសន្តានដ៏សុចរិតពិតត្រង់ ទាំងដួងចិត្តក៏ល្អិតល្អនឹងពួកទាហាន មានតែឲ្យបំណាច់រង្វាន់តាមគុណូបការជាលំដាប់ មិនស្រឡាញ់ទ្រព្យរបស់ តែងយកចិត្តមនុស្សជាប្រមាណ អំណើះទៅខាងមុខខ្ញុំឃើញថា **តាំងតុះ**គង់នឹងបានជានាហ្មឺនធំបំផុតប្រាកដមិនខាន។

**លីប៉ោ**បានស្តាប់ក៏មានចិត្តសោមនស្សត្រេកអរសរសើរថា ខ្ញុំប្រាថ្នានឹងរកទីពឹងយ៉ាងនេះជាយូរមកហើយ តែថារកឱកាសនឹងចេញទៅមិនទាន់បាន។ ទើប**លីសុក**ស្រាយយកមាសមួយពាន់តម្លឹង និងត្បូងពេជ្រទាំងគ្រប់ប្រដាប់ខ្សែក្រវាត់ក្បាលខឹមខាត់ទាំងអស់មកដាក់ចំពោះមុខ **លីប៉ោ**ឃើញដូច្នោះក៏សួរថា របស់ទាំងនេះអ្នកយកមកធ្វើអ្វី? **លីសុក**ឆ្លើយថា **តាំងតុះ**មានចិត្តស្រឡាញ់អ្នកច្រើនណាស់ ទើបប្រើខ្ញុំឱ្យនាំសេះ និងរបស់ទាំងអស់នេះមកជូន។ ឯ**លីប៉ោ**ជាមនុស្សលោភ លុះឃើញរបស់មានតម្លៃ ក៏មានសេចក្តីត្រេកអរពន់ប្រមាណ បានឆ្លើយតបថា ដែល**តាំងតុះ**មានចិត្តស្រឡាញ់ ហើយឱ្យនាំសេះនិងរបស់មកឱ្យនោះ ខ្ញុំនឹងមានវត្ថុអ្វីទៅតបស្នងសងគុណលោកវិញ? **លីសុក**ឆ្លើយតបថា អម្បាលដូចខ្ញុំពុំមានថ្វីដៃអ្វីសោះ ម្តេច**តាំងតុះ**មានចិត្តសប្បុរសស្រឡាញ់សរសើរ ជួយស្នើសេចក្តីគាប់គុណឱ្យបានធ្វើជានាយទាហានប៉ុណ្ណោះ ចំណង់បើខ្លួនអ្នកមានចំណេះវិជ្ជាខ្លាំងពូកែជាងខ្ញុំ បើអ្នកទៅនៅជាពួកក្រុមហើយ ក៏គង់នឹងឡើងយសស័ក្តិជានាហ្មឺនធំពុំខាន លាភសក្ការៈទាំងអម្បាលម៉ានក៏នឹងមានដល់ខ្លួនអ្នកជាច្រើន។

**លីប៉ោ**តបថា ខ្ញុំនឹងយកសេចក្តីគាប់ឯណាទៅជាជំនូន**តាំងតុះ**? **លីសុក**ឆ្លើយថា បើអ្នកនឹងយកសេចក្តីគាប់ទៅជូនបានដោយងាយណាស់ ក្រែងតែអ្នកមិនព្រមធ្វើ បើអ្នកធ្វើហើយក៏គង់នឹងបានក្នុងមួយជំទាស់ម្រាមដៃ ។ **លីប៉ោ**ក៏ស្ងៀមអង្គុយគិតមួយស្របក់ ហើយឆ្លើយថា ដែលនឹងយកសេចក្តីគាប់អ្វីៗក៏គ្មានសោះ មានតែ**តេងង្ងួន**ជាគូវិវាទគ្នានឹង**តាំងតុះ** ហើយសេចក្តីគាប់ប្រសើរគង់នឹងមានដល់អ្នកជាច្រើនណាស់ ឯគំនិតនេះត្រូវគិតយ៉ាងរហ័សរួសរាន់ តែយូរទៅនឹងលាន់ឮបែកការ។ **លីប៉ោ**ក៏ទទួលពាក្យប្តេជ្ញាថាអ្នកចូរវិលទៅជម្រាប**តាំងតុះ** ព្រឹកនេះខ្ញុំនឹងកាត់យកក្បាល**តេងង្ងួន**ទៅជូន**តាំងតុះ**ជាប្រាកដ ហើយខ្លួនខ្ញុំនឹងសុំនៅធ្វើរាជការជាមួយនឹង

**តាំងតុះ**តទៅ។ **លីសុក**ក៏លា**លីប៉ោ**ទៅវិញ យកសេចក្ដីនេះទៅជម្រាប**តាំងតុះ**គ្រប់ប្រការ។ លុះដល់ពេលយប់ប្រមាណយាមពីរប្លាយ **លីប៉ោ**យកគ្រប៊ីសៀតបង្កប់នៅចង្កេះ ហើយដើរចូលទៅដល់ដំណេក**តេងងួន** ឃើញ**តេងងួន**កំពុងតែមើលសំបុត្រ។

ឯ**តេងងួន**ឃើញ**លីប៉ោ**ចូលទៅក៏សួរថា កូនអើយអ្នកចូលមកមានការអ្វី? **លីប៉ោ**ស្រែកគំហកថា ខ្លួនអញជាប្រុសចំពោះមានថ្វីដៃល្បីល្បាញប្រាកដ ឯងនឹងមកលើកខ្លួនជាអាពុកហៅអញថាកូននោះមិនសមគួរសោះ។ **តេងងួន**បានឮដូច្នោះក៏ភ័យណាស់ ស្ទុះក្រោកឡើងនិយាយថា ហេតុម្ដេចចៅគិតត្រឡប់ចិត្តដូច្នេះ? **លីប៉ោ**មិនឆ្លើយសោះ ហូតគ្រប៊ីស្ទុះចូលទៅកាប់**តេងងួន**ស្លាប់នៅទីនោះ ហើយកាត់យកក្បាលយួរឡើងស្រែកប្រកាសដល់ទាហានទាំងពួងថា **តេងងួន**មិនមែនជាមនុស្សទៀងត្រង់នឹងរាជការផែនដីសោះ ចំពោះធ្វើការលាមកអាក្រក់ណាស់ ឥឡូវនេះយើងសម្លាប់ចោលហើយ អ្នកទាំងឡាយនឹងចង់ទៅធ្វើការជាមួយនឹងយើងប៉ុន្មាននាក់ ឬមិនស្ម័គ្រនឹងទៅធ្វើការទេ ក៏ចូរគិតអានវិលទៅស្រុកទេសនៃខ្លួនចុះ។ ទាហានទាំងពួងបានឮឃើញដូច្នោះ នរណាដែលស្អប់មិនស្រឡាញ់**លីប៉ោ** ក៏រត់បែកខ្ញែកទៅប្រមាណពាក់កណ្ដាល ក្រៅពីនោះនរណាដែលរាប់អានស្រឡាញ់**លីប៉ោ**ក៏បបួលគ្នាទៅតាមនៅនឹង**លីប៉ោ**ប្រមាណពាក់កណ្ដាល។ លុះដល់ពេលព្រឹកព្រហាម **លីប៉ោ**ក៏ឡើងសេះយួរក្បាល**តេងងួន**ចូលទៅរក**លីសុក**ក្នុងបន្ទាយ**តាំងតុះ**។ **លីសុក**ឃើញ**លីប៉ោ**យួរក្បាល**តេងងួន**ចូលទៅដល់ ក៏ត្រេកអរណាស់ រលះរលាំងនាំខ្លួន**លីប៉ោ**យួរក្បាល**តេងងួន**ចូលទៅគំនាប់**តាំងតុះ**ក្នុងបន្ទាយ។

ឯ**តាំងតុះ**ឃើញ**លីសុក**នាំខ្លួន**លីប៉ោ**ទៅដល់ ក៏មានសេចក្ដីត្រេកអរពន់ប្រមាណ បានដើរចេញពីទីលំនៅទៅគំនាប់ទទួល**លីប៉ោ** ហើយថា ខ្លួនយើងឧបមាដូចធ្វើស្រែបានប្រែដីស្ងួតអស់ហើយ ទទួលភ្លៀងរាំងគោកទឹកអស់ ស្រូវល្វតលាស់

មិនរួច ក៏ក្រៀមស្វិតខូចទៅ អ្នកមករកយើងឥឡូវនេះ ដូចស្រូវបានទឹកភ្លៀងធ្លាក់មកពេញស្រែ ធម្មតាស្រូវតែត្រូវទឹកភ្លៀងហើយ រមែងបែកគុម្ពស្រស់លូតលាស់សន្ធឹកល្អ។ **លីប៉ោ**ឃើញ**តាំងតុះ**លុតជង្គង់ចុះគំនាប់ដូច្នោះ ក៏ភ័យណាស់ស្ទុះទៅឱបលើក**តាំងតុះ**ឲ្យអង្គុយលើកៅអី ហើយក្រាបគំនាប់ជម្រាបថា ខ្លួនខ្ញុំបាទមានមិត្តភក្តិស្រឡាញ់ចង់ចូលមកធ្វើរាជការជាមួយនឹងលោក ដែលលោកមានសេចក្ដីមេត្តាអាណិតខ្ញុំបាទៗក៏ឃើញជាក់ច្បាស់អស់ហើយ។ ខ្ញុំបាទសូមលោកទុកជាបិតាត្រាអស់ជីវិត។ **តាំងតុះ**បានស្ដាប់ក៏ចាប់ចិត្តអាណិតស្រឡាញ់**លីប៉ោ**ណាស់ ទើបយកអាវយ៉ាងល្អ និងក្រឹសមាសមួយប្រដាប់ពេជ្រមកឲ្យ**លីប៉ោ**។

តាំងអំពី**តាំងតុះ**បាន**លីប៉ោ**មកជួយជាកម្លាំងវេលាណា ការរាជការគ្រប់យ៉ាងក៏សម្រេចលើ**តាំងតុះ**ទាំងអស់ ក៏កាន់តែកំរើបចិត្តអាក្រក់ឡើងជាងពីដើម បណ្ដានាហ្មឺនមុខមន្ត្រីតូចធំក៏សឹងកោតខ្លាចអំណាច**តាំងតុះ**ទាំងអស់ ទើបតាំង**តាំងប៊ុន**ជានាយទាហានឆ្វេង តាំង**លីប៉ោ**ជាបុត្រចិញ្ចឹមជានាយទាហានស្ដាំ **តាំងតុះ**ក៏លើកព្យុហៈយោធាចូលមកនៅក្នុងទីក្រុង។

លុះអំណឹះតមក **លីយូ**និយាយនឹង**តាំងតុះ**ថា រាជការក្នុងស្រុកក្រុងសព្វថ្ងៃនេះជាកម្មសិទ្ធិដាច់ខាតលើលោកទាំងអស់ហើយ បើនឹងគិតប្រការម្ដេច សូមឲ្យលោករិះគិតយ៉ាងស្រួតរហ័សចុះ។ **តាំងតុះ**បានស្ដាប់ដូច្នោះក៏ឃើញត្រូវផង លុះពេលព្រឹកភ្លឺស្រាង **តាំងតុះ**ឲ្យ**លីប៉ោ**ឃុំនាំទាហានមួយពាន់ប្លាយ ចូលទៅឡោមព័ទ្ធក្នុងព្រះបរមរាជវាំង ឯ**តាំងតុះ**ក៏ចូលទៅក្នុងទីព្រះរាជរោងរម្យ ជួបជុំសេវកាមាត្យមុខមន្ត្រី **តាំងតុះ**ឲ្យរៀបលៀងភោជនាហារចំណីបរិភោគក្នុងទីព្រះគំនាល់នោះ លុះរៀបចំរួចស្រេច **តាំងតុះ**ក៏កាន់គ្រប៊ីឈរកណ្ដាលទីប្រជុំហើយស្រែកប្រកាសថា **ហង់ជូពៀន**គ្មានសតិបញ្ញាសោះ នឹងបណ្ដោយឲ្យសោយរាជ្យតទៅមិនបាន យើង

ត្រូវដកហូតចេញ ហើយតាំង**ហង់ជូហៀប**ជាព្រះអនុជឲ្យឡើងសោយរាជសម្បត្តិជាថ្មី ព្រោះមានសេចក្ដីផ្ទៀវផ្លាតវាងវៃ បើអ្នកឯណាមិនចុះចិត្តយល់ព្រមតាមយើងទេ យើងនឹងសម្លាប់ចេញឥឡូវនេះ។ នាហ្មឺនទាំងអស់ក៏នៅអង្គុយតែស្ងៀម។

នៅក្នុងទីប្រជុំនោះមានមន្ត្រីម្នាក់ឈ្មោះ**អ្វូនសៀវ** ក្រោកឈរឡើងស្រែកតបទៅថា **ហង់ជូពៀន**ជាព្រះរាជបុត្រឯក ព្រះចៅ**ឡេនតេ**ជាព្រះវររាជបិតាបានលើករាជសម្បត្តិឲ្យ**ហង់ជូពៀន**ជាស្រេចដាច់ខាតហើយ វេលានេះក៏ព្រះអង្គពុំមានសេចក្ដីខុសអ្វី ហេតុម្ដេចក៏ខ្លួនអាចហ៊ានចេញសម្ដីថានឹងដកហូតចេញ ហើយលើក**ហង់ជូហៀប**ជាព្រះរាជបុត្រទីពីរឲ្យសោយរាជសម្បត្តិវិញ ឬខ្លួនមានប្រាថ្នានឹងគិតក្បត់ផែនដី? **តាំងតុះ**ឮដូច្នោះខឹងណាស់ឆ្លើយថា រាជសម្បត្តិសព្វថ្ងៃនេះនៅក្នុងកណ្ដាប់ដៃយើងអស់ហើយ យើងយល់ថាមិនត្រូវ ទើបធ្វើឲ្យត្រូវឡើងវិញ បើខ្លួនរឹងទទឹងមិនស្ដាប់យើង ចូរក្រឡេកមើលមុខគ្រប៊ីដែលយើងកាន់នេះមុតឬទេ? **អ៊្វូនសៀវ**តបថា យើងក៏មានគ្រប៊ីកាន់ដូចខ្លួនដែរ បើខ្លួនមិនស្ដាប់ហ៊ានតាំង**ហង់ជូហៀប**ឲ្យខុសពីសណ្ដាប់បុរាណរាជប្រវេណី ចូរក្រឡេកមើលមុខគ្រប៊ីដែលយើងកាន់នៅដៃនេះ នឹងមុត ឬមិនមុតសោត? **តាំងតុះ**ក្រេវក្រោធទន់កម្លាំង តាំងតែហូតគ្រប៊ីគិតនឹងស្ទុះទៅកាប់**អ្វូនសៀវ**។ **លីយូ**ឃើញដូច្នោះស្ទុះចូលទៅឃាត់ហើយខ្សឹបថា យើងប្រុងនឹងគិតការធំប្លែកៗ បើមកឈ្លោះជជែកដល់ចាក់កាប់គ្នាដូច្នេះ ការដែលគិតនោះនឹងមិនបង់អសារទេឬ? **តាំងតុះ**ស្ដាប់**លីយូ**ឃាត់ក៏បាត់មាត់និយាយ ឯ**អ្វូនសៀវ**ក៏លាបណ្ដានាហ្មឺនតូចធំទាំងឡាយកាន់គ្រប៊ីដើរចេញទៅ ហើយនាំពួកពលទាហានលើកចេញទៅនៅក្រុងគីជីវ។

ចំណែក**តាំងតុះ**និយាយនឹង**អ្វូនងុយ**ជាមាថា **អ្វូនសៀវ**នេះអង់អាចរឹងទទឹងនឹងយើងណាស់ នេះជួនជាយើងបានគិតដល់មា បើកុំមានមាមកនៅក្នុងទីនេះផង

យើងនឹងសម្លាប់ចេញមួយរំពេចដែរ យើងគិតការទាំងអម្បាលនេះតើយល់ថាខុសឬត្រូវម្តេចខ្លះ? **អ្នួនងុយ**ឆ្លើយថា ដែលលោកជាធំគិតនឹងគ្រឡប់ផែនដីចេញនោះត្រូវហើយ។ **តាំងតុះ**ថាបណ្ដានាហ្មឺនមុខមន្ត្រីតូចធំទាំងពួង បើនរណារឹងទទឹងនឹងយើងដូចយ៉ាង**អ្នួនសៀវ**ហើយ យើងនឹងសម្លាប់ចេញឥឡូវនេះ។ នាហ្មឺងទាំងអស់ឮដូច្នោះក៏កោតខ្លាច**តាំងតុះ**ទើបជម្រាបថា លោកគិតការដូច្នេះ ខ្ញុំបាទក៏យល់ឃើញដូចលោកទាំងអស់គ្នា លុះបរិភោគអាហារហើយ ក៏លាទៅកាន់ទីលំនៅរៀងខ្លួន។

ឯ**តាំងតុះ**នៅក្នុងទីគាល់នោះ លុះនាហ្មឺនទាំងពួងចេញទៅអស់ហើយ ក៏សួរ**ចៀវពី** និង**ង៉ោខេង**ថា **អ្នួនសៀវ**លើកពលទៅនៅស្រុកគីជីវនោះ ប្រហែលជានឹងគិតការយ៉ាងណាខ្លះ? **ចៀវពី**ឆ្លើយថា **អ្នួនសៀវ**ទៅគ្រានេះដោយអំណាចកំហឹងប្រហែលនឹងគិតជាធំពុំខាន។ មួយទៀត សែអ្នួននោះតែងបានជានាហ្មឺនតៗគ្នាមកចំនួនបួនជួរមនុស្ស ហើយអាណាប្រជានុរាស្ត្រគ្រប់ខេត្តខណ្ឌ សឹងប្រកាន់ទាហាន**អ្នួនសៀវ**ជាច្រើន ចិត្ត**អ្នួនសៀវ**ក៏មានមានះណាស់ មុខជានឹងគិតបញ្ចុះបញ្ចូលអ្នកស្រុក ហើយតាំងខ្លួនជាធំនៅក្នុងតំបន់ណាមួយមិនខាន ប្រហែលជាលោកនឹងបង្ក្រាបមិនបានទេ បើដូច្នេះ សុំឲ្យលោកមានសំបុត្រព្រះតម្រាស់ចេញទៅតាំង**អ្នួនសៀវ**ជាចៅហ្វាយខេត្តមួយ នោះប្រហែល**អ្នួនសៀវ**នឹងនៅជាប្រក្រតីវិញ។

**ង៉ោខេង**ឆ្លើយថា **អ្នួនសៀវ**នោះជាមនុស្សមានគំនិតណាស់ តែថានឹងគិតការអ្វីមិនសូវផ្តេះផ្តាយទេ បើលោកមានសំបុត្រព្រះតម្រាស់ទៅតាំងជាចៅហ្វាយស្រុកហើយ បីដូចយើងចងចិត្តរាស្ត្រទុក **អ្នួនសៀវ**នោះក៏នឹងអស់ចិត្តឥតគរហានិទ្ទាដល់លោកផង។ **តាំងតុះ**ស្តាប់ឃើញត្រូវក៏ទៅតែងសំបុត្រជាព្រះតម្រាស់ ហើយចាត់ប្រើទាហានឲ្យកាន់ទៅប្រគល់ដល់**អ្នួនសៀវ** តាំង**អ្នួនសៀវ**ជាចៅហ្វាយស្រុកពុតហៃបណ្ដានាហ្មឺនតូចធំក៏នៅក្នុងបង្គាប់បញ្ជា**តាំងតុះ**ទាំងអស់។

លុះនៅយូរមក **តាំងតុះ**ឲ្យអញ្ជើញ**ហង់ជូពៀន**ចេញមកកាន់ទីព្រះគំនាល់ ឈ្មោះព្រះទីនាំងកែដិកទៀន ហើយឲ្យប្រជុំនាហ្មឺនមុខមន្ត្រីតូចធំជួបជុំក្នុងទីនោះ **តាំងតុះ**ក៏កាន់គ្របីឈរប្រកាសថា សព្វថ្ងៃនេះ អាជ្ញាសិទ្ធិនៅលើដៃយើងហើយ ហើយឃើញថា**ហង់ជូពៀន**មានសតិបញ្ញាតិច មិនគួរស្ថិតនៅក្នុងរាជសម្បត្តិបានសោះ យើងពិគ្រោះនឹង**ហង់ជូហៀប**មានសតិបញ្ញាវាងវៃគួរនឹងគ្រងផែនដី ជាព្រះមហាក្សត្រសោយរាជសម្បត្តិទៅ បណ្ដានាហ្មឺនទាំងពួងក៏គ្មាននរណានឹងឆ្លើយទាស់ថាប្រការម្ដេច ទើប**តាំងតុះ**បង្គាប់ឲ្យពួកខន្ទីព**ហង់ជូពៀន**ចេញចាកទីព្រះគំនាល់ ហើយដកហូតយកត្រាសម្រាប់រាជសម្បត្តិ ដែលចងនឹងព្រះសូរង**ហង់ជូពៀន**នោះចេញ ហើយឲ្យ**ហង់ជូពៀន**គាល់តាមតំណែងព្រះរាជបុត្រនៃអម្ចាស់ផែនដី ហើយបង្គាប់ឲ្យយកខ្លួនព្រះនាង**ហូហៅ** មកដកហូតគ្រឿងប្រដាប់សម្រាប់តំណែងយសព្រះវររាជជននីនោះចេញទាំងអស់ វេលានោះព្រះនាង**ហូហៅ** និង**ហង់ជូពៀន**ក៏មានសេចក្ដីបរិវេទនាការ ទ្រង់ព្រះកន្សែងសោកាទាំងពីរអង្គ បណ្ដានាហ្មឺនតូចធំដែលជួបជុំនៅទីនោះទាំងប៉ុន្មាន លុះបានឃើញដូច្នោះក៏ខ្សឹកខ្សួលក្ដួលចិត្តអាណិតជាទុក្ខស្រក់ទឹកភ្នែកទាំងអស់គ្នា។

**តេងគួន**ជានាហ្មឺនសុចរិតបានពិនិត្យឃើញដូច្នោះ ក៏ទោមនស្សក្ដៅចិត្តណាស់ក្រោកឈរឡើងស្រែកថា **អាតាំងតុះ**នេះជាសត្រូវរាជសម្បត្តិ វាគិតកម្ចាត់ដកហូតស្ដេចជាអម្ចាស់ផែនដីតាមអំពើចិត្តវា ថាហើយក៏កាន់គ្របីស្ទុះម្នីម្នាទៅនឹងកាប់**តាំងតុះ** ៗឃើញដូច្នោះ មានបញ្ជាឲ្យពេជ្ឈឃាដព្រួតចាប់យកខ្លួន**តេងគួន**ទៅសម្លាប់ ឯពួកពេជ្ឈឃាដក៏ព្រួតចាប់ខ្លួន**តេងគួន**បាន។ **តេងគួន**មិនមានភ័យភិតតក់ស្លុតរន្ធត់ខ្លាចស្លាប់សោះ ថែមទាំងស្រែកជេរទ្រគោះជាពាក្យត្អះតិះដៀល**តាំងតុះ** ទាល់តែពេជ្ឈឃាដនាំទៅដល់ទីកន្លែងពិឃាដសូន្យជីវិតទើបបាត់មាត់។

**តាំងតុះ**ឲ្យអញ្ជើញ**ហង់ជូហៀប**ឡើងគង់លើរតនបល្ល័ង្ក ក្រោមព្រះមហាស្វេតច្ឆត្រជួបជុំរាជបរិស័ទសេវកាមាត្យមុខមន្ត្រីសេដ្ឋីគហបតីរាជបរិវារ សឹងតែក្រាបថ្វាយបង្គំរាល់គ្នាឲ្យឧឡារិកគឹកកងក្នុងទីព្រះរាជរោងរម្យ ស្រេចហើយឲ្យយក**ហង់ជូពៀន** និងព្រះនាង**ហូហៅ**ជាមាតា ព្រមទាំងនាងស្នំក្រមការ**ហង់ជូពៀន** ទៅបង្ខាំងទុកក្នុងទីសំណាក់ចាក់សោមិនឲ្យចេញទៅណាបាន ហាមប្រាមពួកនាហ្មឺនខ្ញុំរាជការមិនឲ្យនរណាទៅមកសួនាំសោះ វេលានោះនាហ្មឺនមុខមន្ត្រីនូវអស់អាណាប្រជានុរាស្ត្រទាសករបណ្តាដែលមានទាំងប៉ុន្មាន សឹងមានសេចក្តីសៅសោកអាណិតអានាថនៃ**ហង់ជូពៀន** និងព្រះនាង**ហូហៅ**ពន់ពេកណាស់ កាលដែល**តាំងតុះ**តាំង**ហង់ជូហៀប**ឲ្យឡើងសោយរាជ្យសម្បត្តិនោះ ព្រះជន្មវស្សាបានប្រាំបួនឆ្នាំគត់ (ព.ស ៧៣៣) ថ្វាយព្រះនាមហៅថាព្រះចៅ**ហៀនតេ**។

ចំណែក**តាំងតុះ**ក៏តាំងខ្លួនជា “ស៊ាងកុក” ភាសាខ្មែរហៅថាស្តេចមហាឧបរាជ អាចកាន់ព្រះសែងគ្រប៊ីចូលគាល់រាល់វេលាបានតាមចិត្តប្រាថ្នា និងចេញចូលបានដរាប ឯអាជ្ញាសិទ្ធិឫទ្ធានុភាពនៃ**តាំងតុះ**នោះក៏កាន់តែកំរើបក្លាហានមានជាងពីដើម បណ្តាសេនាទាហាននិងបក្សពួកទាំងប៉ុន្មាន ក៏សឹងតែធ្វើការអាក្រក់ដើរឆក់ដណ្តើមទ្រព្យរបស់អស់អាណាប្រជានុរាស្ត្របានសេចក្តីក្តៅក្រហាយណាស់។

ឯ**ចូឆ្វ**ក៏បានចូលទៅធ្វើខ្លួនឲ្យ**តាំងតុះ**ប្រើប្រាស់ក្នុងកិច្ចការរាជការ **លីយូ**ជាទីប្រឹក្សាក៏បាននិយាយនឹង**តាំងតុះ**ថា សព្វថ្ងៃនេះរាជការផែនដីក៏ចូលមកនៅក្នុងកណ្តាប់ដៃនៃលោកទាំងអស់ហើយ សុំកុំឲ្យលោកសម្តែងអំណាចឲ្យនាហ្មឺន និងរាស្ត្របានសេចក្តីស្អប់ខ្ពាញ់ ចូរលោកផ្សាយបន្ទន់ចិត្តអាណិតស្រឡាញ់អាណាប្រជានុរាស្ត្រ ឲ្យបាននៅជាសុខក្សេមក្សាន្ត លោកក៏នឹងបានចម្រើននូវឥស្សរិយយសខ្ពស់ធំឡើងទៀត។ ប្រការមួយទៀត មានមនុស្សម្នាក់នៅខេត្តក្រៅឈ្មោះ **សួយ៉ុង** មាន

សតិបញ្ញាល្អណាស់ សុំឲ្យលោកយកខ្លួន**ស្ងួយ៉ុង**នោះមកទំនុកបម្រុង តាំងឲ្យមានយសស័ក្តិជានាហ្មឺនក្នុងក្រុង លោកក៏នឹងមានកម្លាំងធ្វើការរាជការចម្រើនឡើងទៀត។ **តាំងតុះ**យល់ព្រមក៏ប្រើបម្រើឲ្យទៅហៅ**ស្ងួយ៉ុង**ៗធ្វើព្រងើយកន្តើយមិនបានចូលមក **តាំងតុះ**ក៏ចាត់បម្រើឲ្យទៅហៅម្តងទៀត ហើយឲ្យប្រាប់ថា បើ**ស្ងួយ៉ុង**រឹងទទឹងមិនចូលមកទេ នឹងឲ្យទាហានទៅចាប់សម្លាប់ចោលឲ្យអស់ទាំងគោត្រ។ **ស្ងួយ៉ុង**បារម្ភខ្លាចមិនអាចនឹងនៅបាន ក៏រៀបខ្លួនប្រាណចូលមកដល់**តាំងតុះ** ៗក៏តាំង**ស្ងួយ៉ុង**បានឡើងទីជាមន្ត្រីមានយសស័ក្តិ **តាំងតុះ**ទុកចិត្តជឿយកជាទីប្រឹក្សាលើការរាជការទាំងពួង។

ឯ**ហង់ជូពៀន** និងព្រះនាង**ហ្វូហៅ** នូវពួកព្រះស្នំដែល**តាំងតុះ**ឲ្យឃុំខ្លួនទុកនោះ ក៏មានសេចក្តីវេទនាសោកាមានខ្លួននោះស្គមស្គាំងទ្រមដោយទុក្ខខ្លាំងណាស់។ ថ្ងៃមួយមានសត្វសារិកាហើរចូលមកក្នុងដំណាក់ទាំងគូ **ហង់ជូពៀន**ទតឃើញក៏ចងជាឃ្លោងព្យួរទុកនៅជញ្ជាំងប្របបង្អួចដំណាក់មានសេចក្តីថា៖

| | |
|---|---|
| ឱទីរាជឋានវិមានស្អាត | គឺប្រាង្គប្រាសាទមហាក្សត្រា |
| ព្រះចៅ**ឡេនតេ**ជាបិតា | ករុណាប្រោសប្រាណប្រទានឲ្យ ។ |
| យើងជារាជបុត្រម្កុដកុមារ | គ្រប់គ្រងរដ្ឋតទៅក្រោយ |
| ឥឡូវយើងមកសោកសុបសោយ | ព្រមដោយព្រះវររាជមាតា ។ |
| ព្រោះគេឃាំងឃាត់បំបាក់មុខ | ធ្វើទោសដាក់គុកក្នុងប្រាង្គប្រា- |
| សាទសមដូចសត្វសេកសារិកា | ខ្លោចផ្សាក្នុងទ្រូងស្តុងវិញ្ញាណ ។ |
| ឱអ្នករាជការនាហ្មឺនមុខ | តពីអាពុកយើងមែនមាន |
| ចិត្តសត្យសុចរិតគួរគិតផ្សាន | ជួយយើងឲ្យបានរួចទុក្ខា ។ |
| ដ្បិតក្នុងទ្រូងយើងដូចភ្លើងឆេះ | ឈ្ងួលឈឹផ្ទុរប្រេះព្រួតផ្សព្វផ្សា |
| បើបានសងសឹកស្រេចកាលណា | យើងមហាអរគុណធ្ងន់អនេក ។ |

ចំណែក**តាំងតុះ**តែងប្រើបម្រើទៅស៊ើបស្ដាប់ការនៅទីព្រះរាជដំណាក់ ដែលបង្ខាំង**ហាង់ជូពៀន**នោះជារឿយៗ ដើម្បីឲ្យដឹងថាគំនិត**ហាង់ជូពៀន**នោះនឹងគិតដូចម្ដេចខ្លះ? លុះបម្រើទៅមើលឃើញពាក្យឃ្លោងចងនៅបង្អួច ក៏លួចស្រាចយកទៅបង្ហាញ**តាំងតុះ**ៗបានមើលដឹងសេចក្ដីក៏ខឹងណាស់ថា **ហាង់ជូពៀន**ធ្វើពាក្យឃ្លោងនេះទុកប្រាថ្នានឹងចង់រកមនុស្សទំនុកចិត្តមកធ្វើសងសឹកយើងវិញ ឥឡូវបើយើងនឹងសម្លាប់ចេញក៏មិនមានអ្នកណានឹងគរហានិន្ទាថាយើងអាក្រក់។ គិតហើយ**តាំងតុះ**ក៏បង្គាប់**លីយូ**ឲ្យពេជ្ឈឃាដដប់នាក់ទៅសម្លាប់**ហាង់ជូពៀន** និងព្រះនាង**ហូហៅ**នូវពួកព្រះស្នំទាំងអស់ចេញ។ **លីយូ**នោះមិញក៏ទទួលបង្គាប់នាំពេជ្ឈឃាដទាំងដប់នាក់ទៅបើកទ្វារដំណាក់ ហើយចូលទៅ។ ពួកស្នំក្រឡេកឃើញក៏ចូលទៅទូល**ហាង់ជូពៀន**ៗក៏ស្លុតព្រះទ័យភ័យណាស់ **លីយូ**ចូលទៅដល់ ក៏ឈរហុចពែងស្រាដាក់ថ្នាំបំពុលឲ្យ**ហាង់ជូពៀន**សោយ។ **ហាង់ជូពៀន**សួរថាអ្វី? **លីយូ**តបថា មហាឧបរាជយល់ឃើញថា ឥឡូវនេះស្រុកទេសជាសុខរាបទាបហើយ ទើបឲ្យទូលព្រះបង្គំយកស្រានេះមកថ្វាយឲ្យទ្រង់សោយ។

ព្រះនាង**ហូហៅ**បានឮដូច្នោះ ក៏ងឿងឆ្ងល់ក្នុងព្រះទ័យណាស់ ទើបត្រាស់សួរទៅថា **តាំងតុះ**ឲ្យយកស្រាមកថ្វាយព្រះរាជបុត្រយើងសោយនោះ យើងក៏មានសេចក្ដីត្រេកអរ និងអរគុណលោកណាស់ តែថាត្រូវខ្លួនអ្នកដែលកាន់ស្រាមកនេះផឹកមុនឲ្យយើងឃើញសិន សឹមយើងឲ្យព្រះរាជបុត្រយើងសោយខាងក្រោយ។ **លីយូ**ឮពាក្យដូច្នោះក៏ខឹងណាស់ស្រែកហៅពេជ្ឈឃាដឲ្យយកគ្រប៊ី និងសោច្រវាក់មកបោះទម្លាក់ទុកចំពោះមុខហើយថា មហាឧបរាជឲ្យយកស្រាមកថ្វាយឲ្យសោយ បើព្រះនាង**ហូហៅ**រឹងទទឹងមិនព្រមឲ្យសោយទេ ត្រូវទទួលយករបស់ពីរនេះវិញ នឹងយកច្រវាក់ ឬគ្រប៊ី? បណ្ដាពួកស្រីស្នំក៏ប្រណាម្យដៃលុតជង្គង់ចុះទាំងអស់គ្នា

ហើយនិយាយនឹង**លីយូ**ថា លោកនឹងឲ្យ**ហង់ជូពៀន**សោយស្រានោះ យើងខ្ញុំទាំងអស់គ្នាទទួលផឹកជំនួសចុះ យើងខ្ញុំសូមតែជីវិតព្រះនាង**ហូហៅ** និង**ហង់ជូពៀន**ឲ្យគង់ព្រះជន្មតទៅ។ **លីយូ**ស្រែកគំហកថា មិនគួរឯងរាល់គ្នានឹងមកទទួលស្លាប់ជួសនោះទេ! ហើយ**លីយូ**ក៏យកពែងស្រាហុចឲ្យព្រះនាង**ហូហៅ**ផឹកមុន ព្រះនាងមិនព្រមទទួលសោយសោះក៏មានបន្ទូលទ្រគោះរំឭកថា ព្រោះតែ**ហូជិន**ជាបងអញវាពេញជាមនុស្សគិតខុស នាំឲ្យពួកអាចោរទុរយសចូលមកក្នុងព្រះរាជឋាន អន្តរាយទើបមានដល់ខ្លួនអញនិងព្រះរាជបុត្រក្នុងគ្រានេះ។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៤

**ចារឹកឡើងវិញដោយ ៖ ឈុល ដាវ៉**

*(តាំងពី**លីយូ**ធ្វើគតព្រះបាទ**ហាង់ជូពៀន** និងព្រះនាង**ហូហៅ** នូវស្រីស្នំដោយថ្នាំបំពុលលាយនឹងស្រា។ លុះដល់**អួនសៀវ**ជាមេទ័ព ប្រើ**គួនអ៊ូ**ទៅច្បាំងនឹង**ហូយ៉ុង**)*

ឯ**លីយូ**នៅឈរតឿនព្រះបាទ**ហាង់ជូពៀន**ថា ទ្រង់នឹងយកគ្រប៊ីឬច្រវាក់ ក៏ត្រូវយកឲ្យឆាប់ប្រញាប់ទៅ។ ព្រះបាទ**ហាង់ជូពៀន**ឆ្លើយថា ខ្លួនយើងនិងព្រះវរមាតាត្រូវស្លាប់ជាមួយគ្នាក្នុងថ្ងៃនេះ យើងក៏បានដឹងច្បាស់លាស់ណាស់ហើយ ប៉ុន្តែសុំបង្អង់ឲ្យយើងទូលលាព្រះវរមាតាយើងសិនចុះ ទ្រង់មានព្រះបន្ទូលតែប៉ុណ្ណោះក៏ទ្រង់ចូលទៅឱបព្រះបាទាព្រះវរមាតា ហើយក៏ទ្រង់ព្រះកន្សែងថ្លែងពិលាបសោកាទាំងពីរព្រះអង្គ នៅក្នុងព្រះដំណាក់មុខគួរឲ្យអនិច្ចា។ **លីយូ**ស្រែកថា ដែលនឹងស្ងៀមព្រងើយនៅដូច្នោះគ្មាននរណានឹងជួយឲ្យរួចជីវិតទេ បើផ្ដែផ្ដាំគ្នាយ៉ាងណាក៏ផ្ដាំឆាប់ៗទៅ មហាឧបរាជនៅចាំយើងឯណោះ ព្រះនាង**ហូហៅ**ឆ្លើយថា **អាតាំងតុះ**វាជាមេចោរក្បត់ផែនដី ដែលវាឲ្យធ្វើអន្តរាយយើងក្នុងថ្ងៃនេះ ទោះបីខ្លួនអញម្ដាយនិងកូនដល់នូវសេចក្ដីស្លាប់ចំពោះមុខទេវតានិងមនុស្ស ក៏អញមិនមែនកោតសរសើរវាដែរ ទាំង**អាលីយូ**សោតក៏វាជាពួកក្បត់ដូចគ្នា វាក៏មិនមានសេចក្ដីចម្រើនប៉ុន្មានយូរទៅគង់មានគេសម្លាប់វាវិញជាប្រាកដ។ **លីយូ**បានឮដូច្នោះ ក៏ឈឺចិត្តណាស់ ស្ទុះទៅអូសកន្ត្រាក់ព្រះនាង**ហូហៅ**ដៃម្ខាង ដៃម្ខាងទៀតហូតកន្ត្រាក់នាងស្នំទាញចេញទៅក្រៅថ្នា ហើយឲ្យពេជ្ឈឃាដចងរឹតព្រះនាង**ហូហៅ**នូវស្រីព្រះស្នំទាល់តែស្លាប់

ហើយ**លីយូ**ក៏ត្រឡប់ចូលទៅចាប់ព្រះបាទ**ហង់ជូពៀន** ហើយចាប់បញ្ចូកចូលទៅក្នុងបំពង់ក ក៏ទ្រង់ទិវង្គតក្នុងទីនោះ។ ស្រេចហើយទើប**លីយូ**បង្គាប់ឲ្យនាំព្រះសពនោះទៅកប់ចោលក្រៅក្រុងទាំងអស់។ **លីយូ**ក៏វិលត្រឡប់មកជម្រាប**តាំងតុះ**ៗមានសេចក្ដីត្រេកអរណាស់ក្នុងខណៈនោះ **តាំងតុះ**មានសេចក្ដីកំរើបចិត្តគិតធ្វើអាក្រក់ផ្សេងៗ មិនមានរអែងក្រែងខ្លាចអំណាចអ្នកឯណា ជួនកាលពេលយប់ ក៏ចូលទៅដេកលើព្រះទែនដែលព្រះចៅ**ឡេនតេ**ទ្រង់ផ្ទំ ហើយលបលួចព្រះស្នំស្រីង្គាររួមបវេណីជាទីត្រេកត្រអាល។

អំណឹះតមក **តាំងតុះ**ក៏លើកព្យុហៈទ័ពចេញទៅស្រុកយ៉ុងសៀ ហើយឲ្យទាហានព័ទ្ធកំពែង ចូលទៅក្នុងស្រុករើជញ្ជូនយករបស់ទ្រព្យ ហើយសម្លាប់ម្ចាស់ផ្ទះប្រុសៗចេញជាច្រើន ចាប់យកស្រីៗមកទុកជាឈ្លើយ ហើយឲ្យកាត់យកក្បាលមនុស្សស្លាប់នោះផ្ទុកដឹកនឹងរទេះត្រឡប់ចូលទីក្រុង ហើយឲ្យស្រែកអាក្រោសតាមផ្លូវផ្សារថា យើងលើកទ័ពទៅចាប់ពួកអាចោរកំណាចបាន កាត់ក្បាលយកមកជាច្រើនណាស់ លុះធ្វើដូច្នេះហើយក៏ឲ្យយកទៅគរដុតចោលទាំងអស់ ឯទ្រព្យរបស់ដែលរឹបយកបាននោះ ហើយនឹងស្រីៗនោះក៏ចែករំលែកគ្នាជាសម្រាប់ទាហានទាំងពួង។

ឯ**ង៉ៅហ៊្វូ**ជាទីមន្ត្រីធំ លុះឃើញ**តាំងតុះ**ប្រព្រឹត្តសេចក្ដីអាក្រក់ខ្លាំង ក៏តាំងតែមានចិត្តនោះក្តួលក្តៅណាស់ គិតនឹងសម្លាប់**តាំងតុះ**មិនលោះមួយវេលា លុះកន្លងមកថ្ងៃមួយនោះ **ង៉ៅហ៊្វូ**យកកាំបិតសៀតបង្កប់ក្នុងអាវ ហើយចូលទៅកាន់ទីគាល់ទទួលពេលនោះ**តាំងតុះ**ចេញមកដល់ទ្វាររាំង **ង៉ៅហ៊្វូ**ដកកាំបិតបង្កប់ចេញនឹងចាក់**តាំងតុះ** ៗក្រឡេកឃើញទាន់ការពារបាន **លីប៉ោ**ក៏ស្ទុះចូលទៅជួយចាប់**ង៉ៅហ៊្វូ**ជាប់ហើយថា ហេតុម្ដេចទើបខ្លួនមកគិតធ្វើគំនិតអាក្រក់ ចាក់មហាឧបរាជបិតាយើង

ដូច្នេះ? **ង៉ៅហ៊្វ**មិនខ្លាចសេចក្តីស្លាប់ប្រាប់ថា **តាំងតុះ**ធ្វើអាក្រក់ណាស់ អញមានបំណងនឹងកាត់យកក្បាលផ្តាលឲ្យទេវតា និងមនុស្សឃើញជាក់ច្បាស់ក្នុងលោកិយ។ **តាំងតុះ**បានឮសម្តីក៏រឹតតែខឹងពន់ប្រមាណ បានបង្គាប់ពេជ្ឈឃាដឲ្យនាំខ្លួន**ង៉ៅហ៊្វ**ទៅអារពន្លះសាច់ផ្តាច់ជីវិត។ ពេជ្ឈឃាដក៏ស្ទុះចូលចាប់យកខ្លួន**ង៉ៅហ៊្វ**ៗមិនមានតក់ស្លុតរំជួលខ្លាច ស្រែកជេរ**តាំងតុះ**ទាល់តែពេជ្ឈឃាដកាប់ដាច់ខ្យល់ស្លាប់។ តាំងពីនោះមក **តាំងតុះ**ឲ្យទាហានវេនរក្សាព្រះបរមរាជវាំងយ៉ាងមាំមួនជាងពីដើម។

ឯ**អ្នួនសៀវ**ដែលជាទីចៅហ្វាយស្រុកពុតហៃ បានឮល្បីកិត្តិស័ព្ទថា **តាំងតុះ**ធ្វើការអាក្រក់សម្លាប់ព្រះនាង**ហូហៅ** នូវព្រះបាទ**ហង់ជូពៀន** ជាម្ចាស់ផែនដីក្ស័យព្រះជន្មដូច្នោះ ក៏តែងសំបុត្រជាសម្ងាត់ទៅដល់**អងអ៊ុន**ដែលជានាហ្មឺននៅក្នុងក្រុង ក្នុងសេចក្តីសំបុត្រនោះថា សព្វថ្ងៃនេះ**តាំងតុះ**កំរើបចិត្តគិតការក្បត់ផែនដី នឹងរកនាហ្មឺនមុខមន្ត្រីណាមានប្រាជ្ញាឆ្លៀវឆ្លាតគិតសង្វាតរំលាងបំផ្លាញ**តាំងតុះ**ចេញគ្មាន ដែលយើងចេញទៅនៅខេត្តក្រៅគ្រានេះ នឹងបានដេកធ្មេចមិនគិតក៏ទេ គឺខំឧស្សាហ៍បញ្ចុះបញ្ចូលសេនាទាហាន និងប្រៀនបង្គាប់ឲ្យស្ទាញស្ទាត់ក្នុងការសង្គ្រាមមិនលោះមួយវេលា ព្រោះជាសេចក្តីកតញ្ញូនឹងផែនដី ដើម្បីយកអាសាកម្ចាត់**តាំងតុះ**ជាសត្រូវរាជសម្បត្តិនោះចេញ បើអ្នកណាយល់ត្រូវតាមគំនិតចិត្តយើងហើយ កុំគប្បីព្រងើយកន្តើយគិតការខាងក្នុងឲ្យមាំមួនចុះ យើងនឹងលើកកងទ័ពចូលមកធ្វើការឲ្យបានសម្រេចដោយងាយ។

**អងអ៊ុន**បានយល់ក្នុងសេចក្តីសំបុត្រនោះគ្រប់ប្រការ ក៏មានសេចក្តីវិតក្កវិចារមិនមានភ្លេចសោះ ។ លុះកន្លងមកថ្ងៃមួយ ជាពេលចេញចាកទីគាល់ **អងអ៊ុន**ក៏រង់ចាំនិយាយនឹងនាហ្មឺនចាស់ទុំទាំងពួងថា ថ្ងៃនេះត្រូវការនឹងអញ្ជើញអស់លោកទៅពិសាក្រយានៅឯផ្ទះខ្ញុំជាកម្សាន្តសប្បាយ បណ្តានាហ្មឺនទាំងឡាយក៏ស្រុះស្រួល

បបួលគ្នាទៅស៊ីលៀងលើផ្ទះ**អងអ៊ុន** កាលដែលប្រជុំព្រមគ្នានឹងបរិភោគអាហារនោះ **អងអ៊ុន**ក៏អង្គុយយំជាទុក្ខខ្សឹកខ្សួល។ នាហ្មឺនទាំងពួងក៏ផ្អើលជ្រួលទៅសួរថា លោកយំសោកជាទុក្ខព្រោះអ្វី? **អងអ៊ុន**ឆ្លើយថា **តាំងតុះ**ចូលមកនៅក្នុងស្រុកក្រុងធ្វើការទុច្ចរិត សម្លាប់ព្រះនាង**ហ្វូហៅ** នូវព្រះបាទ**ហង់ជូពៀន**ក្ស័យព្រះជន្មា ខ្ញុំមានសេចក្ដីក្ដៅចិត្តណាស់ ឧបមាដូចជាដេកលើគំនរភ្លើង ខ្ញុំសម្លឹងទៅមិនឃើញអ្នកឯណា នឹងជួយគិតទំនុកបម្រុងផែនដីឲ្យបានសេចក្ដីសុខសោះ ខ្ញុំគិតឃើញដូច្នោះទើបយំជាទុក្ខ។ នាហ្មឺនទាំងពួងបានស្ដាប់ ក៏មានសេចក្ដីសង្វេគស្រក់ទឹកភ្នែកយំសោកទាំងអស់គ្នា។

មានតែ**ចូឆ្វ**ម្នាក់ ក្រោកឡើងឈរទះដៃសើចហើយថា ចោលម្សៀតអស់លោកនាហ្មឺនចាស់ទុំប្រជុំគិតការប៉ុណ្ណេះមិនផ្ទុះធ្លាយ ហើយមកបបួលគ្នាអង្គុយយំ។ **អងអ៊ុន**ខឹងណាស់និយាយតបទៅ**ចូឆ្វ**ថា ជីតានិងបិតារបស់អ្នកឯងក៏ជានាហ្មឺនបានស៊ីប្រាក់បៀវត្សមកពីដើមដែរ ម្ដេចអ្នកឯងមិនមានកតញ្ញូនឹងផែនដី? យើងគិតការនឹងបំផ្លាញរំលាង**តាំងតុះ**ចេញ តែថា **តាំងតុះ**មានសេនាទាហានខ្លាំងពូកែច្រើនណាស់ យើងជម្រះមិនផ្ទុះធ្លាយទើបឈឺចិត្តអង្គុយយំដូច្នេះ ហេតុអ្វីអ្នកឯងមកក្លែងទះដៃសើចចំអកឡកឲ្យយើងដូច្នេះ? **ចូឆ្វ**ឆ្លើយថា អស់លោកចាស់ទុំសុទ្ធតែជានាហ្មឺនតមកពីផែនដីមុន មានចិត្តគិតនឹងទំនុកបម្រុងផែនដីជាប្រាកដ ហេតុម្ដេចក៏គិតនឹងកម្ចាត់**តាំងតុះ**ប៉ុណ្ណេះមិនបាន? នាំគ្នាអង្គុយយំ ខ្ញុំឃើញដូច្នេះបានជាអស់សំណើច។ ឯជីតា និងបិតារបស់ខ្ញុំជាខ្ញុំរាជការមកពីដើមនោះ ខ្ញុំក៏គិតកតញ្ញូដល់ផែនដីជាដរាប ប៉ុន្តែ**តាំងតុះ**នោះបើខ្ញុំនឹងគិតសម្លាប់ចេញវេលាណាក៏បាន។

**អងអ៊ុន**ថា អ្នកឯងនិយាយដូច្នេះ យើងមិនទាន់យល់ឃើញផងទេដែលនឹងគិតសម្លាប់**តាំងតុះ**នោះ ត្រូវគិតយ៉ាងម្ដេចចូរអធិប្បាយឲ្យយើងស្ដាប់សិនមើល។

**ចូឆ្វូ**ឆ្លើយថា ខ្ញុំត្រូវធ្វើសេចក្តីព្យាយាមចូលទៅផ្ញើខ្លួនឲ្យ**តាំងតុះ**ប្រើប្រាស់ទាល់តែស្និទ្ធទុកចិត្តប្រាកដ មិនមែនឃើញដោយលាភសក្ការៈអ្វីៗ ព្រោះគិតកតញ្ញូដល់ផែនដីប្រាថ្នានឹងសម្លាប់**តាំងតុះ**ឲ្យបាន តែថានៅទាល់ព្រោះគ្មានអាវុធកាន់កំដរដៃ ខ្ញុំដឹងថាគ្រប៊ីខ្លីរបស់លោកមាន បើលោកឲ្យទានគ្រប៊ីនោះមកខ្ញុំខ្ចី ខ្ញុំនឹងសៀតបង្កប់ជាប់នឹងខ្លួនចូលទៅដល់**តាំងតុះ** ហើយនឹងសម្លាប់កាត់យកក្បាលមកជូនលោកឥឡូវនេះ។ **អងអ៊ុន**បានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ទើបក្រោកឡើងលុតជង្គង់គំនាប់**ចូឆ្វូ** ហើយចាក់ស្រាឲ្យ**ចូឆ្វូ**ផឹក។

**ចូឆ្វូ**ទទួលពែងស្រាមកហើយតាំងសច្ចាថា ខ្ញុំសុំសម្លាប់**តាំងតុះ**ឲ្យបាន។ **អងអ៊ុន**បានឮដូច្នេះក៏ត្រេកអរណាស់ ទើបចូលទៅហូតយកគ្រប៊ីភ្លឺមកឲ្យ**ចូឆ្វូ** ។ក៏លា**អងអ៊ុន** និងនាហ្មឺនទាំងពួងចេញទៅ។

លុះដល់វេលាព្រឹកឡើង **ចូឆ្វូ**ក៏យកគ្រប៊ីនោះសៀតបង្កប់ក្នុងអាវ ហើយដើរទៅដល់ផ្ទះ**តាំងតុះ** បានសួរនាយទ្វារថាមហាឧបរាជនៅត្រង់ណា? នាយទ្វារប្រាប់ថា នៅក្នុងផ្ទះ កំពុងមើលសំបុត្រ **ចូឆ្វូ**ក៏ឡើងទៅឃើញ**តាំងតុះ**កំពុងមើលសំបុត្រ ឯ**លីប៉ោ**នៅបម្រើចេញចូលជិត**តាំងតុះ**។**តាំងតុះ**ក្រឡេកឃើញ**ចូឆ្វូ**ក៏សួរថា ហេតុម្តេចក៏មកដល់ថ្ងៃម្ល៉េះ? **ចូឆ្វូ**ជម្រាបថា សេះដែលខ្ញុំធ្លាប់ជិះនោះវាឈឺជើង នឹងរកសេះជំនួសមិនបាន បានជាមកដល់ថ្ងៃ។ **តាំងតុះ**បានស្តាប់ ក៏បង្គាប់**លីប៉ោ**ថា សេះដែលគេយកមកពីស្រុកស៊ីឡុងមួយ ចូរទៅយកមកឲ្យ**ចូឆ្វូ**។ **លីប៉ោ**ទៅហើយ **តាំងតុះ**ក៏ផ្អែកចុះបែរមុខទៅមើលសំបុត្រខាងជញ្ជាំង **ចូឆ្វូ**ឃើញដូច្នោះក៏អរណាស់ នឹកថា**លីប៉ោ**ក៏ចេញទៅហើយ ទីនេះឃើញនឹងសមដូចប្រាថ្នាដែលអញគិតជាប្រាកដ ក៏ហូតដកគ្រប៊ីភ្លឺចេញមក ហើយដើរចូលទៅនឹងសម្លាប់**តាំងតុះ** ។**តាំងតុះ**ក្រឡេកឃើញស្រមោល

ក្នុងកញ្ចក់ដែលព្យួរជាប់នឹងជញ្ជាំង ក៏ស្ពាំងស្មុតចិត្តបែរមុខមកសួរ**ចូឆ្ហូ**ថា ឯងដកគ្រប៊ីកាន់ចូលមកនឹងសម្លាប់អញឬ? ទទួល**លីប៉ោ**ក៏ចូលមកដល់។

**ចូឆ្ហូ**ភ័យណាស់ព្រោះមិនសមតាមប្រាថ្នា ក៏លុតជង្គង់ចុះហុចគ្រប៊ីខាងដងទៅឲ្យ**តាំងតុះ** ហើយកែខ្លួនថា ខ្ញុំបាទនឹងប៉ងប្រមាថលោកដោយគំនិតអាក្រក់ក៏ទេ សព្វថ្ងៃលោកមានគុណូបការៈដល់ខ្លួនខ្ញុំបាទច្រើនណាស់ ខ្ញុំបាទនឹងរកវត្ថុអ្វីនឹងតបស្នងសងគុណលោកក៏គ្មាន មានតែគ្រប៊ីភ្លឺនេះមានតម្លៃច្រើន ជាកេរ្តិ៍ពីជីតាបានរក្សាតៗគ្នាមកដល់ខ្លួនខ្ញុំបាទៗក៏យកមកតបស្នងគុណលោក។ **តាំងតុះ**ក៏ជឿមិនមានសេចក្តីសង្ស័យ ហើយទទួលយកគ្រប៊ីនោះមកមើលក៏ឃើញថាល្អមែន ទើបប្រើ**លីប៉ោ**ឲ្យយកទៅរក្សាទុក ហើយ**តាំងតុះ**ក៏នាំ**ចូឆ្ហូ**ចេញទៅមើលសេះ ហើយថា សេះនេះអ្នកយកទៅជិះចុះ។ **ចូឆ្ហូ**បានឮដូច្នោះក៏គិតថា អញប៉ងមកសម្លាប់**តាំងតុះ**ក៏មិនសមប្រកបតាមប្រាថ្នា បើនឹងនៅក្នុងស្រុកក្រុងតទៅ ខ្លាចក្រែង**តាំងតុះ**នឹងដឹង នឹងសម្លាប់អញវិញ បើដូច្នោះគួរអញកុំនៅក្នុងទីនេះ ត្រូវតែជិះសេះរ៉េះចេញទៅរកបិតានឹងបានគិតការតទៅ លុះគិតហើយក៏និយាយជម្រាប**តាំងតុះ**ថា ដែលលោកឲ្យសេះជំនិះមកខ្ញុំបាទគ្រានេះ ព្រះគុណធ្ងន់មិនមានទីបំផុត តែខ្ញុំសូមឡើងជិះល្បងមើលថ្វីជើងនិងកម្លាំងវាសិន។ **តាំងតុះ**ឆ្លើយថា គ្រឿងក៏ចងអស់ហើយ នឹងជិះល្បងមើលក៏ជិះចុះ។ **ចូឆ្ហូ**មានសេចក្តីត្រេកអរណាស់ ក៏ឡើងផែលសេះហើយបំផាយចេញទៅលុះដល់ទ្វារក្រុងទិសឯកើត ក៏ស្រែកប្រាប់នាយទ្វារថា មហាឧបរាជប្រើយើងចេញទៅជាប្រការប្រញាប់ណាស់ **ចូឆ្ហូ**ក៏បំផាយសេះចេញទៅក្រៅទីក្រុង។

ក្រោយនោះ **លីប៉ោ**ជម្រាប**តាំងតុះ**ថា ដែល**ចូឆ្ហូ**យកគ្រប៊ីមកនោះ បំណងប្រទូសរាយលោកជាប្រាកដណាស់ តែថាបុណ្យលោកមិនត្រូវឲ្យគេធ្វើបាន **ចូឆ្ហូ**ក៏កែខ្លួនធ្វើជាជូនគ្រប៊ីនោះទៅវិញ។ **តាំងតុះ**តបថាអ្នកនិយាយដូច្នេះយើងនៅឆ្ងល់ណាស់

ទទួល**លីយូ**ចូលទៅទៀត **តាំងតុះ**ក៏ពណ៌នាឲ្យ**លីយូ**ស្តាប់ **លីយូ**ថាខ្ញុំបាទនៅតែឆ្ងល់ដែរ បើដូច្នោះសូមលោកចាត់បម្រើទៅមើល**ចូឆ្វ**សិន ជានៅក្នុងទីកន្លែងដែលធ្លាប់នៅ ឬទៅឯណាទៅហើយ បើឃើញខ្លួននៅទេ គឺជាត្រង់ពិត បើមិនឃើញខ្លួនទេ គឺជារៀចដូច**លីប៉ោ**ថាប្រាកដ ទើបគេចរត់ទៅ។ **តាំងតុះ**យល់ឃើញផង ទើបចាត់បម្រើទៅមើល**ចូឆ្វ**ឯទីគ្រឹហាឋាន បម្រើក៏បានវិលមកជម្រាប**តាំងតុះ**ថា រកខ្លួន**ចូឆ្វ**មិនឃើញទេ ឮថាបំផាយសេះចេញទៅទ្វារទិសឯកើត ប្រាប់នាយទ្វារថា មហាឧបរាជប្រើឲ្យទៅជាប្រញាប់ ។ **លីយូ**ក៏ថាមែនហើយ គឺ**ចូឆ្វ**គិតប្រទូសរាយលោកជាប្រាកដ កាលមិនសមដូចប្រាថ្នាបានជារត់ទៅដូច្នេះ។ **តាំងតុះ**យល់ដូច្នោះក៏ខឹងណាស់ថា **ចូឆ្វ**នោះយើងចិញ្ចឹមរក្សាទំនុកទុកចិត្ត គួរឬមកធ្វើប្រទូសរាយនឹងយើងវិញ វានេះចំជាមនុស្សអកតញ្ញូ។ **លីយូ**ឆ្លើយថា ដែល**ចូឆ្វ**គិតប្រទូសរាយដល់លោកវេលានេះ មិនមែនគិតម្នាក់ឯងទេ ប្រហែលមានបក្សពួកគប់គិតជាមួយគ្នាជាច្រើន ទើបអាចហ៊ានធ្វើការធំដល់ម៉្លេះ បើដូច្នេះយើងត្រូវចាំចិត្តគិតចាប់**ចូឆ្វ**ឲ្យបាន ហើយនឹងស៊ើបយកពួកម៉ាកដែលរួមគំនិតជាមួយគ្នានោះសម្លាប់ចេញ ទើបនឹងអស់ចម្រូងចម្រាស។ **តាំងតុះ**យល់ព្រម ក៏បង្គាប់ឲ្យគូររូប**ចូឆ្វ** ហើយសរសេរសំបុត្រចាត់ទៅគ្រប់ខេត្តខណ្ឌថា នរណាឃើញរូបដូច្នេះឲ្យចាប់ខ្លួនបញ្ជូនទៅស្រុកក្រុង យើងនឹងឲ្យបំណាច់រង្វាន់ឡើងទីជានាហ្មឺនធំ បើនរណាចូលសមគំនិតលាក់បាំង**ចូឆ្វ**ទុក នឹងឲ្យធ្វើទោសប្រហារជីវិតព្រមទាំងបុត្រភរិយាបង់។

ឯ**ចូឆ្វ**បរសេះទៅដល់ស្រុកចុងកួន ពួកគយល្បាតឃើញរូប**ចូឆ្វ**ប្រហែលរូបគំនូរក្នុងសំបុត្រ ក៏ព្រួតចាប់ខ្លួនបញ្ជូនទៅឲ្យ**តាន់កុង**ចៅហ្វាយស្រុកចុងគួន សួរថា អ្នកឯងឈ្មោះ**ចូឆ្វ**ឬ? **ចូឆ្វ**ឆ្លើយថា ខ្ញុំបាទឈ្មោះ**ហងអ៊ូ**ជាដង្ហៅលក់ដូរទេ។ **តាន់កុង**ពិនិត្យមើលក៏ចាំបានជាក់លាក់ហើយថា អ្នកឯងឈ្មោះ**ចូឆ្វ**ហេតុម្តេចក៏ថាឈ្មោះ

**ហាងអ៊ូ**វិញ អ្នកឯងនិយាយមិនពិតត្រង់ទេ ពេលនេះយប់ហើយយកទៅដាក់គុកទុកសិនចុះ ព្រឹកស្អែកនឹងបញ្ជូនខ្លួនចូលទៅស្រុកក្រុង។ លុះវេលាពាក់កណ្ដាលអាធ្រាត្រ **តាន់កុង**ក៏ឲ្យទៅយកខ្លួន**ចូវឆ្វ**មកជួបក្នុងទីស្ងាត់ ហើយសួរថា យើងបានឮកិត្តិស័ព្ទថា មហាឧបរាជមានចិត្តស្រឡាញ់រាប់អានអ្នកឯងច្រើន អ្នកឯងមានធ្វើការអ្វីឲ្យមហាឧបរាជទាស់ចិត្តទើបកើតហេតុដូច្នេះ? **ចូវឆ្វ**តបថា ខ្លួនលោកឧបមាដូចសត្វបក្សីតូចមួយ ត្រូវការអ្វីនឹងមកកន្លងដឹងគំនិតស្ដេចគ្រុឌ? ដែលមានសេចក្ដីបង្គាប់**តាំងតុះ**បង្គាប់មកឲ្យធ្វើយ៉ាងម្ដេច លោកត្រូវតែធ្វើតាមបង្គាប់ទៅចុះ ឥឡូវលោកចាប់ខ្លួនយើងបានហើយ ត្រូវតែបញ្ជូនខ្លួនយើងចូលទៅស្រុកក្រុងយកសេចក្ដីគាប់ចុះ កុំមកល្បួងបញ្ឆោតសួរគំនិតរបស់យើងឡើយ។ **តាន់កុង**បានស្ដាប់ដូច្នេះហើយក៏យល់អធ្យាស្រ័យ ទើបបណ្ដេញមនុស្សឯទៀតឲ្យចេញអំពីនោះអស់ហើយនិយាយនឹង**ចូវឆ្វ**ថា អ្នកឯងកុំអាលមើលងាយថា យើងមានគំនិតរាក់ទាក់ សព្វថ្ងៃដែលយើងមកធ្វើជាចៅហ្វាយស្រុកចត្វាយ៉ាងនេះ ព្រោះទាល់គំនិតគិតធ្វើអ្វីមិនកើត ដែលនឹងឲ្យពេញចិត្តនឹងតំណែងនេះក៏ទេ យើងនៅគិតរកមនុស្សក្លាហានខ្លាំងពូកែមានប្រាជ្ញាស្មារតីជាខ្នងបង្អែកសិន ហើយនឹងបានគិតការនេះតទៅទៀត។ **ចូវឆ្វ**បានឮដូច្នោះក៏តបថា ពីដើមជីតា និងបិតាយើងជានាហ្មឺនបានស៊ីបៀវត្សរាជការ ដល់ស្រុកទេសចលាចលដោយសារខន្ទីទាំងដប់នាក់វេលាណា យើងក៏បានចូលធ្វើរាជការវេលានោះ ពេលនោះបណ្ដាលមកអំពី**តាំងតុះ**តាំងខ្លួនជានាហ្មឺនធំសម្លាប់អម្ចាស់ផែនដី មានសេចក្ដីកំរើបឡើងជាខ្លាំងណាស់ បើយើងនឹងស្ងៀមនៅមិនគិតក៏បំបះបំបោរ ក៏ហាក់ដូចជាមិនមានកតញ្ញូនឹងផែនដី ឯដែលយើងទៅនៅធ្វើខ្លួននឹង**តាំងតុះ**ជាមនុស្សអប្រិយ យើងមានបំណងនឹងបំផ្លាញវាចេញប៉ុណ្ណោះ លុះយើងធ្វើការនោះមិនសម្រេចតាមប្រាថ្នា ក៏គឺកម្មវាសនារបស់យើងនិងវិបាករបស់អាណាប្រជានុរាស្ត្រក្នុងផែនដី។

ទើប**តាន់កុង**សួរថា អ្នកដែលរត់ចេញពី**តាំងតុះ**មកនេះនឹងប្រាថ្នាទៅគិតការអ្វី? **ចូអ្វ**ឆ្លើយថា យើងនឹងរត់ទៅរកបិតាយើង ហើយនឹងលបតែងជាសំបុត្រព្រះតម្រាស់ព្រះ**ចៅហៀនតេ** ហើយនឹងបញ្ជូនទៅដល់គ្រប់ខេត្តទាំងពួងឲ្យលើកទាហានមកប្រសព្វគ្នា ហើយចូលទៅព័ទ្ធចាប់**តាំងតុះ** ដែលជាសត្រូវដល់រាជសម្បត្តិនោះសម្លាប់ចេញ។ **តាន់កុង**បានឮដូច្នោះ ក៏ចូលទៅដោះខ្នោះច្រវាក់នាំ**ចូអ្វ**ចេញមក ទើបអញ្ជើញឲ្យអង្គុយលើកៅអីហើយនិយាយថា ដែលអ្នកមានគំនិតគិតដូច្នេះនេះ ខ្ញុំក៏មានសេចក្ដីពេញចិត្តណាស់ ព្រោះថារាស្ត្រទាំងពួងនឹងបានសេចក្ដីសុខក៏ដោយសារគំនិតប្រាជ្ញារបស់អ្នក។ **ចូអ្វ**សួរថា លោកឈ្មោះអ្វី បានជាមានសេចក្ដីត្រេកត្រអាលនឹងយើង? **តាន់កុង**ឆ្លើយថា ខ្ញុំឈ្មោះ**តាន់កុង**ជាសែតាន់ យើងឃើញថាអ្នកមានសេចក្ដីសត្យសុចរិតនឹងផែនដី ទើបមានសេចក្ដីត្រេកអរដូច្នេះ ឯនាទីរបស់យើងគ្រាន់តែជាចៅហ្វាយស្រុកចត្វាប៉ុណ្ណោះ យើងលះចោលមួយរំពេចមិនមានស្ដាយស្រណោះទេ យើងសូមទៅធ្វើការជួយទំនុកបម្រុងផែនដីជាមួយនឹងអ្នក។ ថាហើយ**តាន់កុង**ក៏ចូលទៅរៀបចំយកទ្រព្យរបស់ដែលមានតម្លៃនិងគ្របីឲ្យ**ចូអ្វ**កាន់មួយ ខ្លួនឯងកាន់មួយ ហើយក៏ឡើងជិះសេះមួយម្នាក់នាំគ្នាចេញចាកពីគ្រឹហាឋានក្នុងវេលាយប់នោះ។

លុះ**តាន់កុង** និង**ចូអ្វ**ចេញដំណើរទៅបានបីថ្ងៃដល់ភូមិមួយ **ចូអ្វ**និយាយប្រាប់**តាន់កុង**ថា ពេលនេះក៏ជួនជាល្ងាចណាស់ហើយ ភូមិនេះគឺជាផ្ទះក្មើបិតាខ្ញុំឈ្មោះ**ប៉េះផៀ** យើងនាំគ្នាទៅសំណាក់មួយយប់សិននឹងបានសួររឿងរ៉ាវទាំងពួងផង។ ថាហើយ**ចូអ្វ**នាំ**តាន់កុង**បរសេះចូលទៅផ្ទះ**ប៉េះផៀ** ៗឃើញ**ចូអ្វ**ក៏ចុះមកទទួលឲ្យឡើងទៅលើផ្ទះ ហើយប្រាប់ថា ឥឡូវមានសំបុត្រព្រះតម្រាស់បង្គាប់មកពីស្រុកក្រុង ឲ្យចាប់ខ្លួនក្មួយឯងបញ្ជូនចូលទៅក្រុង ឯ**ចូក្វូ**ជាបិតាក្មួយភ័យណាស់ ដោះខ្លួនទៅនៅ

ស្រុកតាន់លីវហើយ។ **ចូឆ្វូ**ក៏សាស័ព្ទប្រាប់អាថ៌សេចក្ដីសព្វគ្រប់ឲ្យ**ប៉េះឆៀ**ស្ដាប់ ហើយប្រាប់ថា នេះឈ្មោះ**តាន់កុង**ចៅហ្វាយស្រុកចុងក្ឈួន លះបង់ទីរាជការរត់មកគិតការជាមួយនឹងខ្ញុំ បានជាខ្ញុំរួចរស់ជីវិតមកនេះ ។ **ប៉េះឆៀ**បានស្ដាប់ក៏និយាយនឹង**តាន់កុង**ថា ខ្ញុំមានអំណរគុណនឹងលោកដែលមានកតញ្ញូនឹងផែនដីនោះណាស់ បើកុំតែបានលោកជួយដោះទុក្ខមុខជា**ចូឆ្វូ**ស្លាប់មិនខាន បើដូច្នោះលោកនាំគ្នាសម្រាននៅផ្ទះខ្ញុំមួយយប់សិនចុះ ស្អែកសឹមអញ្ជើញទៅ។ ហើយ**ប៉េះឆៀ**ចូលទៅក្នុងផ្ទះបង្គាប់បុត្រភរិយាថា ឲ្យធ្វើជ្រូកនិងមាន់រៀបបាយទឹកជាប្រញាប់ ប្រាប់ហើយក៏ចេញមកខាងក្រៅប្រាប់**ចូឆ្វូ**ថា ស្រាដែលមានក្នុងផ្ទះមិនសូវល្អ មាសុំទៅរកទិញស្រាថ្មីល្អមកជូនក្មួយពិសា ថាហើយក៏ចុះដើរទៅ។

ឯពួកអ្នកធ្វើបាយក្នុងជើងក្រាន ក៏បាននិយាយពិគ្រោះគ្នាថា យើងនឹងចងមុខឬសម្លាប់តែម្ដងទៅ។ **ចូឆ្វូ**បានឮដូច្នោះក៏ពិភាល់ក្នុងចិត្តទើបខ្សិបសួរ**តាន់កុង**ថា **ប៉េះឆៀ**នេះគេគ្រាន់តែជាក្លើនឹងបិតាខ្ញុំ ពុំមែនជាសាច់ញាតិអ្វីសោះ ប្រហែលគេចេញទៅប្រាប់មេស្រុកជំទប់ ភ្នាក់ងារឃុំមកចាប់យើងទេដឹង ទើបគេបង្គាប់ទុកឲ្យមនុស្សក្នុងផ្ទះថាចងមុខ ឬសម្លាប់តែម្ដងដូច្នោះ? **តាន់កុង**ថា ខ្ញុំមិនអាចដឹង ព្រោះមិនបានស្គាល់ចិត្ត**ប៉េះឆៀ**នោះសោះ។ **ចូឆ្វូ**ថា បើដូច្នោះយើងទុកចិត្តម្ដេចបាន? ថាហើយក៏ហូតគ្រប៊ីដើរចូលទៅក្នុងផ្ទះ កាប់ភរិយាបុត្រ និងមនុស្សម្នា**ប៉េះឆៀ**ស្លាប់អស់ប្រាំបីនាក់។ **តាន់កុង**ងាកទៅម្ខាងឃើញជ្រូកគេចងទុកក្នុងចំណាង ក៏ស្ដុតចិត្តគិតថា គេចងជ្រូកគិតនឹងសម្លាប់ផ្សេងទេ ហេតុម្ដេចអ្នកសម្លាប់បុត្រភរិយា**ប៉េះឆៀ**ដូច្នេះខុសណាស់។ **ចូឆ្វូ**ក៏ហួសចិត្តគិតនឹកបារម្ភខ្លាចមិនអាចបង្អង់នៅលើផ្ទះនោះ ក៏នាំ**តាន់កុង**ចុះពីលើផ្ទះជិះសេះបរប្រញាប់ទៅ លុះទៅបានប្រមាណម្ភៃសិន (៨០០ ម៉ែត្រ) ទទួលជួបនឹង**ប៉េះឆៀ**ៗសួរថា ហេតុម្ដេចក្មួយមិននៅពិសាបាយសិន

ប្រញាប់ទៅណា? **ច្វូឆ្វ**ឆ្លើយថា ខ្ញុំបាទជាមនុស្សខុសហើយ នឹងស្រូតទៅឲ្យផុតអំពីភ័យអន្តរាយ មាត់តែនិយាយ សេះតែបរលឿនទៅត្រឡប់គិតបត់សេះមកក្រោយវិញហៅថា មាឈប់សិនខ្ញុំផ្ដាំពាក្យមួយម៉ាត់ទុក **ប៉េះឆៀ**ក៏ឈប់។ **ច្វូឆ្វ**បរសេះទៅដល់ទន្ទឹមក៏ហូតគ្រប៊ីកាប់**ប៉េះឆៀ**ស្លាប់នៅទីនោះទៀត។ **តាន់កុង**ឃើញដូច្នោះក៏រឹតតែស្លុតចិត្តគិតហើយនិយាយនឹង**ច្វូឆ្វ**ថា កាលអម្បាញ់មិញនេះអ្នកសម្លាប់បុត្រភរិយា និងមនុស្សម្នារបស់**ប៉េះឆៀ**ស្លាប់អស់ទៅហើយ ឥឡូវនេះ ហេតុម្ដេចអ្នកសម្លាប់**ប៉េះឆៀ**ទៀត? **ច្វូឆ្វ**ឆ្លើយថា កាលអម្បាញ់មិញ យើងគិតច្រលូសហួសខ្លួនទៅហើយ បើនឹងទុក**ប៉េះឆៀ**ឲ្យរស់នៅ នោះមុខជានឹងទៅប្រាប់មេស្រុកជំទប់ភ្នាក់ងារឃុំ ឲ្យលើកគ្នាមកតាមចាប់យើងមិនខាន ហេតុនេះហើយយើងត្រូវតែសម្លាប់**ប៉េះឆៀ**ចេញ ទើបសូន្យផុតរលត់ដំណឹងនេះមិនមានមកដល់យើង ។ **តាន់កុង**ឆ្លើយថា អ្នកគ្មានសេចក្ដីគិតសោះ ប្រញាប់ទៅសម្លាប់គេឥតខុស បើដឹងថាខ្លួនខុសហើយមកថែមសម្លាប់គេទៀត ដូច្នេះជាមនុស្សអកតញ្ញូមិនល្អទេ ។ **ច្វូឆ្វ**ថា អ្នកនិយាយនេះក៏ត្រូវហើយ តែជាធម្មតាកើតមកជាមនុស្សតែងស្រឡាញ់រក្សាខ្លួនឲ្យបានសេចក្ដីសុខ មិនត្រូវឲ្យអ្នកដទៃប្រទូសរាយបាន ៗជាខ្ញុំធ្វើដូច្នេះ និយាយហើយក៏នាំគ្នាបរសេះទៅដល់ទីដំណាក់មួយ ក៏នាំគ្នាចូលទៅសំណាក់ដេកនៅទីនោះ។ កាល**ច្វូឆ្វ**ដេកលក់ស៊ប់ **តាន់កុង**ក៏ក្រោកអង្គុយរំពឹងគិតថា ខ្លួនអញហៅពេញជាចោលម្សៀតណាស់ តាំងចិត្តកាត់លះបុណ្យស័ក្តិទ្រព្យសម្បត្តិចេញ ព្រោះស្រឡាញ់រាប់អាន**ច្វូឆ្វ**ដោយស្មានថាមនុស្សនេះល្អត្រឹមត្រូវប្រាកដ នឹងបានសន្មតយកគ្នាជាចិត្តគំនិតមួយជួយឧបត្ថម្ភទំនុកបម្រុងគ្នាតទៅ ឥតដឹងថា**ច្វូឆ្វ**ជាមនុស្សអាក្រក់ជួជាតិសាមាន្យគ្មានសេចក្ដីកតញ្ញូដល់អ្នកមានគុណូបការៈសោះ បើដូច្នោះអញនឹងស្ម័គ្រសមាគមរួមចិត្តគំនិតជាមួយទៅឃើញថាពុំបាន គួរតែនឹងសម្លាប់ចោលចេញកុំឲ្យមានភ័យ

បារម្ភតទៅ គិតហើយក៏ហូតគ្រប៊ីចេញមកនឹងសម្លាប់**ចូឆ្វ** ក៏ថយទៅគិតវិញថា ហេតុទាំងនេះមិនពីព្រោះនរណា ព្រោះតែខ្លួនអញត្រូវចិត្តគំនិតនឹងគេមកពីដំបូងបានជាតាមគេមក បើ**ចូឆ្វ**ធ្វើខុសនឹងសម្លាប់ចេញក៏មិនមានផ្លូវចំណេញអ្វីមកដល់អញ បើមិនគាប់ចិត្តស្រឡាញ់ត្រូវតែរត់យកខ្លួនឱ្យរួចទៅជាជាង គិតហើយ**តាន់កុង**ក៏ក្រោកភ្លាមចងសេះជិះបរទាំងយប់ទៅនៅស្រុកតាំងកុង។

**ចូឆ្វ**លុះភ្ញាក់ពីដេកក្រឡេកទៅមិនឃើញ**តាន់កុង** ក៏គិតថា **តាន់កុង**ឃើញអ្វីខុសទើបដោះខ្លួនរត់ចោលអញដូច្នេះ បើអញនឹងនៅក្នុងទីនេះក៏នឹងមិនរួចអំពីភ័យ គិតហើយក៏ក្រោកឡើងចងសេះជិះទៅទាំងយប់នោះ លុះដល់ស្រុកតាន់លីវ ក៏ចូលទៅរក**ចូកូ**ជាបិតា ពណ៌នារឿងរ៉ាវប្រាប់សព្វគ្រប់ប្រការ ហើយថា ដែលខ្ញុំរត់មកនេះប្រាថ្នានឹងសុំមាសប្រាក់របស់បិតាយកទៅទិញសេះនិងគ្រឿងសាស្ត្រាវុធ ដើម្បីបញ្ចុះបញ្ចូលមនុស្សឱ្យបានជាពួកម៉ាកច្រើន ហើយនឹងធ្វើការយកអាសាផែនដីតទៅ។ **ចូកូ**ឆ្លើយថា ទ្រព្យសម្បត្តិយើងមានខ្លះដែរ តែមិនធួននឹងចាត់ការបាន ក្នុងស្រុកនេះយើងឃើញមនុស្សម្នាក់ឈ្មោះ**អ៊ុយហង**មានទ្រព្យសម្បត្តិច្រើនណាស់ ចិត្តក៏ធូរទូលាយហើយត្រង់នឹងផែនដី បើកូនយកហេតុនេះទៅប្រាប់ដល់គេៗក៏ជួយទំនុកបម្រុងខ្លះមិនខាន កូនក៏មុខជានឹងបានទិញសេះនិងគ្រឿងសាស្ត្រាវុធតាមប្រាថ្នា។

**ចូឆ្វ**បានឮដំណឹងបិតាឱ្យដូច្នោះក៏អរណាស់ ទើបបង្គាប់ឱ្យរៀបចំណីអាហារ ហើយទៅអញ្ជើញ**អ៊ុយហង**មកពិសាបាយ **ចូឆ្វ**ក៏និយាយរ៉ាយរឿងឱ្យ**អ៊ុយហង**ស្តាប់សេចក្តីថា សព្វថ្ងៃនេះ**តាំងតុះ**ទុច្ចរិតគិតធ្វើការរាជការលាមកអាក្រក់ គឺសត្រូវនឹងផែនដីខ្លាំងណាស់។ ខ្ញុំបាទឈឺចិត្តគិតខំស្វះស្វែងមកទាំងម្ល៉េះនេះ ពីព្រោះតែប្រាថ្នានឹងយកអាសាផែនដីប្រយោជន៍ដើម្បីនឹងរំលាយបំផ្លាញ**តាំងតុះ**នោះចេញ តែថា

កម្លាំងទ្រព្យសម្បត្តិរបស់ខ្ញុំមានតិចណាស់ ទើបភៀសខ្លួនមករកឧបាយនឹងបញ្ចុះបញ្ចូលពួកម៉ាកឲ្យបានច្រើន ហើយនឹងលើកជាកងទ័ពត្រឡប់ចូលទៅច្បាំងនឹង**តាំងតុះ** បើទុកជាយ៉ាងណាក៏ត្រូវសម្លាប់វាឲ្យបាន។ ឥឡូវខ្ញុំបាទបានឮដំណឹងថា លោកមានទ្រព្យសម្បត្តិជាច្រើន មានទាំងសន្តានចិត្តសុចរិតត្រង់នឹងផែនដី ខ្ញុំបាទនឹងសុំខ្ចីប្រាក់លោកយកទៅទិញគ្រឿងប្រដាប់ចម្បាំង គឺសេះ និងគ្រឿងសាស្ត្រាវុធនានានឹងបានធ្វើការតទៅ។

**អ៊ុយហាង**បានស្តាប់ក៏ចាប់ចិត្តត្រេកអរណាស់ថា តាំងពីខ្ញុំបានឮដំណឹងថាស្រុកក្រុងកើតចលាចល ក៏មានតែសេចក្តីខ្វាយខ្វល់នឹងចង់ទំនុកបម្រុងផែនដី តែគ្មាននរណាប្រារព្ធប្រាប់សេចក្តីឲ្យចូលចិត្តសោះ ឥឡូវបានអ្នកមកបំភ្លឺឲ្យខ្ញុំយល់នោះខ្ញុំមានសេចក្តីត្រេកអរណាស់ ទ្រព្យសម្បត្តិរបស់ខ្ញុំមានមិនខ្វះ ខ្ញុំហ៊ានប្រគល់ឲ្យអ្នកចាត់ចែងតាមត្រូវការ។

**ចូឆ្វ**មានសេចក្តីត្រេកអរណាស់ ទើបធ្វើទង់ជ័យសមួយបន្ទះ ហើយសរសេរអក្សរកណ្តាលទង់ថា "ឲ្យមនុស្សទាំងពួងមានចិត្តសុចរិតទៀងត្រង់នឹងផែនដី" ហើយដោតទង់នោះនៅចំមុខផ្ទះ បណ្តាអ្នកស្រុកទាំងពួង ដល់បានឃើញទង់និងអក្សរដូច្នោះ ក៏នាំគ្នាចូលមកនៅជាមួយក្រុម**ចូឆ្វ**ច្រើនណាស់ **ចូឆ្វ**ក៏ចេះតែបញ្ចុះបញ្ចូលជាមនុស្សចុះមូលជាច្រើន។

គ្រានោះមានឈ្មោះ**ហៃហ្វូទុន**ជាបង **ហៃហ្វូអៀន**ជាប្អូននៅស្រុកថៃកុក ឯ**ហៃហ្វូទុន**នោះកាលពីអាយុដប់បួនឆ្នាំ ទៅរៀនចំណេះទាហានក្នុងសំណាក់គ្រូម្នាក់ មានកូនសិស្សម្នាក់មាក់ងាយគ្រូ **ហៃហ្វូទុន**ខឹងក៏សម្លាប់ឈ្មោះនោះស្លាប់ ហើយរត់ទៅនៅចុងស្រុក លុះដឹងដំណឹងថា**ចូឆ្វ**ឲ្យបញ្ចុះបញ្ចូលមនុស្សជាកងទ័ពដូច្នោះ ក៏

បញ្ចុះបញ្ចូលពួកក្រុមបានមួយពាន់ប្លាយ ហើយនាំ**ហែហ្វូអៀន**ជាប្អូនទៅនៅជាពួក**ចូឆ្វូ**។

ឯ**ចោឃិន** និង**ចោហាង**ជាបងប្អូនពីរនាក់ ក៏នាំពួកពលបានមួយពាន់ប្លាយទៅជាមួយនឹង**ង៉ាក់ជិន**នៅស្រុកយុងបេង **លីកៀន**នៅស្រុកសាន់យុងទាំងអស់គ្នា ក៏ចូលទៅនៅជាមួយនឹង**ចូឆ្វូ** គ្រានោះ**អ៊ុយហាង**ឃើញបណ្ដាអ្នកស្រុកនាំពួកម៉ាកទៅនៅនឹង**ចូឆ្វូ**ជាច្រើនដូច្នោះ ក៏មានសេចក្ដីត្រេកអរណាស់ ទើបយកមាសប្រាក់ទៅឲ្យ**ចូឆ្វូ**ទិញសេះនិងគ្រឿងសាស្ត្រាវុធសម្រាប់ការសង្គ្រាមចម្រើនឡើងរាល់ៗថ្ងៃ បណ្ដាអ្នកស្រុកទាំងប្រុសស្រីក៏បបួលគ្នានាំយកសេះ និងគ្រឿងអាវុធនូវស្រូវអង្ករស្បៀងអាហារទៅឲ្យ**ចូឆ្វូ**ជាច្រើន ឯ**ចូឆ្វូ**ក៏រឹងរឹតតែមានសេចក្ដីត្រេកអរសប្បាយរីករាយឡើង ទើបឲ្យសង់រោងសម្រាប់ជាទីប្រជុំខុំរាជការ និងសេនាទាហានជួបជុំនិយាយការខាងសឹកសង្គ្រាមតាមពេលព្រឹកល្ងាច បណ្ដាសេនាទាហានសឹងមានគ្រូហ្វឹកហាត់នូវស្នៀតគុនអាវុធមុតមាំពុំមានខានមួយថ្ងៃ។

ឯ**អ្នួនសៀវ**ដែលតាំង**តាំតុះ**ល្បួងលួងលោមយកចិត្ត តាំងទុកជាទីចៅហ្វាយស្រុកពុតហៃ លុះឮដំណឹងថា **ចូឆ្វូ**ប្រមូលពួកក្រុមបានច្រើន ក៏ប្រឹក្សានឹងក្រុមការទាំងពួងថា យើងនឹងលើកពលទាហានទៅចូលនៅជាមួយពួក**ចូឆ្វូ**ចុះ សេនាទាហានទាំងនោះក៏ឃើញត្រូវផង ទើប**អ្នួនសៀវ**ក៏លើកកងយោធាទៅរួបរួមជាមួយពួក**ចូឆ្វូ**បីម៉ឺនប្លាយ ឯ**ចូឆ្វូ**លុះឃើញ**អ្នួនសៀវ**លើកពលមកជាពួកកងដូច្នោះ ក៏មានសេចក្ដីត្រេកអរណាស់ ចេញមកប្រឹក្សានឹង**អ្នួនសៀវ**ថា ឥឡូវនេះ យើងប្រជុំគ្នាធ្វើការធំមាំមួនណាស់ តែត្រូវធ្វើសំបុត្រព្រះតម្រាស់ត្រាស់ទៅគ្រប់ខេត្តខណ្ឌ ជាសេចក្ដីបញ្ចុះបញ្ចូលឲ្យមូលមករួបរួមនឹងយើងទើបស្រួល។ **អ្នួនសៀវ**យល់ព្រមក៏តែងជាសំបុត្រព្រះតម្រាស់ព្រះចៅ**ហៀនតេ** សេចក្ដីថា ទ្រង់ត្រាស់ប្រើ**ចូឆ្វូ**ឲ្យលបចេញមកប្រកាស

អស់បណ្តាចៅហ្វាយខេត្តខណ្ឌក្នុងព្រះរាជាណាចក្រចូរឲ្យបានដឹងគ្រប់គ្នា ដ្បិតសព្វថ្ងៃនេះបណ្តានាហ្មឺនតូចធំនិងអាណាប្រជានុរាស្ត្រក្នុងព្រះនគរ មានសេចក្តីក្តៅក្រហាយណាស់ ព្រោះ**តាំងតុះ**ជាសត្រូវរាជសម្បត្តិក្បត់សម្លាប់**ហង់ជូពៀន** ដែលជាព្រះជេដ្ឋាក្ស័យព្រះជន្មទៅ ហើយលើកយើងឲ្យសោយរាជ្យជាម្ចាស់ផែនដីបីដូចអ្នកតា តាំងខ្លួនវាជាមហាឧបរាជមានអំណាចកាន់កាប់មុខងាររាជការផែនដីស្រេចលើខ្លួនវាទាំងអស់ មានតែ**ចូឆ្វ**ជាមនុស្សកតញ្ញូ ស៊ូប្តូរជីវិតក្រោមព្រះបាទ មានចិត្តឱហាតសង្វាត ខំធ្វើរាជការជាសុចរិតទៀងត្រង់ប្រាកដ បានសាបាលស្បថចំពោះព្រះភក្ត្រថា នឹងយកអាសារំលាង**តាំងតុះ**ដែលជាសត្រូវរាជសម្បត្តិចេញឲ្យបានជាឆាប់ ។

ខណៈនោះចៅហ្វាយខេត្តទាំងដប់ប្រាំមណ្ឌលដែលជាធំគឺ **អ្នួនសុត**ចៅហ្វាយស្រុកឡាំយ៉ុង១, **ហ័នហុក**ចៅហ្វាយស្រុកគីជីវ១, **ខុងម៉**ចៅហ្វាយស្រុកអៀងជីវ១, **ឡៅតាយ**ចៅហ្វាយស្រុកអ៊ីវជីវ១, **អងខង**ចៅហ្វាយស្រុកហោឡាយ១, **តៀវម៉ៅ**ចៅហ្វាយស្រុកតាន់លីវ១, **តៀវប៉ោ**ចៅហ្វាយស្រុកតងគុន១, **អ្នួនអ៊ុយ**ចៅហ្វាយស្រុកស៊ុនយ៉ុង១, **ប៉ៅស៊ិន**ចៅហ្វាយស្រុកចេប៉ាក១, **ខុងឡេង**ចៅហ្វាយស្រុកប៉ាកហៃ១, **តៀវចៀវ**ចៅហ្វាយស្រុកកងឡេង១, **តូកៀម**ចៅហ្វាយស្រុកឈីជីវ១, **ម៉ាថេង**ចៅហ្វាយស្រុកសេលៀង១, **តៀវអៀង**ចៅហ្វាយស្រុកសៀងតុង១, **ស៊ុនកៀន**ចៅហ្វាយស្រុកទៀងសា១ បានទទួលសំបុត្រព្រះតម្រាស់ បានដឹងច្បាស់សេចក្តីហើយ ក៏មានសេចក្តីក្រេកអរទាំងអស់គ្នា ទើបចាត់ការឃុំនាំពលយោធាខេត្តនីមួយៗ ខ្លះមួយម៉ឺន ខ្លះពីរម៉ឺន ខ្លះបីម៉ឺន លើកទៅបញ្ចូលជាមួយនឹងកងទ័ព**ចូឆ្វ** រួមជាដប់ប្រាំមួយខេត្តនឹង**អ្នួនសៀវ**។ **ចូឆ្វ**ក៏លើកប្រមូលកងទ័ពទាំងអស់នោះទៅដល់ព្រំដែនស្រុកឡុកអៀង ជាទីក្រុង។

គ្រានោះ ឈ្មោះ**កងស៊ុនថាន**ចៅហ្វាយស្រុកប៉ាក់ប៉េងឮដំណឹងថាមានព្រះតម្រាស់ដូច្នោះ ក៏ប្រមូលបានទាហានមួយម៉ឺនប្រាំពាន់លើកទៅដល់ខេត្តផេងគួនតួនដែល**ឡៅពី**ឈររក្សា ឯ**ឡៅពី**ដឹងថា**កងស៊ុនថាន**លើកទាហានមក ក៏នាំ**គួនអ៊ូ, តៀវហ៊ុយ**ចេញទៅទទួលដល់ទ្វារស្រុក **កងស៊ុនថាន**ក៏ម្នីម្នាគំនាប់ហើយសួរថា ដែលបានមកជាមួយពីរនាក់នោះឈ្មោះអ្វី? មកនេះប្រាថ្នានឹងទៅណា? **ឡៅពី**ឆ្លើយថា នោះឈ្មោះ**គួនអ៊ូ**, នោះឈ្មោះ**តៀវហ៊ុយ**ទាហានសេះរបស់ខ្ញុំកាន់ធ្នូសរ គឺជាប្អូនខ្ញុំទាំងពីរនាក់ខ្លាំងពូកែណាស់ ដែលអ្នកមានគុណូបការៈនឹងខ្ញុំពីដើមនោះ ខ្ញុំឮថាអ្នកលើកទ័ពមកផ្លូវនេះបានជាចេញមកទទួល ប្រាថ្នានឹងអញ្ជើញអ្នកទៅឈប់ស្នាក់សម្រាកកម្លាំងទាហានមួយវេលា។ **កងស៊ុនថាន**បានស្ដាប់ក៏នឹកឃើញ**គួនអ៊ូ, តៀវហ៊ុយ**ហើយក៏ចូលទៅក្នុងស្រុកផេងងួនគួន ទើបនិយាយនឹង**ឡៅពី**ថា **គួនអ៊ូ, តៀវហ៊ុយ** នេះបានទៅជួយច្បាំងនឹងពួកចោរជូតក្បាលលឿងមានថ្វីដៃល្អ តែនឹងរកអ្នកឯណាជួយស្នើសរសើរគុណបំណាច់ឲ្យគ្មាន បានជានៅជាមួយទាហានឡេវដូច្នេះ ។ លុះនិយាយហើយក៏អធិប្បាយពីព្រះតម្រាស់ ដែលត្រាស់ប្រើ**ចូអ្វ** ឲ្យចេញមកប្រកាសដល់បណ្ដាខេត្តទាំងពួងឲ្យ**ឡៅពី**ស្ដាប់ ហើយបបួល**ឡៅពី**ថា សព្វថ្ងៃនេះអ្នកបានជាទីចៅហ្វាយស្រុកហើយ តែជាស្រុកតូចណាស់ ពេលនេះចូរអ្នកទៅជាមួយនឹងយើងចុះ បើសម្រេចការហើយ ខ្លួនអ្នកនិងប្អូនអ្នកទាំងពីរនាក់ មិនលែងបានជាចៅហ្វាយស្រុកខេត្តឯកទេ។ **ឡៅពី**មានសេចក្ដីត្រេកអរណាស់ ក៏ស្រុះស្រួលទទួលពាក្យនឹង**កងស៊ុនថាន**។ **តៀវហ៊ុយ**ឆ្លើយថា កាលទៅច្បាំងនឹងពួកចោរជូតក្បាលលឿងនោះ ខ្ញុំឃើញកិរិយា**តាំងតុះ**ជាមនុស្សអាក្រក់ មិនជាអ្នកស្គាល់ទោសនិងគុណសោះ ខ្ញុំប្រុងនឹងសម្លាប់វាចេញ បងចេះតែឃាត់ខ្ញុំ បើកុំតែបងឃាត់ប្រហែលមិនមានរឿងធំដូច្នេះទេ។ **គួនអ៊ូ**ក៏ឃាត់**តៀវហ៊ុយ**ថា កុំឲ្យនិយាយថ្វី ឥឡូវ

យើងបានទៅជាមួយនឹង**កងស៊ុនចាន**ហើយ គង់បានប្រទះគ្នាទៀតទេ ខ្ញុំអរណាស់។ **ឡៅពី**ក៏ឱ្យរៀបចាត់ចែងទាហាន រើសយកតែមនុស្សណាដែលជាទំនុកទុកចិត្ត។ លុះរើសបានរួចស្រេចហើយ **កងស៊ុនចាន, ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លើកកងទ័ពទៅដល់ប្រទល់ដែនទីក្រុងឡុកអៀង។

ឯ**ចូឆូ**និងចៅហ្វាយខេត្តទាំងពួង ក៏ឱ្យតាំងបន្ទាយវាយកងទ័ពជាប់គ្នាជាលំដាប់ទៅផ្លូវនៅឆ្ងាយពីទីក្រុងប្រហែលពីររយសិន (៨ គ.ម) **ចូឆូ**ឱ្យរៀបតុតាំងលៀងភោជនាហារបណ្ដាចៅហ្វាយខេត្តទាំងអស់សឹងមកស៊ីលៀងព្រមគ្នា លុះបរិភោគរួចវេលាណា ក៏ចាត់ការនឹងឱ្យលើកទាហានចូលវាយស្រុកឡុកអៀង។ **អងខង**និយាយឡើងថា ឥឡូវនេះយើងរាល់គ្នាសុទ្ធតែកតញ្ញូនឹងផែនដី ទើបនាំគ្នាចូលមកប្រជុំធ្វើការនេះ យើងមិនមានតាំងអ្នកឯណាឱ្យកាន់អាជ្ញាសិទ្ធិធំនឹងបង្គាប់បញ្ជានាយកងនាយពលសោះ បើដូច្នេះឃើញថានឹងលើកចូលទៅវាយនោះនៅមិនទាន់បានទេ។ **ចូឆូ**បានស្ដាប់ក៏ចាប់ចិត្តគិតឃើញត្រូវ ទើបនិយាយប្រកាសថា **អ្ហួនសៀវ**នេះ ជាមនុស្សមានពូជពង្សវង្សត្រកូលជានាហ្មឺនរៀងមកដល់បួនប្រាំតំណហើយ គួរនឹងលើកឱ្យធ្វើជាមេទ័ពធំកាន់អាជ្ញាសិទ្ធិ បង្គាប់បញ្ជានាយកងនាយទ័ពទាំងពួង តើអ្នកទាំងអស់គ្នាយល់ឃើញដូចម្ដេច? (មន្ត្រីខេត្តទាំងអស់ក៏បានទទួលយល់ព្រម) តែ**អ្ហួនសៀវ**បែរជាមិនទទួលតំណែងនេះ។ ចៅហ្វាយខេត្តទាំងអស់ទាស់អធ្យាស្រ័យគ្នាថា បើ**អ្ហួនសៀវ**មិនព្រមទទួលធ្វើជាមេទ័ពធំទេ ឃើញថានឹងរើសរកតទៅទៀតមិនបាន បើដូច្នេះតើនឹងត្រូវធ្វើដូចម្ដេច? ឯ**អ្ហួនសៀវ**ឃើញថាមិនស្រួល ក៏ព្រមទទួលធ្វើជាមេទ័ពធំក្នុងពេលនោះ។ **ចូឆូ**ក៏ឱ្យសង់រោងធំមួយ សម្រាប់**អ្ហួនសៀវ**ចេញនិយាយការរាជការក្នុងបន្ទាយ លុះដល់ថ្ងៃមានឫក្សជោគជ័យល្អ ក៏អញ្ជើញ**អ្ហួនសៀវ**ឡើងអង្គុយលើទីដ៏សមគួរ ហើយ**ចូឆូ**និងចៅហ្វាយខេត្តទាំងដប់ប្រាំពីរ

មណ្ឌល ក៏តម្កល់គ្រឿងសក្ការៈអុជទៀនធូបបួងសួងទេវតាអារក្សផឹកទឹកពិភទ្ទសច្ចាសន្មតថានឹងតាំងចិត្តជាសុចរិតទៀតត្រង់នឹងផែនដីតទៅ **ចូអ្វ**ទើបចាក់ស្រាគំនាប់ចៅហ្វាយខេត្តទាំងពួង ផឹកហើយក៏និយាយថា យើងនឹងធ្វើសង្គ្រាមធំគ្រានេះ មិនត្រូវបែកចិត្តគ្នាឲ្យខូចរាជការទេ ចូរមានចិត្តជាពិតត្រង់នឹងគ្នា ទើបធ្វើការនោះនឹងបានសម្រេចដោយស្រួលងាយ។

**អ្នួនសៀវ**ឆ្លើយថា តម្រិះប្រាជ្ញាយើងក៏នៅជាប្រមាណ ដែលអ្នកទាំងអស់ស្រុះចិត្តគ្នាលើកឲ្យយើងធ្វើជាមេទ័ពធំនោះ យើងក៏ត្រូវតាមអាជ្ញាសិទ្ធិនិងទំនៀមច្បាប់ពិជ័យសង្គ្រាម បើអ្នកឯណាមានគុណគាប់ប្រសប់ធ្វើការ យើងក៏ត្រូវបំណាច់រង្វាន់ទាន់ចិត្ត បើអ្នកឯណាទុច្ចរិតប្រព្រឹត្តខុស យើងក៏ត្រូវចុះទោសតាមច្បាប់អយ្យការសឹក អ្នកទាំងអស់គ្នាបានស្ដាប់ហើយ កុំបីតូចចិត្តនឹងយើងឡើយ។ **ចូអ្វ**និងចៅហ្វាយខេត្តទាំងដប់ប្រាំពីរមណ្ឌលក៏ទទួលយល់ព្រម **អ្នួនសៀវ**ទើបចាត់ឲ្យ**អ្នួនសុត**ជាប្អូនធ្វើមេទ័ពណ្ឌូនសម្រាប់ស្បៀងអាហារកុំឲ្យដាច់ ចាត់**ស៊ុនកៀន**មេទ័ពមុខលើកទាហានទៅវាយគយគីស៊ុយគួន។ **ស៊ុនកៀន**ក៏លើកទាហានទៅតាំងបន្ទាយជាប់នឹងគយនោះ។

ឯនាយគយលុះឃើញដូច្នោះ ក៏ធ្វើសំបុត្រឲ្យបម្រើសេះនាំចូលទៅប្ដឹងដល់ស្រុកក្រុង **លីយូ**បានដឹងការ ក៏នាំសេចក្ដីនោះទៅជម្រាប**តាំងតុះ** ៗស្លុតចិត្តភិតភ័យណាស់ ទើបប្រឹក្សានឹង**លីយូ**ថា គ្រានេះនឹងបានអ្នកឯណាយកអាសាចេញទៅតតាំងច្បាំងចាប់យក**ស៊ុនកៀន**ឲ្យបាន? **លីប៉ោ**ឆ្លើយថា ដែលចៅហ្វាយខេត្តលើកពលចូលមកតាំងនេះប្រៀបដូចមមាច ខ្ញុំបាទនឹងសូមយកអាសាលើកកងទ័ពចេញទៅសម្លាប់ឲ្យបាន លោកកុំបីមានចិត្តគិតព្រួយបារម្ភឡើយ។ **តាំងតុះ**បានស្ដាប់ដូច្នោះហើយក៏អស់វិតក្កវិកមុខរួសរាយ ទើបនិយាយថា សព្វថ្ងៃនេះយើងបាន**លីប៉ោ**មក

ទុកជាបុត្រចិញ្ចឹម ក៏នឹកសង្ឃឹមថា បើនឹងបានទាហានដរ៏ទៃដប់ម៉ឺន ក៏មិនគួរស្មើនឹងមនុស្សម្នាក់នេះឡើយ។ ខណៈនោះមានទាហានម្នាក់ឈ្មោះ**ហ្ស៊ួយយុង**ទ្រង់ទ្រាយដូចខ្លាកម្ពស់ប្រាំមួយហត្ថប្លាយ លុះបានឮ**លីប៉ោ**អួតខ្លាយដូច្នោះ ក៏លុតជង្គង់សំពះ**តាំងតុះ**ហើយថា ដែលនឹងសម្លាប់មាន់ មិនត្រូវទៅកាន់កាំបិតដែលសម្លាប់គោ យកទៅសម្លាប់មាន់ទេ ការគ្រានេះ គ្រាន់តែត្រឹមចៅហ្វាយខេត្តទាំងពួងលើកទ័ពមកប៉ុណ្ណេះ មិនបាច់នឹងឲ្យ**លីប៉ោ**ជាបុត្រលោកលើកពលទៅតាំងច្បាំងឲ្យលំបាកទេ តែត្រឹមខ្ញុំបាទក៏សូមយកអាសាចេញទៅកាត់ក្បាលចៅហ្វាយខេត្តទាំងអស់ មកជូនលោកបានហើយ។ **តាំងតុះ**បានស្តាប់ក៏ពេញចិត្តណាស់ ទើបឲ្យ**ហ្ស៊ួយយុង**ឡើងទីជានាយទាហានធំ ហើយចាត់ទាហានឲ្យ**ហ្ស៊ួយយុង**ប្រាំម៉ឺនចេញទៅជាមួយនឹង**លីសុក១, ហោជិន១, តៀវង៉ឹម១,** ទាំងបួននាយលើកចេញទៅ ឯ**ហ្ស៊ួយយុង**និងនាយទាហានទាំងបី លើកពលទាំងប្រាំម៉ឺនស្រូតរូតចេញទៅតាំងបន្ទាយនៅគយគីស៊ុយគួន។

ខណៈនោះ**ប៉ៅស៊ិន**ដែលនៅក្នុងទ័ព**អួនសៀវ** គិតថា **ស៊ុនកៀន**ជាមេទ័ពមុខលើកពលទៅវាយបន្ទាយគីស៊ុយគួននោះ បើបានការក៏មានសេចក្តីគាប់ប្រសើរតែ**ស៊ុនកៀន**ម្នាក់ឯង ទើបចាត់ចែងឲ្យ**ប៉ៅតុង**ជាប្អូននាំទាហានចេញទៅមួយផ្លូវទៀត ប្រយោជន៍ឲ្យស្រូតវាយបន្ទាយគីស៊ុយគួនឲ្យបានជាមុន សេចក្តីគាប់នឹងត្រឡប់បានមកខាងខ្លួន ក៏បានចាត់ការស្រេចឲ្យ**ប៉ៅតុង**លើកទ័ពចេញទៅ លុះដល់ទល់គ្នាហើយ ក៏បរពលឲ្យចូលវាយបន្ទាយជាមុន**ស៊ុនកៀន**។

ឯ**ហ្ស៊ួយយុង**ឃើញដូច្នោះ ក៏ដេញទាហានប្រាំរយបើកទ្វារបន្ទាយចេញមកហើយស្រែកឲ្យ**ប៉ៅតុង**ថា ខ្លួនជាពួកចោរមកតតាំងច្បាំងនឹងអញឬ? **ប៉ៅតុង**បានឮក៏បែរមុខទៅឃើញ**ហ្ស៊ួយយុង**មានសេចក្តីភ័យណាស់ ញាក់សេះបរត្រឡប់ទៅខាងក្រោយ **ហ្ស៊ួយយុង**ក៏បរសេះដេញបណ្តោយតាម យកដាវកាប់ត្រូវ**ប៉ៅតុង**ធ្លាក់ពីលើ

សេះស្លាប់ ចាប់បានទាហានឈ្លើយជាច្រើន ហើយឲ្យកាត់យកក្បាល**ប៉ៅតុង**ដាក់តាំងយកសំបុត្របញ្ជូនចូលទៅឲ្យ**តាំងតុះ**ក្នុងស្រុកក្រុង **តាំងតុះ**មានសេចក្តីត្រេកអរណាស់ ក៏ឆ្លើយតបសំបុត្រមកតាំង**ហ្គួយុង**ជាទីនាហ្មឺនធំ។

ចំណែក**ស៊ុនកៀន**មានទាហានទៅជាមួយបួននាក់ ឈ្មោះ**តៀផៅ**កាន់លំពែង១, **អ៊ុយកាយ**កាន់ដំបងដែក១ មានមុខស្រួច៤, **ហាន់តុង**កាន់ដាវ១, **ចូម៉ៅ**កាន់ដាវដៃមួយម្ខាង **ស៊ុនកៀន**តែងខ្លួនពាក់ក្រោះ និងកាន់ដាវវែង នាំពួកទាហានចេញទៅឈរនៅមុខបន្ទាយហើយស្រែកថា អាពួកក្បត់ អាឯងចូរបើកទ្វារចេញមកតយុទ្ធនឹងអញជាប្រញាប់ បើបង្អង់យូរអញនឹងហែកបន្ទាយចូលទៅកាត់ក្បាលឲ្យអស់ឥឡូវនេះ។ **ហោជិន**បានឮដូច្នោះក៏និយាយនឹង**ហ្គួយុង**ថា ខ្ញុំបាទសុំទាហានប្រាំពាន់ចេញទៅយកអាសាលោកជាមុន។ **ហ្គួយុង**ក៏ចាត់ទាហានឲ្យ**ហោជិន**ហើយបើកទ្វារចេញទៅ។

**តៀផៅ**ឃើញ**ហោជិន**ចេញមក ក៏ឡើងសេះរាំលំពែងចេញទៅទទួលតនឹង**ហោជិន**បានប្រាំពីរភ្លែង **តៀផៅ**យកលំពែងចាក់ត្រូវ**ហោជិន**ធ្លាក់ពីលើសេះស្លាប់ ទាហានក៏ដេញប្រកាប់ ចូលទៅចាក់កាប់សម្លាប់ទាហាន**ហោជិន**ទល់នឹងជើងកំពែង។

**ហ្គួយុង**ឃើញបរាជ័យ ក៏ឲ្យទាហានឡើងលើខ្នងកំពែងបាញ់ធ្នូសរ ចោលដុំថ្មទម្លាក់ចុះទៅត្រូវទាហាន**ស៊ុនកៀន**បែកបាក់ពិការជាច្រើន។ **ស៊ុនកៀន**យល់ថានឹងវាយទម្លុះពុំបាន ក៏ឲ្យទាហានថយក្រោយមកវិញ ហើយតាំងបន្ទាយនៅតំបន់លៀងតុង ទើបឲ្យបកសំបុត្រតាមដំណើរចូលទៅស្នើឲ្យ**អ្លួនសៀវ**ជ្រាបសេចក្តី សំបុត្រមួយបកទៅដល់**អ្លួនសុត**ជាមេទ័ពឈ្វូន ឲ្យបញ្ជូនស្បៀងអាហារមកឲ្យពួកពលទាហានបរិភោគជាប្រញាប់។

ខណៈកាលសំបុត្របកទៅដល់**អ្វួនសុត**នោះ មានទាហានម្នាក់ជម្រាប**អ្វួនសុត**ថា **ស៊ុនកៀន**កាលនៅស្រុកកាំងតាំង ឧបមាដូចខ្លាធំខ្លាំងពូកែណាស់ ឯ**តាំងតុះ**ឧបមាដូចខ្លាឃ្មុំ ឥឡូវ**ស៊ុនកៀន**លើកទាហានចេញទៅជាមេទ័ពមុខ បើវាយស្រុកឡុកអៀងចាប់**តាំងតុះ**សម្លាប់បានវេលាណា **ស៊ុនកៀន**ក៏នឹងកំរើបចិត្តឥតកោតខ្លាចនរណា ហេតុនេះខ្ញុំយល់ឃើញថា នឹងស្ងៀមកុំបញ្ជូនស្បៀងទៅឲ្យស្រួលជាងបើពួកសេនាទាហានគ្មានស្បៀងអាហារបរិភោគហើយ គង់នឹងរសាប់រសាយថយអស់ពលាការ ដូចខ្លាដាច់សង្វែងលែងមានកម្លាំងសោះ។ **អ្វួនសុត**បានឮដូច្នោះ ក៏ចូលចិត្តគិតមិនឲ្យបញ្ជូនស្បៀងទៅ ខណៈនោះពួកកងទ័ព**ស៊ុនកៀន**ក៏ដាច់អស់ស្បៀងអាហារ នឹងរកបាយទឹកបរិភោគពុំបានសោះអស់កម្លាំងទាំងអស់គ្នា។

ឯពួកគយល្បាតខាងស្រុកក្រុង លុះបានដឹងដំណឹងដូច្នោះ ក៏នាំយកសេចក្តីនោះទៅនិយាយបរិហារក្នុងបន្ទាយ នោះនាយទាហានឈ្មោះ**លីសុក**បានឮក៏ទៅប្រឹក្សានឹង**ហ្វួយុង**ថា ឥឡូវកងទ័ព**ស៊ុនកៀន**អត់ឃ្លានបាយទឹកសន្ធឹកណាស់ បើដូច្នេះយប់នេះខ្ញុំនឹងសុំនាំទាហានទ័ពចូលទៅខាងក្រោយបន្ទាយ**ស៊ុនកៀន** សុំឲ្យលោកលើកទ័ពចូលទៅវាយខាងមុខបន្ទាយវាយខ្ទប់ប្រសព្វគ្នា ឃើញនឹងបែកបានដោយងាយ ហើយនឹងចាប់យកខ្លួន**ស៊ុនកៀន**ឲ្យបាន។ **ហ្វួយុង**យល់ត្រូវផង ក៏ចេញទៅចាត់ចែងបែងទាហានជាពីរកងតាមដែលគិតទុកនោះ ខណៈកាលលើកពលទៅដល់បន្ទាយ**ស៊ុនកៀន**ពេលយប់យាមពីរ **ហ្វួយុង**ក៏ឲ្យទាហានវាយស្គរហោកញ្ជ្រៀវចូលប្លន់យកបន្ទាយ។

ឯ**ស៊ុនកៀន**ក៏មានសេចក្តីភ័យខ្លាំងណាស់ ស្ទុះទៅរៀបខ្លួនពាក់ក្រោះ ហើយឡើងជិះសេះកាន់ដាវចេញមកតយុទ្ធនឹង**ហ្វួយុង**បានប្រាំបីភ្លែង។ **ស៊ុនកៀន**ក្រឡេកទៅឃើញពន្លឺភ្លើងខាងក្រោយបន្ទាយភ្លឺស្រឡះ ឃើញទាហានផ្អើលបះពេញក្នុង

បន្ទាយ ខ្លះក៏រត់ព្រាត់ព្រាយស្លាប់គរលើគ្នា **ចូម៉ៅ**មីម្នាឡើងសេះបរទៅតាម **ស៊ុនកៀន**។ ពេលនោះ ទាហាន**ហួយុង**ក៏តាំងព័ទ្ធជុំវិញ **ស៊ុនកៀន**និង**ចូម៉ៅ**ក៏ស្ទុះទៅកាប់ចាក់ទម្លាយចេញទៅបាន **ហួយុង**បំផាយសេះតាមប្រកិតជិតពីក្រោយទៅ **ស៊ុនកៀន**ក៏ងាកមកវិញទាញធ្នូបាញ់**ហួយុង** ៗរាំងការពារព្រួញបានទាំងសងខាង **ស៊ុនកៀន**ថែមបាញ់ខ្នាន់ៗទៅទៀត ដងធ្នូបាក់ដាច់ជាពីរ **ស៊ុនកៀន**និង**ចូម៉ៅ**ទប់ពុំឈ្នះ ក៏បំផាយសេះរត់ទៅ **ហួយុង**ក៏បំផាយសេះតាម ។ **ចូម៉ៅ**និយាយនឹង**ស៊ុនកៀន**ថា មួកដែលលោកពាក់នោះ ពួកសត្រូវចាំបានច្បាស់ណាស់ លោកចូរផ្លាស់មកឲ្យខ្ញុំពាក់វិញ **ស៊ុនកៀន**ក៏ដោះមួកហុចឲ្យទៅ ហើយបំផាយសេះបែកផ្លូវគ្នាទៅដោយខ្លួន។ ខណៈនោះ**ហួយុង**និងទាហានក៏បំផាយសេះតាមទៅ មិនដឹងថា**ស៊ុនកៀន**ទៅខាងណាចាំសម្គាល់ច្បាស់តែមួក **ហួយុង**គិតថា**ស៊ុនកៀន**ប្រាកដជាមិតបរសេះតាម **ចូម៉ៅ** ឯ**ចូម៉ៅ**ឃើញគេដេញប្រកិតជិតខ្លួនណាស់ ក៏ផ្លាស់ដោះមួកនោះពាក់លើគល់ឈើ ហើយគេចសេះវេះចូលទៅក្នុងព្រៃ។ កាល**ហួយុង**ដេញជិតប្រកិតតាមទៅនោះក៏ជាវេលាពាក់កណ្តាលអាធ្រាត្រស្ងាត់ **ហួយុង**មិនដឹងកល**ចូម៉ៅ** មើលទៅស្គាល់បានតែមួក ទើបឲ្យទាហានចោមព័ទ្ធគល់ឈើជុំវិញ ហើយបាញ់នឹងធ្នូតម្រង់មួកនោះនៅជាយូរណាស់ លុះមិនឃើញកម្រើកសោះ **ហួយុង**ក៏នាំទាហានចូលទៅមើលក៏ឃើញឯមួកពាក់លើគល់ឈើសោះ។

ឯ**ចូម៉ៅ**កាលរត់ទៅៗពួននៅក្នុងព្រៃលបមើល ឃើញ**ហួយុង** និងទាហានចោមព័ទ្ធគល់ឈើដូច្នោះ ក៏ស្ទុះបរសេះត្រឡប់មកនឹងកាប់**ហួយុង** ទទួល**ហួយុង**ងាកទៅឃើញ ក៏ញាក់សេះស្ទុះទៅទល់មុខគ្នា **ហួយុង**ក៏ស្រែកគំហកសង្ឃកឲ្យ**ចូម៉ៅ** ហើយយកដាវកាប់ត្រូវ**ចូម៉ៅ**ដាច់ពាក់កណ្តាលខ្លួនធ្លាក់ពីលើសេះស្លាប់។

លុះព្រឹកស្វាងឡើង **ហ្សួយុង**ក៏លើកពលទាហានត្រឡប់ចូលបន្ទាយគយខាងស្រុកក្រុង ឯ**តៀផៅ** នូវ**អ៊ុយកាយ** និង**ហាន់តុង** ព្រមទាំងទាហាននានា ដែលនៅសល់ពីបែកខ្ញែកគ្នាទៅនោះ លុះលើកទៅជួបប្រទះនឹង**ស៊ុនកៀន** ៗក៏នាំត្រឡប់ចូលទៅក្នុងបន្ទាយលៀងតុង ហើយធ្វើសំបុត្របកទៅដល់**អ្វួនសៀវ**តាមដែលបានច្បាំងគ្នានោះ **អ្វួនសៀវ**បានដឹងសេចក្តីដូច្នោះក៏ទោមនស្សណាស់ ទើបប្រជុំចៅហ្វាយខេត្តទាំងអស់មកប្រឹក្សាថា ឥឡូវនេះ**ស៊ុនកៀន**ជាទាហានខ្លាំងពូកែបរាជ័យចាញ់**ហ្សួយុង**ដូច្នេះយើងនឹងគិតប្រការដូចម្តេច? មួយទៀត**ប៉ៅស៊ិន**លបប្រើ**ប៉ៅតុង**ទៅដណ្តើមច្បាំង ក៏តាំងតែអន្តរាយស្លាប់ខ្លួនទៅទៀត ហើយខូចខាតទាហានក៏ច្រើន។ វេលានោះ នាយកងនាយទ័ពទាំងពួងមិនទាន់ឆ្លើយថាដូចម្តេច ទទួល**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ** ដើរចូលទៅឈរពីក្រោយ**កងស៊ុនចាន**។ **អ្វួនសៀវ**ក្រឡេកឃើញរូបរាងអ្នកទាំងបីធំមាំមួន មានខ្លួនខ្ពស់ស្រឡះ មានអាការដូចជាញញឹមញញែម ក៏សួរ**កងស៊ុនចាន**ថា បីនាក់ដែលឈរនៅពីក្រោយអ្នកនោះឈ្មោះអ្វី? **កងស៊ុនចាន**ងាកទៅឃើញ**ឡៅពី** ក៏ទាញដៃឲ្យចូលមកឈរខាងមុខ ហើយជម្រាបថា អ្នកនោះឈ្មោះ**ឡៅពី**ជាសម្លាញ់នឹងខ្ញុំកាលនៅជាកូនសិស្សរៀនតាំងពីតូចមក ឥឡូវបានធ្វើជាចៅហ្វាយស្រុកផេងង្វនគួន។

**ចូវឆ្វ**ឆ្លើយថា **ឡៅពី**នោះ កាលគ្រាពួកចោរជូតក្បាលលឿងបានទៅជួយច្បាំងដែរ។ **កងស៊ុនចាន**ឆ្លើយទៀតថា **ឡៅពី**នេះជាពូជព្រះរាជវង្សព្រះចៅ**ហាន់តេ** មានសេចក្តីគាប់ប្រសើរក្នុងរាជការជាច្រើនគ្រា ថាហើយ**កងស៊ុនចាន**ឲ្យ**ឡៅពី**គំនាប់**អ្វួនសៀវ**ៗក៏អញ្ជើញ**ឡៅពី**ឲ្យអង្គុយក្នុងទីគួរសម ឯ**គួនអ៊ូ**, **តៀវហ៊ុយ**ក៏ចូលទៅឈរពីក្រោយ**ឡៅពី**។ ខណៈនោះ **ហ្សួយុង**យុំនាំពួកសេនាទាហានចេញទៅដល់មុខបន្ទាយ**អ្វួនសៀវ** ហើយឲ្យទាហានយកឈើវែងត្បៀតម្ជុក**ស៊ុនកៀន**លើកឡើង

ហើយប្រកាសថា រឺយអាពួកចៅហ្វាយស្រុកខេត្តក្រៅដែលជាសត្រូវក្បត់ ឯងបានចាត់ប្រើ**ស៊ុនកៀន**ឲ្យចេញទៅច្បាំង យើងក៏តាំងវាយបែកបាក់ចាក់កាប់សម្លាប់ពលទាហានជាច្រើនណាស់ហើយ ឥឡូវនេះដែលជាតួនាយធំនោះ ចូរចំពោះចេញមុខមកទៀតចុះនឹងតយុទ្ធគ្នា។ សេះបម្រើបានឮដូច្នោះ ក៏យកសេចក្ដីទៅជម្រាបដល់**អ្លួនសៀវ**ៗប្រឹក្សានឹងនាយទ័ពនាយកងថា **ហ្លួយុង**លើកទ័ពមកធ្វើអាការដូច្នេះ នរណានឹងយកអាសាចេញទៅតទល់បាន? **យូស៊ិន**ទាហាន**អ្លួនសុត**ស្រែកឡើងថា ខ្ញុំបាទនឹងសូមអាសាចេញទៅតទល់នឹង**ហ្លួយុង**។ **អ្លួនសៀវ**បានឮដូច្នោះ ក៏ចាត់ទាហានឲ្យ**យូស៊ិន** ៗលើកទាហានចេញទៅតយុទ្ធនឹង**ហ្លួយុង**បានបីភ្លែង **ហ្លួយុង**យកដាវកាប់**យូស៊ិន**ធ្លាក់ពីលើសេះស្លាប់។ សេះបម្រើយកសេចក្ដីចូលទៅជម្រាប**អ្លួនសៀវ** ៗនិងចៅហ្វាយខេត្តទាំងពួងប្រឹក្សាគ្នាថា ពេលនេះ នរណានឹងអាសាចេញទៅតយុទ្ធនឹង**ហ្លួយុង**ទៀត? ខណៈនោះ **ហាន់ហុក**ចៅហ្វាយស្រុកគីជីវឆ្លើយឡើងថា ខ្ញុំមានទាហានឯកម្នាក់ឈ្មោះ**ប្លួហង** នឹងសុំអាសាចេញទៅកាត់ក្បាល**ហ្លួយុង**មកជូនលោកឲ្យបាន។ **អ្លួនសៀវ**មានសេចក្ដីត្រេកអរណាស់ ក៏ចាត់ទាហានឲ្យ**ប្លួហង**ៗរៀបខ្លួនពាក់ក្រោះហើយ ឡើងជិះសេះកាន់ពូថៅធំជាអាវុធ លើកទាហានចេញទៅតយុទ្ធនឹង**ហ្លួយុង**បានបីភ្លែង **ហ្លួយុង**យកដាវកាប់**ប្លួហង**ធ្លាក់ពីលើសេះស្លាប់។ សេះបម្រើក៏នាំសេចក្ដីចូលទៅជម្រាប**អ្លួនសៀវ** គ្រានោះនាយកងនាយទ័ពស្ដាប់ដឹងសេចក្ដីក៏ភ័យបារម្ភណាស់ **អ្លួនសៀវ**និយាយថា ទាហានឯករបស់យើងមានពីរនាក់ឈ្មោះ**ង៉ាន់លៀង១, ប៊ុនធីវ១** តែមិនទាន់ឃើញមក បើមកហើយក៏នឹងខ្លាចអ្វីដែ**ហ្លួយុង**នោះ បើដូច្នោះគ្រានេះនឹងមាននរណាយកអាសាបាន?

ក្នុងពេលនោះ **គួនអ៊ូ**ជម្រាប**អ្លួនសៀវ**ថា ខ្ញុំបាទនឹងសុំអាសាចេញទៅកាត់ក្បាល**ហ្លួយុង**មកជូនលោក។ **អ្លួនសៀវ**ឮហើយសួរតបថា ដែលអ្នកឯងនឹងសុំ

អាសានោះតើខ្លួនជាតំណែងអ្វី? **កងស៊ុនចាន**ជម្រាបថា អ្នកនោះឈ្មោះ**គួនអ៊ូ** គឺជាប្អូន**ឡៅពី** ទីជាសេនាសេះកាន់ធ្នូ។ **អ្នួនសុត**បានឮដូច្នោះខឹងណាស់ ទើបស្រែកគំហកថា "**គួនអ៊ូ**គ្រាន់តែជាទាហានឡេវជិះសេះប៉ុណ្ណោះ អាចមកមើលងាយនាយទ័ពនាយកងចៅហ្វាយខេត្តទាំងពួង ហើយអួតអាងថានឹងសុំយកអាសាមិនគួរការសោះ ព្រោះទាហានចៅហ្វាយខេត្តទាំងអស់មាននៅច្រើនណាស់ ល្មមនឹងប្រើការតទៅគ្រប់គ្រាន់បាន" ហើយឲ្យទាហានបណ្ដេញ**គួនអ៊ូ**ចេញ។ **ចូឆ្វូ**ក៏ឃាត់**អ្នួនសុត**ថា អ្នកកុំអាលខឹងសម្បារសិនចុះ ត្រូវកលការ**គួនអ៊ូ**នេះនៅមានថ្វីដៃខ្លាំងពូកែមែន ទើបសុំយកអាសា បើមិនសមដូចមាត់ថា នឹងយកទោសដល់ស្លាប់ក៏បាន។ **អ្នួនសៀវ**ឆ្លើយថា **គួនអ៊ូ**ជាទាហានឡេវ បើនឹងឲ្យចេញទៅតយុទ្ធនឹង**ហ្វាយុង** ៗក៏គង់នឹងសើចចំអកឡកលេងថា ក្នុងកងទ័ពពួកយើងគ្មានទាហានឯកសោះឡើយ។ **ចូឆ្វូ**ឆ្លើយតបថា ខ្ញុំបានឃើញរូប**គួនអ៊ូ**នេះជាទាហានធំមាំមួនគួរជាឯកណាស់ **ហ្វាយុង**គង់មិនស្គាល់ជាទាហានឡេវទេ។ **គួនអ៊ូ**ជម្រាបថា ខ្ញុំបាទនឹងសុំយកអាសាចេញទៅគ្រានេះ បើមិនបានក្បាល**ហ្វាយុង**នាំមកជូនលោកទេ សូមឲ្យលោកយកក្បាលខ្ញុំបាទជាជំនួសចុះ។ **អ្នួនសៀវ**បានឮដូច្នោះ ក៏អស់គំនិតគិត បែរជាមានចិត្តត្រេកអរហើយទើបបានចាត់ចែងទាហានឲ្យ**គួនអ៊ូ**។ **ចូឆ្វូ**ក៏ឲ្យយកស្រាទៅកំដៅ ហើយយកមកចាក់ឲ្យ**គួនអ៊ូ**មួយពែង **គួនអ៊ូ**ឱនគំនាប់ ហើយជម្រាប**ចូឆ្វូ**ថា ខ្ញុំបាទត្រឹមតែថ្នាក់ទាហានឡេវ នឹងទទួលយកស្រាពីលោកមកទទួលទានពុំសមគួរ សូមឲ្យលោករង់បង្អង់សិនចុះ បើកាលណាខ្ញុំបាទចេញទៅបានក្បាល**ហ្វាយុង**មកជូន ខ្ញុំបាទនឹងសុំទទួលស្រាពីលោកទទួលទានជាក្រោយ ថាហើយ**គួនអ៊ូ**ក៏ឡើងសេះកាន់ដាវវែងចេញទៅតយុទ្ធនឹង**ហ្វាយុង**។

# រឿង សាមកុក

# អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៥

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**គួនអ៊ូ**ចេញទៅតយុទ្ធកាត់យកក្បាល**ហួយុង**បាន រហូតដល់**កងស៊ុនចាន** គិតលើកទ័ពទៅវាយយកស្រុកគីជីវ)*

ពេលនោះចៅហ្វាយខេត្តទាំងអស់ដែលនៅក្នុងបន្ទាយ លុះបានឮសំឡេងគងស្គរដ៏សន្ធឹកអឺងអាប់ ក៏ប្រញាប់ប្រមូលគ្នាចេញទៅមើល **គួនអ៊ូ**ច្បាំងនឹង**ហួយុង** កាលបើបានចេញទៅដល់មាត់ទ្វារបន្ទាយ ស្រាប់តែឃើញ**គួនអ៊ូ**យកក្បាល**ហួយុង**ត្រឡប់មកបោះទុកនៅមាត់ទ្វារនោះ នាយទ័ពនាយកងទាំងពួងត្រេកអរសប្បាយរីករាយទាំងអស់គ្នា ហើយម៉្មីម្នានាំ**គួនអ៊ូ**ចូលទៅគំនាប់**អួនសៀវ**។ **ចូឆូ**បានលើកពែងស្រាចេញមកគំនាប់**គួនអ៊ូ**ៗទទួលហើយគំនាប់តប ទើបលើកពែងស្រាឡើងទទួលទាន ស្រានោះក៏នៅក្តៅៗ។

ឯ**តៀវហ៊ុយ**ក៏ចូលទៅគំនាប់នាយទ័ពនាយកងហើយជម្រាបថា **គួនអ៊ូ**បងខ្ញុំបាទបានចេញទៅយកអាសា កាត់ក្បាល**ហួយុង**មកជូនហើយ ខ្ញុំបាទសូមយកអាសាវាយទម្លាយកងទ័ពចូលទៅក្នុងស្រុកក្រុង កាត់យកក្បាល**តាំងតុះ**មកជូនអស់លោកទៀត។ **អួនសុត**ឮដូច្នោះខឹងណាស់ ស្រែកគំហកហើយថា “បណ្តានាយកងនាយទ័ពទាំងពួង គេមិនទាន់យល់ឃើញប្រការម្តេច ស្រេចអ្វីលើខ្លួនមកគួននិយាយកាត់មុខអ្នកធំថាសុំអាសាទៀត! ខ្លួនជាមនុស្សអាក្រក់ណាស់”។ ថាហើយក៏ឲ្យបណ្តេញ**តៀវហ៊ុយ**ចេញអំពីទីជំនុំ។

**ចូឆ្វ**ឆ្លើយថា ធម្មតាទំនៀមធ្វើសឹកសង្គ្រាម បើអ្នកឯណាធ្វើសេចក្ដីគាប់ប្រសើរក្នុងការសង្គ្រាម លោកតែងឲ្យតុរង្វាន់តាមគុណបំណាច់យ៉ាងគួរសម បើអ្នកឯណាធ្វើការខុសលោកឲ្យចុះទោសយ៉ាងរហ័ស ដែលនឹងមកខឹងត្អះតិះដៀលដោយកាន់ឥស្សរិយយសចំពោះទីប្រជុំនោះមិនសមគួរទេ។ **អ្នួនសុត**តបថា បើរាប់អានទាហានឡេវជាឯកដូច្នេះ យើងក៏នឹងមិនចូលចិត្តគិតធ្វើការជាមួយគ្នាតទៅទៀតឡើយ នឹងលើកទាហានវិលទៅស្រុកវិញ។ **ចូឆ្វ**តបថា គ្រាន់តែនិយាយរំឭកគ្នាជាសេចក្ដីបន្តិចបន្តួចប៉ុណ្ណោះ បែរជាចង់បង់ការធំចោលនោះមិនគួរសោះ ថាតែប៉ុណ្ណោះក៏ឲ្យ**កងស៊ុនថាន**នាំ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**ត្រឡប់ទៅកាន់ទីលំនៅរៀងខ្លួន ឯ**ចូឆ្វ**ក៏ឲ្យនាំយកមាន់ទ្រាជ្រូកលបទៅឲ្យ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**។

បណ្ដាទាហាន**ហួយុង**ដែលសេសសល់ពីស្លាប់នោះ ក៏នាំត្រឡប់ចូលទៅក្នុងបន្ទាយគីស៊ុយគួនវិញ ហើយឲ្យបម្រើនាំសំបុត្របកចូលទៅជម្រាបសួរ**លីសុត** ១ បកសំបុត្រចូលទៅដល់**តាំងតុះ**១ដឹងសេចក្ដីក៏ភ័យបារម្ភណាស់ ទើបប្រឹក្សានឹង**លីយូលីប៉ោ**ថា ឥឡូវនេះ**ហួយុង**ស្លាប់ហើយ តើយើងនឹងគិតធ្វើម្ដេច? **លីយូ**ឆ្លើយថា **ហួយុង**ជាទាហានឯកស្លាប់អសារឥតការដូច្នេះ លើសពីទាហានឡេវស្លាប់មួយម៉ឺនក៏មិនធួន ឯក្នុងកងទ័ពដែលលើកមកធ្វើការគ្រានេះ គង់គប់គិតដឹងគំនិតគ្នាទៅវិញទៅមកជាកលសឹកពុំខាន សូមឲ្យលោកគិតអានចាប់**អ្នួនងុយ**សម្លាប់ចេញចុះ។ **តាំងតុះ**ឮដូច្នោះក៏ត្រូវចិត្ត ទើបបង្គាប់**លីឈុយ, គុយគី**ឲ្យនាំទាហានប្រាំម៉ឺនទៅចាប់**អ្នួនងុយ** និងបក្សពួកស្រីប្រុសទាំងអស់សម្លាប់ចេញ ហើយឲ្យកាត់ក្បាល**អ្នួនងុយ**ទៅដោតផ្ដាលនៅមុខបន្ទាយគីស៊ុយគួន ដើម្បីឲ្យ**អ្នួនសៀវ**ជាក្អួយក្រឡេកឃើញ ហើយឲ្យ**លីឈុយ**នាំពលប្រាំម៉ឺនតាំងទប់ឲ្យខ្ជាប់ខ្ជួន កុំឲ្យបន្ទាយគីស៊ុយគួនអន្តរាយ

បាន។ **លីឈុយ**, **គុយគី**ក៏នាំទាហានទាំងប្រាំម៉ឺនទៅធ្វើតាម**តាំងតុះ**បង្គាប់គ្រប់ប្រការ។

ឯ**តាំងតុះ** និង**លីយូ**, **លីប៉ោ**, **ហួនតៀវ**, **តៀវឆេ** ក៏ឃុំនាំទាហានដប់ម៉ឺនលើកទៅរក្សាគយហៅលោគួន ជាប់ព្រំនឹងស្រុកក្រុងឡុកអៀង ផ្លូវចម្ងាយប្រហែលប្រាំរយសិន (២០ គ.ម) ហើយ**តាំងតុះ**ឲ្យ**លីប៉ោ**នាំទាហានបីម៉ឺនចេញទៅតាំងបន្ទាយធំក្រៅកំពែងគយ។

សេះបម្រើដឹងការណ៍ ក៏យកសេចក្តីទៅជម្រាប**អួនសៀវ** ៗប្រឹក្សានឹងចៅហ្វាយខេត្តទាំងពួងថា **តាំងតុះ**លើកទ័ពចេញមកតាំងបន្ទាយនៅគយហៅលោគួនឥឡូវនេះយើងនឹងគិតប្រការម្តេច? **ចូវឆូ**ឆ្លើយថា ដែល**តាំងតុះ**លើកទ័ពចេញមកតាំងនៅក្រៅកំពែងនោះប្រាថ្នានឹងស្ទាក់ស្កាត់ដើមផ្លូវទុក បើដូច្នេះយើងត្រូវបែងនាយទ័ពនាយកងទាំងពួងម្នាក់មួយចំណែក លើកទៅវាយទ័ព**តាំងតុះ**កុំឲ្យតាំងនៅបាន។ **អួនសៀវ**ស្តាប់ឃើញត្រូវ ទើបចាត់ឲ្យ**អងខង១**, **តៀវប៉ោ១**, **ប៉ៅស៊ិន១**, **ខុងឡេង១**, **តៀវអៀង**, **តូកៀម១**, **កងស៊ុនចាន១** ឃុំនាំទាហានម្នាក់មួយចំណែកលើកចេញទៅ។ ឯ**ចូវឆូ** ជាមេទ័ពល្បាតចាំយកដំណឹងល្អអាក្រក់មកពន្យល់ឲ្យនាយទ័ពនាយកងទាំងពួង។

ខណៈនោះ**អងខង**បានលើកទាហានទៅដល់គយហៅលោគួនមុនគេ។ ឯ**លីប៉ោ**ដឹងការណ៍ ក៏លើកទាហានឯកបីពាន់ចេញតយុទ្ធនឹង**អងខង** ៗក៏រៀបពលតាំងជាប៉ែកឆ្វេងស្តាំ ហើយបរសេះចេញទៅឈរមុខទាហានទាំងពួង លុះក្រឡេកទៅឃើញ**លីប៉ោ** តែងខ្លួនប្រាណហ៊ឹហាក្នុងក្បួនសង្គ្រាមកាន់លំពែងជិះសេះដូច្នោះ ក៏គិតថា **លីប៉ោ**នេះសមជាទាហានសេះណាស់ ទើបស្រែកប្រាប់ទាហានថា នរណាអាចយកអាសាចេញទៅតទល់នឹង**លីប៉ោ**បាន? **ហាងយ៉ុក**ជាទាហានឯករបស់**អងខង**

ឆ្លើយសុំទទួលអាសា ហើយឡើងសេះកាន់លំពែងចេញតយុទ្ធនឹង**លីប៉ោ**បានប្រាំភ្លែង **លីប៉ោ**យកលំពែងចាក់**ហាងយ៉ុក**ធ្លាក់ពីលើសេះស្លាប់ ហើយ**លីប៉ោ**និងទាហានទាំងពួងក៏វាំលំពែងដេញចាក់កាប់សម្លាប់កងទ័ព**ហាងយ៉ុក**ជាច្រឡំបល់ ទាហានទាំងនោះក៏វិនាសស្លាប់បែកបាក់អស់ទៅ។ ទទួល**តៀវម៉ៅ** និង**អួនថាយ**លើកទាហានពាក់ព័ន្ធចូលមកទៀត លុះឃើញកងទ័ព**អងខង**បែកមកក៏បរពលចូលទៅ។ **លីប៉ោ**ឃើញទ័ពណ្ហូនបញ្ហូនមកទៀត ក៏លើកទាហានត្រឡប់ចូលបន្ទាយ ឯ**អងខង**និង**តៀវប៉ោ, អួនអ៊ុយ**ឃើញដូច្នោះ ក៏បន្ថយទាហានមកតាំងបន្ទាយនៅជិតនឹងបន្ទាយ**លីប៉ោ**ប្រមាណសាមសិបសិន (១២០០ម) **អងខង**ត្រួតរាប់ពលមើល ក៏ឃើញបាត់ខ្ចាត់ទាហានជាច្រើន។

ខណៈនោះនាយទ័ពទាំងប្រាំកង បានលើកពលមកដល់តាំងបន្ទាយនៅជាមួយគ្នា ដល់ពេលព្រឹកឡើង នាយទ័ពទាំងប្រាំបីនាក់ប្រឹក្សាគ្នាថា **លីប៉ោ**មានកម្លាំងខ្លាំងពូកែណាស់ នរណានឹងមានថ្វីដៃចេញទៅច្បាំងនឹង**លីប៉ោ**បាន? កាលប្រឹក្សាមិនទាន់ផុតសម្តី ទទួលសេះបម្រើមកប្រាប់ថា ឥឡូវនេះ**លីប៉ោ**លើកពលមកតាំងជាក្បួនទ័ពនៅមុខបន្ទាយហើយ នាយទ័ពទាំងប្រាំបីឮដូច្នោះ ក៏ឡើងមើលលើខ្នងបន្ទាយឃើញពួកទាហាន**លីប៉ោ**រេវាំក្លៀវក្លាហ៊ោកញ្ជ្រៀវគឹកកងជាច្រើនណាស់។ ខណៈនោះ មានទាហាន**តៀវអៀង**ឈ្មោះ**បកស៊ុន**ជិះសេះវាំលំពែងចេញទៅប្រយុទ្ធគ្នានឹង**លីប៉ោ**ៗ ចាក់ត្រូវ**បកស៊ុន**ធ្លាក់ពីលើសេះស្លាប់។ នាយទ័ពទាំងប្រាំបីឃើញដូច្នោះក៏ភ័យស្លុតទាំងអស់គ្នា ឈ្មោះ**ប៊ូអាន់កុក**ទាហានឯក**ខុងឡេង**ក៏ឡើងជិះសេះកាន់ដំបងដែលធំចេញទៅតយុទ្ធនឹង**លីប៉ោ**ទៀត **លីប៉ោ**ក៏ចូលទទួលតគ្នាបានដប់ពីរភ្លែង **លីប៉ោ**វាត់នឹងលំពែងត្រូវដៃ**ប៊ូអាន់កុក**ដាច់ជាពីរ ដំបងដែកក៏ខ្ទាតធ្លាក់ទៅ **ប៊ូអាន់កុក**ញាក់សេះបំផាយរត់ថយក្រោយមកវិញ។ នាយទ័ពប្រាំបីនាក់ក្រឡេកឃើញក៏ចុះពី

លើខ្នងបន្ទាយ ហើយបរពលចូលតច្បាំងនឹង**លីប៉ោ**។ **ប៊ូអាន់កុក**ត្រឡប់ចូលបន្ទាយបាន ហើយប្រឹក្សាគ្នាថា **លីប៉ោ**នោះចេញធ្វើការចម្បាំងខ្លាំងពូកែណាស់ បើនឹងនៅតសង្គ្រាមឃើញមិនងាយនឹងយកជ័យជម្នះបាន។ អ្នកឯណានឹងគិតឃើញប្រការដូចម្ដេចខ្លះ? **ចូឆ្វូ**ឆ្លើយថា ចាំបកសំបុត្រប្ដឹងទៅដល់**អ្នួនសៀវ**ឲ្យជ្រាប វេលានោះនាយទ័ពទាំងពួងក៏ប្រឹក្សាគ្នាថា នរណាចេះគិតកលសឹកដូចម្ដេចខ្លះ ដើម្បីនឹងយកខ្លួន**លីប៉ោ**ឲ្យបាន បើបាន**លីប៉ោ**ហើយគង់នឹងបានខ្លួន**តាំងតុះ**ដោយងាយ។

ខណៈនោះ សេះបម្រើចូលមកប្រាប់នាយទ័ពទាំងប្រាំបីកងថា **លីប៉ោ**លើកទាហានមកតាំងនៅមុខបន្ទាយទៀតហើយ។ នាយទ័ពទាំងប្រាំបីកង ក៏ចាត់ចែងទាហានលើកចេញទៅ ស្រែកជេរតគ្នា ទទួល**កងស៊ុនចាន**ជិះសេះកាន់លំពែងចូលទៅតយុទ្ធនឹង**លីប៉ោ**បានដប់ភ្លែង **លីប៉ោ**នោះជិះសេះដែលមានថ្វីជើងពូកែណាស់ឈ្មោះសឹកថៅ។ **កងស៊ុនចាន**អស់កម្លាំងណាស់ក្រឡះញាក់សេះថយរត់ **លីប៉ោ**ក៏ដេញតាមប្រកិតពីក្រោយ លុះដល់ជិតក៏លើកលំពែងនឹងចាក់ ទទួល**តៀវហ៊ុយ**បរសេះស្ទុះមកស្ទាក់ពីមុខជាប់ ហើយស្រែកសន្ធាប់ដោយសំឡេងខ្លាំង សេះ**លីប៉ោ**ភ័យភាំងស្ទុះថយក្រោយភ្លាត់ជើងជាច្រើនជំហាន **តៀវហ៊ុយ**រឹតតែស្រែកជេរបំពានថាអាកូនបីឪពុក អញមកនឹងច្បាំងផង ហេតុម្ដេចអាឯងញាក់សេះវេះរត់ថយទៅវិញ? **លីប៉ោ**ខឹងណាស់ក៏ញាក់សេះចូលតយុទ្ធនឹង**តៀវហ៊ុយ**បានហាសិបភ្លែង មិនទាន់ចាញ់ឈ្នះ។ **គួនអ៊ូ**ឃើញកម្លាំង**តៀវហ៊ុយ**ទន់ជាង**លីប៉ោ** ក៏បរសេះចូលទៅតយុទ្ធនឹង**លីប៉ោ**ទៀតបានសាមសិបភ្លែង **ឡៅពី**ក៏បរសេះកាន់គ្រប៊ីដៃទាំងសងខាងចូលទៅជួយ។ ខណៈនោះសេះ**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**ចោមព័ទ្ធសេះ**លីប៉ោ**ជាបីជ្រុង **លីប៉ោ**ក៏តាំងតែប្រយុទ្ធដោយគុនអាវុធការពារខ្លួនទាំងសងខាង លុះឃើញប្រឡោះក៏ទៅចាក់**ឡៅពី**នឹងលំពែង **ឡៅពី**យកគ្រប៊ីកាត់ជាប់ ហើយបរសេះសន្ធាប់ចូលទៅនឹង

ចាក់**លីប៉ោ**ៗឃើញស្នៀតអាវុធព័ទ្ធជុំខ្លួនដូច្នោះ ក៏បរសេះស្ទុះទម្លុះចេញបាន ហើយនាំទាហានចូលបន្ទាយហៅលោគួន។

ឯ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** និងនាយទ័ពទាំងប្រាំបីកងនាំពលទាហានលើកតាមទៅដល់ទល់នឹងកំពែងបន្ទាយ ឲ្យទាហានវាយទម្លាយជុំវិញ។ **លីប៉ោ**ឡើងទៅលើជើងបន្ទាយ ហើយឲ្យពលទាហានបាញ់នឹងធ្នូ ចោលដុំថ្មចុះព្រោងព្រាតហាក់បីដូចគ្រាប់ភ្លៀង។ នាយទ័ពទាំងពួងឃើញថានឹងវាយរំលំមិនបែក ក៏លើកទាហានថយចូលបន្ទាយវិញ ហើយតែងសេចក្ដីសំបុត្របកប្ដឹងទៅដល់**អ្លួនសៀវ** ៗដឹងសេចក្ដីក៏មានចិត្តសោមនស្សត្រេកអរណាស់ ទើបចាត់សំបុត្រទៅឲ្យ**ស៊ុនកៀន**ស្រួតលើកទ័ពចូលមកខ្ទប់វាយបន្ទាយគីស៊ុយគួនបាន។ ឯ**ស៊ុនកៀន**បានទទួលសំបុត្រដឹងសេចក្ដីហើយ ក៏ដឹងថាមានមនុស្សញុះញង់**អ្លួនសុត**មិនឲ្យបញ្ជូនស្បៀងអាហារទៅឲ្យ ទើបចាត់ទាហានឲ្យទៅរក្សាបន្ទាយ ខ្លួនក៏នាំ**សៀវផៅ** និង**អ៊ុនកាយ**ទៅរក**អ្លួនសុត**ជានាយទ័ពណ្យូន។ **ស៊ុនកៀន**និយាយនឹង**អ្លួនសុត**ថា **តាំងតុះ**ធ្វើការអាក្រក់ជាសត្រូវក្បត់ផែនដី ហើយតាំងខ្លួនជាធំ មិនមែនមកធ្វើដល់ខ្លួនយើងឲ្យរំខានអ្វីក៏ទេ ដែលយើងខំឧិហាតមកធ្វើការ ដោយនឿយព្រួយលំបាកជាមួយនឹង**អ្លួនសៀវ**គ្រានេះ ព្រោះតាំងចិត្តជាសុចរិតត្រង់នឹងផែនដី ហើយដើម្បីនឹងរំលាង**តាំងតុះ**ដែលសម្លាប់**អ៊្លួនងុយ**ដែលជាមាអ្នកនោះចេញផង យើងក៏ទ្រាំរងគ្រាប់រំសេវព្រួញនិងគ្រឿងអាវុធមិនគិតសេចក្ដីស្លាប់។ យើងឲ្យដំណឹងប្រាប់អ្នកឲ្យបញ្ជូនស្បៀងអាហារទៅឲ្យទាហាន ហេតុម្ដេចអ្នកមានចិត្តឫស្យាមិនចាត់ការឲ្យយើងតាមសុំ ខ្លួនអ្នកធ្វើជាធំ ហើយមកស្ដាប់ពាក្យមនុស្សញុះញង់ដូច្នេះមិនគួរការ ដែលអ្នកបង្អង់ស្បៀងអាហារសេនាទាហានវេលានេះ បានជាយើងត្រូវបរាជ័យដល់បច្ចាមិត្ត គួរឲ្យយើងឈឺចិត្តទោមនស្សនឹងអ្នកខ្លាំងណាស់។

**អ្លួនសុត**បានឮសម្ដី**ស៊ុនកៀន**និយាយប្រៀបប្រាយដូច្នេះ ក៏មានចិត្តអៀនខ្មាសណាស់ ទើបឲ្យយកខ្លួនទាហានដែលញុះញង់មិនឲ្យបញ្ជូនស្បៀងអាហារនោះទៅពិឃាដជីវិតចំពោះមុខ**ស៊ុនកៀន**។ ខណៈនោះសេះបម្រើនៅក្នុងបន្ទាយ**ស៊ុនកៀន**មកឲ្យដំណឹងថា ឥឡូវនេះ**លីឈុយ**ជិះសេះចេញពីបន្ទាយអឺស៊ុនគួន ថានឹងមករកលោក។ **ស៊ុនកៀន**បានស្ដាប់ក៏លា**អ្លួនសុត**ត្រឡប់ទៅបន្ទាយ ហើយឲ្យរកខ្លួន**លីឈុយ**ចូលមកជួបក៏សួរថា អ្នកមកនេះមានការអ្វី? **លីឈុយ**ឆ្លើយថា មហាឧបរាជឲ្យខ្ញុំមកនិយាយប្រាប់អស់ទាំងចៅហ្វាយខេត្ត ដែលគប់គិតគ្នាមកធ្វើសង្គ្រាមទាំងនេះ ឯមហាឧបរាជនឹងបានកោតញញើតខ្លាចអ្នកឯណាទេ គិតនឹងឲ្យចាប់សម្លាប់ចេញទាំងអស់ តែឥឡូវទ្រង់មានមេត្តាដល់អ្នកតែមួយនឹងបណ្ដោយឲ្យស្លាប់ជាមួយនឹងគេក៏មិនគួរសោះ បើនឹងឲ្យអ្នកដទៃមកចរចាជាមួយនឹងអ្នកពីការនេះទៅ ក្រែងអ្នកសម្គាល់ថាជាកិច្ចបញ្ឆុះបញ្ចូល ហេតុនេះបានជាមហាឧបរាជចាត់ខ្ញុំឲ្យមកហាមឃាត់អ្នក កុំឲ្យចូលដៃគិតជាមួយនឹងចៅហ្វាយខេត្តទាំងពួងព្រោះមហាឧបរាជប្រុងនឹងលើកកូនក្រមុំផ្សំផ្គុំនឹង**ស៊ុនសេក**ជាកូនអ្នក នឹងបានជាមេត្រីរាប់អានគ្នាតទៅ។

**ស៊ុនកៀន**បានស្ដាប់ដូច្នោះក៏ទាស់ចិត្តខ្លាំង តាំងតែស្រែកគំរាមគំហកហើយថា អា**តាំងតុះ**នោះជាមនុស្សក្បត់ផែនដីទាំងមូល ក្ដៅរំជួលគ្រប់ដើមស្មៅនូវដើមឈើព្រៃទាំងអស់ យើងរិះគិតគ្នានឹងប្រហារវាចេញ ទើបកេណ្ឌកងសេនាយោធាលើកមកនេះ បើចាប់បានខ្លួនវាវេលាណា ត្រូវប្រហារឲ្យអស់ប្រាំពីរជួរគោត្រ ទើបអាណាប្រជានុរាស្ត្រទាំងពួងនឹងបានសេចក្ដីសុខក្សេមក្សាន្ត ដែល**តាំងតុះ**នឹងលើកកូនក្រមុំមកឲ្យជាភរិយា**ស៊ុនសេក**កូនយើង យកយើងធ្វើជាដន្លងនឹង**តាំងតុះ**សត្រូវរាជសម្បត្តិនោះ យើងមានសេចក្ដីអៀនខ្មាសពន់ពេកណាស់ មួយទៀតទោសដែល

អ្នកចេញមកនិយាយបញ្ចុះបញ្ចូលយើងនេះ យើងលើកចោលគ្រានេះម្តងចុះ អ្នកចូរស្រូតរូតត្រឡប់ចូលទៅបបួលពលទាហានទាំងពួង ឲ្យចូលមកជាចិត្តមួយនឹងយើងត្រូវបើកទ្វារបន្ទាយចាំទទួលយើងចុះ យើងនឹងលើកទាហានចូលទៅចាប់**តាំងតុះ**សម្លាប់ចេញ បើអ្នកនិងទាហានទាំងពួងមិនធ្វើតាមយើងពន្យល់ដូច្នេះទេ កាលណាយើងលើកទៅកាច់យកស្រុកបាន យើងត្រូវប្រហារជីវិតឲ្យអស់មិនសល់។ **លីឈុយ**បានស្តាប់ក៏ស្លុតចិត្តគិតខ្លាច ហើយលា**ស៊ុនកៀន**ស្រូតត្រឡប់ចូលទៅប្រាប់**តាំងតុះ**ៗបានស្តាប់ក៏ខឹងណាស់ ទើបប្រឹក្សានឹង**លីយូ**ថា ដែលយើងនឹងទៅបញ្ចុះបញ្ចូល**ស៊ុនកៀន**មិនព្រមចូលចិត្តនឹងយើងនោះ អ្នកនឹងឃើញប្រការដូចម្តេច? **លីយូ**ឆ្លើយថា ដែល**លីប៉ោ**បង់ប្រៀបគ្រានេះ ទាហានទាំងពួងក៏មានតែរាចិត្តថយចុះ សុំឲ្យលោកលើកទាហានចូលទៅក្រុងសិន ហើយអញ្ជើញព្រះចៅ**ហៀនតេ**ទៅប្រថាប់ឯស្រុកតៀងហាន់ ព្រោះខ្ញុំបានឮភ្លេងក្នុងស្រុកចៀងទំនុកភ្លេងថា “ត័ងចៅអ៊ិតកោហ័ន សៃចៅអ៊ិតកោហ័ន ឡុកចៅយិបតៀងហ័នហាង កោបឈ្យូល័ន” ប្រែថា “ទិសឯលិចមានស្រុកតៀងហ័ន១ ទិសឯកើតក៏មានស្រុក បើប្រើសបោលចូលក្នុងស្រុកតៀងហ័នហើយ ក៏មិនមានភ័យអន្តរាយឡើយ” ខ្ញុំបាទគិតឃើញក្នុងពាក្យភ្លេងនោះថា ពីដើមព្រះចៅ**ហ័នកូចូ**បានសាងព្រះរាជធានីនៅស្រុកតៀងហ័ន ហើយមានព្រះមហាក្សត្រសោយរាជសម្បត្តិតៗគ្នាមកបានដប់ពីរព្រះអង្គ ក្រោយនោះព្រះចៅ**ហ័នកងប៊ូ**បានកសាងព្រះរាជធានីនៅស្រុកឡុកអៀងវិញ មានព្រះមហាក្សត្រសោយរាជសម្បត្តិជាលំដាប់គ្នាមក លុះដល់ព្រះចៅ**ហៀនតេ**មានដប់ពីរព្រះអង្គដែរ ខ្ញុំឃើញថាពូជព្រះរាជវង្សព្រះចៅ**ហ័នកងប៊ូ**នឹងសាបសូន្យគ្រានេះហើយ រាជសម្បត្តិនោះគង់នឹងធ្លាក់បានមកលោកជាប្រាកដ បើអ្នកបានទៅកសាងរាជធានីនៅស្រុកតៀងហ័នវេលាណា ក៏នឹងមិនមានកើតភ័យអន្តរាយអ្វីឡើយ។ **តាំងតុះ**បានស្តាប់ហើយក៏មាន

សេចក្ដីត្រេកអរជាអនេក ហើយនិយាយនឹង**លីយូ**ថា ដែលអ្នកអធិប្បាយឲ្យយើងស្ដាប់វេលានេះ យើងចូលចិត្តគិតឃើញត្រូវ។ ថាហើយក៏លើកទ័ពត្រឡប់ទៅស្រុកក្រុង។ លុះវេលាព្រឹកភ្លឺស្វាងឡើង **តាំងតុះ**ឲ្យប្រជុំនាហ្មឺនមុខមន្ត្រីតូចធំមកព្រមគ្នាក្នុងទីគាល់ ហើយនិយាយថា យើងមើលក្នុងតម្រាឃើញជតាស្រុកឡុកអៀង ដែលនៅខាងទិសឯកើត នឹងរៀវរោយសាបសូន្យហើយ ស្រុកទិសឯលិចនឹងវឌ្ឍនាចម្រើនរុងរឿងទៅខាងមុខ យើងនឹងអញ្ជើញព្រះថៅ**ហៀនតេ** ស្ដេចទៅសាងព្រះរាជធានីនៅក្នុងស្រុកតៀងហ័ន បើដូច្នេះត្រូវអស់អ្នករាល់គ្នាលើកគ្រប់គ្រួទៅតាមសាងទីលំនៅៗទីនោះឯង។

**អៀវពៀវ**ឆ្លើយថា ឯស្រុកឡុកអៀងនេះព្រះថៅ**ហ័នកងប៊ូ**សាងក្រុងសោយរាជសម្បត្តិមកជាយូរហើយ មានព្រះមហាក្សត្រដល់ដប់ពីរព្រះអង្គ ដែលលោកនឹងឲ្យលះបង់ស្រុកនេះ លើកគ្នាទៅនៅស្រុកតៀងហ័ននោះ ខ្ញុំឃើញថាអាណាខេត្តនឹងកើតចលាចលបណ្ដាប្រជាជនក៏នឹងបានសេចក្ដីក្ដៅក្រហាយ ដូចមានពាក្យបុរាណថា "ធម្មតាផ្ទះដែលនឹងរើរុះនោះងាយណាស់ លុះនឹងសង់ឡើងវិញក៏បានដោយកម្រ" បើមិនស្ដាប់ពាក្យខ្ញុំខំតែលើកទៅតាំងនៅស្រុកតៀងហ័នហើយ បណ្ដារាស្ត្រនឹងបានសេចក្ដីភ្ញាក់ផ្អើលបែកខ្ចាត់ខ្ចាយអស់ លុះនឹងកៀរប្រមូលឲ្យមូលមកវិញបានដោយក្រណាស់ ដែលខ្ញុំជម្រាបទាំងនេះ សូមលោកត្រិះរិះមើលតាមសមគួរ។

**តាំងតុះ**បានឮក៏ខឹងខ្លាំងណាស់ទើបនិយាយថា ខ្លួនយើងជាមហាឧបរាជ នឹងបង្គាប់បញ្ជាការអ្វីក៏ជាសិទ្ធិប្រាកដ យើងមើលតម្រាឃើញថា នឹងកើតមានអន្តរាយទើបបានជានិយាយពន្យល់ដូច្នេះ ហេតុអ្វីខ្លួនមកចេះឃាត់ឃាំងទទឹងនឹងពាក្យរបស់យើង?

**អ៊ុយអ៊ួន**ផ្ទួនឡើងថា ដែល**អៀវពៀវ**ទទឹងកាត់នោះត្រូវណាស់ ព្រោះកាល**អងម៉ាំង**ជាសត្រូវក្បត់ដណ្ដើមយករាជសម្បត្តិ ហើយដុតស្រុកវិនាសអស់ទៅ ស្រុកនោះក៏ទៅជាព្រៃផ្សៃ ដែលលោកនឹងលះបង់ស្រុកនេះហើយទៅយកព្រៃធ្វើស្រុកនោះ ខ្ញុំឃើញមិនគួរសម។

**តាំងតុះ**តបថា យើងឃើញខាងទិសឯកើត កើតចលាចលដោយពួកចោរធ្វើអន្តរាយផ្សេងៗមកជាច្រើនគ្រាហើយ ខាងស្រុកតៀងហ័ននោះពីដើមក៏ជាទីក្រុងដែរ យើងឃើញគួរសមដោយភ្នំនិងថ្មសិលា គួរនឹងចាត់ការរៀបស្រុកបានមិនលើសពីមួយខែ ក៏នឹងជាសុខសប្បាយជាមួយគ្នា ហេតុនេះកុំបីអ្នកទាំងពួងទទឹងទាស់តទៅទៀតឡើយ។

**ស៊ុនសង**ឆ្លើយកាត់**តាំងតុះ**ដូចពាក្យ**អ៊ុយអួន**។ **តាំងតុះ**ឆ្លើយថា យើងនឹងទំនុកបម្រុងរាជសម្បត្តិនេះជាការធំមាំមួនណាស់ ឧបមាដូចគាស់រំលើងគល់ឈើធ្វើស្រែចម្ការ បើនឹងស្ដាយគល់ឈើ កាលណានឹងបានស្រូវស៊ី។ ថាហើយ**តាំងតុះ**ក៏ឲ្យដកហូតងារពី**អៀវពៀវ**, **អ៊ុយអួន**, និង**ស៊ុនសង**ចេញចាកតំណែងមន្ត្រីខ្ញុំរាជការ ហើយ**តាំងតុះ**ឯងឡើងជិះរទេះនឹងទៅកាន់ទីលំនៅ ។ លុះចេញទៅដល់ក្រៅទ្វារព្រះរាជវាំង ប្រទះ**អៀវពៀវ** និង**ងៅខេង**ចូលមកគំនាប់ពីមុខរទេះ **តាំងតុះ**សួរថា អ្នកទាំងពីរមានការមករកអ្វី? **អៀវពៀវ** និង**ងៅខេង**ជម្រាបថា យើងខ្ញុំបានឮកិត្តិស័ព្ទថាលោកនឹងលះបង់ចោលស្រុកនេះទៅសាងក្រុងនៅស្រុកតៀងហ័ន យើងខ្ញុំយល់ឃើញមិនសមគួរ ទើបចូលមកជម្រាបឃាត់លោក។ **តាំងតុះ**បានស្ដាប់ក៏ក្រេវក្រោធហើយថា ឯងទាំងពីររូបនេះកាលពីពេលមុន បាននិយាយឲ្យយើងតាំង**អួនសៀវ**ជាចៅហ្វាយខេត្ត យើងបានធ្វើតាមសម្ដីឯងទាំងពីរនាក់ ឥឡូវនេះ**អួនសៀវ**ត្រឡប់មកប្រទូសរាយនឹងយើងវិញ ប្រហែលជាគាត់ឯងទាំងពីរនាក់ចូលគំនិតគិត

ធ្វើកលជាមួយនឹង**អ្នួនសៀវ**ពិតមែន ថាហើយក៏បង្គាប់ពេជ្ឈឃាដឲ្យចាប់**អៀវពៀវ**និង**ជៅខេង**ទៅសម្លាប់ក្នុងគ្រានោះ។ ហើយ**តាំងតុះ**ក៏ហួសទៅដល់ទីលំនៅ ទើបកំណត់ពេលដែលនឹងលើកគ្រប់គ្រួសារទៅតាំងវាំងកំពែងនៅស្រុកតៀងហ័ន។

ពេលនោះ**លីយូ**ជម្រាបថា ដែលលោកនឹងលើកគ្រប់គ្រួទៅសាងទីក្រុងនោះ ស្បៀងអាហារនិងមាសប្រាក់ក្នុងផ្ទៃព្រះឃ្លាំងមានមិនច្រើនទេ ឃើញចាត់ការមិនគ្រប់គ្រាន់ នៅក្នុងស្រុកឡុកអៀងមានសេដ្ឋីគហបតីដែលមានភោគសម្បត្តិក៏ច្រើន សូមឲ្យលោកទៅរឹបជាន់រើយកមកដាក់ឃ្លាំងឲ្យហើយ ទើបនឹងគិតធ្វើការនេះបានដោយងាយ មួយទៀតបណ្ដាបក្សពួក**អ្នួនសៀវ**ដែលនៅក្នុងស្រុកក្រុងនេះក៏ច្រើន សូមឲ្យលោកចាប់សម្លាប់ចេញឲ្យអស់ ហើយរឹបយកទ្រព្យរបស់មកដាក់ឃ្លាំងកុំឲ្យសល់។ **តាំងតុះ**ស្ដាប់យល់ត្រូវក៏ចាត់សេនាទាហានប្រាំពាន់នាក់ ឲ្យទៅសង្កត់សង្កិនពួកអាណាប្រជាជនដែលមានទ្រព្យសម្បត្តិមាសប្រាក់នោះយកមកទាំងអស់ ក្នុងពេលនោះ**តាំងតុះ**បានទ្រព្យសម្បត្តិច្រើន។ លុះស្រេចការហើយ **តាំងតុះ**ក៏ឲ្យ**លីឈុយ, គុយគី**បណ្ដេញបំបរអាណាប្រជានុរាស្ត្រក្នុងស្រុកឡុកអៀង ឡើងទៅនៅក្នុងស្រុកតៀងហ័នមិនមានសល់ដល់ម្នាក់។

កាល**លីឈុយ, គុយគី**បណ្ដេញបំបរអាហារប្រជានុរាស្ត្រទៅនោះ មនុស្សអ្នកនគរទាំងប្រុសទាំងស្រីក្មេងចាស់ប្រហែលប្រាំមួយទៅប្រាំពីររយម៉ឺននាក់ និងទាហាន**តាំងតុះ**ក៏លើកពពាក់ពពូនទៅជាកងៗ មនុស្សផងជ្រៀតបៀតជាន់គ្នាស្លាប់ក៏មាន ទាហានខ្លះក៏មកដណ្ដើមយកទ្រព្យរបស់បណ្ដារាស្ត្រ ខ្លះក៏អូសកន្ត្រាក់យកភរិយាបុត្រគេទៅធ្វើបរទាកម្មតាមអំពើចិត្តឥតកោតខ្លាច រាស្ត្រទាំងនោះសឹងលុះដោយអំណាច ដែលគេគំហកកំហែងជាចលាចល មនុស្សទាំងក្មេងទាំងចាស់ខ្លះទួញយំតាមផ្លូវទៅ មុខគួរឲ្យអនោចអធម៌ពន់ពេក។

ឯ**តាំងតុះ**ត្រៀមការទាំងអស់ស្រេចហើយ ក៏ឲ្យទាហានយកភ្លើងឆួលអុជព្រះរាជវាំង និងផ្ទះសម្បែងបណ្តាដែលមានក្នុងស្រុកឡុកអៀងនោះឆេះទាំងអស់ ហើយឲ្យ**លីប៉ោ**នាំពលទាហានទៅជីករំលំរំលើងព្រះបរមសព នៃព្រះមហាក្សត្រពីបុរាណ ដែលមានផ្នូរបញ្ចុះទុកតមក ហើយកាយរើយកមាសប្រាក់ដែលនៅជាមួយនឹងសពនោះជាច្រើន ទាហានខ្លះក៏បន្លំជីកគាស់កកាយយកទ្រព្យរបស់ក្នុងសពរបស់អាណាប្រជានុរាស្ត្រមកជាប្រយោជន៍រៀងខ្លួន។ **តាំងតុះ**ក៏ឲ្យដញ្ជូនទ្រព្យទាំងនោះផ្ទុកលើរទេះជាងពាន់ បរសន្ទឹកលាន់ទាំងប្រចពីចេញទៅ ហើយក៏អញ្ជើញព្រះចៅ**ហៀនតេ**ស្តេចទៅជាមួយនឹងស្រីស្នំក្រមការ និងខ្ញុំរាជការទាំងពួង។

ខណៈនោះ **តៀវងឹម**ដែលចេញទៅតាំងបន្ទាយនៅគយគីស៊ុនគួន ជាមួយនឹង**ហួយុង**ដែលស្លាប់ ហើយនិងទាហានដែលនៅរក្សាគយហៅឈោគួននោះ លុះដឹងថា **តាំងតុះ**ចោលស្រុកឡុកអៀងហើយ **តៀវងឹម**ក៏នាំទាហានទាំងអស់នោះទៅតាម **តាំងតុះ** ។

ឯ**ស៊ុនកៀន** កាលឃើញបន្ទាយគីស៊ុនគួនស្ងាត់ឥតមនុស្សម្នាដូច្នោះ ក៏ពិគ្រោះនឹងនាយទ័ពទាំងប្រាំបីហើយនិង**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ដើម្បីស្តាប់ការ។ លុះដឹងថា **តាំងតុះ**លើកពលទាហានទៅអស់ហើយ ក៏បរពលចូលទៅក្នុងស្រុកឡុកអៀង កាលចូលទៅដល់ ក៏ក្រឡេកទៅឃើញភ្លើងកំពុងឆេះផ្ទះសម្បែងពេញក្នុងស្រុកនោះ នឹងរកមនុស្សក៏មិនឃើញមានសោះ នោះនាយទ័ពទាំងពួង ក៏ចាត់ឲ្យទាហានចូលលត់ភ្លើងរលត់អស់ហើយក៏តាំងទ័ពនៅទីនោះ។

**ចូឆូ**ជម្រាប**អួនសៀវ**ថា **តាំងតុះ**ឲ្យដុតស្រុកចោល បានលើកទាហានរត់ទៅខាងទិសឯលិចហើយ ឯព្រះចៅ**ហៀនតេ**សោតយើងមិនទាន់ដឹងជាក់ច្បាស់ជាល្អ ឬអាក្រក់ វេលានេះអាណាប្រជានុរាស្ត្រកំពុងមានសេចក្តីក្តៅក្រហាយវរវីកណាស់

បើដូច្នោះត្រូវតែយើងលើកទ័ពទៅតាមដើម្បីនឹងចាប់**តាំងតុះ**បានដោយងាយ ហេតុម្ដេចលោកនៅស្ងៀមដូច្នេះ?

**អ្នួនសៀវ**និងចៅហ្វាយខេត្តទាំងពួងឆ្លើយថា ទាហានយើងកំពុងនឿយហត់ណាស់ ចាំឈប់សម្រាកកម្លាំងបន្តិចសិនសឹមគិតការលើកតាមទៅ។ **ចូឆ្វ**បានស្ដាប់ហើយក៏នឹកតែក្នុងចិត្តថា ការដែលមករួមគំនិតគិតធ្វើជាមួយចៅហ្វាយខេត្តទាំងនេះជាការធំមាំមួនណាស់ តែបីដូចជាទៅគិតគ្នាជាមួយនឹងក្មេងក្មេងគង្វាលគោ។ គិតដូច្នោះហើយក៏រៀបចាត់ចែងទាហាន ដែលជាបក្សពួករបស់ខ្លួនបានប្រហែលមួយម៉ឺនប្លាយ ហើយក៏នាំ**ហែហ្សូទុន, ហែហ្សូអៀន, ចោហង, ចោយិន, លីតៀន, ង៉ាក់ជិន** និងទាហានទាំងពួងស្រូតលើកតាម**តាំងតុះ**ទាំងថ្ងៃទាំងយប់។

ឯ**តាំងតុះ**កាលលើកពលទៅដល់ស្រុកអេងយ៉ុង នោះ**ស៊ីអេង**ជាចៅហ្វាយស្រុកដឹងដំណឹងក៏ចេញមកទទួល**តាំងតុះ**។ **លីយូ**ជម្រាប**តាំងតុះ**ថា យើងលើកពលចេញពីស្រុកក្រុងមកគ្រានេះ ខ្លាចក្រែងពួកសត្រូវនឹងលើកតាមមកពីក្រោយ បើពួកយើងនឹងតទល់មិនបាន ឃើញនឹងខូចការធំ ដូច្នេះសូមឲ្យ**ស៊ីអេង**ឃុំនាំទាហានទៅបង្កប់នៅលើភ្នំចំដើមផ្លូវចុះ បើកងទ័ពទាំងប្រាំបីស្រុកលើកមកតាមមែន ក៏ឲ្យ**ស៊ីអេង**ចេញតទល់ជាមុន ប្រសិនកងទ័ពគេទម្លាយចូលមកបានតនឹងកងទ័ពយើង ៗឲ្យ**ស៊ីអេង**ចេញវាយខ្ទប់ពីក្រោយថែមមកទៀត ទ័ពដែលតាមមកគង់នឹងចាញ់ប្រៀបយើងជាប្រាកដ។ **តាំងតុះ**បានស្ដាប់យល់ឃើញត្រូវ ទើបបង្គាប់ឲ្យ**ស៊ីអេង**ឃុំនាំទាហានលើកទៅបង្កប់លើភ្នំដើមផ្លូវនោះ ហើយឲ្យ**លីប៉ោ**និង**លីឈុយ, គុយគី**លើកទាហានតាមទៅដើរជាទ័ពក្បួនក្រោយ។

ពេលនោះ**ចូឆ្វូ**ក៏លើកទ័ពឆ្លងតាមដើមផ្លូវឡើងទៅ លុះ**លីប៉ោ**ឮសន្ធឹករេហ៍ពលលើកតាមអឹងអាប់មក ទើបគិតឃើញថា **លីយូ**នេះជាមនុស្សមានសតិបញ្ញា

វាងវៃជាប្រាកដ គិតអ្វីក៏គ្មានដែលខុស។ **លីប៉ោ**កាលឃើញទ័ព**ចូឆ្វ**លើកមកជិតហើយ ក៏ឲ្យត្រឡប់មុខទាហានទៅទទួលតទល់ **ចូឆ្វ**ក៏ជិះសេះស្ទុះចេញទៅខាងមុខទ័ពហើយស្រែកថា អាសត្រូវរាជសម្បត្តិ! អាឯងនាំព្រះចៅ**ហៀនតេ**យកទៅណា? **លីប៉ោ**ឮច្បាស់ខឹងណាស់តបទៅវិញថា អាឯងចំជាមនុស្សអកតញ្ញូ មហាឧបរាជជប់លៀងឲ្យបានសេចក្តីសុខ អាឯងគ្មានដឹងគុណលោកសោះ បែរជាប្រទូសចំពោះលោកវិញ លុះមិនសម្រេចតាមសេចក្តីប្រាថ្នា ក៏ភៀសខ្លួនរត់បាត់ទៅ ទើបតែឥឡូវនេះមកគប់គិតគំនិតអាក្រក់តាមប្រទូសលោកទៀត។ ក្នុងពេលនោះ**ហែហួទុន**ញាក់សេះស្ទុះទៅតយុទ្ធនឹង**លីប៉ោ**បានប្រាំស្នៀត **លីឈុយ**ក៏បំផាយសេះចូលទៅតទល់ពីខាងស្តាំ **ចូឆ្វ**ក៏ប្រើ**ហែហួអៀន**ឲ្យបរសេះចេញទៅតនឹង**លីឈុយ** ឯ**គុយគី**ក៏បរសេះចូលទៅតពីខាងឆ្វេង **ចូឆ្វ**ប្រើ**ថោឃិន**ឲ្យបរសេះចេញទៅតទល់នឹង**គុយគី**ជាច្របូកច្របល់គ្នា សំឡេងទាហានទាំងសងខាងក៏លាន់ឮគគ្រឹកគគ្រេងហុយផ្សែងអ័ព្ទទិសទី ព្រះធរណីហាក់បីដូចជានឹងក្រឡាប់ **ហែហួទុន**ឃើញថាកម្លាំងខ្លួនមិនធួននឹងកម្លាំង**លីប៉ោ** ក៏ញាក់សេះវេះស្រឡប់មកក្រោយ **លីប៉ោ**ក៏បរសេះស្ទុះដេញបណ្តោយតាម កាប់ទាហាន**ចូឆ្វ**បែកខ្ចាត់ខ្ចាយអន្តរាយស្លាប់ជាច្រើន។ ឯ**ចូឆ្វ**និងទាហានដែលនៅសល់នោះក៏ស្ទុះត្រឡប់ថយទៅដល់ភ្នំដើមផ្លូវ ត្រូវពេលនោះក៏យប់យាមពីរភ្លឺដោយពន្លឺព្រះចន្ទ ក្រឡេកឃើញពលទាហានហត់នឿយណាស់ ក៏ប្រាសចេញពីផ្លូវទៅសម្រាកឈប់ឲ្យទាហានដាំបាយទឹកបរិភោគ មិនទាន់ទាំងឆ្អិនបាយផង ស្រាប់តែ**ស៊ីអេង**ដែលលើកពលទៅបង្កប់ត្រឡប់ចេញមកស្ទាក់ពីមុខ ទាហាន**ចូឆ្វ**ក៏ផ្អើលគឹលរត់ត្រសុកចូលព្រៃខ្ចាត់ខ្ចាយអស់ទៅ នៅតែ**ចូឆ្វ**ប្រវាឡើងសេះបំផាយតាមផ្លូវទៅប្រទះនឹង**ស៊ីអេង**។ **ចូឆ្វ**ក៏ភ័យវង្វេងស្មារតីញាក់សេះវេះទៅខាងព្រៃ **ស៊ីអេង**ក៏ឃឹតធ្នូបាញ់ទៅត្រូវជាប់ស្មា**ចូឆ្វ** ៗក៏បំផាយសេះរត់កាត់មុខទៅ ទាហាន**ស៊ីអេង**ក៏

យកលំពែងចាក់ត្រូវសេះ**ច្វូឆ្វ**ដួលចុះ ហើយក៏ស្ទុះទៅចាប់ខ្លួន**ច្វូឆ្វ**បាន។ ខណៈនោះ **ចោហាង** ទទួលតាមមកឃើញទាហាន**ស៊ីអេង**ចាប់**ច្វូឆ្វ**ទុក ក៏ដេញលុកកាប់ទាហាននោះស្លាប់ដេរដាស ខ្លះក៏ក្រឡាស់រត់ចោល**ច្វូឆ្វ**ទៅ **ច្វូឆ្វ**ត្រូវព្រួញឈឺចាប់ញាប់ញ័រអស់ទាំងសព៌ាង្គកាយ ហើយនិយាយទៅនឹង**ចោហាង**ថា ខ្លួនយើងមុខជានឹងស្លាប់ហើយ បើដូច្នេះអ្នកចូរជួយយកអាយុយើងផង។ **ចោហាង**និយាយថា លោកអញ្ជើញឡើងជិះសេះចុះ ខ្ញុំនឹងដើរច្បាំងរាំងពីខាងមុខ។ **ច្វូឆ្វ**ឆ្លើយតបថា ដែលអ្នកដើរជើងនោះនឹងច្បាំងបានដូចជាជិះសេះដែរឬទេ? **ចោហាង**តបថា ស្រុកកើតចលាចលគ្រានេះគ្មាននរណានឹងជួយទំនុកបម្រុងសោះ មានតែលោកជាដើមគំនិតគិតនាំចៅហ្វាយខេត្តទាំងពួងមកធ្វើការជាមួយ ឯជីវិតរបស់ខ្ញុំបើស្លាប់ក៏ស្លាប់ចុះ សុំឲ្យរួចរស់តែជីវិតលោកនឹងបាននៅគិតការផែនដីតទៅ។ **ច្វូឆ្វ**បានឮសម្ដី**ចោហាង**ដូច្នេះក៏ឆ្លើយតបថា ខ្ញុំមានអំណរគុណនឹងអ្នកច្រើន ថាហើយក៏ឡើងជិះសេះ។ ឯ**ចោហាង**ដោះក្រោះចោលអស់កាន់តែដាវដើរទៅ លុះទៅប្រមាណយាមបីប្លាយក៏ទៅដល់ស្ទឹងមួយស្រាប់តែឮសូរសំឡេងទាហានស្រែកហៅពីខាងក្រោយ។ **ច្វូឆ្វ**និយាយនឹង**ចោហាង**ថា យើងនឹងរត់ទៅខាងណា បើមានស្ទឹងនៅពីមុខដូច្នេះ សត្រូវមកដល់ឥឡូវហើយជីវិតរបស់យើងទៀងតែស្លាប់ក្នុងទីនេះជាប្រាកដ។ **ចោហាង**ឆ្លើយថា លោកកុំព្រួយបារម្ភអ្វីឲ្យសោះ ធានាលើរូបខ្ញុំនឹងនាំលោកឆ្លងទៅឲ្យរួចឥឡូវនេះ ថាហើយក៏ដោះអាវចោលអស់ពីខ្លួន ហើយឲ្យ**ច្វូឆ្វ**ឡើងជិះលើស្មានាំហែលឆ្លងស្ទឹងនោះទៅដល់ត្រើយម្ខាង។ ឯពួកទាហានខំស្រូតតាមមកដល់ក្បែរមាត់ស្ទឹងនោះ ក្រឡេកទៅឃើញ**ច្វូឆ្វ**ទៅដល់ត្រើយម្ខាង ក៏បបួលគ្នាបាញ់ធ្នូរណ្ដំពីខាងក្រោយទៅ។ **ចោហាង**នាំ**ច្វូឆ្វ**ដើរទៅប្រមាណសាមសិបសិន ទទួលថ្ងៃរះឡើង ក៏ចូលទៅឈប់សម្រាកក្បែរ

ជើងភ្នំមួយ ឯ**ស៊ីអេង**ក៏នាំទាហានឆ្លងស្ទឹងតាមទៅទៀត ឃើញ**ចូឆ្វ** និង**ចោហង** ឈប់នៅទីនោះ ក៏បង្គាប់ឲ្យទាហានចោមព័ទ្ធជុំវិញ។

ខណៈនោះ**ហែហ្សួទុន** និង**ហែហ្សួអៀន**ឃុំនាំទាហានសេះបានប្រហែលដប់ប្រាំមួយ ឬដប់ប្រាំពីរនាក់ឆ្លងស្ទឹងស្រូតតាមទៅ ឃើញ**ស៊ីអេង**និងទាហានកំពុងឡោមព័ទ្ធ**ចូឆ្វ** និង**ចោហង** ក៏បរសេះបំពានកាត់មុខ**ស៊ីអេង**ចូលទៅ ហើយស្រែកគំរាមថា នែវ៉ឺយពួកអាក្បត់ អាឯងកុំមកធ្វើអន្តរាយដល់នាយចៅហ្វាយអញ។ **ស៊ីអេង**បានឮក៏បរសេះចូលទៅតច្បាំងនឹង**ហែហ្សួទុន**បានដប់ស្ទៀត **ហែហ្សួទុន**យកលំពែងចាក់ត្រូវ**ស៊ីអេង**ធ្លាក់ពីលើសេះស្លាប់ ហើយដេញកាប់ទាហានទាំងនោះបែកខ្ចាត់ខ្ចាយអស់។ ខណៈនោះ**ចោយិន, លីតៀន** និង**ង៉ាក់ជិន** ទាំងបីនាក់នេះឃុំនាំទាហានបានប្រហែលបីរយប្លាយ លើកគ្នាតាមក្រោយទៅ ក៏បានជួបនឹង**ហែហ្សួអៀន** ទើបបបួលគ្នាទៅរក**ចូឆ្វ**។ លុះ**ចូឆ្វ**ឃើញទាហានឯករបស់ខ្លួននាំពលមកបានខ្លះ ក៏ធូរសប្បាយចិត្តឡើងវិញ ហើយក៏លើកពលទាហានតម្រង់ទៅស្រុកហោឡាយ។

គ្រានោះ ចៅហ្វាយខេត្តទាំងពួងដែលនៅក្នុងស្រុកឡុកអៀងមាន**ស៊ុនកៀន**ជាប្រធាន បាននាំគ្នាចូលទៅជំនុំការក្នុងទីព្រះទីនាំងកៀនសៀនតៀន ហើយទៅមើលទីព្រះដំណាក់របស់ព្រះមហាក្សត្រ ដែលមាននៅក្នុងបរិវេណនៃព្រះបរមរាជវាំងនោះ ឃើញស្នាមដែល**តាំងតុះ**ឲ្យជីករំលើងទាំងប៉ុន្មាន ក៏បានឲ្យទាហានកាយលុបដីទៅវិញហើយសង់ជារោងឡើង ទើបនាំគ្នាទៅអុជទៀនធូបធ្វើសក្ការៈបូជាគ្រប់ទីព្រះដំណាក់ទាំងអស់គ្នា រួចត្រឡប់ទៅកាន់ទីប្រជុំ។ លុះវេលាកណ្ដាលយប់ខែភ្លឺច្បាស់ **ស៊ុនកៀន**កាន់គ្រប៊ីចេញទៅអង្គុយនៅមុខព្រះលាន ក្រឡេកមើលទៅលើឃើញផ្កាយសម្រាប់ព្រះមហាក្សត្រអ័ព្ទសៅហ្មងរស្មី ក៏រំពឹងថា គ្រានេះព្រះមហាក្សត្រមិនបានសេចក្ដីសុខក្នុងព្រះអង្គឡើយ បានជាអាណាប្រជានុរាស្ត្រកើតសេចក្ដីក្ដៅក្រហាយ

ដូច្នេះ ហេតុទាំងនេះមកតែអំពីអា**តាំងតុះ**ចេញជាសត្រូវក្បត់ផែនដី ទាល់តែស្រុកទៅជាព្រៃរហោឋាន បានជាផ្កាយនេះកើតវិបរិតដូច្នោះ។ **ស៊ុនកៀន**រំពឹងសព្វគ្រប់ទប់ពុំបានក៏ក្តុកក្តួលស្រក់ទឹកភ្នែក។ ពេលនោះមានទាហានម្នាក់ឃើញហេតុប្លែកណាស់ ក៏ស្ទុះទៅជម្រាប**ស៊ុនកៀន**ថា សូមលោក សូមទានមេត្តាប្រោស នៅក្បែរខាងព្រះទីនាំងទិសខាងត្បូងមានអ្វីភ្លឺត្រចះម្ល៉េះទេ! **ស៊ុនកៀន**ក្រឡេកមើលទៅឃើញរស្មីប្លែក ទើបក្រោកដើរទៅឲ្យទាហានអុជគប់ភ្លើងបំភ្លឺមើល ក៏ឃើញអណ្តូងមួយទើបប្រើទាហានឲ្យចុះទៅពិនិត្យមើលក្នុងអណ្តូងនោះ ឃើញខ្មោចស្រីម្នាក់ក៏ឲ្យលើកឡើងមក។ ឯសពនោះក៏នៅស្រស់ មិនទាន់រឹងហើមសោះ មានកំណាត់សំពត់រុំនៅក **ស៊ុនកៀន**ក៏ឲ្យស្រាយចេញ មើលក្នុងកំណាត់សនោះឃើញមានកូនហិបតូចមួយចាក់សោយ៉ាងជាប់ ទើបឲ្យគាស់បើកចេញឃើញត្រាមួយ (ធ្វើអំពីថ្មពណ៌) មានមុខបួនជ្រុងស្មើ កម្រាស់ប្រាំបីធ្នាប់ កំពូលឆ្លាក់ជាប់ជារូបម្ករបួនរុំព័ទ្ធគ្នា តែជ្រុងម្ខាងនោះរបេះ យកមាសប៉ះបំពេញឲ្យស្មើ មុខត្រានោះឆ្លាក់ជាអក្សរថា “ទេវតាប្រសិទ្ធិទុកឲ្យ បើអ្នកឯណាបានថែរក្សាទុកហើយ នឹងអាចគ្រងរាជសម្បត្តិ បានចម្រើនព្រះជន្មវស្សាយឺនយូរអង្វែង”។ **ស៊ុនកៀន**ឃើញប្លែកអស្ចារ្យដូច្នោះ ទើបសួរទៅ**តៀផៅ**ថា ត្រាឆ្លាក់នេះជារបស់នរណា? **តៀផៅ**ជម្រាបថា ត្រានេះជាព្រះរាជទ្រព្យសម្បត្តិរាជសម្បត្តិ ឯក្បាច់ចម្លាក់ដែលឆ្លាក់ត្រានេះ តាំងពី**បេងហ្វ**ឃើញសត្វហង្សទំលើកំពូលភ្នំមួយ ដល់សត្វហង្សនោះហើរចេញទៅ **បេងហ្វ**ក៏យកដុំថ្មនោះមកឆ្លាក់ជាក្បាច់ស្រេចហើយ នាំយកទៅថ្វាយព្រះចៅ**ស៊្វប៊ូអង**ៗក៏ក្ស័យព្រះជន្មទៅ លុះដល់ព្រចៅ**ជិនស៊ីអង**បានសោយរាជសម្បត្តិឡើង ទើបទ្រង់ចាត់ឲ្យរកជាងមកធ្វើជាត្រាសម្រាប់ព្រះមហាក្សត្រគ្រងផែនដី។ **លីស៊្វ**ជាជាងឆ្លាក់ក៏ទទួលឆ្លាក់ជាអក្សរប្រាំបីតួ លុះព្រះចៅ**ជិនស៊ីអង**សោយរាជ្យបានម្ភៃប្រាំមួយឆ្នាំ ព.ស២៣១ស្តេចទៅ

ប្រពាតដោយផ្លូវជលមាគ៌ា ក៏បណ្ដាលព្យុះខ្យល់យ៉ាងធំពន្លឹក ស្ដេចទ្រង់ភ័យខ្លាចក្រែងទូកព្រះទីនាំងលង់លិច ទើបយកត្រានោះចោលទៅក្នុងទឹក ព្យុះខ្យល់ក៏បាត់ស្ងប់ស្ងាត់ឈឹងទៅវិញ។ លុះតមកប្រាំបីឆ្នាំទៀត ព្រះចៅ**ជិបស៊ីអង**ស្ដេចទៅប្រពាតដោយសថលមាគ៌ា មានមនុស្សម្នាក់យកត្រាទៅថ្វាយផ្ទាល់ព្រះហស្ថ មនុស្សនោះក៏អន្តរធានបាត់ទៅ។ កាលព្រះចៅ**ជិនស៊ីអង**ស្ដេចត្រឡប់មកដល់ព្រះបរមរាជវាំងវិញ ក៏ទ្រង់សោយព្រះទិវង្គតក្នុងពេលនោះ **ជូនអេង**ទើបយកត្រានោះទៅថ្វាយព្រះចៅ**ហាន់កូចូ** ពេលនោះ**អងម៉ាំង**ជាសត្រូវក្បត់ ព្រះនាង**តាំងថៃហ**យកត្រានេះគ្រវែងចោល**អងសិម, សោសៀម**ជាទាហាន**អងម៉ាំង** ខ្ទាតទៅត្រូវជញ្ជាំងផ្ទះរបេះជ្រុងបន្តិចទៅ ហើយឲ្យយកមាសប៉ះគែមដែលរបេះនោះស្មើឡើងវិញ លុះព្រះចៅ**ហ័នកងប៊ូ**បានត្រានេះទើបសោយរាជ្យតៗមក ដល់ភ្លើងឆេះព្រះបរមរាជវាំង ពួកខន្ទីក៏នាំ**ហង់ជូពៀន, ហង់ជូហៀប** រត់ទៅនៅក្នុងព្រៃ ដល់ពេលត្រឡប់ចូលមកវិញ បានឲ្យខ្ញុំរាជការត្រួតពិនិត្យមើលព្រះរាជទ្រព្យក្នុងផ្ទៃព្រះឃ្លាំងគង់នៅទាំងអស់ បាត់តែត្រាផ្ដាក់នេះរកមិនឃើញសោះ ក៏ឥឡូវលោកមកបានត្រានេះ ខ្ញុំយល់ថារាជសម្បត្តិនឹងបានដល់លោកជាប្រាកដ សុំឲ្យលោកនាំយកទៅស្រុកកាំងតាំងចុះ ទើបនឹងបានគិតការធំតទៅ។

**ស៊ុនកៀន**បានស្ដាប់ព័ត៌មានដូច្នោះ ក៏មានសេចក្ដីត្រេកអរណាស់ ហើយនិយាយថា ព្រឹកនេះយើងទៅលា**អ្វួនសៀវ**ថាឈឺ សុំវិលទៅស្រុកវិញ។ និយាយហើយហាមទាហានទាំងពួងថា កុំឲ្យប្រាប់សេចក្ដីនេះឲ្យនរណាដឹងជាប្រាកដ ។ ក្នុងពេលយប់នោះមានទាហាន**ស៊ុនកៀន**ម្នាក់ បានដឹងហេតុក៏លបយកហេតុនោះទៅជម្រាប**អ្វួនសៀវ** ។ក៏ឃាត់ទាហាននោះទុក ហើយឲ្យបំណាច់រង្វាន់ជាច្រើន។ លុះវេលាព្រឹកឡើង**ស៊ុនកៀន**ក៏ឡើងទៅជម្រាប**អ្វួនសៀវ**ថា ខ្ញុំបាទឈឺមិនសប្បាយ

សុំលាលោកទៅនៅរក្សាខ្លួនឯស្រុកតៀងស៊ា។ **អ្នួនសៀវ**សើចហើយថា ខ្ញុំដឹងហើយ ដែលអ្នកឈឺសុំទៅរក្សាខ្លួននោះ ព្រោះអ្នកបានត្រាឆ្លាក់សម្រាប់រាជសម្បត្តិទេឬ? **ស៊ុនកៀន**បានស្តាប់ធ្វើជាភ្ញាក់ខ្លួន ហើយសួរថា នរណាមកជម្រាបលោកដូច្នេះ? **អ្នួនសៀវ**ថា យើងទាំងអស់គ្នាបានរួមគំនិតគិតនឹងរំលាងសត្រូវរាជសម្បត្តិចេញ ប្រយោជន៍ដើម្បីឲ្យព្រះមហាក្សត្រសោយរាជ្យបានសេចក្តីសុខសប្បាយ ព្រមទាំងអាណាប្រជានុរាស្ត្រក្នុងព្រះអាណាខេត្ត ដែលអ្នករើសយកត្រាសម្រាប់ព្រះមហាក្សត្រ ហើយលាក់ទុកនោះមិនគួរទេ ត្រូវតែអ្នកនាំយកមកឲ្យយើងដែលជាមេទ័ពធំ បើធ្វើការសម្រេចវេលាណា នឹងបាននាំទៅថ្វាយព្រះចៅ**ហៀនតេ**ឲ្យទ្រង់សោយរាជសម្បត្តិតទៅ។ ឥឡូវបើអ្នកនឹងលាក់ទុកហើយនាំទៅនោះ អ្នកនឹងគិតយករាជសម្បត្តិឬ?

**ស៊ុនកៀន**ថា ខ្ញុំបាទមិនបានរើសត្រាសោះ ហេតុម្តេចលោកមកថាដូច្នោះ? **អ្នួនសៀវ**តបថា យើងដឹងប្រាកដថា អ្នកបានត្រានោះមកទុក អ្នកចូរយកមកឲ្យយើងឥឡូវនេះ បើអ្នកមិនស្តាប់មុខជាមានរឿងមិនស្រួល។

**ស៊ុនកៀន**លើកដៃចង្អុលលើអាកាស ហើយនិយាយប្រកាសសេចក្តីពិតត្រង់ថា បើខ្ញុំបាទយកបានត្រាឆ្លាក់ទៅលាក់ទុកមែន សុំឲ្យខ្ញុំស្លាប់នឹងអាវុធផ្សេងៗចុះ។ ចៅហ្វាយខេត្តទាំងអស់ឃើញហើយ ក៏ជម្រាបឃាត់**អ្នួនសៀវ**ថា ឥឡូវនេះ**ស៊ុនកៀន**និយាយស្បថស្បែហើយ សូមលោកលោះលាទោសទៅចុះ។ **អ្នួនសៀវ**ក៏នាំទាហាន**ស៊ុនកៀន**ដែលទៅជម្រាបរឿងនោះ ឲ្យចេញមកតទល់ចំពោះមុខហើយថា កាលដែលអ្នកប្រើទាហានឲ្យចុះរើក្នុងអណ្តូងប្រទះត្រានោះ ទាហាននេះហើយដែលទៅជាមួយនឹងអ្នក **ស៊ុនកៀន**ឃើញទាហានរបស់ខ្លួន ក៏ដឹងថាច្បាស់ថាវានាំរឿងនេះមកជម្រាប**អ្នួនសៀវ**ជាប្រាកដ។ **ស៊ុនកៀន**ខឹងណាស់ហូតគ្រប៊ីនឹងចាក់ទាហាននោះ

សម្លាប់ **អួនសៀវ**ក៏ហូតគ្រប៊ីស្ទុះទៅឈរពាំងពីមុខ ហើយថា បើអ្នកសម្លាប់ទាហាននេះ ខ្ញុំក៏ត្រូវសម្លាប់អ្នកវិញដូចគ្នា។

ឯ**ង៉ាន់លៀង**និង**ប៊ុនធីវ**ជាទាហាន**អួនសៀវ** ដែលឈរពីក្រោយឃើញដូច្នោះ ក៏ហូតគ្រប៊ីប្រុងទុក ខាង**តៀផៅ, អ៊ុយកាយ, ហាន់តុង** ទាហាន**ស៊ុនកៀន**ក៏ហូតគ្រប៊ីប្រុងទុកដូចគ្នា។ ចំណែកឯចៅហ្វាយខេត្តទាំងពួង លុះបានឃើញហេតុទាស់ទែងគ្នាដូច្នោះ ក៏ចេញទៅហាមឃាត់ទាំងសងខាង **ស៊ុនកៀន**ក៏ឡើងសេះត្រឡប់ទៅកាន់ទីបន្ទាយខ្លួនវិញ ហើយរៀបចាត់ចែងពលទាហានស្រេចក៏លើកចេញពីក្រុងឡុកអៀង។

**អួនសៀវ**ដឹងថា **ស៊ុនកៀន**លើកចេញទៅហើយ ក៏ធ្វើសំបុត្រតាមហេតុនោះឲ្យសេះបម្រើនាំទៅដល់**ឡៅពីវ**ចៅហ្វាយខេត្តកេងជីវ ឲ្យ**ឡៅពីវ**លើកទាហានចាំស្កាត់ដណ្តើមយកត្រាផ្ទាក់ ដែល**ស៊ុនកៀន**នាំជំរត់យកទៅនោះឲ្យបាន។ លុះដល់វេលាព្រឹក មានទាហានសេះដែលនៅយាមល្បាតត្រឡប់មកប្តឹង**អួនសៀវ**ថា ទ័ព**ចូឆួ**ដែលលើកទៅតាម**តាំងតុះ**នោះ ឥឡូវបែកទៅនៅស្រុកហោឡាយហើយ។ **អួនសៀវ**ឮដូច្នោះ ក៏ចាត់ទាហានឲ្យទៅទទួល**ចូឆួ** និងចៅហ្វាយខេត្តទាំងពួង បណ្តាមន្ត្រីខេត្តទាំងនោះ ក៏សាកសួរ**ចូឆួ**តាមរឿងដែលទៅធ្វើការនោះ។ **ចូឆួ**ស្តាប់ហើយក៏ដកដង្ហើមធំហើយថា កាលពីដើមខ្លួនខ្ញុំជាដើមគំនិតគិតបញ្ចុះបញ្ចូលមនុស្សទាំងពួងមកជាកម្លាំង នឹងឲ្យដំណើងទៅអស់លោកជាចៅហ្វាយខេត្តទាំងអស់ថា នឹងទំនុកបម្រុងផែនដី អស់លោកក៏ចូលចិត្តតាមគំនិតខ្ញុំ បានជានាំគ្នាលើកសេនាទាហានមកជួយធ្វើការ ឥឡូវ**តាំងតុះ**លះបង់ចោលស្រុកឡុកអៀងជាទីក្រុង នាំព្រះចៅ**ហៀនតេ**និងអាណាប្រជានុរាស្ត្រទៅកសាងក្រុងខាងទិសឯលិចវិញ ខ្ញុំក៏លើកទាហានតាមទៅប្រាថ្នានឹងច្បាំងបំផ្លាញ**តាំងតុះ**ឲ្យវិនាសចេញ ការនោះមិនសម្រេចតាមបំណង

ត្រឡប់បរាជ័យចាញ់ប្រៀបគេ វិលមកពេលនេះខ្ញុំមានសេចក្ដីទោមនស្សតូចចិត្តណាស់ តើអស់លោកនឹងយល់ឃើញដូចម្ដេច? ចូរជួយត្រិះរិះមើលផងចុះ។

**អ្នួនសៀវ**និងបណ្ដាចៅហ្វាយខេត្តទាំងអស់ ក៏មិនបានតបថាប្រការម្ដេច។ **ចូអ្នូ**នឹកតូចចិត្តណាស់គិតរំពឹងថា ពួកយើងនេះមុខជាប្រែចិត្តគិតដកថយពីគ្នាជាប្រាកដហើយ ដែលនឹងសង្ឃឹមយកជាគំនិតចិត្តមួយផងគ្នាឃើញជាមិនបាន **ចូអ្នូ**ខឹងណាស់ចុះដើរចេញទៅចាត់ចែងទាហាន ហើយលើកត្រឡប់ទៅស្រុកអេងជីវ បណ្ដាចៅហ្វាយខេត្តទាំងអស់ក៏ត្រឡប់ទៅកាន់ទីជំនុំវិញ។

ឯ**កងស៊ុនចាន**និយាយនឹង**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**ថា **អ្នួនសៀវ**នេះដែលនឹងគិតការធំតទៅមិនបានទេ យូរទៅនឹងមានអន្តរាយ បើយើងតាមផងនឹងបានតែសេចក្ដីលំបាក ដូច្នេះយើងត្រូវនាំគ្នាទៅស្រុកវិញល្អជាង។

**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ឃើញត្រូវផងក៏បបួលគ្នាលើកពលទាហានត្រឡប់ទៅស្រុកផេងងួនគួន **ឡៅពី**ក៏លាចូលទៅនៅថែរក្សាស្រុក **កងស៊ុនចាន**ក៏លើកហួសទៅស្រុកប៉ាក់ប៉េង។

ឯ**ឡៅតាយ**ដាច់ស្បៀងអាហារ នឹងចាត់ការឲ្យសេនាទាហានពុំគ្រប់គ្រាន់បានឲ្យបម្រើទៅនិយាយខ្ចីស្បៀងអាហារពី**តៀវម៉ៅ**ៗមិនព្រមឲ្យ **ឡៅតាយ**ខឹងណាស់ ដល់ពេលកណ្ដាលយប់ ក៏លើកទាហានទៅលុកបន្ទាយ**តៀវម៉ៅ** សម្លាប់**តៀវម៉ៅ**ស្លាប់។ ក្នុងពេលនោះពួកទាហាន**តៀវម៉ៅ**នាំគ្នាមកចូលនឹង**ឡៅតាយ**ទាំងអស់។ **អ្នួនសៀវ**ឃើញចៅហ្វាយខេត្តទាំងអស់គ្នាបែកខ្ញែកចិត្តប្រែគំនិតទៅដោយខ្លួន ខ្លះលើកទាហានទៅវិញដូច្នោះ **អ្នួនសៀវ**ក៏ឃុំនាំទាហានទៅស្រុកហូឡាយ ចៅហ្វាយខេត្តក្រៅពីនោះ លើកទាហាននាំវិលទៅខេត្តខណ្ឌរៀងខ្លួន។ ឯ**ឡៅពីវ** ចៅហ្វាយស្រុកកេងជីវនោះ ជាពូជព្រះរាជវង្សព្រះចៅ**ហាន់កួច្ច** មានទីប្រឹក្សាប្រាំពីរ

នាក់ ឈ្មោះ**តាន់សៀង** ពួកស្រុកយីឡាំ១, **ខុងលិប** ពួកស្រុកឡោកុក១, **ហួនខុង** ពួកស្រុកពុតហៃ១, **តៀវលី** ពួកស្រុកសាន់យ៉ុង១, **តៀវខៀម** ពួកស្រុកសាន់យ៉ុង១, **ង៉ីមទិត** ពួកស្រុកឡាំយ៉ុង១, **ហួនហុង**ពួកស្រុកយីឡាំ១ ទាំងប្រាំពីរនាក់នេះជាភៀនស្និទ្ធស្នាលនឹង**ឡៅពីរ**មកពីដើម។ នៅមានសេនាទាហានឯកបីនាក់ទៀតឈ្មោះ **កេងលៀង១, កេងអួត១, ឈូម៉១** ទាំងបីនាក់នេះជាពួកស្រុកអៀងប៉េង។

**ឡៅពីរ**កាលបានដឹងហេតុតាមសេចក្ដីសំបុត្រ ដែល**អួនសៀវ**ឲ្យ ក៏ចាត់ប្រើ **កេងអួត** និង**ឈូម៉**ឲ្យលើកទាហានមួយម៉ឺនទៅស្កាត់ផ្លូវដែល**ស៊ុនកៀន**លើកមកនោះ លុះជួបប្រទះទ័ពគ្នាហើយ **កេងអួត**ក៏ចេញទៅឈរពីមុខទាហានទាំងពួង។ **ស៊ុនកៀន**ស្រែកសួរ**កេងអួត**ថា អ្នកលើកទាហានមកស្ទាក់ផ្លូវយើងទុកដូច្នេះ តើអ្នកនឹងប្រាថ្នារបស់អ្វី? **កេងអួត**តបថា ខ្លួនអ្នកជាខ្ញុំរាជការព្រះចៅ**ហៀនតេ** បានទាំងស៊ីបៀវត្សដរាបមក ហេតុអ្វីអ្នកនាំយកត្រាឆ្លាក់សម្រាប់ព្រះមហាក្សត្រនៅនឹងខ្លួន អ្នកយកទៅធ្វើអ្វី? អ្នកចូរយកត្រានោះមកប្រគល់ឲ្យយើងជាប្រញាប់ យើងនឹងបាននាំចូលទៅថ្វាយព្រះចៅ**ហៀនតេ** បើអ្នកមិនព្រមឲ្យទេ យើងក៏មិនបើកផ្លូវឲ្យទៅ។ **ស៊ុនកៀន**បានស្ដាប់ហើយខឹងណាស់ ទើបប្រើ**អ៊ុយកាយ**ឲ្យចេញទៅតយុទ្ធនឹង**កេងអួត** ពេលនោះ**ឈូម៉**បរសេះស្ទុះទៅមុខ**កេងអួត**ប្រយុទ្ធនឹង**អ៊ុយកាយ**បានប្រាំពីរស្នៀត **អ៊ុយកាយ**យកដំបងដែកបួនជ្រុងបុកត្រូវដើមទ្រូង**ឈូម៉** ៗញាក់សេះរត់ **ស៊ុនកៀន**ក៏ថែមដេញចាក់កាប់ទាហាន**ឈូម៉**ទៅដល់មុខស្រុកកេងជីវ ហើយស្រាប់តែឮសំឡេងគងឃ្មោះលើកំពូលភ្នំ **ស៊ុកកៀន**ក្រឡេកទៅឃើញ**ឡៅពីរ**លើកទាហានមកជាច្រើនព័ទ្ធជុំវិញខ្លួន ក៏មានសេចក្ដីភិតភ័យណាស់។ **ស៊ុនកៀន**ឱនគំនាប់**ឡៅពីរ**ហើយថា លោកជឿស្ដាប់តែសំបុត្រ**អួនសៀវ** ហើយលើកទាហានមកធ្វើការទាំងនេះ ហាក់បីដូចជាមិនអាណិតអាសូរដល់ខ្ញុំសោះ។ **ឡៅពីរ**សួរថា ដែលអ្នកនាំយកត្រាសម្រាប់រាជ្យមក

នេះ នឹងគិតដណ្ដើមយករាជសម្បត្តិឬ? **ស៊ុនកៀន**ឆ្លើយថា បើខ្ញុំបានយកត្រាសម្រាប់រាជ្យមក ដូច**អួនសៀវ**ឲ្យដំណឹងមែន សូមឲ្យខ្ញុំស្លាប់ដោយគ្រឿងសាស្ត្រាវុធផ្សេងៗចុះ។ **ឡៅពីវ**ឆ្លើយថា បើអ្នកនឹងចង់ឲ្យយើងអស់សង្ស័យ ចូរហៅទាហានទាំងអស់របស់អ្នកមកឲ្យយើងត្រួតពិនិត្យមើល ទើបយើងជឿជាក់។ **ស៊ុនកៀន**ខឹងណាស់ឆ្លើយតបថា យើងបានស្បថស្បាន់តម្រង់ខ្លួនហើយ នៅតែមិនជឿទៀត បើអ្នកមានថ្វីដៃខ្លាំងពូកែយ៉ាងណា ចូរមកល្បងគ្នាចុះ។ **ឡៅពីវ**បានស្ដាប់ដូច្នោះ ក៏ក្លែងធ្វើជាលើកពលទៅក្រោយវិញ **ស៊ុនកៀន**បំផាយសេះដេញទៅដល់ជើងភ្នំសងខាងផ្លូវ ឯទាហាន**ឡៅពីវ** ដែលបង្កប់នៅទីនោះស្ទុះចេញមកទាំងសងខាង។ ទទួល**ឈូម៉**និង**កេងអួត**ដែលរត់ដោយចាញ់ដៃទ័ព**ស៊ុនកៀន**នោះ បរសេះនាំទាហានមកពីក្រោយថែមទៀតព្រួតវាយផ្ទប់ប្រសព្វគ្នា **ឡៅពីវ**ក៏បរពលវាយប្រសព្វមកពីមុខទៀត **ស៊ុនកៀន**ទាល់ច្រកក៏វាចឡាំងទាំងខាងមុខក្រោយ **អ៊ុយកាយ**និង**តៀវផៅ**, **ហាន់តុង** ឃើញខូចខាតទាហានច្រើនណាស់ ព្រោះទាហាន**ឡៅពីវ**ឡោមព័ទ្ធជាប់**ស៊ុនកៀន**នៅក្នុងចំណោមទ័ព ក៏ស្ទុះទម្លុះទម្លាយទៅជួយ ហើយនាំយក**ស៊ុនកៀន**ចេញមកបានស្រួតលើកទាហានតម្រង់ទៅស្រុកកាំងតាំង។ ចាប់តាំងពីនោះមក **ឡៅពីវ** និង **ស៊ុនកៀន** ក៏មានសេចក្ដីគំនុំគំគួនព្យាបាទគ្នាជាប់ក្នុងចិត្ត។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៦

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំង**ហាងគីម**បបួល**អ្នួនសៀវ**ទៅច្បាំងយកស្រុកគីជីវ រៀងរហូតដល់**អងអ៊ុន**និយាយល្បួងលោមនាង**តៀវសៀន**ជាកូនចិញ្ចឹម ឲ្យទៅធ្វើប្រពន្ធ**តាំងតុះ**ផង**លីប៉ោ**ផង ដើម្បីនឹងឲ្យអ្នកទាំងពីរនេះទាស់ទែងខ្វែងគំនិតគ្នា)។*

**ខណៈ**កាល**អ្នួនសៀវ**ដែលលើកសេនាយោធាទៅស្រុកហូឡាយនោះ ក៏ដាច់ស្បៀងអាហារអស់រលីង លុះដំណឹងនេះជ្រាបដល់**ហាន់ហុក**ចៅហ្វាយស្រុកគីជីវ **ហាន់ហុក**ក៏ចាត់មនុស្សឲ្យនាំស្បៀងទៅជូន**អ្នួនសៀវ**។ ពេលនោះ**ហាងគី**និយាយនឹង**អ្នួនសៀវ**ថា បណ្ដាមនុស្សទាំងអស់ក៏បានដឹងច្បាស់ប្រាកដថា លោកនេះពូជនាហ្មឺនតៗមកពីដើម ដែលលោកមកធ្វើការទំនុកបម្រុងផែនដីសម័យនេះ មិនគួរនឹងមកអង្គុយចាំពិសាដោយគេបញ្ជូនស្បៀងអាហារមកឲ្យនោះសោះ ប្រសិនជាមិនមានគេបញ្ជូនមកជូនលោកៗក៏មានសេចក្ដីលំបាក ការណ៍នេះខ្ញុំឃើញថាស្រុកគីជីវ មានមនុស្សអ្នកមានទ្រព្យសម្បត្តិ ទាំងស្រូវអង្ករចំណីត្រីសាច់ក៏សឹងមានបរិបូរមិនខ្វះខាត សុំឲ្យលោកលើកសេនាទាហានទៅវាយយកស្រុកគីជីវចុះ ដល់វាយបានហើយលោកត្រូវទៅកាន់កាប់ស្រុកនោះតទៅ បើលោកនឹងប្រាថ្នាគិតការអ្វីជាធំក៏នឹងបានសម្រេចតាមប្រាថ្នា។ **អ្នួនសៀវ**ឆ្លើយតបថា យើងក៏បានរិះគិតដូច្នេះដែរ តែថាមិនទាន់មានឱកាសនឹងធ្វើបាន ៗជាបង្អង់នៅស្ងៀមសិន។ **ហាងគី**ថា បើលោកគិតជាប្រាកដ ត្រូវមានសំបុត្រសម្ងាត់ទៅដល់**កងស៊ុនចាន** ឲ្យលើកទាហានចូលវាយស្រុក

គឺជីវមួយផ្លូវ ចំណែកលោកលើកទៅវាយប្រសព្វមួយផ្លូវទៀត បើបានស្រុកនោះហើយ សឹមបែងរំលែកចែកទ្រព្យរបស់និងមនុស្សចំណុះស្រុកឲ្យ**កងស៊ុនចាន**ពាក់កណ្ដាលចុះ នោះបើក**កងស៊ុនចាន**លើកទាហានទៅជួយវាយលើកនេះ ឯ**ហាន់ហុក**ចៅហ្វាយស្រុកនោះ ជាមនុស្សមិនចេះគិតអ្វីសោះ គង់នឹងមានសំបុត្របកដល់លោកឲ្យលើកទាហានទៅជួយ លោកក៏នឹងបានស្រុកគីជីវដោយងាយមិនព្រួយបារម្ភ។ **អ្នួនសៀវ**ឃើញត្រូវ ទើបតែងសំបុត្រសម្ងាត់ប្រាប់ទៅ**កងស៊ុងចាន**តាមគំនិតរបស់**ហងគី**។

សម័យនោះ **កងស៊ុនចាន**បានទទួលសំបុត្រ**អ្នួនសៀវ**មើលដឹងសេចក្ដីហើយក៏មានចិត្តត្រេកអរពន់ពេក ទើបធ្វើសំបុត្រតបទៅ**អ្នួនសៀវ**វិញ ប្រាប់ពេលកំណត់ដែលនឹងលើកទាហានទៅវាយស្រុកគីជីវនោះ។ **អ្នួនសៀវ**បានដឹងសេចក្ដីសំបុត្រនោះហើយ ក៏ចាត់បម្រើម្នាក់ឲ្យនាំសំបុត្រមួយច្បាប់ទៅប្រាប់**ហាន់ហុក**ចៅហ្វាយស្រុកគីជីវថា ឥឡូវនេះ**កងស៊ុនចាន**មានសំបុត្រមកប្រឹក្សាថា នឹងលើកទាហានមកវាយយកស្រុកគីជីវហើយ។ **ហាន់ហុក**ទទួលសំបុត្រហើយ ក៏ហៅទីប្រឹក្សាឈ្មោះ**ស៊ុនសុិម** និង**សុិនប៉េង**មកពិគ្រោះថា ឥឡូវ**កងស៊ុនចាន**មុខជានឹងលើកទាហានមកវាយស្រុកយើងហើយ តើយើងនឹងគិតដូចម្ដេច?

**ស៊ុនសុិម**ឆ្លើយថា ដែល**កងស៊ុនចាន**នឹងលើកទាហានមកវាយស្រុកយើងនេះឃើញថា នឹងលើកមកច្រើនណាស់ ហើយ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**ក៏គង់នឹងមកផង ទាហានរបស់យើងឃើញថាតស៊ូនឹងគេមិនបាន ឯ**អ្នួនសៀវ**ក៏ប្រកបទៅដោយសតិបញ្ញា មានទាហានឯកនិងទាហានឡេវក៏ច្រើន បើដូច្នោះសូមឲ្យលោកមានសំបុត្រទៅអញ្ជើញ**អ្នួនសៀវ**មកនៅឈរក្សាស្រុកយើងចុះ នឹងបានជួយការពារ

រក្សាគ្នាតទៅ **អ្នួនសៀវ**ក៏គង់មានសេចក្ដីមេត្តាដល់លោកខ្លះ ឯ**កងស៊ុនថាន**ក៏គង់មិនហ៊ានមកញាំញីស្រុកយើងព្រោះក្រែងខ្លាច**អ្នួនសៀវ**។

**ហាន់ហុក**ស្ដាប់ហើយឃើញត្រូវផង ក៏តែងសំបុត្រមួយច្បាប់ ឲ្យ**គួនគី**នាំយកទៅជូន**អ្នួនសៀវ**តាមពាក្យ**ស៊ុនស៊ិម**។ ពេលនោះ **កេងប៊ូ**ជម្រាប**ហាន់ហុក**ថា **អ្នួនសៀវ**ជាមនុស្សទាល់គំនិតហើយ ដែលនៅគង់ទ្រង់តាំងខ្លួនចិញ្ចឹមទាហានសព្វថ្ងៃនេះបាន ដោយអាស្រ័យស្បៀងអាហារដែលលោកជញ្ជូនទៅឲ្យ ឧបមាបីដូចជាទារក បើមាតាមិនឲ្យទឹកដោះបៅហើយ ក៏តែងមានសេចក្ដីយំសោកជាទុក្ខដោយការស្រេកឃ្លាន បើលោកនឹងឲ្យ**អ្នួនសៀវ**មកជួយរក្សាស្រុកជាប្រធាន ក៏ដូចជាចាប់ខ្លាទៅលែងក្នុងហ្វូងប្រើសទ្រាយ គង់នឹងមានភ័យអន្តរាយដល់សត្វទាំងនោះ ការណ៍នេះសូមលោកត្រិះរិះមើលតាមសមគួរសិន។ **ហាន់ហុក**តបថា ខ្លួនយើងពីដើមដែលនឹងបានធ្វើជានាហ្មឺនជាប់មកនោះ ក៏ព្រោះតែសែ**អ្នួន**ជួយឧបត្ថម្ភនាំសេចក្ដីគុណគាប់ឲ្យកើតឡើង ទើបយើងបានមកធ្វើចៅហ្វាយស្រុកនេះ យើងក៏ឃើញថា **អ្នួនសៀវ**មានសតិបញ្ញាល្អជាងយើង ម្យ៉ាងទៀតចាស់បុរាណមានថាទុកមកថា "បើអ្នកឯណាមានសតិបញ្ញា ត្រូវឲ្យអ្នកល្ងង់ឧស្សាហ៍គោរពកោតខ្លាច ទើបអាចរក្សាសេចក្ដីសុខបាន" ដែលអ្នកមកយល់ទាស់ឲ្យខុសនឹងពាក្យចាស់បុរាណដូច្នេះ យើងមិនយល់ព្រមផងទេ។

**កេងប៊ូ**បានឮដូច្នោះក៏ដកដង្ហើមធំហើយនិយាយថា ស្រុកគីជីវនេះគង់នឹងសាបសូន្យជាឆាប់ប្រាកដ។ **កេងប៊ូ**និងនាហ្មឺនចំនួនម្ភៃបីនាក់ក៏លាងារចេញពីរាជការ។ **កេងប៊ូ**បាននាំ**កួនស៊ុន**ទៅចាំអែបប្របទ្វារដែល**អ្នួនសៀវ**នឹងចូលទៅនោះ។

វេលាដែល**អ្នួនសៀវ**បានទទួលសំបុត្រ**ហាន់ហុក**មើលដឹងសេចក្ដីហើយ ក៏ចាត់ចែងសេនាទាហានលើកទៅស្រុកគីជីវ។ **អ្នួនសៀវ**កាលចូលទៅដល់ទ្វារស្រុក

**កេងប៊ូ**និង**ក្លួនស៊ុន**ដកគ្រប៊ីស្ទុះចេញទៅនឹងចាក់**អ្លួនសៀវ**។ **ង៉ាន់លៀង**និង**ប៊ុនធីវ**ឃើញដូច្នោះក៏ស្ទុះដកគ្រប៊ីរត់ទៅការពារ ហើយកាប់**កេងប៊ូ**និង**ក្លួនស៊ុន**ស្លាប់។ **អ្លួនសៀវ**លើកទាហានចូលទៅក្នុងស្រុក **ហាន់ហុក**ក៏ចេញមកទទួលហើយនាំទៅកាន់ទីសំណាក់រាជការ។ **អ្លួនសៀវ**ទទួលកាន់កាប់រក្សាស្រុកនោះពេញទី ហើយតាំង**ហាន់ហុក**ជា**ប៊ូចុងគុន** ប្រែថា នាយទាហានឯក។ ឯបណ្តាខ្ញុំរាជការក្រៅពីនោះ **អ្លួនសៀវ**ឲ្យដកហូតចេញទាំងអស់ ហើយតាំង**កៀនហង១, ចោស៊ីវ១, ហងគី១** ដែលជាទាហាន**អ្លួនសៀវ**នោះធ្វើជានាហ្មឺនខ្ញុំរាជការ។

សម័យនោះ ការរាជការក្នុងស្រុកគីជីវ ជាកម្មសិទ្ធិស្រេចដាច់ខាតលើ**អ្លួនសៀវ**ទាំងអស់។ **ហាន់ហុក**ឃើញដូច្នោះក៏ភ្ញាក់ខ្លួនថា “**អ្លួនសៀវ**មកធ្វើដូច្នេះក៏ព្រោះតែអញគិតខុស ដែលអញនឹងនៅស្រុកនេះជាមួយនឹង**អ្លួនសៀវ**នោះ អំណើះតទៅមុខឃើញនឹងកើតអន្តរាយពុំខាន”។ លុះគិតដូច្នោះ ក៏កាត់ចិត្តចោលភរិយាបុត្រ រត់តែម្នាក់ឯងទៅនៅស្រុកតាន់លីវ។

ឯ**កងស៊ុនចាន**កាលបានដឹងថា **អ្លួនសៀវ**បានស្រុកគីជីវហើយ ក៏ឲ្យ**កងស៊ុនអ្លួត**ជាប្អូនទៅសួរ**អ្លួនសៀវ** តើនឹងព្រមបែងទ្រព្យរបស់មនុស្សប្រុសស្រីទឹកដីក្នុងស្រុកគីជីវពាក់កណ្តាល តាមសំបុត្រសញ្ញាធ្វើទុកនោះទេ? **អ្លួនសៀវ**តបថា ឲ្យទៅអញ្ជើញ**កងស៊ុនចាន**ជាបងអ្នកមកចុះនឹងនិយាយគ្នា។ **កងស៊ុនអ្លួត**ក៏លាត្រឡប់ទៅវិញ បានពាក់កណ្តាលផ្លូវ ស្រាប់តែជួបនឹងកងទ័ពលើកផ្ទប់មកទាំងសងខាងហើយស្រែកថា “អញជាទាហានមហាឧបរាជ” ថាហើយក៏លើកធ្នូបាញ់ត្រូវ**កងស៊ុនអ្លួន**ស្លាប់នៅទីនោះ។ បណ្តាទាហាន**កងស៊ុនអ្លួត**ដែលមកជាមួយ ក៏រត់រួចទៅដល់ស្រុកហើយយកសេចក្តីទៅជម្រាប**កងស៊ុនចាន**តាមការណ៍។

**កងស៊ុនចាន**ខឹងណាស់ក៏ថា វេលានេះ**អ្ហួនសៀវ**មានភ័ព្វត្រឡប់បានស្រុកគីជីវដោយស្រួលហើយ ហេតុម្ដេចគេប្រើកលឧបាយឲ្យទាហានមកចាំបង្កប់សម្លាប់**កងស៊ុនអ្ហួន**ប្អូនអញទៀត ហើយក្លែងថាជាទាហាន**តាំងតុះ**។ **អ្ហួនសៀវ**ធ្វើដូច្នេះមុខគួរឲ្យស្ដាយណាស់ បើអញសងសឹក**អ្ហួនសៀវ**មិនបានទេ ខ្លួនអញមិនពេញជាកូនប្រុសជាតិជាទាហានឡើយ។ តមក **កងស៊ុនចាន**ក៏រៀបចាត់ចែងទាហានកេណ្ឌមកអស់ពីក្នុងស្រុក លើកទៅច្បាំងនឹង**អ្ហួនសៀវ**។

ឯ**អ្ហួនសៀវ**ដឹងការណ៍ជា**កងស៊ុនចាន**លើកទាហានមកដល់ព្រំខេត្តហើយ ក៏កេណ្ឌទាហានលើកជាក្បួនទ័ពចេញទៅទទួលនៅមាត់ស្ទឹងភួនហូ ត្រើយខាងលិចស្ទឹងនោះមានស្ពានថ្មសិលាឆ្លងរហូតទៅ។ **កងស៊ុនចាន**ឃើញទ័ព**អ្ហួនសៀវ**លើកមកក៏ជិះសេះឆ្លងស្ពានទៅ ហើយស្រែកហៅ**អ្ហួនសៀវ**ថា ខ្លួនឯងនេះចំជាមនុស្សទុច្ចរិតគិតមកល្បួងបញ្ឆោតអញយកប្រយោជន៍ខ្លួន ហើយថែមធ្វើឧបាយកលសម្លាប់ប្អូនអញទៀត។ **អ្ហួនសៀម**ឮដូច្នោះក៏ឡើងជិះសេះបរឆ្លងស្ពានទៅ ប្រទល់មុខនឹង**កងស៊ុនចាន**ហើយឆ្លើយថា **ហាន់ហុក**ជាមនុស្សឆោតល្ងង់មិនដឹងគិតអ្វីសោះ លើកស្រុកគីជីវឲ្យយើងទាំងអស់ជាស្រេចហើយ ត្រូវការអ្វីអ្នកឯងមកលាដៃទារយកចំណែកទទេដូច្នេះមិនគួរឡើយ។ **កងស៊ុនចាន**តបថា ចៅហ្វាយខេត្តទាំងអស់ប្រឹក្សាមូលមាត់គ្នា ព្រោះឃើញថាឯងជាមនុស្សពិតត្រង់ ទើបតាំងឲ្យធ្វើជាមេទ័ពធំដូច្នេះ ឥឡូវអញឃើញចិត្តគំនិតឯងប្រហែលគ្នានឹងសត្វតិរច្ឆាន មិនគួរមកនៅនឹងស្ថានមនុស្សលោកឲ្យចង្អៀតទេ។ **អ្ហួនសៀវ**ខឹងណាស់ក៏សួរទាហានថា នរណានឹងយកអាសាចេញចាប់**កងស៊ុនចាន**មកឲ្យយើងបាន? **ប៊ុនធីវ**ឆ្លើយសុំខ្លួនហើយវាំទួនជិះសេះឆ្លងស្ពានទៅ **កងស៊ុនចាន**ក៏ញាក់សេះថយទៅឈរដល់ផែនដី **ប៊ុនធីវ**ក៏បរសេះតាមទៅចូលប្រយុទ្ធគ្នាបានប្រាំបួនឬដប់ស្នៀត **កងស៊ុនចាន**កម្លាំងខ្សោយក៏ថយសេះ

ទៅបំបាំងនឹងពួកទាហាន **ប៊ុនធីវ**ក៏ដេញបំពានទៅទៀត ទាហានទប់ពុំឈ្នះក៏ប្រាសបែកបាក់ខ្ចាត់ខ្ចាយអស់ នៅមានទាហាន**កងស៊ុនចាន**ពីរនាក់ទៀត បំផាយសេះចូលមកតយុទ្ធនឹង**ប៊ុនធីវ** ៗចាក់នឹងលំពែង ត្រូវទាហានម្នាក់ធ្លាក់ពីលើសេះស្លាប់ ទាហានបីនាក់ញាក់សេះរត់ថយចេញ **ប៊ុនធីវ**ដេញតាមទៅទៀតជិតទាន់**កងស៊ុនចាន**ក៏លើកលំពែងប្រុងនឹងចាក់ **កងស៊ុនចាន**កន្ត្រាក់សេះបំផាយរត់ទម្លាយកាត់ព្រៃទៅច្រើនតំបន់ **ប៊ុនធីវ**ក៏តាមប្រកិតពីក្រោយហើយស្រែកថា អាឯងចុះពីលើសេះឱ្យឆាប់ អញនឹងចាប់យកទាំងរស់ បើខំរត់ដោះអញនឹងចាក់ឱ្យស្លាប់ឥឡូវ។ **កងស៊ុនចាន**ក៏បំផាយសេះទៅទៀត ឯធ្នូនិងអាវុធក៏របូតធ្លាក់ពីដៃ មួកក៏ធ្លាក់ពីលើក្បាល លុះរត់ទៅដល់ជើងភ្នំមួយកន្លែង សេះក៏ជំពប់នឹងដុំថ្មដួលចុះ **ប៊ុនធីវ**លើកលំពែងនឹងចាក់ទទួលមានទាហានម្នាក់ឈ្មោះ**ជូឡុង** ជិះសេះបរស្ទុងមកស្ទាក់ពីមុខ**ប៊ុនធីវ**ជាប់ តាំងតែប្រកាប់តគ្នានឹង**ប៊ុនធីវ**។ ឯ**កងស៊ុនចាន**ក៏ស្ទុះរត់រួចទៅពួននៅកៀនភ្នំនោះ **ជូឡុង**និង**ប៊ុនធីវ**តយុទ្ធគ្នាដល់ហុកសិបស្នៀតមិនចាញ់មិនឈ្នះ។ វេលានោះមានពួកទាហាន**កងស៊ុនចាន**ដែលបែកទ័ពត្រឡប់លើកគ្នាមកទាន់ ក៏ចូលទៅឡោមព័ទ្ធ**ប៊ុនធីវ**នៅក្នុងចំណោម **ប៊ុនធីវ**ឃើញថានឹងចាញ់ប្រៀបគេ ក៏ញាក់សេះទម្លុះទម្លាយរត់ចេញទៅបាន។ **កងស៊ុនចាន**ក៏ចេញមកពីកៀនភ្នំឃើញទាហាននោះមាឌធំខ្ពស់ប្រហែលប្រាំមួយហត្ថ មុខមាត់សម្បើមចញ្ចើមក្រាស់ ភ្នែកក្រឡោតក៏សួរថាអ្នកឈ្មោះអ្វី បានជាមកជួយជីវិតយើងពេលនេះ? យើងមានសេចក្ដីអរគុណជាច្រើន។ **ជូឡុង**បន្ទន់ខ្លួនឱនគំនាប់ហើយថា ខ្ញុំបាទឈ្មោះ**ជូឡុងសែតៀវ**នៅស្រុកសៀងសាន់ ពីមុនខ្ញុំបាទទៅនៅនឹង**អួនសៀវ**ម្ដង តែខ្ញុំបាទឃើញថា**អួនសៀវ**ជាមនុស្សកំណាចអាក្រក់ណាស់ មិនជាមនុស្សសុចរិតទៀងត្រង់ទេ ខ្ញុំក៏រត់មកដោយបំណងទីពឹងនៅនឹងលោក ទទួលខ្ញុំបាទចេញមកជួនជាជួបនឹងលោកនៅទីនេះ។ **កងស៊ុនចាន**ក៏មាន

សេចក្តីត្រេកអរណាស់ ទើបឡើងជិះសេះមួយម្នាក់ ហើយនាំ**ជូឡុង** និងទាហានទាំងពួងលើកត្រឡប់ទៅបន្ទាយត្រើយស្ទឹង។

ឯ**អ្នួនសៀវ**ដល់ដឹងដំណឹងថា **កងស៊ុនចាន**វិលទៅចូលបន្ទាយហើយ ក៏ចាត់ឲ្យ**ង៉ាន់លៀង, ប៊ុនធីវ**ឲ្យលើកទាហានធ្នូម្នាក់មួយពាន់ បំបែកជាពីរផ្លូវទៅបង្កប់នៅដើមស្ពាន បានសន្មតគ្នាថា “បើឮសំឡេងផាវជាសញ្ញាហើយ ឲ្យបាញ់ចម្រុះទាំងឆ្វេងទាំងស្តាំតម្រង់ទៅបន្ទាយ” ហើយចាត់ឲ្យ**ចុកឃី**លើកទាហានធ្នូប្រាំបីរយនិងទាហានឡេវមួយម៉ឺនប្រាំពាន់ជាកងចេញមុខឡើងបញ្ឆោត ឯ**អ្នួនសៀវ**លើកទាហានប្រាំម៉ឺនជាទ័ពហ្លួង លុះចាត់ស្រេចការហើយក៏ឲ្យទាហានទាំងអស់សំងំនៅស្ងៀម។

ខណៈនោះ **កងស៊ុនចាន**ចាត់ឲ្យ**យ៉ាំកុង**លើកទាហានជាកងមុខ ហើយបំបែកជាពីរប៉ែកខាងឆ្វេងស្តាំ តែ**ជូឡុង**នោះ**កងស៊ុនចាន**ពុំទាន់ស្គាល់ចិត្ត ក៏ចាត់ឲ្យលើកទាហានជាកងខាងក្រោយ ហើយឲ្យយកទង់សរសេរជាតួអក្សរហើយដោតឡើង អក្សរនោះថា “ឈ្មួយគី” ប្រែថា “ទង់សម្រាប់មេទ័ព” ហើយលើកទាហានតាំងជាក្បួនទ័ពនៅលើស្ពានសិលានោះ ស្រេចហើយឲ្យទាហានទាំងពួងវាយឃ្មោះវាយគងទូងភិរី ហ៊ោកញ្ជ្រៀវអឺងកងតាំងពីព្រឹកដល់ថ្ងៃរសៀល ទាហានក្នុងកងទ័ព**អ្នួនសៀវ**ក៏នៅសំងំស្ងៀម។ ឯ**យ៉ាំកុង**ជានាយកងទ័ពមុខក៏លើកទាហានទន្ទ្រានចូលទៅ។

ខាងទ័ព**អ្នួនសៀវ**គឺ**ចុកឃី**ជានាយកងទ័ពមុខ បានលើកទាហានថយបញ្ឆោតទៅផុតចុងស្ពាន ឃើញបានការហើយ ក៏អុជផាវជាសញ្ញាឡើង ឯពួកទាហានធ្នូប្រាំបីរយនាក់បាញ់ចម្រុះតម្រង់មក។ **យ៉ាំកុង**យល់ថានឹងទ្រាំទ្រតទល់ពុំបាន ក៏ដេញទាហានថយក្រោយទៅដល់ដើមស្ពានវិញ។ **ចុកឃី**ឃើញបានការក៏បំផាយសេះចូលតយុទ្ធនឹង**យ៉ាំកុង**បានប្រាំស្ទៀត ហើយយកដាវកាប់**យ៉ាំកុង**ធ្លាក់ពីលើសេះស្លាប់ កងទ័ព**កងស៊ុនចាន**ខាងប៉ែកឆ្វេងនិងស្តាំក៏លើកគ្នាចូលព្រួតទាំងសងខាងមកទៀត។

ខណៈនោះ**ង៉ាន់លៀង** និង**ប៊ុនធីវ** ក៏លើកទាហានឆ្វេងស្ដាំដែលបង្កប់នៅដើមស្ពាននោះបាញ់ធ្នូចម្រុះពីក្រោយ ទាហាន**កងស៊ុនចាន**ចូលជួយពុំបាន **ចុកឃី**ក៏ដេញទាហានចូលប្រកាប់សង្គ្រុញទៅដល់**កងស៊ុនចាន** ហើយយកគ្រប៊ីកាប់ដងទង់ជ័យបាក់ធ្លាក់ចុះ **កងស៊ុនចាន** ទប់ពុំឈ្នះក៏ត្រឡប់ថយទ័ពចុះពីស្ពានរត់ទៅ **ចុកឃី**ដេញជិតប្រកិតកាប់ចាក់សម្លាប់ទាហាន**កងស៊ុនចាន**ជាច្រឡំបល់ ទាហានដែលនៅសល់ទាំងប៉ុន្មានក៏រត់បែកបាក់ខ្ចាត់ខ្ចាយអស់ទៅ។

កាល**ចុកឃី**កាប់ដងទង់សម្រាប់មេទ័ពបាក់ **កងស៊ុនចាន**បែកទ័ពត្រឡប់ទៅក្រោយនោះ មានទាហានម្នាក់ទៅប្រាប់**អ្វួនសៀវ**ថា កងទ័ព**ចុកឃី**បែកហើយ។ **អ្វួនសៀវ**ត្រេកអរណាស់ ក៏នាំ**តៀនហង** និងទាហានកាន់ទូនប្រមាណបីរយ កាន់ធ្នូហាសិបចេញមក សម្លឹងមើលក្រៅបន្ទាយឃើញសមដូចពាក្យទាហាននិយាយ **អ្វួនសៀវ**ក៏ទះដៃសើចហើយថា **កងស៊ុនចាន**នោះជាមនុស្សមិនចំណានក្នុងការសង្គ្រាមសោះ យើងគ្រាន់តែច្បាំងប៉ុណ្ណេះបែកទ័ពទៅហើយ។ **អ្វួនសៀវ**ក៏មានសេចក្ដីប្រមាទធ្វេសការ។

ក្រោយនោះ**ជូឡុង**និង**កងស៊ុនចាន** ស្រូតលើកទាហានឆ្លងស្ពានតាមទៅទៀត លុះឃើញពួកទាហានអ្វួនសៀវ **ជូឡុង**ក៏បរសេះស្ទុះតាមទៅចាក់កាប់សម្លាប់ទាហានទាំងនោះពិការជាច្រើន ឯ**កងស៊ុនចាន**ក៏ស្រូតលើកទាហានព័ទ្ធស្ទាក់ជុំវិញទ័ព**អ្វួនសៀវ** ហើយបាញ់ធ្នូចម្រុះទៅទៀត។ **តៀនហង**ឃើញដូច្នោះភ័យណាស់ និយាយនឹង**អ្វួនសៀវ**ថា គ្រានេះយើងមុខជាខូចការនឹងសត្រូវហើយ លោកចូរអែបទៅខាងក្បែរបន្ទាយរត់ទៅចុះ។ **អ្វួនសៀវ**តបថា “កើតមកជាជាតិទាហានហើយមិនត្រូវខ្លាចស្លាប់ទេ” ថាហើយក៏ស្រែកហៅទាហានឱ្យចូលច្បាំងប្រកាប់ជាប់គ្នា ពួកទាហានទាំងសងខាងក៏ប្រពាក់ប្រពូនទៅវិញទៅមក។ **ង៉ាន់លៀង**ឃើញ**កងស៊ុនចាន**

និង**ជូឡុង**ច្បាំងជាប់ដៃគ្នានឹងទាហានខាងខ្លួន ក៏ដេញបញ្ជូនទាហានវាយព័ទ្ធខ្ទប់ពីខាងក្រោយថែមទៅទៀត។ ទាហាន**អួនសៀវ**ដែលលើកទៅបញ្ឆោតហើយបែកទៅនោះ លុះក្រឡេកឃើញទ័ពកំពុងប្រកាប់ជាប់ដៃគ្នា ក៏វាមកព្រួតខ្ទប់ពីខាងម្ខាង។ **ជូឡុង**ច្បាំងទល់ក្នុងកងទ័ពដែលខ្ទប់ជុំវិញ ហើយថានឹងការពារពុំឈ្នះទម្លាយចេញឆ្លងស្ពានរួចទៅ។ **អួនសៀវ** និង**ង៉ាន់លៀង** ក៏លើកទាហានទន្ទ្រានតាមទាល់តែផុតស្ពាន បានចាក់កាប់សម្លាប់កងទ័ព**កងស៊ុនចាន**ធ្លាក់ពីលើស្ពានស្លាប់ជាច្រើន ហើយដេញ**កងស៊ុនចាន** និង**ជូឡុង**ហួសស្ពានទៅទៀត ប្រហែលចម្ងាយផ្លូវហាសិបសិន។

វេលានោះ**ឡៅពី**ដឹងដំណឹង ទើបនាំ**គួនអ៊ូ**, **តៀវហ៊ុយ** និងទាហានទាំងពួងលើកមកជួយ**កងស៊ុនចាន**។ កាលក្រឡេកឃើញទ័ព**អួនសៀវ**លើកដេញ**កងស៊ុនចាន**បានទៅដល់ជើងភ្នំ **ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ** នាំគ្នាបំផាយសេះស្ទុះទៅស្ទាក់ពីមុខសេះ**អួនសៀវ** ៗក្រឡេកឃើញ**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**នៅទទឹងពីមុខ ក៏តក់ស្លុតស្ទើរនឹងបាត់ស្មារតី ដាវដែលកាន់នៅដៃក៏របូតធ្លាក់អស់នៅតែខ្លួនទទេ ហើយបែរត្រឡប់សេះស្ទុះថយក្រោយទៅចូលបន្ទាយ។

ឯ**កងស៊ុនចាន**បានឃើញ**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**មកជួយដូច្នោះ ក៏មានសេចក្ដីសោមនស្សពន់ពេក សាកសួរគ្នាហើយក៏ថយចូលទៅក្នុងបន្ទាយ។ **កងស៊ុនចាន**បាននិយាយប្រាប់**ឡៅពី**ថា កាលគ្រា**ប៊ុនធីវ**ជាទាហាន**អួនសៀវ**ដេញខ្ញុំមក កុំតែបាន**ជូឡុង**ចេញមកជួយ ខ្ញុំក៏មិនបានគង់ជីវិតទេ ពេលនេះ**អួនសៀវ**ដេញខ្ញុំមកម្ដងទៀត បើកុំតែបានអ្នកមកជួយខ្ញុំ ៗក៏អន្តរាយជីវិតប្រាកដណាស់។

**កងស៊ុនចាន** និង**អួនសៀវ** ក៏ប្រុងប្រៀបរៀបសេនាទាហានទៅវិញទៅមកយ៉ាងមាំមួនតាំងបន្ទាយវាយទ័ពជាប់ដែនគ្នាខាងត្រើយស្ទឹងម្ខាងម្នាក់ ត្រឹមតែតាំងទ័ពទុកនៅទីនោះប្រហែលមួយខែប្លាយ។

វេលានោះ មានមនុស្សម្នាក់យកដំណឹងនោះទៅប្រាប់**លីយូ**នៅក្រុងទៀងហាន់តាមដំណើរដែល**អ្ហួនសៀវ**និង**កងស៊ុនថាន**តតាំងច្បាំងគ្នានោះគ្រប់ប្រការ។ **លីយូ**ក៏នាំសេចក្ដីនោះទៅប្រាប់**តាំងតុះ** ៗពិគ្រោះនឹង**លីយូ**ថា ដែល**អ្ហួនសៀវ**និង**កងស៊ុនថាន**មានថ្វីដៃធ្វើពិជ័យសង្គ្រាមនឹងគ្នាដូច្នេះ យើងនឹងគិតប្រការដូចម្ដេច? **លីយូ**ថា **អ្ហួនសៀវ**និង**កងស៊ុនថាន**នោះ សុទ្ធតែមានថ្វីដៃខ្លាំងពូកែណាស់ បានតតាំងច្បាំងគ្នានៅតំបន់ស្ទឹងភ្នួនហួយូរខែហើយ បើខាងណាមានជ័យជម្នះ ខាងនោះក៏នឹងកំរើបឡើង យូរទៅគង់នឹងនាំឲ្យរំខានដល់ខ្លួនលោក បើដូច្នោះសូមឲ្យលោកតែងសំបុត្រព្រះតម្រាស់ព្រះចៅ**ហៀនតេ**ទៅហាមឃាត់ទាំងសងខាងឲ្យជាមេត្រីនឹងគ្នាទៅវិញ យូរទៅ**អ្ហួនសៀវ**និង**កងស៊ុនថាន**នឹងនៅក្នុងបង្គាប់បញ្ជាលោក។ **តាំងតុះ**ឃើញត្រូវ ក៏តែងជាព្រះតម្រាស់ព្រះចៅ**ហៀនតេ**ពីរច្បាប់តាមពាក្យ**លីយូ**ថានោះ ហើយឲ្យ**តៀវគី**និង**ម៉ាឃឹត**នាំទៅឲ្យ**អ្ហួនសៀវ** និង**កងស៊ុនថាន**។

ឯ**អ្ហួនសៀវ**កាលដឹងដំណឹងហើយ ក៏ចេញទៅទទួលព្រះតម្រាស់តាមទំនៀមទម្លាប់រួចនាំត្រឡប់ចូលទៅក្នុងបន្ទាយ លុះមើលដឹងសេចក្ដីហើយ ក៏ព្រមទទួលប្រតិបត្តិតាមព្រះរាជតម្រាស់គ្រប់ប្រការ។ រួច**តៀវគី** និង**ម៉ាឃឹត**នាំគ្នាកាន់ព្រះតម្រាស់មួយច្បាប់ទៀតឆ្លងទៅឲ្យ**កងស៊ុនថាន**ក្នុងបន្ទាយ។ **កងស៊ុនថាន**កាលដឹងសេចក្ដី ក៏ទទួលប្រតិបត្តិតាមព្រះរាជតម្រាស់នោះ ហើយចាត់បម្រើទៅចរចាប្រាប់**អ្ហួនសៀវ** ៗទទួលព្រមល្មមតាមគ្នា ព្រះរាជបម្រើទាំងពីរនាំសេចក្ដីត្រឡប់ចូលទៅក្រុងទៀងហាន់ ខាង**អ្ហួនសៀវ**លើកពលត្រឡប់ទៅគីជីវវិញ។

ចំណែក**កងស៊ុនថាន**បានរៀបចំសេនាទាហាន ហើយនាំ**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**, **ជូឡុង**លើកទ័ពត្រឡប់ទៅខេត្ត លុះដល់ស្រុកផេងង្ហួនគួន **ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**លាចូលទៅនៅនិយាយរាជការដូចដើម។ **ជូឡុង**បាននិយាយនឹង**ឡៅពី**ថា

កាលពីដើមមកខ្ញុំឃើញ**អ្នួនសៀវ**ជាមនុស្សអាក្រក់ បានជាត្រឡប់មកនៅនឹង**កងស៊ុនថាន** ឥឡូវនេះខ្ញុំបានឃើញថា **កងស៊ុនថាន**ជាមនុស្សគ្មានតម្រិះប្រាជ្ញាសោះ ក៏មានសេចក្ដីព្រួយលំបាកក្នុងចិត្តពន់ពេក ដល់ខ្ញុំបាទបានឃើញលោកមានសតិបញ្ញាភ្លៀវក្លាគិតថា នឹងចង់ចូលសមាគមជាមួយផង ប៉ុន្តែទាស់នៅឆ្ងាយដាច់ស្រយាលពីគ្នាពេក ខ្ញុំបាទមិនដឹងជានឹងគិតរបៀបណា។ **ឡៅពី**តបដោយយកចិត្ត**ជូឡុង**ថា អ្នកនិងយើងស្គាល់ចិត្តគ្នាក្នុងគ្រានេះ ក៏ត្រូវនៅរាប់អានជាស្និទ្ធស្នាលនឹងគ្នាតទៅ តែឥឡូវនេះអ្នកទ្រាំនៅជាមួយនឹង**កងស៊ុនថាន**សិនចុះ បើជីវិតយើងនៅមានទៅខាងឯមុខទៀត អ្នកក៏គង់បានជួបប្រសព្វធ្វើការជាមួយមិនខានទេ អ្នកចូរចាំពាក្យនេះទុកកុំភ្លេច។ **ឡៅពី**ទាញដៃ**ជូឡុង**ចូលទៅជិត ហើយក៏មានសេចក្ដីសោកសៅ។ **ជូឡុង**ក៏យំអាល័យ**ឡៅពី** ហើយ**ឡៅពី**លា**ជូឡុង**ចូលទៅក្នុងស្រុកផេងងួនគួន **កងស៊ុនថាន**នាំ**ជូឡុង**លើកទាហានទៅស្រុកប៉ាក់ប៉េង។

ឯ**អ្នួនសុត**ចៅហ្វាយស្រុកឡាំយ៉ុង លុះដឹងដំណឹងថា **អ្នួនសៀវ**ជាបងបានស្រុកគីជីវដូច្នោះ ក៏ធ្វើសំបុត្រមួយច្បាប់ឲ្យនាំទៅជម្រាបសុំសេះ**អ្នួនសៀវ**មួយពាន់ តែ**អ្នួនសៀវ**មិនព្រមឲ្យដូចប្រាថ្នា **អ្នួនសុត**ខឹងណាស់មានសេចក្ដីព្យាបាទ**អ្នួនសៀវ**ជាបង។ **អ្នួនសុត**ធ្វើសំបុត្រទៅសុំស្បៀងអាហារពី**ឡៅពីវ**ចៅហ្វាយស្រុកកេងជីវវិញ ខាង**ឡៅពីវ**ក៏មិនព្រមឲ្យស្បៀងអាហារទៅ**អ្នួនសុត** ៗក៏ខឹងចង់ព្យាបាទនឹង**ឡៅពីវ**ទៀត។ **អ្នួនសុត**ធ្វើសំបុត្រទៅដល់**ស៊ុនកៀន**ចៅហ្វាយស្រុកកាំងតាំងថា **ឡៅពីវ**លើកទាហានចេញស្កាត់ច្បាំងដណ្ដើមយកត្រាសម្រាប់រាជ្យពីលោកនោះ ក៏ព្រោះ**អ្នួនសៀវ**បងខ្ញុំឲ្យដំណឹង ឥឡូវនេះ**អ្នួនសៀវ**និង**ឡៅពីវ**រួមគំនិតគ្នានឹងលើកទ័ពមកវាយយកស្រុកកាំងតាំង ដណ្ដើមយកត្រាឲ្យបាន។ រឿងនេះបើលោកនឹងតាំងចិត្តសំងំស្ងៀមមិនគួរទេ ចូរប្រញាប់លើកទាហានទៅវាយយកស្រុកកេងជីវឲ្យហើយ

ទៅ ខ្ញុំនឹងជួយសងសឹកលោក ហើយនឹងលើកទ័ពប្រសព្វគ្នាទៅវាយស្រុកគីជីវទៀត ដែល**អ្នួនសៀវ**នៅនោះ។ ឯ**ស៊ុនក្វៀន**បានទទួលសំបុត្រដឹងសេចក្ដីហើយ ក៏ពេញចិត្តណាស់ ទើបប្រឹក្សានឹងសេនាទាហានថា អ្នកឯណានឹងយល់ឃើញដូចម្ដេច? **តៀផៅ**ឆ្លើយតបថា ដែល**អ្នួនសុត**ឲ្យសំបុត្រមកនេះ យើងនឹងជឿស្ដាប់ពុំទាន់បាន ព្រោះ**អ្នួនសុត**នោះជាមនុស្សអាក្រក់ រមែងញុះញង់អ្នកដទៃឲ្យទាស់ទែងគ្នា ម្យ៉ាងទៀត**អ្នួនសុត**ត្រូវជាប្អូន**អ្នួនសៀវ**ផង ដែលថានឹងលើកទ័ពទៅច្បាំងនឹងបងវានោះដូចមិនពិត។ **ស៊ុនក្វៀន**ឆ្លើយតបថា ដែល**តៀផៅ**ថានោះក៏ត្រូវហើយ តែថា**ឡៅពីវ**នោះជាមនុស្សមិនត្រង់នឹងយើង បើប្រសិនជា**អ្នួនសុត**មិនមានសំបុត្រមកដល់យើង ៗក៏មិនមែននៅស្ងៀមដែរ គង់នឹងលើកទ័ពទៅច្បាំង ការទាំងនេះមិនមែនដឹងដោយសារគេជួយប៉ុណ្ណោះទេ ថាហើយក៏បង្គាប់**អ៊ុយកាយ**ឲ្យទៅកេណ្ឌប្រមូលទាហាន និងរៀបយានជំនិះខាងផ្លូវជលវិធីព្រមទាំងទូកក្ដារច្រវាថែវគ្រឿងសាស្ត្រាវុធ មានទូកតូចធំភ្ជុំដាក់សេះនិងស្បៀងអាហារបរិបូរ ចាំដល់ពេលឫក្សល្អនឹងលើកព្យុហៈយាត្រា។ ឯពួកកងក្រវែលល្បាត កាលបានដឹងដំណឹងច្បាស់ ក៏នាំសេចក្ដីនោះទៅជម្រាបដល់**ឡៅពីវ** ៗក៏ប្រជុំទីប្រឹក្សាថា **ស៊ុនក្វៀន**នឹងលើកទ័ពទឹកមកនោះ តើអ្នកទាំងអស់គ្នាយល់ឃើញដូចម្ដេច? **កេងលៀង**ឆ្លើយថា ដែល**ស៊ុនក្វៀន**នឹងលើកទ័ពទឹកមកនោះ ឃើញថានឹងតស៊ូនឹងយើងខាងទ័ពគោកមិនបានទេ ព្រោះបញ្ជូនស្បៀងលំបាក សូមឲ្យលោកកេណ្ឌទាហានរបស់**ហងច** ថៅហ្វាយខេត្តកាំងហែ ដែលឡើងខេត្តយើងតាំងជាទ័ពមុខ ខ្លួនលោកលើកជាទាហានទ័ពហ្លួង។ **ឡៅពីវ**ឃើញត្រូវក៏ឲ្យទៅកេណ្ឌទាហាន**ហងច** លើកទៅតាំងនៅមាត់ព្រែកហ៊្វូនសៀ ហើយចាត់ចែងទាហានក្នុងស្រុកកេងជីវកេណ្ឌទុកតាមពាក្យ**កេងលៀង**ថា។

ឯ**ស៊ុនកៀន**មានភរិយាពីរនាក់ ជាបងប្អូនបង្កើតនឹងគ្នា បងឈ្មោះនាង**ង៉ហ៊ូយិន** ប្អូនឈ្មោះនាង**ង៉យីហ៊ូយិន** ។ នាងបងមានបុត្រប្រុសបួននាក់ ឈ្មោះ**ស៊ុនសេក១, ស៊ុនគួន១, ស៊ុនសៀង១, ស៊ុនខង១**។ នាងប្អូនមានបុត្រប្រុសឈ្មោះ**ស៊ុនឡង១** បុត្រស្រីឈ្មោះ**ស៊ុនហ៊ូយិន១** បុត្រប្រុសចិញ្ចឹមម្នាក់ទៀតឈ្មោះ**កងឡេ**។ **ស៊ុនកៀន**មានប្អូនប្រុសម្នាក់ឈ្មោះ**ស៊ុនចេង**។ កាលថ្ងៃមានឫក្សល្អ **ស៊ុនកៀន**នឹងចុះទូកទៅនោះ **ស៊ុនចេង**ជាប្អូនក៏នាំបុត្រ**ស៊ុនកៀន**ទាំងប្រាំពីរនាក់ តាមចុះទៅឃាត់**ស៊ុនកៀន**ថា គ្រានេះព្រះចៅ**ហៀនតេ**បានសោយរាជសម្បត្តិ រាជការអាណាចក្រក៏ជាកម្មសិទ្ធិដាច់ខាតលើ**តាំងតុះ** ៗធ្វើការទុច្ចរិតអាក្រក់ អាណាខេត្តទាំងពួងក៏កើតចលាចលលែងចំណុះចុះចូលគ្នា អាណាប្រជានុរាស្ត្រក៏បានសេចក្តីក្តៅក្រហាយទូទាំងផែនដី ឥឡូវដែនស្រុកកាំងតាំងទើបនឹងរាបទាបជាសុខសាន្តត្រាណហើយ ដែលអ្នកជាបងនឹងលើកទ័ពទៅច្បាំងនឹង**ឡៅពីវ**ចៅហ្វាយខេត្តកេងជីវ សូមឲ្យត្រិះរិះរំពឹងមើលសិន។ **ស៊ុនកៀន**តបថា កាលពីមុនមកខ្លួនយើងម្នាក់ឯង ម្តេចក៏តាំងខ្លួនឡើងបាន ឥឡូវយើងបានសេនាទាហានមកជាកម្លាំងដៃជើងច្រើនប៉ុណ្ណោះហើយ យើងនឹងលះបង់នៅស្ងៀមមិនទៅធ្វើការសងសឹក**ឡៅពីវ**ដែលជាគូសត្រូវឲ្យបានទេ ក៏ហាក់ដូចជាយើងមិនមែនកូនប្រុសជាជាតិទាហានមានថ្វីដៃ។

**ស៊ុនសេក**ឆ្លើយជម្រាប**ស៊ុនកៀន**ជាបិតាថា បើបិតាមិនព្រមឈប់ នឹងលើកទ័ពទៅឲ្យបាននោះ ខ្ញុំបាទក៏សូមទៅជាមួយផង។ **ស៊ុនកៀន**មានសេចក្តីស្រឡាញ់**ស៊ុនសេក**ជាទីបំផុត តែនឹងឃាត់មិនកើត ក៏ទទួលឲ្យទៅជាមួយ ហើយលើកទាហានចុះទូកចម្បាំងឆ្លងឈូងសមុទ្រទៅដល់ពាមស្រុកហ៊្វួនសៀ ប្រទល់នឹងស្រុកកាំងហែ។

ចំណែក**ហាងច**ចៅហ្វាយស្រុកកាំងហែដឹងតាមសំបុត្របង្គាប់អំពី**ឡៅពីវ** ឲ្យមក ក៏តាំងតែកេណ្ឌប្រមូលជាកងទ័ព ហើយលើកទៅបម្រុងការនៅមាត់កំពង់ស្រុកហ៊្វូនសៀ។ លុះឃើញ**ស៊ុនកៀន**លើកទាហានទឹកមកប្រពាក់ប្រពួនដល់មាត់កំពង់ ក៏តាំងតែឲ្យទាហានបាញ់ធ្នូចម្រុះចុះទៅសំដៅទូកទាំងនោះ។ **ស៊ុនកៀន**ឃើញដូច្នោះក៏បំបាំងខ្លួន ថយទូកបញ្ឆោត បណ្ដែតឲ្យបាញ់ដល់បីយប់បីថ្ងៃ ទាហានកងទ័ពទូកក៏មិនមានសេចក្ដីអន្តរាយ។ **ហាងច**ក៏ឲ្យបាញ់បន្ថែមទាល់តែអស់ព្រួញ ។

ឯ**ស៊ុនកៀន**បានដឹងថា ព្រួញធ្នូស្ងប់ស្ងាត់ហើយ ក៏ឲ្យទាហានដកយកព្រួញដែលជាប់នៅនឹងទូកទាំងអស់បានចំនួនព្រួញប្រហែលដប់ប្រាំម៉ឺន។

ពេលនោះមានខ្យល់បក់ត្រឡប់ខ្ទប់ច្រាំង **ស៊ុនកៀន**ឲ្យថែវទូកចម្បាំងចូលទៅចត ហើយឲ្យបាញ់ធ្នូឡើង។ ទាហាន**ហាងច**អស់ព្រួញហើយ ឃើញនឹងទប់ពុំឈ្នះ ក៏លើកទ័ពថយចូលស្រុកហ៊្វូនសៀ។ **តៀផៅ**និង**អ៊ុយកាយ**ឃើញដូច្នោះ ក៏លើកទាហានបំបែកជាពីរកងដេញប្រកាប់ជាប់ចូលទៅដល់ទ្វារស្រុកហ៊្វូនសៀ **ស៊ុនកៀន**និង**ហាន់តុង**ក៏លើកទាហានទ័ពជំនួយប្រពាក់ប្រពួនចូលទៅទៀត លុះឃើញ**ហាងច**ថយទ័ពចូលទ្វារស្រុក ក៏បរទាហានសម្រុកតាមទៅក្នុងស្រុកតេងសៀ។ **ស៊ុនកៀន**ឃើញបានការ ក៏ឲ្យ**អ៊ុយកាយ**លើកពលត្រឡប់ទៅថែរក្សាទូកចម្បាំង ឯខ្លួនលើកទាហានតាម**ហាងច**ទៅទៀត **ហាងច**ឃើញ**ស៊ុនកៀន**ទន្ទ្រានលើកទ័ពតាមទល់នឹងកំពែងស្រុកដូច្នោះ ក៏លើកទាហានចេញមកច្បាំងតទល់នៅក្រៅកំពែង។

សម័យនោះ **ស៊ុនកៀន**និង**ស៊ុនសេក**ជាកូនបានតែងខ្លួនជិះសេះស្រូតទៅឈរនៅមុខទាហាន **ហាងច**បរសេះចេញមកប្រទល់មុខហើយស្រែកជេរ**ស៊ុនកៀន**ថា "អាឯងនេះជាពួកចោរ អាឯងមិនខ្លាចស្លាប់ទេឬ?" ហើយប្រើ**តៀវហៅ**ឲ្យចូលទៅតយុទ្ធ។ **ស៊ុនកៀន**ប្រើ**ហាន់តុង**ច្បាំងនឹង**តៀវហៅ**បានសាមសិបស្ទៀត **តាន់សេង**ក៏

បរសេះចេញមកជួយ**តៀវហៅ**ទៀត **ស៊ុនសេក**ឃើញដូច្នោះ ក៏យឹតធ្នូបាញ់ត្រូវមុខ**តាន់សេង**ធ្លាក់ពីលើសេះស្លាប់ **តៀវហៅ**ឃើញ**តាន់សេង**ស្លាប់ដូច្នោះ ស្តុតស្លាំងភាំងស្មារតីភ័យឡឺនឡង់ **ហាន់តុង**ក៏លើកដាវកាប់**តៀវហៅ**ធ្លាក់ពីលើសេះស្លាប់ទៅទៀត**តៀផៅ**ក៏បំផាយសេះត្រង់ទៅប្រុងនឹងកាប់**ហាងច** ៗភ័យណាស់ ស្ទុះដកម្មួកចោលពីក្បាល ហើយលោតចុះពីលើសេះរត់ទៅបន្លំខ្លួនជាមួយនឹងទាហាន **ស៊ុនកៀន**ដេញបរទាហានចូលទៅចាក់កាប់សម្លាប់ពល**ហាងច** តទៅដល់តំបន់ហាន់ស៊ុយ **ហាងច**គេចរត់ទៅរួច **ស៊ុនកៀន**ប្រើទាហានទៅប្រាប់**អ៊ុយកាយ**ឲ្យនាំទូកចម្បាំងទៅទទួលឯកំពង់ហាន់កាំង។

ចំណែក**ហាងច**ខូចខាតសេនាទាហានជាច្រើន ខំស្រូតរូតកាត់ទៅដល់ស្រុកកេងជីវ យកសេចក្តីចូលទៅជម្រាប**ឡៅពីវ** ៗបានដឹងភ័យណាស់ ទើបប្រឹក្សានឹង**កេងលៀង**ៗឆ្លើយជម្រាបថា ដែល**ហាងច**បែកមកនោះ ទាហាន**ស៊ុនកៀន**មុខជានឹងមានចិត្តកំរើប បើយើងនឹងលើកទ័ពទៅច្បាំងឥឡូវនេះ ក៏ហាក់បីដូចជាលត់ភ្លើងក្រោមខ្យល់ បើដូច្នេះយើងត្រូវតែឲ្យរក្សាបន្ទាយនិងទ្វារស្រុកទីចម្បាំងឲ្យមាំមួនសិនហើយត្រូវឲ្យមានសំបុត្រទៅសុំកងទ័ពពី**អ្នួនសៀវ**លើកមកជួយ ទើបឃើញថា**ស៊ុនកៀន**នឹងមិនប្រទូសរាយបាន។ **ឈ្មួម៉**ឆ្លើយថា ដែល**កេងលៀង**ថានោះមិនត្រូវសោះ ព្រោះទ័ព**ស៊ុនកៀន**លើកមកដល់ជើងកំពែងហើយ ត្រូវតែបម្រុងរក្សាស្រុកឲ្យមាំមួនក្នុងគ្រានេះ ដែលនឹងធ្វើសំបុត្រទៅសុំកងទ័ព**អ្នួនសៀវ**មកជួយនោះ មុខជាមិនទាន់ការ ឥឡូវនេះ ខ្ញុំបាទបានសុំយកអាសាលើកទាហានចេញទៅវាយទ័ព**ស៊ុនកៀន**ជាមុន។ **ឡៅពីវ**បានស្តាប់ហើយក៏យល់ព្រម ហើយប្រគល់ទាហានឲ្យ**ឈ្មួម៉**ចំនួនមួយម៉ឺនលើកចេញទៅដល់ភ្នំហ៊ីសាន់ ក៏បោះកងទ័ពឈប់នៅទីនោះ។ ឯ**ស៊ុនកៀន**មិនបានដឹងជា**ឈ្មួម៉**លើកទ័ពមកតាំងនៅទីនោះទេ ក៏លើកទាហានស្រូតរូតទៅដល់ភ្នំ

ហ៊ីសាន់ **ឈួម៉**ដឹងច្បាស់ក៏ឡើងសេះកាន់លំពែងចេញមកឈរមុខទាហាន **ស៊ុនកៀន** ឃើញ**ឈួម៉**ក៏និយាយនឹងពួកទាហានថា នរណានឹងអាចយកអាសាទៅចាប់យក **ឈួម៉** បងថ្លៃ**ឡៅពីរ**ឲ្យយើងបាន?

**តៀផៅ**ឆ្លើយទទួលយកអាសា ស្រេចហើយឡើងសេះវាំទួនចេញទៅតយុទ្ធនឹង**ឈួម៉**បានដប់ស្ទៀត **ឈួម៉**ដឹងកម្លាំងនឹងតដៃ**តៀផៅ**ពុំបាន ក៏ញាក់សេះគេចថយក្រោយ។ **ស៊ុនកៀន**លើកទាហានដេញបណ្ដោយហើយចាក់កាប់សម្លាប់ពួក**ឈួម៉**ស្លាប់ជាច្រើន។ ឯ**ឈួម៉**ក៏រត់ចូលទៅក្នុងស្រុក ហើយនាំព័ត៌មាននោះទៅជម្រាប**ឡៅពីរ** ។ **កេងលៀង**និយាយនឹង**ឡៅពីរ**ថា ព្រោះលោកមិនស្ដាប់ពាក្យខ្ញុំទើបថ្លោះការយ៉ាងនេះ **ឈួម៉**ដែលអួតខ្លួនយកអាសាទៅធ្វើការ ហើយបែកទ័ពចូលមកវិញខូចខាតពលជាច្រើនដូច្នេះ ត្រូវតែកាត់ក្បាល**ឈួម៉**ដោតផ្ចាតទើបគួរ។ **ឡៅពីរ**បានឮដូច្នោះ ក៏នឹកក្ដៅក្រហាយណាស់ តែដោយមានសេចក្ដីស្រឡាញ់នាង**ឈួហ៊ូយិន**ដែលជាភរិយា ក៏មានចិត្តអាណិតមេត្តា**ឈួម៉**មិនបានយកទោស។

ចំណែក**ស៊ុនកៀន** បានកេណ្ឌទាហានទាំងពួងឡោមព័ទ្ធជុំវិញស្រុកកេងជីវថ្ងៃមួយបណ្ដាលកើតព្យុះយ៉ាងធំអស្ចារ្យ បោកបក់លើដងទង់ជ័យមេទ័ពរបស់**សុនកៀន**បាក់ដាច់ជាពីរចំណែក។ **ហាន់តុង**ឃើញដូច្នោះក៏ជម្រាប**ស៊ុនកៀន**ថា ពេលនេះមានបង្កើតអភោទអស្ចារ្យណាស់។ នេះជាប្រផ្នូលកងទ័ពរបស់យើង ទើបបាក់ដងទង់ជ័យដែលយើងកំពុងឡោមព័ទ្ធស្រុកកេងជីវទុកដូច្នេះ ខ្លាចក្រែងមានសេចក្ដីភ័យអន្តរាយដល់លោក សុំឲ្យលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញទៅ ចាំពេលក្រោយសឹមគិតការជាថ្មីទៀត។ **ស៊ុនកៀន**តបថា "យើងលើកទ័ពមកធ្វើសង្គ្រាមលើកនេះ ឃើញមានជ័យជម្នះជាច្រើនលើក ឥឡូវនេះជិតនឹងបានស្រុកកេងជីវព្រឹកស្អែកនេះហើយ អ្នកមកសង្ស័យឆ្ងល់ពីព្រោះខ្យល់បក់បាក់ងទង់ជ័យ

ប៉ុណ្ណោះមិនគួរទេ” ថាហើយក៏លើកទាហានបំពានចូលទៅ ដោយប្រាថ្នានឹងទម្លាយកំពែងស្រុកកេងជីវឱ្យបានក្នុងពេលយប់នោះ។ លុះដល់ពេលយប់ **កេងលៀង**ឃើញផ្កាយមួយដួងធ្លាក់ពីលើអាកាស បានពិនិត្យមើលក្នុងតម្រាឃើញច្បាស់ទើបជម្រាប**ឡៅពីរ**ថា ខ្ញុំឃើញផ្កាយមួយដួងសៅហ្មងធ្លាក់ចុះមកយ៉ាងអស្ចារ្យ បានមើលក្នុងតម្រាឃើញថាមានគ្រោះធ្ងន់លើ**ស៊ុនកៀន** បើដូច្នេះសូមឱ្យលោកធ្វើសំបុត្រទៅសុំកងទ័ព**អួនសៀវ** ឱ្យលើកមកវាយទ័ព**ស៊ុនកៀន**ខ្នប់ពីខាងក្រោយ។ **ឡៅពីរ**ឆ្លើយថា ដែលនឹងឱ្យទៅសុំកងទ័ព**អួនសៀវ**នោះ យើងបានយល់ព្រមផងហើយ តែថាពេលនេះកងទ័ព**ស៊ុនកៀន**ឡោមព័ទ្ធជុំវិញស្រុកទាំងអស់ គ្មានចន្លោះនឹងចេញទៅបានដោយងាយ បើយ៉ាងនេះនឹងមាននរណាយកអាសាពុះទម្លាយកាន់សំបុត្រទៅបាន។ **លីកុង**ជាទាហាន**ឡៅពីរ**ឆ្លើយទទួលយកអាសា **កេងលៀង**ឆ្លើយថែមថា “បើអ្នកហ៊ានទទួលយកអាសានោះខ្ញុំអរណាស់ តែអ្នកត្រូវធ្វើតាមពាក្យខ្ញុំ ៗនឹងកេណ្ឌទាហានធ្នូប្រាំរយឱ្យទៅជាមួយ បើអ្នកទម្លាយចេញទៅបាន ត្រូវបែងទាហានពីររយជាប្រញាប់ គឺទាហានមួយឱ្យទៅបង្កប់នៅចុងភ្នំហ៊ីសាន់ ទាហានមួយរយទៀតឱ្យឡើងទៅបង្កប់នៅលើកំពូលភ្នំ រើសយកដុំថ្មធំៗបម្រុងទុកឱ្យច្រើន ហើយប្រាប់ថាបើឃើញកងទ័ព**ស៊ុនកៀន**តាមច្បាំង ឱ្យអ្នកនិងទាហានបីរយតទល់ ហើយថយរត់ទៅ ត្រាតែដល់ជើងភ្នំហ៊ីសាន់ បើទាហានពីរកងដែលបង្កប់នៅទីនោះបានបាញ់ធ្នូចោលដុំថ្មគ្រាណា អ្នកត្រូវអុជផាវជាសញ្ញាបីដង យើងបានឮសំឡេងផាវហើយនឹងលើកទាហានចេញទៅវាយខ្នប់ពីខាងក្រោយ បើសត្រូវមិនបានតាមអ្នកទៅទេឱ្យអ្នកខំស្រូតរូតនាំសំបុត្រទៅឱ្យ**អួនសៀវ**ជាប្រញាប់ឱ្យបាន ក្នុងពេលយប់នេះខែងងឹតណាស់ អ្នកចូរលើកទាហានស្រូតចេញទៅចុះ។ **លីកុង**បានស្ដាប់ក៏ទទួលពាក្យ**កេងលៀង**បង្គាប់នោះគ្រប់ប្រការ ហើយលា**ឡៅពីរ**លើកទាហានធ្នូប្រាំរយបើកទ្វារ

ទិសឯកើតចេញទៅ។ **លីកុង**ក៏តាំងតែច្បាំងកាប់ទម្លាយដោយកម្លាំងខ្លួននិងទាហានចេញទៅបាន ហើយចាត់ទាហានពីររយបង្កប់ទុកនៅភ្នំហ៊ីសាន់ជាពីរកង តាមពាក្យ**កេងលៀង**បង្គាប់។

ខណៈនោះ**ស៊ុនកៀន**ឃើញទាហានក្នុងស្រុកហែកទម្លាយចេញទៅបាន ក៏ឡើងសេះកាន់ដាវនាំទាហានសាមសិបនាក់ដែលជិតស្និទ្ធ សុទ្ធតែជិះសេះលើកតាមទៅ។ ឯសេះ**ស៊ុនកៀន**លឿនស្រួតទៅទាន់សេះ**លីកុង**ហើយស្រែកថា វ៉ឺយអាឯងចេញពីក្នុងស្រុកនេះនឹងរត់វេះទៅណា? **លីកុង**ឮហើយក៏ញាក់សេះត្រឡប់មកតទល់ច្បាំងនឹង**ស៊ុនកៀន**បានប្រាំស្នៀត ហើយត្រឡប់សេះបរគេចទៅមុខ តម្រង់ត្រង់ទាហានបង្កប់នោះ **ស៊ុនកៀន**ក៏បរសេះតាមទៅដល់ច្រកភ្នំ កាលមិនឃើញ**លីកុង**ក៏ញាក់សេះត្រឡប់មកក្រោយ រកទាហានរបស់ខ្លួនទាំងសាមសិបនាក់វិញ ស្រាប់តែឮសំឡេងឃ្មោះគងទូងស្គរលើកំពូលភ្នំ ដុំថ្មធំៗក៏ធ្លាក់ចុះមកព្រោងព្រាត ទាហានដែលបង្កប់នៅជើងភ្នំក៏បាញ់ធ្នូចម្រុះមកទៀត។ **ស៊ុនកៀន**និងសេះនោះ ត្រូវព្រួញនិងដុំថ្មបែកឈាមជោកប្រឡាក់ពេញអស់ទាំងខ្លួន សេះនិងមនុស្សក៏អស់ជីវិតក្ស័យនៅទីច្រកភ្នំនោះ កាល**ស៊ុនកៀន**ស្លាប់អាយុបានសាមសិបឆ្នាំគត់។

**លីកុង**លុះឃើញដូច្នោះ ក៏ចាត់ទាហានទៅស្ទាក់សម្លាប់ទាហានសេះ **ស៊ុនកៀន**ស្លាប់ទាំងសាមសិបនាក់ ហើយឲ្យអុជផាវធំជាសញ្ញាបីដង **កេងលៀង**បានឮច្បាស់ចាត់ឲ្យ**កេងអួន, ហាងច, ឈួម៉** លើកទាហានចេញទៅជាបីផ្លូវ ទាហាន**ស៊ុនកៀន**មិនទាន់ដឹងខ្លួនក៏បែកពពាក់ពពូនរបួសស្លាប់ជាច្រើន។

ឯ**អ៊ុយកាយ** ដែលនៅរក្សាទូកចម្បាំងនោះ ដល់បានឮសំឡេងហ៊ោកញ្ជៀវគឹកកងក៏លើកទាហានឡើងគោកនឹងទៅជួយ ស្រាប់តែប្រទះនឹងកងទ័ព**ហាងច**

ចៅហ្វាយស្រុកកាំងហែលើកទៅទល់ពីមុខ ក៏តយុទ្ធគ្នាអស់ប្រាំមួយស្មៀត **អ៊ុយកាយ** ចាប់**ហាងច**បាន។

ខាង**តៀផៅ,** **ស៊ុនសេក**លើកទ័ពទៅតាម**ស៊ុនកៀន** ស្រាប់តែជួបប្រទះនឹង**លីកុង,** **តៀផៅ**ច្បាំងនឹង**លីកុង**បានប្រាំភ្លែង **តៀផៅ**ចាក់**លីកុង**នឹងទួនធ្លាក់ពីលើសេះស្លាប់។ ក្នុងពេលយប់នោះ ទាហាន**ឡៅពីវ**និងទាហាន**ស៊ុនកៀន**ច្បាំងប្រកាប់គ្នាស្លាប់ជាច្រើន ឯទាហានដែល**លីកុង**នាំទៅនោះ ក៏យកសព**ស៊ុនកៀន**នាំទៅជូន**ឡៅពីវ** ដល់ពេកព្រឹកឡើងទាហាន**ឡៅពីវ**ក៏នាំគ្នាចូលទៅក្នុងស្រុក។

ឯ**ស៊ុនសេក**និង**តៀផៅ** ដល់មិនបានជួបប្រទះនឹង**ស្នួនកៀន** ហើយក៏នាំសេនាទាហានដែលបាក់បែកទាំងប៉ុន្មាននោះ ទៅតាំងទីនៅតំបន់ហាន់ស៊ុយ។ ពេលនោះមានទាហានម្នាក់នាំព័ត៌មានទៅប្រាប់**ស៊ុនសេក**ថា **ស៊ុនកៀន**ជាបិតាអ្នកនោះត្រូវព្រួញស្លាប់នៅទីច្រកភ្នំហ៊ីសាន់ពីយប់មិញទៅហើយ សពនោះពួកទាហានស្រុកកេងជីវនាំចូលទៅជូន**ឡៅពីវ**ហើយ។

**ស៊ុនសេក**ដឹងដំណឹងច្បាស់ ក៏បោកប្រាសខ្លួនផ្តួលយំសោកស្រណោះបិតាជាអនេក លុះស្វាងសេចក្តីសោកសៅហើយ ក្រោកឡើងនិយាយនឹងពួកទាហានទាំងពួងថា ឥឡូវសពបិតារបស់យើងនៅក្នុងស្រុកកេងជីវឯណោះ បើយើងនឹងលះបង់មិនច្បាំងយកស្រុកនេះឲ្យបាន ហាក់ដូចជាគ្មានសេចក្តីកតញ្ញូចំពោះបិតា ។ **អ៊ុយកាយ**តបថា ខ្ញុំចាប់ខ្លួន**ហាងច**ចៅហ្វាយស្រុកកាំងហែបានយកមកទុកក្នុងកងទ័ព បើដូច្នេះចាំប្រើបម្រើចូលទៅឲ្យដំណឹង**ឡៅពីវ**សិន បើគេព្រមបញ្ជូនសពបិតាអ្នកមកឲ្យយើង សឹមយើងបញ្ជូនខ្លួន**ហាងច**ទៅឲ្យគេវិញ ឯការដែលធ្វើសង្គ្រាមនឹងគ្នានោះត្រូវបង្អង់ទុកឲ្យជាមេត្រីនឹងគ្នាតទៅ បើបានការដូច្នេះ ត្រូវលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ។

**ហួនកាយ**និយាយឡើងថា ខ្ញុំនិង**ឡៅពីរ**ស្គាល់គ្នាតាំងពីតូចមក ខ្ញុំនឹងសុំយកអាសាទៅនិយាយនឹង**ឡៅពីរ**ព្រមតាមពាក្យ**អ៊ុយកាយ**ថានោះ។ **ស៊ុនសេក**បានស្តាប់ហើយមានសេចក្តីត្រេកអរជាពន្លឹក ហើយចាត់ឲ្យ**ហួនកាយ**ចេញទៅនិយាយការនោះ។ កាល**ហួនកាយ**ទៅដល់**ឡៅពីរ**ហើយនិយាយថា ឥឡូវនេះ**ស៊ុនសេក**មិនបានធ្វើសង្គ្រាមនឹងលោកតទៅទៀតទេ នឹងសុំយកតែសព**ស៊ុនកៀន**ជាបិតាទៅវិញ បើខាងលោកយល់ព្រមឲ្យហើយ នឹងបញ្ជូនខ្លួន**ហាងច**ដែលចាប់បាននោះមកលោក ហើយ**ស៊ុនសេក**នឹងលើកទ័ពត្រឡប់ទៅស្រុកតែម្តង។

**ឡៅពីរ**ឆ្លើយថា សព**ស៊ុនកៀន**ដែលពួកទាហាននាំមកឲ្យយើងនោះ យើងបានតុបតែងទុកតាមប្រវេណីដោយសមគួរ ដែល**ស៊ុនសេក**ឲ្យអ្នកមកនិយាយនេះយើងមិនថាអ្វីទេ តែថាតទៅមុខ កុំឲ្យ**ស៊ុនសេក**គិតបំពានចូលមកធ្វើអន្តរាយដល់យើងទៀត។

**កេងលៀង**ឆ្លើយជម្រាប**ឡៅពីរ**ថា ដែលលោកនឹងព្រមឲ្យសព**ស៊ុនកៀន**ទៅគេនោះ ខ្ញុំមិនទាន់យល់ព្រមផងទេ ព្រោះ**ស៊ុនកៀន**បំពានមកធ្វើការទាំងនេះដោយចិត្តអាក្រក់ណាស់ ទើបដល់នូវសេចក្តីវិនាសជីវិតយ៉ាងនេះ ឯ**ស៊ុនសេក**ជាកូននៅក្មេងណាស់ សេនាទាហាន**ស៊ុនសេក**មានសេចក្តីកោតញញើតយើងជាច្រើន បើលោកស្តាប់ខ្ញុំ ៗនឹងគិតធ្វើទាហានស្រុកកាំងតាំងដែលសល់នៅនោះ កុំឲ្យវិលទៅរួចដល់ម្នាក់ឡើយ សូមឲ្យលោកចាប់**ហួនកាយ**នេះសម្លាប់ចេញទៅ រួចសឹមលើកទ័ពទៅវាយកងទ័ពទាំងនោះជាក្រោយ ស្រុកកាំងតាំងនេះគង់នឹងធ្លាក់មកជាកម្មសិទ្ធិរបស់លោក បើលោកមិនស្តាប់ខ្ញុំហើយប្រគល់សព**ស៊ុនកៀន**ទៅឲ្យគេ ថ្ងៃក្រោយលោកគង់មានសេចក្តីអន្តរាយជាប្រាកដ។

**ឡៅពីរ**ឆ្លើយថា "**ហាងច**និងយើងជាមនុស្សស្រឡាញ់រាប់អានទុកចិត្តគ្នាមកពីដើម កាលបើយើងធ្វើដូច្នោះហាក់ដូចជាក្លែងសម្លាប់**ហាងច**ឱ្យស្លាប់ សេចក្ដីដែលយើងប្ដេជ្ញាទុកពីដើមក៏ខូចអាសាទៅវិញ។ រួចហើយប្រាប់**ហ្លួនកាយ**ឱ្យស្រូតត្រឡប់ទៅវិញ ហើយថា "ព្រឹកស្អែកឱ្យនាំខ្លួន**ហាងច**មកប្រគល់ឱ្យយើងត្រឹមទ្វារស្រុកយើងនឹងជូនសព**ស៊ុនកៀន**ទៅឱ្យ"។ **ហ្លួនកាយ**ក៏នាំសេចក្ដីនោះត្រឡប់ទៅជម្រាប**ស៊ុនសេក** ៗមានសេចក្ដីត្រេកអរជាទីបំផុត។ ដល់វេលាព្រឹកឡើង បានចាត់ទាហានឱ្យនាំខ្លួន**ហាងច**ទៅជូន**ឡៅពីរ**ដល់ទ្វារស្រុក ហើយទទួលយកសព**ស៊ុនកៀន**ដាក់ទូកលើកទាហានត្រឡប់ទៅស្រុកកាំងតាំងវិញ។

កាលនាំសពឡើងទៅដល់តម្កល់លើទីគ្រឹហាស្ថានហើយ ក៏ឱ្យតាក់តែងគ្រឿងដង្ហែដ៏រុងរឿង នាំទៅបញ្ចុះនៅតំបន់ខយ៉ុកឱ។ សម័យនោះ**ស៊ុនសេក**បានឡើងយសស័ក្ដិជាធំក្នុងស្រុកកាំងតាំង បណ្ដាអ្នកស្រុកទាំងអស់នៅក្រោមបញ្ជា**ស៊ុនសេក** ឯភរិយា**ស៊ុនសេក**នោះជាមនុស្សមានសតិបញ្ញា បើឃើញអ្នកឯណាដែលឆ្លៀវឆ្លាសខ្លាំងពូកែ តែងមានសេចក្ដីគោរពកោតក្រែង ហើយចងចិត្តយកមកជាបក្សពួកធ្វើរាជការជាមួយ មនុស្សក៏ចុះចូលកុះករមកជាច្រើន។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៧

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំងពី**តាំងតុះ**កំរើបចិត្តតាំងខ្លួនជា **សងអ៊ូ** (ធម្មបិតា) រួចគិតកលឧបាយនឹងសម្លាប់**តៀនអ៊ុយ**។ តមក**អងអ៊ុន**លួងលោមនាង**តៀវសៀន**ជាកូនចិញ្ចឹមឲ្យទៅធ្វើជាភរិយា**លីប៉ោ**និង**តាំងតុះ** ដើម្បីឲ្យអ្នកទាំងពីរនេះទាស់ទែងខ្វែងគំនិតគ្នារហូតដល់**តាំងតុះ**ប្រឹក្សានឹង**លីសុក**អំពីទំនុកដែលក្មេងច្រៀង)។*

**តាំងតុះ**នៅស្រុកតៀវហាន់ជាទីក្រុង លុះបានឮថា**ស៊ុនកៀន**ជាចៅហ្វាយស្រុកកាំងតាំងស្លាប់ហើយ មានសតិសោមនស្សពន់ពេក ទើបប្រជុំទីប្រឹក្សាហើយថ្លែងសេចក្ដីថា ដែល**ស៊ុនកៀន**ស្លាប់នោះ យើងបានធូរស្រួលក្នុងចិត្តច្រើន ឧបមាដូចជាគេដកបន្លាចេញពីដើមទ្រូងនៃយើងបាន ចុះក្នុងសម័យនេះ នរណាបានដឹងថា **ស៊ុនកៀន**អាយុប៉ុន្មានហើយ? **លីយូ**ថា **ស៊ុនកៀន**នោះទើបនឹងបានអាយុសាមសិបឆ្នាំគត់។ **តាំងតុះ**បានឮដូច្នោះក៏ឃើញថា **ស៊ុនកៀន**នោះនៅក្មេងនៅឡើយ មិនមានសង្ស័យថាដូចម្ដេច។ ក្នុងខណៈនោះ **តាំងតុះ**ក៏រឹតតែមានចិត្តកំរើបឡើង នឹងធ្វើការអ្វីក៏រំលោភបំពានទៅតាមអំពើចិត្តលើសពីដើម តាំងតម្កើងលើកខ្លួនឲ្យមនុស្សទាំងពួងហៅថា “សងអ៊ូ” ប្រែថា “ព្រះធម្មបិតានៃព្រះចៅ**ហៀនតេ**” បើនឹងចេញដំណើរទៅទីឯណា ក៏ឲ្យមានក្បួនហែទាំងព្រះមហាក្សត្រស្ដេចយាង ហើយលើកតម្កើង**តាំងហាង**ជាប្អូនឲ្យធ្វើនាយទាហានកងក្រៅ បណ្ដាសែ**តាំង**ទាំងប៉ុន្មានក៏ហៅទៅតាំងជានាហ្មឺនតូចធំទាំងអស់។ **តាំងតុះ**ឲ្យកេណ្ឌរាស្ត្រម្ភៃប្រាំម៉ឺនទៅកសាងវាំងមួយ

ចម្ងាយពីទីក្រុងតៀវហាន់ពីរពាន់ប្រាំរយសិន (១០០ គ.ម) ធ្វើកំពែងខ្ពស់ប្រហែលនឹងកំពែងស្រុកក្រុង ខាងក្នុងក៏ឲ្យសង់ដំណាក់តូចធំជុំវិញខាងមុខនិងខាងក្រោយ មានទីឃ្លាំងនិងជង្រុកដាក់ស្រូវអង្ករ ស្បៀងអាហារសម្រាប់សេនាទាហានបរិភោគបានម្ភៃឆ្នាំ ឯមាសប្រាក់ពន្ធដារនិងសួយសារអាករទាំងប៉ុន្មាន ក៏ឲ្យបញ្ជូនទៅដាក់ឃ្លាំងក្នុងក្រុងថ្មីទាំងអស់ ហើយឲ្យចាត់ស្រីរូបល្អមកបម្រុងទុកប្រមាណប្រាំបីរយនាក់។ ឯ**តាំងតុះ**ជួនកាលម្ភៃថ្ងៃទើបឡើងគាល់ព្រះចៅ**ហៀនតេ**ម្ដង បណ្ដានាហ្មឺនតូចធំក្នុងស្រុកក្រុងទាំងប៉ុន្មាន ក៏ត្រូវទៅចាំទទួលឬជូនដំណើរចេញទៅវិញដល់មាត់ទ្វារក្រុង ឯកន្លែងដែលចូលទៅគាល់នោះមានទីប្រថាប់ជាច្រើនតំបន់។ ក្នុងស្រុកតៀងហាន់នោះ ក៏មានទីកន្លែងមួយសម្រាប់សំណាក់នៅតាមត្រូវការ។ មានមួយថ្ងៃនោះ **តាំងតុះ**ចេញអំពីទីគាល់ បណ្ដានាហ្មឺនទាំងពួងក៏ជូនដំណើរទៅដល់មាត់ទ្វារក្រុង **តាំងតុះ**ទើបបង្គាប់ឲ្យនាហ្មឺនទាំងនោះទៅពិសាលៀងជាទីប្រថាប់។

ក្នុងខណៈនោះ ចៅហ្វាយស្រុកមណ្ឌលខាងជើងបញ្ជូនមនុស្សបះបោរប្រហែលប្រាំរយនាក់មកដល់**តាំងតុះ** ៗបង្គាប់ទាហានឲ្យយកមនុស្សអស់នោះទៅកាត់ដៃខ្លះ កាត់ជើងខ្លះកាត់ត្រចៀកខ្លះ កាត់អណ្ដាខ្លះ ឲ្យស្ងោរដាក់ក្នុងខ្ទះដែកខ្លះ។ មនុស្សទាំងនោះក៏មានសេចក្ដីសោយទុក្ខវេទនា នរណាដែលមិនទាន់ដាច់ខ្យល់ក៏បម្រះនៀលដោយឈឺចាប់ស្រែកទ្រហោយំរងំអឺងកង។ នាហ្មឺនទាំងពួង ដែលកំពុងបរិភោគអាហារបានក្រឡេកទៅឃើញ មានសេចក្ដីអាណិតអាសូរពន់ប្រមាណណាស់ ខ្លះក៏ភ័យស្លុតរបូតចង្កឹះធ្លាក់ពីដៃ ខ្លះក៏វង្វេងស្មារតីធ្លាក់កែវស្រាពីដៃកំពប់ស្រាអស់ ព្រោះឃើញសេចក្ដីទុក្ខវេទនាយ៉ាងជាក់ស្ដែងមុខគួរឲ្យកើតធម្មសង្វេគពន់ពេក។ ឯ**តាំងតុះ**នោះជាមនុស្សចិត្តអាក្រក់ គ្មានមេត្តាករុណាសោះ លើកពែងស្រា

ផឹកភ្លាង មើលភ្លាង សើចភ្លាង មនុស្សទាំងប្រាំរយនោះក៏ស្លាប់ទាំងអស់គ្នា។ នាហ្មឺនទាំងអស់ បរិភោគអាហារហើយ ក៏លាចុះទៅជាប្រញាប់។

ក្រោយនោះ **តាំងតុះ**បង្គាប់**លីប៉ោ**ថា យើងនឹងអញ្ជើញនាហ្មឺនទាំងអស់មកលៀងអាហារម្តងទៀត បើកាលណាជួបជុំគ្នាហើយ ចូរកូនឯងទៅខិនខ្សិបត្រចៀកបិតាចុះ បិតានឹងឲ្យចាប់**តៀនអ៊ុយ**ទៅសម្លាប់ចេញ ហើយកាត់ក្បាលយកមក។ លុះដល់ថ្ងៃកំណត់ ដែលនាហ្មឺនទាំងពួងមកស៊ីលៀងអាហារព្រមគ្នាហើយ **តាំងតុះ**ក៏អង្គុយផឹកស្រាតាមធម្មតា ឯ**លីប៉ោ**ធ្វើជាចូលទៅខិនខ្សិបដាក់ត្រចៀក**តាំងតុះ** ៗធ្វើជាសើចហើយថា គិតយ៉ាងនេះឬ! ចូរចាប់ខ្លួនវាទៅឲ្យឆាប់! **លីប៉ោ**ក៏ស្ទុះទៅចាប់ខ្លួន**តៀនអ៊ុយ**អូសកន្ត្រាក់ទៅ។ នាហ្មឺនទាំងពួងដែលកំពុងបរិភោគនោះ មិនដឹងសេចក្តីអ្វីសោះទាំងអស់គ្នា ក៏ស្រឡាំងកាំងមួយស្របក់ ស្រាប់តែឃើញ**លីប៉ោ**យួរក្បាល**តៀនអ៊ុយ**ដាក់ក្នុងបាវចូលមកឲ្យ**តាំងតុះ**មើល។ នាហ្មឺនក៏រឹតតែភិតភ័យណាស់។ **តាំងតុះ**ឃើញដូច្នោះហើយសើចថា អ្នកទាំងអស់គ្នាកុំភ័យបារម្ភថ្វី ដែលកើតហេតុទាំងនេះ ព្រោះ**តៀនអ៊ុយ**ឲ្យសំបុត្រសម្ងាត់ទៅ**អ្វួនសុត** ឲ្យមកធ្វើសេចក្តីអន្តរាយដល់យើងមានគេដឹងរឿងនេះ គេធ្វើសំបុត្រមកឲ្យយើង បានជា**លីប៉ោ**ខ្សិបប្រាប់យើង ៗទើបឲ្យចាប់ទៅសម្លាប់ចេញដូច្នេះ បើអ្នកឯណាមិនបានរួមគំនិតជាមួយនឹង**តៀនអ៊ុយ**នោះទេ ក៏កុំគប្បីជាទុក្ខ ត្រូវបរិភោគលេងឲ្យសប្បាយទៅចុះ។ ខណៈកាលនាហ្មឺនទាំងនោះបរិភោគហើយ ក៏លាទៅ។

ខណៈនោះ មានមន្ត្រីម្នាក់ឈ្មោះ**អងអ៊ុន** កាលត្រឡប់ទៅដល់ផ្ទះហើយគិតរំពឹងថា រឿងដែល**តាំងតុះ**ឲ្យហៅទៅស៊ីលៀងហើយចាប់**តៀនអ៊ុយ**សម្លាប់ចេញនោះ បើនឹងសង្កេតឲ្យឃើញពិតទៅថា **តៀនអ៊ុយ**នេះគ្មានចិត្តគំនិតអាក្រក់ឲ្យសំបុត្រទៅ**អ្វួនសុត**មកធ្វើសេចក្តីអន្តរាយដល់**តាំងតុះ**សោះទេ តែដែល**តាំងតុះ**មានសេចក្តី

ព្យាបាទសម្លាប់គ្នាទាំងម្ល៉េះ ក៏គឺធ្វើយកអំណាច មិនឲ្យនាហ្មឺនទាំងពួងគិតអាក្រក់នឹងវាតទៅ ដែលវាធ្វើដូច្នេះក៏មិនមានអ្នកឯណានឹងគិតរំលាងបំផ្លាញវាចេញសោះ។ **អងអ៊ុន**មានសេចក្តីរំខានមិនបានស៊ីដេកជាសុខ លុះដល់ពេលយប់ស្ងាត់ ក៏កាន់ឈើច្រត់ទៅឈរផ្អែកនៅដើមឈើមួយក្នុងសួនផ្កា ហើយក្រឡេកមើលទៅលើអាកាសឃើញផ្កាយរក្សាស្រុកអាប់រស្មីមិនមានពន្លឺ ទើបគិតថា សព្វថ្ងៃនេះ ព្រះមហាក្សត្រនិងអាណាប្រជានុរាស្ត្រមានសេចក្តីក្តៅក្រហាយព្រោះ**តាំងតុះ**។ **អងអ៊ុន**គិតហើយក៏ដកដង្ហើមធំ ហើយយំខ្សឹកខ្សួល។ ក្នុងទីនោះ ស្រាប់តែឮសំឡេងស្រីម្នាក់ទៅដកដង្ហើមធំអំពីខាងមុខ**អងអ៊ុន** ៗក្រឡេកទៅឃើញ ក៏ឈ្ងោកមើលមុខស្គាល់ច្បាស់ជានាង**តៀវសៀន** ដែល**អងអ៊ុន**លោះយកមកពីតូច ឃើញរូបរាងល្អចេះច្រៀងពីរោះក៏សន្មតទុកជាកូនចិញ្ចឹម នាងនោះក៏ចម្រើនអាយុបានដប់ប្រាំមួយឆ្នាំ។ វេលានោះ **អងអ៊ុន**សួរថា ពេលយប់ថ្មើរនេះហើយម្តេចមិនទៅដេក ចុះមករកអ្វីក្នុងសួនផ្កានេះហើយដកដង្ហើមធំឬកើតទុក្ខពីព្រោះមិនឃើញសាហាយមកជួបឬអ្វី? នាង**តៀវសៀន**បានឮដូច្នោះក៏ភ័យស្លុត ទទួលលុតជង្គង់ហើយជម្រាប**អងអ៊ុន**ថា ខ្ញុំនឹងបានមានសាហាយស្មន់ហើយមកនៅចាំដូច្នោះក៏ទេ ខ្លួនខ្ញុំជាទាសីលោក ៗក៏បានបីបាច់ចិញ្ចឹមរក្សាទុកជាកូនតាំងពីតូចមក ព្រះតេជព្រះគុណរកទីបំផុតគ្មាន សព្វថ្ងៃខ្លួនខ្ញុំក៏គិតនៅជានិច្ចថា បើលោកមានសេចក្តីទុក្ខព្រួយប្រការដូចម្តេច ខ្ញុំនឹងត្រូវជួយធុរៈនោះទៅតាមសតិបញ្ញា ដើម្បីនឹងបានតបស្នងសងគុណលោក ប្រសិនបើជីវិតខ្ញុំនឹងរលត់ផុតទៅ សាច់ឈាមសរសៃនឹងរលួយជាផេះផង់ធូលី ឬឆ្អឹងនឹងខ្ទេចខ្ទីជាធូលី ខ្ញុំក៏មិនបានសោកស្តាយដល់ជីវិតសោះឡើយ ពីថ្ងៃព្រឹកមិញដែល**តាំងតុះ**អញ្ជើញលោកទៅពិសាលៀង ហើយលោកត្រឡប់មកដល់ផ្ទះវិញនោះ ខ្ញុំឃើញទឹកមុខលោកសៅហ្មងប្លែកជាងសព្វថ្ងៃ ខ្ញុំក៏ស្មានថាលោកប្រហែលជាទុក្ខព្រួយអំពីការអ្វីជាទម្ងន់ណាស់

ទើបបានជាប្លែកអស្ចារ្យដូច្នេះ លុះខ្ញុំឃើញលោកអញ្ជើញមកទីនេះ ខ្ញុំក៏លបចុះមកសង្កេតមើលឲ្យដឹងការ ដើម្បីនឹងជួយរិះគិតជាផ្លូវតបស្នងសងព្រះតេជព្រះគុណត្រាតែអស់ជីវិត។

**អងអ៊ុន**បានឮដូច្នោះក៏គិតថា គ្រានេះបើផែនដីនឹងបានសុខក្សេមក្សាន្តឡើងវិញ ក៏ដោយសារនាង**តៀវសៀន**ជាប្រាកដ។ ទើបនាំនាង**តៀវសៀន**ឡើងទៅលំនៅក្នុងល្វែងស្ងាត់ ហើយឲ្យនាងអង្គុយលើកៅអីរួចលុតជង្គង់ចុះគំនាប់នាង។ នាង**តៀវសៀន**ឃើញដូច្នោះក៏ភ័យណាស់ ស្ទុះចុះអំពីកៅអីមកគំនាប់**អងអ៊ុន**វិញ ហើយចូលទៅក្រាបឱបបាទាឃាត់ថា លោកឪពុកមិនត្រូវគំនាប់ខ្ញុំជាកូនទេ។ **អងអ៊ុន**តបថា "ឪពុកបានឮកូនថាអម្បាញ់មិញនោះ ឪពុកមានសេចក្ដីត្រេកអរណាស់ បានជាឱនគំនាប់កូន ៗចូរមានមេត្តាករុណាដល់ព្រះមហាក្សត្រ និងអាណាប្រជានុរាស្ត្រក្នុងព្រះរាជអាណាខេត្តចុះ"។ ថាតែប៉ុណ្ណោះ ក៏យំរអាក់រអួល។ នាង**តៀវសៀន**បានឃើញបិតាទួញយំក៏លើកដៃប្រណមជម្រាបថា ខ្ញុំបានចេញវាចាថានឹងយកជីវិតតបស្នងសងគុណលោកឪពុកហើយ ហេតុអ្វីមិនមានប្រសាសន៍ប្រាប់រឿងហេតុដែលកើតទុក្ខនោះឲ្យខ្ញុំដឹង ដែលលោកឪពុកមកប្រឹងអង្គុយយំដូច្នេះនឹងអស់ទុក្ខហើយ? **អងអ៊ុន**ឆ្លើយថា សព្វថ្ងៃនេះផែនដីក្ដៅរំជួលគ្រប់ដើមស្មៅនូវឈើព្រៃទាំងអស់ កូនក៏ល្មមដឹងឮណាស់ហើយ ព្រះចៅ**ហៀនតេ**នោះឧបមាដូចពងមាន់ដែលគេចោលទុកលើថ្ម ឯនាហ្មឺនមុខមន្ត្រីនិងអាណាប្រជានុរាស្ត្រក្នុងព្រះនគរ ឧបមាដូចជាគំនរសំរាមដែលនៅជិតភ្លើង មិនបានដឹងថាសេចក្ដីស្លាប់នឹងមកដល់វេលាណា **តាំងតុះ**ធ្វើការអាក្រក់កំរើបឡើងប្រុងនឹងយករាជសម្បត្តិ នឹងរកអ្នកឯណាគិតរំលាងវាចេញគ្មាន។ ឯ**តាំងតុះ**នោះវាមានកូនចិញ្ចឹមមួយឈ្មោះ **លីប៉ោ** ឯ**លីប៉ោ**នោះក៏មានថ្វីដៃខ្លាំងពូកែណាស់ តែថាសន្ដានចិត្តអ្នកទាំងពីរនេះ រមែងរង្វេងស្រឡាញ់ទៅក្នុង

រូបស្ត្រីភាពដែលស្អាតល្អ បើកូននឹងជួយទ្រទ្រង់ផែនដី ឪពុកនឹងគិតឧបាយកលលើកកូនឲ្យធ្វើជាភរិយា**លីប៉ោ** ហើយទើបទៅប្រាប់**តាំងតុះ**ឲ្យមកទទួលកូនយកទៅធ្វើជាភរិយាទៀត បើកូនទៅនៅនឹង**តាំងតុះ**វេលាណា ចូរលបធ្វើកលមាយាផ្សេងៗឲ្យ**លីប៉ោ**មានចិត្តស្ម័គ្រស្រឡាញ់កូនជាប្រាកដ ហើយកូនលបប្រាប់**តាំងតុះ**ដោយកលមាយាតាមតម្រិះប្រាជ្ញារបស់កូនស្រាប់ យូរទៅឃើញថា**តាំងតុះ**និង**លីប៉ោ**មានសេចក្ដីបែរចិត្តគិតប្រទូសរាយគ្នា **លីប៉ោ**គង់នឹងសម្លាប់**តាំងតុះ**ចេញ កាលអាស្រូវរាជសម្បត្តិវិនាសហើយ អាណាខេត្តទាំងអស់ក្នុងព្រះនគរនឹងបានសេចក្ដីសុខតទៅ ឯខ្លួនកូនដែលបានយកអាសាផែនដី នោះនឹងមានកេរ្តិ៍ឈ្មោះពីរោះទាល់តែអស់អាយុផែនដី។ ឪពុកគិតដូច្នេះ តើកូននឹងយល់ព្រមធ្វើតាមដែរឬដូចម្ដេច? នាង**តៀវសៀន**ឆ្លើយតបថា ខ្ញុំបានចេញវាចាថានឹងតបស្នងសងគុណលោកឪពុកហើយ កុំថាឡើយតែត្រឹមរូបកាយខ្ញុំទៅធ្វើប៉ុណ្ណោះ ទោះបីនឹងប្រើឲ្យទៅស្លាប់ក៏ខ្ញុំមិនស្ដាយជីវិតសង្ខារ វេលានេះបើបិតានឹងគិតការយ៉ាងណា ក៏ត្រូវគិតលៃលកឲ្យបានស្រេចឆាប់ៗទៅចុះ បើខ្ញុំបានទៅនៅនឹង**តាំងតុះ**ហើយ ខ្ញុំនឹងធ្វើកលមាយាឲ្យ**លីប៉ោ**សម្លាប់**តាំងតុះ**ឲ្យបាន។ **អងអ៊ុន**តបថា បើកូនបានយកអាសាផែនដីជំនួសឪពុកហើយ ការអ្វីៗដែលកូនគិតនោះត្រូវបិទឲ្យជិតកុំឲ្យនរណាដឹងឮមួយជាពីរឡើយ កូនអើយរឿងនេះបើបែកធ្លាយចេញទៅកាលណា អាយុកូននិងបិតាមុខជានឹងវិនាសអន្តរាយទៅថ្ងៃមុខជាប្រាកដ។ នាង**តៀវសៀន**បានស្ដាប់ច្បាស់ក៏ឆ្លើយថា សេចក្ដីនេះបើខ្ញុំមិនបិទបាំងតាំងធ្វើឲ្យបែកខ្ចាយហើយ ខ្ញុំសូមឲ្យត្រូវប្រហារដោយអាវុធផ្សេងៗចុះ។ **អងអ៊ុន**បានឮពាក្យនាងជម្រាបដូច្នេះហើយ ក៏មានសេចក្ដីសោមនស្សត្រេកអរពន់ពេក។ លុះដល់ព្រឹកឡើង **អងអ៊ុន**ក៏ចាត់ចែងរើយកត្បូងពេជ្រនិងមាសប្រាក់មកទុក ហើយហៅជាងមកធ្វើជាម្កុកសម្រាប់បុត្រព្រះមហាក្សត្រទ្រង់ពាក់ លុះធ្វើរួចហើយ

ក៏ប្រើមនុស្សទំនុកទុកចិត្តឲ្យលបយកទៅឲ្យ**លីប៉ោ** ៗឃើញម្ហូបដ៏វិសេសដូច្នោះទទួលយកហើយដោយសេចក្តីពេញចិត្ត លុះដល់ថ្ងៃក្រោយលបមកជួបនឹង**អងអ៊ុន**ដល់ផ្ទះ។

ឯ**អងអ៊ុន**នោះ លុះបានឃើញ**លីប៉ោ**មករកដល់ផ្ទះហើយ ទើបចេញទៅទទួលឲ្យចូលមកនិយាយការខាងក្នុងល្វែងផ្ទះ ហើយឲ្យលើកអាហារមកបរិភោគជាមួយគ្នា។ លុះបរិភោគរួចស្រេចហើយ **លីប៉ោ**ជម្រាបថា ខ្លួនខ្ញុំបាទគ្រាន់តែជាទីនាយទាហានមហាឧបរាជ ចំណែកលោកជានាហ្មឺនមានបណ្តាស័ក្តិធំក្នុងហ្លួង ហេតុម្តេចបានជាលោកឲ្យយករបស់ទៅឲ្យខ្ញុំបាទល្អម្ល៉េះ? ខ្ញុំបាទជាអ្នកតូចមិនគួរលោករាប់អានដល់ប៉ុណ្ណេះទេ។ **អងអ៊ុន**តបថា សព្វថ្ងៃនេះ ខ្ញុំសម្លឹងមើលក្នុងទីក្រុងនិងខេត្តក្រៅទាំងអស់ នឹងរកអ្នកឯណាឲ្យខ្លាំងពូកែស្មើនឹងអ្នកគ្មានសោះ ខ្ញុំឲ្យរបស់នេះព្រោះស្រឡាញ់ថ្វីដៃអ្នកក្នុងការទាហាន។ **លីប៉ោ**បានស្តាប់ក៏មានសេចក្តីត្រេកអរណាស់។ **អងអ៊ុន**ចាក់ស្រាគំនាប់**លីប៉ោ** ហើយនិយាយបញ្ចោរសរសើរ**លីប៉ោ**ជាអនេកប្រការ ទើបបណ្តេញមនុស្សបម្រើឲ្យដើរចេញអស់ នៅសល់តែពួកស្រីបម្រើបួននាក់។ **អងអ៊ុន**ប្រើស្រីៗនោះឲ្យទៅហៅនាង**តៀវសៀន**ចេញមក ស្រីបម្រើពីរនាក់ក៏ចូលទៅអញ្ជើញនាង**តៀវសៀន** ហើយហែហមចេញមក។

**លីប៉ោ**ឃើញនាង**តៀវសៀន** មានរូបភាពនិងដំណើរញ៉ៅញ៉ាំងស្រស់ល្អណាស់ អត់ទ្រាំមិនបានក៏សួរ**អងអ៊ុន**ថា នាងនេះជាកូនអ្នកឯណា? **អងអ៊ុន**ប្រាប់ថា នាង**តៀវសៀន**នេះជាបុត្រីរបស់ខ្ញុំ សព្វថ្ងៃនេះខ្ញុំបានសេចក្តីសុខនៅធ្វើរាជការបានដោយបុណ្យអំណាចមហាឧបរាជនិងអ្នក ៗក៏មានសេចក្តីរាប់អានមេត្តាដល់ខ្ញុំដូចសាច់ញាតិជាប្រាកដ ហេតុនេះទើបខ្ញុំឲ្យហៅបុត្រីខ្ញុំចេញមក ដោយសេចក្តីប៉ុនប៉ង

នឹងលើកជូនអ្នកឲ្យធ្វើជាភរិយា ដើម្បីទុកជាទីបញ្ចាំចិត្តដោយស្មោះត្រង់។ ថាហើយបង្គាប់នាង**តៀវសៀន**ឲ្យចាក់ស្រាគំនាប់**លីប៉ោ**។

ឯនាង**តៀវសៀន**បានចាក់ស្រាលើកជូនទៅ**លីប៉ោ** ហើយប្រើកិរិយាចោលដើមភ្នែកចុងភ្នែក ទៅឲ្យ**លីប៉ោ**ស្គាល់បានថាមានចិត្តស្ម័គ្រស្រឡាញ់។ ចំណែកខាង**អងអ៊ុន**ពុតធ្វើជាស្រវឹងស្រា ហើយនិយាយទៅកាន់នាង**តៀវសៀន**ថា ឪពុកចាស់ជរាហើយ កម្លាំងក៏ថមថយ ផឹកស្រាតែបន្តិចបន្តួចក៏ស្រវឹងវិលអស់មុខមាត់ កូននៅគួរសមបម្រើបម្រាស់ជួសឪពុកចុះ។

ពេលនោះ**លីប៉ោ**បានអញ្ជើញនាង**តៀវសៀន**ឲ្យអង្គុយលើកៅអី។ នាង**តៀវសៀន**ក្លែងធ្វើជាអៀនខ្មាសមិនព្រមអង្គុយ ទើបគំនាប់បិតាហើយលាចូលទៅក្នុងបន្ទប់វិញ។ **អងអ៊ុន**ថា កូនអើយកុំខ្មាសអៀនអី **លីប៉ោ**គេមានមេត្តាដល់យើងដូចសាច់ញាតិពិតប្រាកដ ចូរកូនអង្គុយចាក់ស្រាជូនគេតាមត្រូវការចុះ។ នាង**តៀវសៀន**រៀបខ្លួនអង្គុយលើកៅអីប្រប**អងអ៊ុន** ហើយចាក់ស្រាគំនាប់**លីប៉ោ** កាលចាក់ស្រាជូនវេលាណា តែងចោលកន្ទុយភ្នែកទៅប៉ះនឹងភ្នែក**លីប៉ោ**។ ឯ**លីប៉ោ**បានទទួលពែងស្រាហើយ តែងក្រឡេកភ្នែកទៅជួបនឹងភ្នែកនាង**តៀវសៀន**ជានិច្ច ក្នុងដួងចិត្តគិតគួចប្រតិព័ទ្ធស្នេហាស្រឡាញ់នាងពន់ពេកណាស់។ **អងអ៊ុន**ឃើញកិរិយាមានចិត្តស្ម័គ្រស្រឡាញ់កូនខ្លួនដូច្នោះ ក៏មានសេចក្តីសោមនស្សជាពន្លឹកហើយថា ខ្ញុំសព្វថ្ងៃជាមន្ត្រីមានយសស័ក្តិធំក្នុងរាជការក៏ពិត តែថាខ្លួនក៏កាន់តែជរាទុព្វលភាពណាស់ហើយ ឧបមាដូចដើមឈើដែលដុះក្បែរមាត់ច្រាំង ខ្ញុំនឹងលើកបុត្រីនេះជូនជាភរិយាតូចរបស់អ្នក ដើម្បីប្រយោជន៍នឹងបានទុកអ្នកធ្វើរូបកាយជាទីពឹងតទៅ ដែលខ្ញុំថាយ៉ាងនេះតើអ្នកយល់ឃើញដូចម្តេច បើជាសេចក្តីមិនសមគួរ កុំអ្នកប្រកាន់ទោសពៃរ៍អ្វីឡើយ។ **លីប៉ោ**បានស្តាប់ហើយក្រោកលុតជង្គង់គំនាប់**អងអ៊ុន**ហើយនិយាយថា

ដែលលោកឪពុកអាណិតមេត្តាខ្ញុំទាំងម្ល៉េះ ព្រះគុណធ្ងន់ជាទីបំផុតនឹងរកប្រៀបផ្ទឹមពុំបាន ទោះបីដូចម្ដេចខ្ញុំបាទនឹងធ្វើសេចក្ដីតបស្នងគុណលោកឪពុកតទៅ។ **អងអ៊ុន**តបថា កូននេះខ្ញុំលើកជូនជាសិទ្ធិដល់អ្នកហើយ ប៉ុន្តែសុំឲ្យខ្ញុំបង្អង់រើសយកឫក្សពារពេលាថ្ងៃណាដែលល្អ នឹងបញ្ជូនបុត្រីនេះទៅដល់ទីលំនៅអ្នកតែម្ដង។ **លីប៉ោ**ទទួលថា "ការនេះតាមតែលោកឪពុកគិតគួរចុះ" ថាហើយក៏ក្រោកឡើងប្រុងនឹងលា**អងអ៊ុន**។ **អងអ៊ុន**ចាប់ដៃឃាត់ថា កុំអាលសិន ដ្បិតចិត្តខ្ញុំចង់អញ្ជើញអ្នកឲ្យនៅសម្រាន្តនិយាយលេងបន្តិច តែក្រែងមហាឧបរាជត្រូវការរកអ្នក។ **លីប៉ោ**តបថា "លោកឪពុកមានប្រសាសន៍នោះ ខ្ញុំបាទអរគុណណាស់ តែថាថ្ងៃនេះខ្ញុំបាទមានកិច្ចធុរៈ ចាំដល់ថ្ងៃក្រោយសឹមមកនៅទទួលទានដំណេកលេងឲ្យយូរ" ថាហើយក៏លា**អងអ៊ុន**ចេញទៅ។

លុះពេលព្រឹកថ្ងៃក្រោយ **អងអ៊ុន**ចូលទៅក្រាបបង្គំគាល់ព្រះចៅ**ហៀនតេ** មិនបានឃើញ**លីប៉ោ**ចូលទៅគាល់ជាមួយនឹង**តាំងតុះ**ផង។ **អងអ៊ុន**លុតជង្គង់គំនាប់**តាំងតុះ**ហើយជម្រាបថា សព្វថ្ងៃនេះខ្ញុំបាទបានសេចក្ដីសុខប្រាសចាកទុក្ខភ័យអន្តរាយទាំងឡាយទាំងពួង ព្រោះព្រះតេជព្រះគុណមហាឧបរាជឃុំគ្រងរក្សាខ្ញុំបាទ នឹងរករបស់អ្វីថ្លៃថ្លាជាទីតបស្នងសងគុណគ្មាន វេលាព្រឹកថ្ងៃនេះខ្ញុំបាទសូមអញ្ជើញលោកទៅពិសាក្រយានៅផ្ទះខ្ញុំបាទជាសប្បាយម្ដង ដែលខ្ញុំបាទជម្រាបនេះ ទោះបីខុសត្រូវប្រការម្ដេច សូមលោកមានសេចក្ដីអនុញ្ញាតទោស។ **តាំងតុះ**បានស្ដាប់មានសេចក្ដីសោមនស្សទទួលថា ចាំដល់ពេលថ្ងៃត្រង់ខ្ញុំនឹងទៅ។ **អងអ៊ុន**បានឮដូច្នោះហើយ ក៏លា**តាំងតុះ**ទៅរៀបចំទីលំនៅនិងភោជនាហារបម្រុងទុកស្រេច។

លុះដល់ពេលថ្ងៃត្រង់**តាំងតុះ**ចេញចាកទីគាល់ ក៏ឡើងរថមានទាហានហែហមអមជាក្បួនតម្រង់ទៅផ្ទះ**អងអ៊ុន** ៗចេញទទួលគំនាប់ដល់ក្រៅផ្ទះ ហើយ

អញ្ជើញ**តាំងតុះ**ឲ្យឡើងទៅកាន់ទីកន្លែងរៀបក្រយាហារ។ **អងអ៊ុន**លុតជង្គង់ចាក់ស្រាគំនាប់**តាំងតុះ** ៗទទួលហើយហាមថា លោកកុំលុតជង្គង់គំនាប់ខ្ញុំដូច្នោះ ចូរអង្គុយតាមទីសមគួរចុះ។ **អងអ៊ុន**ធ្វើជាឱនបន្ទន់ខ្លួន ហើយនិយាយលើកសរសើរ**តាំងតុះ**ជាច្រើនប្រការ។ **តាំងតុះ**បានឮហើយលើកស្រាផឹកញញឹមញញែមក្អកក្រហែម ទំនងជារួសរាយសប្បាយចិត្តណាស់ ចាប់បរិភោគអាហារជាមួយនឹង**អងអ៊ុន**ទាល់តែថ្ងៃរសៀល។ រួច**អងអ៊ុន**អញ្ជើញ**តាំងតុះ**ទៅអង្គុយក្នុងល្វែងស្ងាត់ **តាំងតុះ**អស់ចិត្តមិនមានគិតរង្កៀសសង្ស័យ។ ពេលនោះ**អងអ៊ុន**ដេញមនុស្សប្រុសស្រីបម្រើឲ្យចេញទៅក្រៅអស់ ហើយនិយាយថា កាលអាយុខ្ញុំបាទបានម្ភៃប្រាំឆ្នាំ ខ្ញុំបាទបានរៀនក្បួនហោរា មើលផ្កាយរក្សាស្រុកសម្រាប់ព្រះមហាក្សត្រ និងផ្កាយទាំងពួង ឥឡូវនេះខ្ញុំបាទឃើញផ្កាយសម្រាប់ព្រះមហាក្សត្រនោះសៅហ្មង ឃើញផ្កាយមហាឧបរាជមានរស្មីដ៏រុងរឿង ខ្ញុំបាទពិគ្រោះឃើញថា ព្រះចៅ**ហៀនតេ**សព្វថ្ងៃនេះនឹងវិនាសសាបសូន្យជាឆាប់ រាជសម្បត្តិនោះគង់នឹងបានដល់មហាឧបរាជជាប្រាកដ។ **តាំងតុះ**បានស្តាប់ដូច្នោះ មានសេចក្តីសោមនស្សត្រេកអរសួរថា ខ្លួនខ្ញុំនឹងដល់ស្វេតច្ឆ័ត្រពិតឬ? ខ្ញុំមិនទាន់ឃើញផងទេ។ **អងអ៊ុន**តបថា ទំនៀមបុរាណថា បើអ្នកឯណាគ្មានតម្រិះប្រាជ្ញានិងបុណ្យវាសនាហើយ ក៏រមែងចាញ់អ្នកមានបុណ្យមានតម្រិះប្រាជ្ញា។ ខ្ញុំបាទឃើញដូច្នេះ ហេតុម្តេចលោកថាមិនទាន់ឃើញផងដូច្នោះ?

**តាំងតុះ**តបថា បើខ្ញុំបានរាជសម្បត្តិពិតដូចលោកពោលថា ខ្ញុំនឹងតាំងលោកឲ្យធ្វើជាមហាឧបរាជជំនួសខ្ញុំ ដើម្បីជាបំណាច់រង្វាន់មាត់ដែលទំនាយនោះ។ **អងអ៊ុន**ធ្វើជាត្រេកអររួសរាយសប្បាយចិត្តណាស់ ដល់វេលាព្រលប់ឲ្យអុជប្រទីបផ្កាលាក្នុងទីគ្រឹហាស្ថាន ហើយឲ្យលើកក្រយាហារនិងស្រាមកលៀង**តាំងតុះ**ម្តងទៀត។ ពេលដែល**តាំងតុះ**កំពុងបរិភោគអាហារនោះ **អងអ៊ុន**ឲ្យពួកពិណពាទ្យមហោរីប្រគំ មាន

នាងរបាំចេញមកច្រៀងរាំគំនាប់ ឲ្យនាង**តៀវសៀន**រាំបម្រើ**តាំងតុះ**ក្បែរៗខ្លួន។ ឯ**តាំងតុះ**ដែលប្រកបដោយចិត្តស្រឡាញ់រូបសំឡេងនៃស្រីកញ្ញា លុះក្រឡេកនេត្រាឃើញរូបនាង**តៀវសៀន**ស្រៀវស្រស់ជាងអស់ស្រីឯទៀត ក៏ឆ្មៀតមើលមិនដាក់ភ្នែក ទើបស្រែកហៅឲ្យចូលមកជិតហើយសួរ**អងអ៊ុន**ថា នាងនេះឈ្មោះអ្វី? **អងអ៊ុន**ជម្រាបថា នាងឈ្មោះ**តៀវសៀន**ជាកូន ខ្ញុំសុំគេមកចិញ្ចឹមតាំងពីតូច។ **តាំងតុះ**សួរថា ចេះច្រៀងដែរឬទេ? **អងអ៊ុន**ជម្រាបថា ចេះច្រៀងពីរោះណាស់ ថាហើយបង្គាប់ឲ្យនាង**តៀវសៀន**ស្រែកច្រៀងទទួលតាមទំនុកភ្លេង។

នាង**តៀវសៀន**ស្រែកច្រៀងរាយទំនុកថា "ស្រីរូបស្រស់ច្រៀងសំឡេងពីរោះ បបូរមាត់នាងសម្បុរក្រហមដូចផ្លែទន្លាប់ ធ្វើសម្រស់ឲ្យស្រស់ឡើង និងពាក់កងយក់ពីរ ទោះបីមិនមានក្បាច់ជារូបអ្វី មើលទៅកងហើយនឹងសាច់ស៊ីគ្នា ធម្មតាគ្រាប់ម្រេចតូចពិត កាលបើលិឍទៅដល់អណ្តាតហើយ តែងមានជាតិហិរក្តៅ"។

**តាំងតុះ**កាលបើបានស្តាប់នាង**តៀវសៀន**ច្រៀងរៀបរាប់ទំនុកដូច្នោះ ក៏មានសេចក្តីសម្គាល់ថាជាចម្រៀងពីរោះចាប់ចិត្ត ព្រោះមិនមានសង្កេតក្នុងកលឧបាយនៃស្ត្រី។ **អងអ៊ុន**បង្គាប់ឲ្យនាង**តៀវសៀន**ចាក់ស្រាជូន**តាំងតុះ** ៗទទួលហើយសួរថា នាងឯងអាយុប៉ុន្មានហើយ? នាងឆ្លើយជម្រាបថា ខ្ញុំម្ចាស់មានអាយុដប់ប្រាំមួយឆ្នាំហើយ។ **តាំងតុះ**ឃើញរូបសោភាស្អាតល្អ ទាំងច្រៀងក៏ពីរោះទៀត ក៏ចាប់ចិត្តក្លួចកើតប្រតិព័ទ្ធស្រឡាញ់ពេញហឫទ័យ ទើបនិយាយថា នាងឯងរូបស្អាតល្អដូចស្រីទេពអប្សរកញ្ញា នឹងរកស្រីណាមកប្រៀបផ្ទឹមពុំបាន។

នាង**តៀវសៀន**បានឮដូច្នោះ ក៏រឹតតែធ្វើកលមាយាឲ្យ**តាំងតុះ**ចាប់ចិត្តឡើងទៀត។ **អងអ៊ុន**ឃើញដូច្នោះក្រោកលុតជង្គង់គំនាប់**តាំងតុះ**ហើយថា សព្វថ្ងៃនេះខ្ញុំបាទមានសេចក្តីសុខព្រោះបុណ្យគុណអំណាចលោក ខ្ញុំបាទនឹងរកអ្វីតបព្រះគុណ

គ្មាន មានតែនាង**តៀវសៀន**ជាកូនចិញ្ចឹមនេះ ខ្ញុំបាទក៏ស្រឡាញ់ទុកដូចជាកូនបង្កើត ខ្ញុំបាទសូមលើកជូនជាស្រេចដល់លោក។ **តាំងតុះ**បានឮដូច្នោះ ក៏មានសេចក្តីត្រេកអរជាពន្លឹក ទើបតបថា ដែលលោកមានដួងចិត្តគិតលើកនាង**តៀវសៀន**ឲ្យដល់រូបខ្ញុំនោះ ខ្ញុំនឹងតបស្នងសងគុណលោកតទៅ។ **អងអ៊ុន**ទើបឲ្យចាត់ចែងទ្រព្យរបស់ជាគ្រឿងសំពត់អាវសារស្បៃដ៏មានតម្លៃរៀបដំណើរឲ្យនាង**តៀវសៀន**ជាច្រើន ហើយឲ្យនាងឡើងជិះរថ ចាត់ឲ្យមនុស្សម្នាហែហមទៅដល់លំនៅឋាន**តាំងតុះ**ក្នុងស្រុកក្រុងនៅវេលាយប់នោះ។

ឯ**តាំងតុះ**នោះ កាលឃើញ**អងអ៊ុន**ចាត់ប្រើមនុស្សម្នាឲ្យនាំខ្លួន**តៀវសៀន**ទៅឲ្យដូច្នោះ ក៏លា**អងអ៊ុន**ចេញទៅ។ ក្នុងពេលនោះ **អងអ៊ុន**ក៏ជូនដំណើរ**តាំងតុះ**ទៅដល់ផ្ទះហើយលាត្រឡប់វិលមកវិញ ចេញមកដល់ពាក់កណ្តាលផ្លូវទទួលជួបនឹង**លីប៉ោ**ជិះសេះកាន់ទួនមកពីមុខ។ **លីប៉ោ**ឈប់ចាប់ជាយអាវ**អងអ៊ុន**ហើយសួរថា នាង**តៀវសៀន**នោះខ្លួនលើកឲ្យជាភរិយាយើងហើយ ហេតុម្តេចក៏បញ្ជូននាងទៅឲ្យមហាឧបរាជវិញ ដែលខ្លួនធ្វើដូច្នេះនឹងបញ្ឆោតយើងលេងឬទេ?

**អងអ៊ុន**តបថា ទីនេះជាកណ្តាលផ្លូវ ខ្ញុំនឹងជម្រាបអ្នកឲ្យអស់សេចក្តីមិនបាន សុំអញ្ជើញអ្នកទៅផ្ទះខ្ញុំមួយរំពេចសិន ខ្ញុំនឹងជម្រាបរឿងនេះឲ្យបានជ្រាប។ **លីប៉ោ**តាមទៅដល់ផ្ទះ**អងអ៊ុន** ៗនាំ**លីប៉ោ**ឡើងទៅលើល្វែងផ្ទះ ហើយនិយាយថា អ្នកកុំអាលខឹងសម្បារនឹងខ្ញុំ ៗនឹងជម្រាបឲ្យជ្រាប កាលពីព្រឹកមិញ ខ្ញុំបាទចូលទៅគាល់ព្រះចៅ**ហៀនតេ** មហាឧបរាជបាននិយាយនឹងខ្ញុំថា មានកិច្ចនឹងត្រូវការចង់ទៅរកខ្ញុំឯផ្ទះក្នុងពេលថ្ងៃត្រង់ ខ្ញុំបានរៀបក្រយាហារទុកជូនពិសា លុះមហាឧបរាជទៅពិសាហើយឈ្លេចសួរខ្ញុំថា មានគេទៅជម្រាបខ្ញុំថា ខ្ញុំលើកនាង**តៀវសៀន**ជាកូនឲ្យធ្វើជាភរិយាអ្នក ខ្ញុំបានទទួលថាមែន មហាឧបរាជថាចង់សុំមើលខ្លួន ខ្ញុំឲ្យនាង

**តៀវសៀន**ចេញមកគំនាប់ មហាឧបរាជបានឃើញរូបរាងហើយថា ដែលខ្ញុំលើកកូនឲ្យអ្នកជាបុត្រធម៌មហាឧបរាជនោះ មហាឧបរាជមានសេចក្តីពេញចិត្តណាស់និយាយនឹងខ្ញុំថា ថ្ងៃនេះឫក្សពារល្អហើយនឹងសុំយកខ្លួននាង**តៀវសៀន**ទៅរៀបការនឹងអ្នកជាកូន ឲ្យរួមសុខទុក្ខនឹងគ្នាតាមប្រវេណី ដែលមហាឧបរាជថាដូច្នេះ អ្នកចូរគិតមើលទៅចុះ ខ្ញុំជាអ្នកតូចនឹងអាចរឹងទទឹងបានឬ? ខ្ញុំទើបបញ្ជូនកូនឲ្យទៅ។

**លីប៉ោ**បានស្តាប់ទើបឆ្លើយថា "ខ្ញុំបាទដែលក្រោធនឹងលោកនោះខុសហួសទៅហើយ សូមឲ្យលោកអភ័យទោសចុះ" ថាហើយលាទៅវិញ ក្នុងវេលាយប់នោះស្រូតទៅដល់ផ្ទះ**តាំងតុះ** ហើយចាំស្តាប់ដំណឹង ជា**តាំងតុះ**នឹងគិតរៀបការឲ្យមែនឬប្រការម្តេចបានជាមិនមានឮអ្វីសោះ។ លុះព្រឹកឡើង **លីប៉ោ**ឡើងចូលទៅក្នុងល្វែងផ្ទះសួរស្រីបម្រើថា មហាឧបរាជនៅឯណា? ពួកស្រីប្រាប់ថា លោកមិនដឹងទេឬយប់មិញមហាឧបរាជបានស្រីរូបល្អម្នាក់មក ឥឡូវកំពុងសម្រាន្តនៅឯក្នុង។ **លីប៉ោ**បានស្តាប់ដូច្នោះនឹកក្តៅឈ្លួលក្នុងចិត្ត ទើបដើរចូលទៅអែបស្តាប់ក្បែរជញ្ជាំង។ ឯនាង**តៀវសៀន**ក្រោកពីដំណេកមុន**តាំងតុះ** ចេញទៅលុបមុខ ក្រឡេកឃើញស្រមោលចូលទៅតាមបង្អួច ក៏អើតចេញទៅមើលឃើញ**លីប៉ោ**។ នាង**តៀវសៀន**ធ្វើជាយំ ហើយយកសំពត់ជូតទឹកភ្នែក។ **លីប៉ោ**ឃើញដូច្នោះ រឹតតែមានចិត្តខឹងក្តៅនឹង**តាំងតុះ**ខ្លាំងណាស់ ទើបដើរត្រឡប់ចេញទៅខាងក្រៅ។

កាល**តាំងតុះ**ភ្ញាក់ឡើងចេញទៅខាងមុខ **លីប៉ោ**ក៏ឡើងទៅវិញ **តាំងតុះ**សួរថាថ្ងៃនេះមានការរាជការអ្វីខ្លះ? **លីប៉ោ**ឆ្លើយដោយសំលេងទ្រគោះថា គ្មានការអ្វីទេ។ **តាំងតុះ**ក៏នៅស្ងៀម ហើយបរិភោគអាហារ។ **លីប៉ោ**ចូលទៅឈរពីខាងក្រោយ**តាំងតុះ**តាមទម្លាប់។ ឯនាង**តៀវសៀន**ផាត់សក់ចេញ ហើយងាកមុខមើលទៅឃើញ**លីប៉ោ** ធ្វើជាចោលភ្នែកក្រឡេកទៅប្រទះនឹងភ្នែក**លីប៉ោ** ៗរឹតតែមានសេចក្តី

អាណិតស្រឡាញ់ជាច្រើន។ ឯ**តាំងតុះ**ដូចជាចោលភ្នែកក្រឡេកទៅឃើញជាក់ជា**លីប៉ោ**សម្លឹងមើលនាង**តៀវសៀន**ច្រើនដងដូច្នោះ ក៏មានចិត្តប្រច័ណ្ឌ ទើបនិយាយនឹង**លីប៉ោ**ថា ថ្ងៃនេះគ្មានការអ្វីទេ បើត្រូវការទៅផ្ទះក៏ទៅចុះ។ **លីប៉ោ**ឮដូច្នោះក្រឡេកមើលទៅមុខនាង**តៀវសៀន**ម្តងទៀត ហើយដកដង្ហើមធំរួចចុះទៅ។

កាល**តាំងតុះ**បាននាង**តៀវសៀន**មកទុកនោះ ក៏មានសេចក្តីស្រឡាញ់ពេញចិត្តវង្វេងជាប់ក្នុងកាមដោយមាតុគ្រាម ក៏ភ្លេចចេញមកនិយាយការជាងមួយខែ។ ពេលណាដែល**តាំងតុះ**មានជំងឺឈឺ នាង**តៀវសៀន**តែងមានសេចក្តីឧស្សាហ៍គក់ច្របាច់បម្រើបម្រាស់**តាំងតុះ**មិនឲ្យមានសេចក្តីទាស់ឆ្គងគំនិតឡើយ។ **តាំងតុះ**រឹតតែមានសេចក្តីស្រឡាញ់ពេញចិត្តនឹងនាង**តៀវសៀន**ទ្វេគុណឡើងទៀត។

មានថ្ងៃមួយ **លីប៉ោ**ចូលទៅសួរដល់ខាងក្នុងផ្ទះ **តាំងតុះ**កំពុងតែដេកលក់ នាង**តៀវសៀន**ឃើញ**លីប៉ោ**ចូលមកងាកខ្លួនចេញទៅខាងក្រៅមុន ធ្វើកលមាយាយកដៃចង្អុលទៅត្រង់**តាំងតុះ** ហើយចង្អុលទៅដើមទ្រូងរបស់ខ្លួន ហើយយំអណ្តឹតអណ្តក់ក្នុងទីនោះ។ **លីប៉ោ**ដឹងក្នុងកិរិយាដែលនាង**តៀវសៀន**ធ្វើនោះ រឹតតែមានសេចក្តីស្នេហាស្រឡាញ់ឡើងបែរជាស្អប់ខ្នាញ់នឹង**តាំងតុះ**ទៅវិញ។

ចំណែក**តាំងតុះ**ភ្ញាក់ឡើងឃើញ**លីប៉ោ**ចូលទៅ ក៏លបលួចគយគន់មើលអាកប្បកិរិយា ឃើញ**លីប៉ោ**លួចសម្លឹងទៅនាង**តៀវសៀន**ខាងក្បែរមុងដូច្នោះ ក៏ខឹងណាស់ស្រែកគំហកថា “នែ៎ អា**លីប៉ោ** អាអប្រិយ! អញខំប្រឹងយកឯងមកចិញ្ចឹមរក្សាទុកដូចជាកូនបង្កើត បង់កម្លាំងសោះ អាឯងចិត្តធំហ៊ានលួចស្រឡាញ់ប្រពន្ធអញ” ថាហើយបង្គាប់ស្រីបម្រើឲ្យបណ្តេញ**លីប៉ោ**ចុះពីលើផ្ទះហើយប្រាប់ថា តាំងពីថ្ងៃនេះទៅកុំឲ្យវាចូលមកផ្ទះអញទៀត។ ពេលនោះ**លីប៉ោ**មានសេចក្តីអៀនខ្មាសណាស់ នឹកទោមនស្សតូចចិត្តចុះដើរចេញពីផ្ទះ**តាំងតុះ**ទៅ ដល់បានពាក់កណ្តាលផ្លូវ

ជួបប្រទះនឹង**លីយូ** ហើយបាននិយាយរឿងរ៉ាវប្រាប់**លីយូ**សព្វគ្រប់ថា “**តាំងតុះ**មានចិត្តរំលោភលួចយកប្រពន្ធរបស់ខ្លួនផង ជេរប្រមាថបណ្ដេញខ្លួនថែមទៀតផង” លុះថ្លែងរឿងខ្លួនប្រាប់សព្វគ្រប់ហើយ ក៏គំនាប់លា**លីយូ**ដើរសំដៅទៅកាន់ផ្ទះ។ ឯ**លីយូ**បានស្ដាប់ពាក្យ**លីប៉ោ**ប្រាប់សព្វគ្រប់ហើយនឹកតូចចិត្ត ខំដើរស្រូតរូតរះទៅដល់ផ្ទះ**តាំងតុះ** ហើយចូលទៅជម្រាបថា លោកមានសេចក្ដីប្រាថ្នានឹងគិតការធំដុំ ចុះហេតុម្ដេចមកទាស់ទែងនឹង**លីប៉ោ** ដោយសេចក្ដីមិនមានខ្លឹមសារដូច្នេះ បើ**លីប៉ោ**បែកចិត្តពីលោកហើយ លោកនឹងយកនរណាធ្វើជាកម្លាំងតទៅបាន? **តាំងតុះ**ឮ**លីយូ**ថាដូច្នោះ ក៏ភ័យរន្ធត់ស្លុតចិត្តហើយថា ដែល**លីប៉ោ**ខឹងនឹងយើងនោះ អ្នកនឹងឲ្យយើងគិតដូចម្ដេចឲ្យបានស្រួលឡើងវិញ? **លីយូ**ជម្រាបថា សូមឲ្យលោករកខ្លួន**លីប៉ោ**មក ហើយយកមាសប្រាក់ និងទ្រព្យរបស់ដែលមានតម្លៃឲ្យ**លីប៉ោ** ហើយនិយាយល្បួងលួងលោមថ្នមចិត្តឲ្យស្រួល ប្រហែលជា**លីប៉ោ**នឹងមានចិត្តគិតស្រឡាញ់លោកឡើងវិញ។ **តាំងតុះ**ស្ដាប់ហើយក៏យល់ព្រមជាមួយផង។

លុះព្រឹកឡើង**តាំងតុះ**ឲ្យបម្រើទៅហៅខ្លួន**លីប៉ោ**មកដល់និយាយថា “ក្នុងវេលាថ្ងៃម្សិលមិញ បិតាមិនសប្បាយ ខ្លួនមានជំងឺឈឺក្ដៅក្រហាយសព្វសាច់ ដូចជាភ្លេចស្មារតីបានជាខឹងស្ដីឲ្យកូនដូច្នេះ ដូច្នោះហួសទៅហើយ កូនអើយអ្នកកុំប្រកាន់ទោសបិតាឡើយ” ថាហើយលើកមាសដប់ជញ្ជីង ព្រែយ៉ាងល្អម្ភៃផាប់ឲ្យ**លីប៉ោ** ៗ គំនាប់ទទួលហើយយកទៅ។ តាំងពីថ្ងៃនោះរៀងមក **លីប៉ោ**តែងទៅមករក**តាំងតុះ**ដូចដើម តែចិត្តនោះនៅនឹករឭកនាង**តៀវសៀន**មិនមានភ្លេចមួយវេលា។ លុះយូរមក **តាំងតុះ**ជាជំងឺហើយក៏ចូលទៅគាល់ព្រះចៅ**ហៀនតេ**។ **លីប៉ោ**ជិះសេះកាន់ទួនតាមទៅជាមួយផង ពេលដែល**តាំងតុះ**កំពុងអង្គុយគាល់ **លីប៉ោ**លបចេញទៅឡើងសេះជិះបំផាយទៅដល់ផ្ទះ**តាំងតុះ** ចងសេះទុកនៅមុខផ្ទះហើយកាន់ទួនចូលទៅរក

នាង**តៀវសៀន**ខាងល្វែងក្នុង។ នាង**តៀវសៀន**ក្រឡេកឃើញ**លីប៉ោ** ធ្វើជាមានចិត្តអាល័យណាស់គំនាប់ហើយថា បើយើងនឹងនិយាយគ្នាក្នុងទីនេះ ខ្លាចក្រែង**តាំងតុះ**មកទាន់នឹងកែខ្លួនលំបាក បើដូច្នេះសូមអញ្ជើញអ្នកទៅចាំខ្ញុំឯកន្លែងត្រជាក់ក្នុងសួនផ្កា ខ្ញុំនឹងចុះទៅតាមឥឡូវនេះ។ ឯ**លីប៉ោ**ក៏ចុះទៅតាមសញ្ញា។

នាង**តៀវសៀន**ក៏ចុះទៅតាម**លីប៉ោ** ហើយអង្គុយជាមួយគ្នាក្បែរមាត់ស្រះ ភ្នែកចេះតែសម្លឹងមើលផ្លូវក្រែង**តាំងតុះ**មកទាន់។ នាង**តៀវសៀន**ធ្វើកលឧបាយស្ទុះទៅឱបជើង**លីប៉ោ** ហើយក្រាបទួញយំថា "ខ្លួនខ្ញុំជាកូន**អងអ៊ុន** ៗឪពុកខ្ញុំរាប់អានស្រឡាញ់អ្នកដូចជាកូនបង្កើត បានលើកខ្ញុំជាភរិយាអ្នក ខ្ញុំមានសេចក្ដីត្រេកអរណាស់ ដែលមហាឧបរាជទៅទទួលយកខ្ញុំមកថា នឹងរៀបការអ្នកនឹងខ្ញុំបានជាស្វាមីភរិយានៅជាមួយគ្នា លុះមកដល់ផ្ទះមហាឧបរាជ មិនឃើញធ្វើតាមពាក្យថា ត្រឡប់កំហែងខ្ញុំរួមប្រវេណីដូច្នេះ ទ្រូងរបស់ខ្ញុំមានតែសេចក្ដីក្រំដំណំជានិច្ច ប្រហែលជាងមួយខែប្លាយហើយ គិតថានឹងអត់ដង្ហើមឲ្យស្លាប់ទៅពុំគាប់ ព្រោះមិនទាន់បានជម្រាបអ្នក ព្រមទាំងប្រាប់ទុក្ខដែលមានក្នុងទ្រូងខ្ញុំ ឥឡូវបានជួបហើយ ខ្ញុំសូមលាអ្នកស្លាប់វេលានេះ នឹងទ្រាំរស់នៅនាំឲ្យរងកម្មចិត្តឥតអំពើ បើខ្ញុំមិនធ្វើឲ្យអ្នកឃើញដូច្នោះ មិនពិតជាត្រង់ប្រាកដ" ថាហើយក៏ស្ទុះចុះពីលើគ្រែលោតតម្រង់ទៅក្នុងស្រះឲ្យស្លាប់។

**លីប៉ោ**ស្ទុះប្រញាប់ទៅឱបនាង**តៀវសៀន**ជាប់ហើយយំថា សេចក្ដីទៀងត្រង់សុចរិតនិងសេចក្ដីស្ម័គ្រស្រឡាញ់របស់ប្អូននោះ បងបានឃើញច្បាស់លាស់ហើយ តែថាមានអកុសលមកជំទាស់ ទើបយើងមិនបានដឹងសុខទុក្ខគ្នា ។ នាង**តៀវសៀន**តបថា ខ្ញុំដែលនឹងខំទ្រាំទូន្មានខ្លួនក្នុងជាតិនេះ មានតែសេចក្ដីលំបាកព្រួយទ្វេឡើងទៀត ព្រោះមានកម្មតាមមកទាន់ ជាតិនេះបុណ្យវាសនាតិចណាស់ ទើបព្រាត់ប្រាស

មិនឲ្យជួបគ្នាជាស្វាមីភរិយា នឹងរស់នៅថ្វីឲ្យវេទនាសូមលាអ្នកស្លាប់ហើយ ជាតិក្រោយសូមចាប់ឲ្យកើតមកជួបជាភរិយាអ្នក នឹងបានប្រណិប័តិន៍ឲ្យអស់ចិត្តដែលស្រឡាញ់។ **លីប៉ោ**ឆ្លើយថា ប្អូននឹងមកធ្វើខ្លួនឲ្យស្លាប់មុនឈឺនោះមិនគួរសោះ នាងចាំស្តាប់ពាក្យបងសិនចុះ ក្នុងជាតិនេះបើបងមិនបានខ្លួនប្អូនជាភរិយាទេ បងក៏មិនស៊ូនៅរស់ជាកូនប្រុសតទៅទៀត។ នាង**តៀវសៀន**តបថា តាំងពីខ្ញុំទ្រាំលំបាករៀងមកជាងមួយខែហើយ អ្នកអើយទុក្ខក្នុងទ្រូងខ្ញុំតែត្រឹមមួយថ្ងៃវិស័យដូចទុក្ខកន្លះឆ្នាំ បើអាណិតទ្រូងខ្ញុំឲ្យបាននៅរស់ធ្វើជាភរិយាអ្នក ត្រូវគិតដូចម្តេចឲ្យស្រេចដោយរួសរាន់ទៅចុះ។ **លីប៉ោ**ឆ្លើយថា បងតាម**តាំងតុះ**ចូលទៅក្នុងវាំង ដល់មានឱកាសស្រួលបានជាត្រឡប់ចូលមករកប្អូន មិនបានប្រាប់**តាំងតុះ**ថាទៅណាទេ ឥឡូវនេះនៅបារម្ភក្រែង**តាំងតុះ**រកមិនឃើញខឹងសង្ស័យ បើដូច្នេះបងសូមលាប្អូនទៅសិនចុះ។ នាង**តៀវសៀន**តបថា បើអ្នកខ្លាចអាសត្រូវកញ្ចាស់ហើយ អ្នកប្រហែលមិនបានឃើញមុខខ្ញុំទៀតឡើយ។ **លីប៉ោ**ឆ្លើយថា សូមឲ្យប្អូនបង្អង់សិនចុះ ចាំឲ្យបងទៅត្រិះរិះគិតសិន។ នាង**តៀវសៀន**ថ្លែងតបថា “ខ្ញុំបានឮកេរ្តិ៍ឈ្មោះអ្នកល្បីល្បាញខ្លាំងណាស់ សូម្បីតែឈ្មោះក៏ដូចផ្គររន្ទះ ខ្ញុំឮឈ្មោះច្បាស់មានតែយកដៃខ្ទប់ត្រចៀកដរាបដោយការខ្លាចអំណាចលោក ព្រោះថាអ្នកខ្លាំងពូកែក្នុងការសង្គ្រាមនឹងរកអ្នកឯណាត្រឹមស្មើគ្មាន។ ឥឡូវខ្ញុំបានឃើញបានស្តាប់វាចារបស់អ្នកមិនសមដូចពាក្យឮសោះ បើនឹងពិគ្រោះមើលទៅឃើញថាអ្នកជាមនុស្សខ្លាច សូម្បីតែត្រឹមអំណាច**តាំងតុះ**ប៉ុណ្ណោះខ្លាចណាស់ទៅហើយ បើដូច្នេះហើយនឹងគិតការអ្វីបាន?” ថាហើយក៏ធ្វើជាទួញយំខ្វេះដោះដៃពី**លីប៉ោ**ចេញ ហើយស្ទុះទៅនឹងលោតទឹកសម្លាប់។ **លីប៉ោ**នឹកតូចចិត្តណាស់បោះចោលទួនចេញពីដៃ ហើយស្ទុះទៅឱបត្រកងនាង**តៀវសៀន**ដាក់លើភ្លៅ ហើយនិយាយលួងលោមថ្នាក់ថ្នមនាងជាយូរណាស់។

ចំណែកខាង**តាំងតុះ** កាលដែលកំពុងអង្គុយគាល់ព្រះចៅ**ហៀនតេ**នោះ ដល់ក្រឡេកមើលទៅរក**លីប៉ោ**ពុំឃើញក៏ពិភាល់ក្នុងចិត្ត។ ទទួលស្ដេចចូលទៅខាងក្នុង **តាំងតុះ**ឡើងរថស្រូតមកផ្ទះជាប្រញាប់ ស្រាប់តែឃើញសេះ**លីប៉ោ**ចងទុកនៅមុខផ្ទះ ក៏រលះរលាំងឡើងទៅដល់ទីដំណេក ក្រឡេករកនាង**តៀវសៀន**ពុំឃើញ សួរពួកស្រីទាំងពួងៗជម្រាបថា នាងចុះទៅមើលសួនផ្កា។ **តាំងតុះ**ភ័យភ្លានឹកថា "ប្រហែលអា**លីប៉ោ**ទៅជួបគ្នាទេដឹង?" ហើយប្រឹងចុះដើរទៅតាមមើលដល់សួនឧទ្យាន។

ឯនាង**តៀវសៀន**បានក្រឡេកទៅឃើញ**តាំងតុះ**ចុះទៅដល់មាត់ទ្វារ ធ្វើជាមាយាស្ទុះទៅនឹងលោតទឹកសម្លាប់។ **លីប៉ោ**ក៏ស្ទុះទៅចាប់ឱបចាប់ពនាងឡើងមកវិញ **តាំងតុះ**ដើរលឿនលេញទៅដល់គ្រែអង្គុយក្នុងសួន ឃើញ**លីប៉ោ**ឱបពនាង**តៀវសៀន** ៗបេះប្រឡេះដៃចេញ **តាំងតុះ**នោះមិញក៏មានសេចក្ដីក្ដៅខ្លាំង ព្រោះមិនដឹងកលមាយាស្រីក៏ស្រែកទន្ទ្រាំដីថា ម៉ែអា**លីប៉ោ**អាចោរក្បាលអាក្រក់ ហ៊ានមកឆក់លួចថ្លើមអញ។ **លីប៉ោ**ងាកចេញមកមើលឃើញច្បាស់ជា**តាំងតុះ** ក៏ភ្ញាក់ខ្លួនដូចគេកន្ត្រាក់ ស្ទុះចោលទួនដែលដាក់លើគ្រែម្ទីម្នារត់ទៅ។ **តាំងតុះ**ស្ទុះចាប់បានទួននៅលើគ្រែ បែរដេញតាមប្រកិតទៅផុតមាត់ទ្វារ។ **លីយូ**ឃើញហើយក៏ស្ទុះទៅរាំងរាប៉ះពារលើ**តាំងតុះ** ៗដួលសន្លប់នៅទីនោះ។ **លីយូ**ក៏ស្ទុះទៅគ្រាហ៍លើកឡើងនាំទៅដាក់លើផ្ទះ លុះដល់**តាំងតុះ**ដឹងស្មារតីសួរ**លីយូ**ថា អ្នករត់មកមានការអ្វី? **លីយូ**ឆ្លើយថា ខ្ញុំបាទចេញមកប៉ងនឹងឃាត់លោក ទទួលលោករត់ចេញមកទង្គិចនឹងខ្ញុំបាទដួលទៅ ខ្ញុំបាទសូមអភ័យទោសលោកចុះ។ **តាំងតុះ**និយាយប្រាប់**លីយូ**ថា អា**លីប៉ោ**នេះជាមនុស្សអកតញ្ញូណាស់ បង់កម្លាំងសោះដែលយើងចិញ្ចឹមវាជាបុត្រ គួរវាមកលួចហុតឈាមយើង គឺវាមកលួចឱបក្រសោបនាង**តៀវសៀន**ក្នុងទីសួនផ្កា យើងនឹងតាមសម្លាប់វាចេញទើបអស់សេចក្ដីទោម្នេញក្នុងចិត្ត។

**លីយូ**ឆ្លើយថា លោកនឹងសម្លាប់**លីប៉ោ**ចេញនោះមិនគួរទេ ខ្ញុំបាទសូមនាំសេចក្ដីមកប្រៀបជូនលោកស្ដាប់ កាលព្រះចៅ**ឆសងអង**ខឹងដំណឹងថា ស្ដេចនគរមួយមានកូនក្រមុំល្អណាស់ បានចាត់គេចូលដណ្ដឹង ស្ដេចនគរនោះមិនព្រមថ្វាយព្រះចៅ**ឆសងអង**ទ្រង់ខ្ញាល់ ទើបប្រើ**ចៀវយ៉ង**ទាហានឯកលើកពលទៅវាយយកស្រុកនោះបាន **ចៀវយ៉ង**ក៏នាំយកកូនក្រមុំនោះទៅថ្វាយព្រះចៅ**ឆសងអង** ៗមានព្រះបន្ទូលនឹង**ចៀវយ៉ង**ថា អ្នកទៅវាយយកស្រុកបាននិងយកនាងនេះមកថ្វាយយើង ៗមិនត្រូវនឹងត្រេកអរទទួលយកទេ គួរតែអ្នកយកទុកធ្វើជាភរិយាចុះ។ ស្ដេចលើកនាងនោះឲ្យជាភរិយា**ចៀវយ៉ង**តាមមានគុណបំណាច់ **ចៀវយ៉ង**មានសេចក្ដីត្រេកអរគិតកតញ្ញូដល់ព្រះចៅ**ឆសងអង**។ លុះយូរមកមានសឹកលើកមកឡោមព័ទ្ធទីព្រះនគរជុំវិញ ស្ដេចទ្រង់ព្រួយព្រះហឫទ័យខ្លាំងណាស់ ព្រោះគ្មាននរណានឹងយកអាសាចេញច្បាំងនឹងបច្ចាមិត្តបាន។ **ចៀវយ៉ង**មានសេចក្ដីភក្ដិដល់ព្រះចៅផែនដីណាស់ ក៏ទទួលអាសាចេញច្បាំងបង្ក្រាបសត្រូវបាន ។ ឯ**លីប៉ោ**ជាទាហានឯករបស់លោកហើយលោកទទួលចិញ្ចឹមជាបុត្រធម៌ពេញមុខ គួរតែលោកទំនុកបម្រុងបំពេញចិត្ត**លីប៉ោ**តាមប្រាថ្នា ដែលលោកនឹងមកខាំងខាស្រីម្នាក់ឲ្យខូចការជាប្រយោជន៍ដ៏ល្អតទៅមុខនោះមិនគួរសោះ ហេតុនេះខ្ញុំបាទសុំឲ្យលោកលើកនាង**តៀវសៀន**ឲ្យទៅធ្វើជាភរិយា**លីប៉ោ**ចុះទើបគួរ **លីប៉ោ**នឹងមានចិត្តភក្ដិដល់លោក។

**តាំងតុះ**តបថា ដែលអ្នកថាទាំងនោះត្រូវណាស់ តែសុំបង្អង់ឲ្យយើងត្រិះរិះបន្តិចទៅសិន **លីយូ**ក៏វិលត្រឡប់ទៅផ្ទះវិញ។ កាល**តាំងតុះ**និង**លីយូ**កំពុងនិយាយគ្នានោះ នាង**តៀវសៀន**មកលបស្ដាប់ផ្ទាប់នៅជញ្ជាំង លុះ**លីយូ**ត្រឡប់ទៅហើយ**តាំងតុះ**ចូលទៅសួរនាង**តៀវសៀន**ថា ឯងនិង**លីប៉ោ**សហាយនឹងគ្នាឬ? នាង**តៀវសៀន**ឮដូច្នោះយំខ្សឹកខ្សួល ហើយស្រែកឡើងជម្រាប**តាំងតុះ**ថា កាលពីព្រឹក

មិញនេះខ្ញុំម្ចាស់ចុះទៅបេះផ្កាក្នុងសួន មិនដឹងខ្លួនជា**លីប៉ោ**ចូលទៅរកខ្ញុំ ៗក្រឡេកឃើញ**លីប៉ោ**កាន់ទួននៅដៃ ខ្ញុំម្ចាស់ភ័យណាស់ស្ទុះជៀសទៅ **លីប៉ោ**តាមទៅជិតខ្ញុំម្ចាស់ហើយនិយាយថា ខ្ញុំជាកូនមហាឧបរាជ ខ្លួនអ្នកជាភរិយាមហាឧបរាជ នឹងខ្លាចខ្ញុំថ្វីឈប់និយាយគ្នាសិន **លីប៉ោ**ក៏ស្ទុះទៅសង្កិនចាប់ខ្ញុំម្ចាស់ទាំងអំណាច ខ្ញុំម្ចាស់ជេរថាក៏វាមិនស្តាប់ រឹតតែឱបក្រសោមខ្លួនខ្ញុំម្ចាស់ ៗខឹងពេកណាស់ ស្ទុះទៅប្រារព្ធនឹងលោតទឹកសម្លាប់ វាស្ទុះទៅត្រកងចាប់ពខ្ញុំម្ចាស់មកវិញ ទទួលលោកអញ្ជើញទៅទាន់ កុំអី**លីប៉ោ**ធ្វើទុក្ខទោសខ្ញុំយ៉ាងណាមិនដឹង ខ្ញុំម្ចាស់នឹកខឹងណាស់ដែល**លីប៉ោ**ធ្វើឲ្យអាប់យសដូច្នេះ។

**តាំងតុះ**បានស្តាប់ហើយឆ្លើយតបថា **លីប៉ោ**នោះវាមានសេចក្តីស្ម័គ្រស្រឡាញ់នាងខ្លាំងណាស់ យើងនឹងលើកនាងឲ្យជាភរិយាវាចុះ។ នាង**តៀវសៀន**បានស្តាប់ដូច្នោះ ក៏ត្រឡប់ធ្វើជាភ្ញាក់ខ្លួន ហើយក្រំក្រួនវិយោគសោកាថា “ខ្ញុំម្ចាស់ជាស្រីមានសេចក្តីឧស្សាហ៍រក្សាកេរ្តិ៍ឈ្មោះតាំងពីតូចមក ដល់លោកយកមកធ្វើជាភរិយា ទោះបីមិនពេញជាបឋមភរិយាក្តីណា ក៏ហាក់ដូចជាមាតា**លីប៉ោ**ជាប្រាកដ ដែលលោកនឹងលើកខ្ញុំម្ចាស់ឲ្យទៅជាភរិយា**លីប៉ោ**ជាបុត្រលោកវិញនោះ លោកនឹងឲ្យខ្ញុំទៅយកបាវព្រាវលោកក្រៅផ្ទះល្អជាជាង ខ្ញុំម្ចាស់មិនព្រមយក**លីប៉ោ**សោះឡើយ ឧបមាដូចលោកគូររូបក្លោកហើយយកទឹកខ្មៅទៅលាបឲ្យខូចពណ៌សម្បុរទៅដូច្នោះ ខ្ញុំម្ចាស់មានសេចក្តីអាប់យសណាស់ ដែលនឹងបម្រុងជីវិតឲ្យរស់នៅមើលមុខគេតទៅទៀតមិនបាន” ថាហើយធ្វើជាក្រោកឡើងទាញយកគ្រប៊ីដែលនៅប្របខ្លួននោះមកនឹងអារកសម្លាប់។ **តាំងតុះ**ស្ទុះទៅចាប់ដណ្តើមយកគ្រប៊ីពីដៃបាន ហើយល្បួងលោមថា ដែលបងថាទាំងនេះជាពាក្យចំអកឡកបញ្ឆោតលេងទេ។ នាង**តៀវសៀន**ឱនជ្រប់ក្រាបឱបបាតជើង**តាំងតុះ**ហើយសោកាថា ការដែលកើតហេតុទាំងនេះក៏ព្រោះតែ

**លីយូ**ស្រឡាញ់**លីប៉ោ** ទើបនាំបង្កហេតុឲ្យលោកលើកខ្ញុំម្ចាស់ទៅធ្វើជាភរិយា**លីប៉ោ** ដូច្នេះ ខ្ញុំឃើញថា**លីយូ**មិនមែនស្រឡាញ់លោកដោយស្មោះត្រង់ ហើយមិនមែនអាណិតខ្ញុំម្ចាស់សោះ។ **តាំងតុះ**តបថា ដែល**លីយូ**និយាយដូចម្ដេច ៗនោះ បងមិនបានជឿពាក្យវាទេ។ នាង**តៀវសៀន**ជម្រាបថា ខ្ញុំម្ចាស់ដែលនឹងនៅក្នុងទីនេះតទៅគង់តែ**លីប៉ោ**នឹងមកធ្វើអន្តរាយដល់ខ្ញុំម្ចាស់ជាប្រាកដ ខ្ញុំម្ចាស់ក៏គង់តែបានសេចក្ដីអាស្រូវភាសខ្មាសគេជាងនេះទៅទៀត ហេតុនេះសូមលោកអញ្ជើញទៅនៅឯទីក្រុងថ្មី ទើបខ្ញុំម្ចាស់អស់ភ័យបារម្ភតទៅ។ **តាំងតុះ**ក៏យល់ឃើញត្រូវទើបនិយាយថា ចាំដល់ព្រឹកស្អែកសឹមយើងលើកទៅ។

លុះដល់វេលាព្រឹកឡើង **លីយូ**ចូលទៅជម្រាបតាំងតុះថា ថ្ងៃនេះល្អហើយ សុំឲ្យលោកលើកនាង**តៀវសៀន**ឲ្យជាភរិយា**លីប៉ោ**ចុះ។ **តាំងតុះ**តបថា **លីប៉ោ**ជាកូនចិញ្ចឹមរបស់យើង នាង**តៀវសៀន**ជាភរិយានៃយើងដែរ បើនឹងលើកឲ្យធ្វើជាភរិយា**លីប៉ោ**ដូច្នោះ ឃើញខុសនឹងទំនៀមទម្លាប់បុរាណ ដែល**លីប៉ោ**បានជាធ្វើល្មើសដល់នាង**តៀវសៀន**ឲ្យមានសេចក្ដីអៀនខ្មាសនោះ យើងក៏លើកទោសចោលទៅហើយ ការណ៍នេះសុំឲ្យអ្នកទៅប្រាប់**លីប៉ោ**ចុះ។ **លីយូ**តបថា ដែលលោកមិនព្រមស្ដាប់ពាក្យខ្ញុំបាទនេះ ការណ៍ដែលគិតទុកទាំងប៉ុន្មានគង់នឹងអន្តរធានព្រោះស្រីម្នាក់នេះ។ **តាំងតុះ**បានស្ដាប់ក៏នឹកខឹងណាស់តបថា អ្នកនៅទទូចឲ្យយើងលើកភរិយាឲ្យ**លីប៉ោ**នោះ យើងមិនស្ដាប់ពាក្យអ្នកទេ បើអ្នកមានចិត្តស្រឡាញ់**លីប៉ោ** ចូរអ្នកលើកភរិយារបស់អ្នកឲ្យ**លីប៉ោ**ចុះ ពីថ្ងៃនេះតទៅកុំឲ្យនរណាយករឿងនេះមកនិយាយដដែលទៀត បើនរណាមិនស្ដាប់ យើងនឹងបង្គាប់ឲ្យកាត់ក្បាលចេញ។ **លីយូ**ឮដូច្នោះក៏លាក្រោកដើរចេញទៅ ហើយនិយាយប្រាប់សេនាដែលចូលទៅរក**តាំងតុះ**នោះថា

“យើងទាំងឡាយនឹងបានសេចក្ដីវិនាសអន្តរាយ ព្រោះមេ**តៀវសៀន**ម្នាក់នេះជាប្រាកដហើយ” និយាយហើយ**លីយូ**ក៏ត្រឡប់ទៅផ្ទះ។

ក្រោយនោះ**តាំងតុះ**រៀបចាត់ចែងសេនាទាហាន ហើយនាំនាង**តៀវសៀន**ឡើងរថទៅនៅក្រុងថ្មី បណ្ដានាហ្មឺនសព្វមុខមន្ត្រីតូចធំក៏តាមជូនដំណើរ**តាំងតុះ**ទៅដល់ទ្វារស្រុក ឯនាង**តៀវសៀន**ដែលអង្គុយលើរថ លុះក្រឡេកទៅឃើញ**លីប៉ោ**ឈរនៅជាមួយនឹងពួកនាហ្មឺនក្បែរផ្លូវ នាងក៏សម្លឹងមើលទៅប្រទះភ្នែក**លីប៉ោ**ធ្វើជាទួញយំសោក **លីប៉ោ**ឃើញដូច្នោះកើតទោមនស្សក្ដៅផ្សាជាទុក្ខ ប្រឹងឈរមើលទាល់តែផុតកន្ទុយភ្នែក ហើយដកដង្ហើមធំ។ **អងអ៊ុន**ឃើញ**លីប៉ោ**ដើរចូលទៅចាប់ដៃហើយសួរថា មហាឧបរាជចេញទៅហើយ ខ្លួនអ្នកមានកង្វល់អ្វីបានជាមិនទៅតាម? **អងអ៊ុន**និយាយថា ខ្លួនខ្ញុំមិនសូវសប្បាយជាយូរថ្ងៃមកហើយ ទើបបានជាខានមកជួបនឹងលោកមហាឧបរាជ ថ្ងៃនេះឮគេនិយាយថា មហាឧបរាជរើទៅនៅក្រុងថ្មី ខ្ញុំខំប្រឹងមកដើម្បីជូនដំណើរលោក ឥឡូវឃើញទឹកមុខអ្នកមិនសប្បាយ តើអ្នកមានសេចក្ដីទុក្ខព្រួយពីការអ្វី? **លីប៉ោ**តបថា ដែលខ្ញុំមានសេចក្ដីទុក្ខក្ដៅក្រហាយទាំងម្ល៉េះនេះ ពីព្រោះតែនាង**តៀវសៀន**ជាកូនលោក។ **អងអ៊ុន**ក្លែងសួរធ្វើបែបមិនដឹងថា មហាឧបរាជមិនទាន់រៀបការនាង**តៀវសៀន**ឲ្យអ្នកទេឬ? **លីប៉ោ**តបថា រៀបការឯណា បើវាយកទៅទុកជាភរិយាវាទៅហើយ។ **អងអ៊ុន**ធ្វើជាភ្ញាក់ស្រឡាំងកាំងហើយថា ដែលអ្នកនិយាយនេះខ្ញុំមិនទាន់ជឿផងសោះ មហាឧបរាជនោះនឹងហ៊ានធ្វើដូច្នោះឬ? **លីប៉ោ**ក៏នាំដំណើរតាំងពីដើមហេតុដល់ចុងឲ្យ**អងអ៊ុន**ស្ដាប់គ្រប់ប្រការ។ **អងអ៊ុន**ស្ដាប់ហើយ ក៏លោតទន្ទ្រាំជើងហើយថា “ដែលមហាឧបរាជធ្វើដូច្នេះឧបមាដូចសត្វតិរច្ឆានអាក្រក់ណាស់” និយាយហើយក៏នាំ**លីប៉ោ**ទៅផ្ទះ ឲ្យរៀបភោជនាហារអញ្ជើញ**លីប៉ោ**បរិភោគផឹកស្រា។ **អងអ៊ុន**និយាយថា **តាំងតុះ**ធ្វើការ

អាក្រក់ដល់កូនខ្ញុំដែលជាភរិយាអ្នក ៗនឹងខ្ញុំក៏បានសេចក្តីអាស្រូវភាសខ្មាសគេណាស់ តែថាខ្លួនខ្ញុំនេះចាស់ជរាហើយ ជីវិតគង់នៅប៉ុន្មានថ្ងៃ ខ្ញុំគិតអាណិតខ្លួនអ្នកដែលនៅក្មេង ព្រោះសព្វថ្ងៃមានមនុស្សក្នុងព្រះនគរសរសើររាប់អានអ្នកថា មានថ្វីដៃខ្លាំងពូកែ ដែល**តាំងតុះ**ធ្វើអ្នកបានដូច្នេះ មនុស្សទាំងអស់គង់ត្មះតិះដៀលថា អ្នកជាមនុស្សល្ងង់ខ្លៅខ្លាចវិញ។ **លីប៉ោ**បានឮដូច្នោះខឹងណាស់ យកដៃទះតុហើយតបថា ដែលអា**តាំងតុះ**វាធ្វើខ្ញុំដល់ទីនេះ ខ្ញុំត្រូវសងសឹកវាឲ្យបាន។ **អងអ៊ុន**បានឮ ធ្វើជាយកដៃខ្ទប់មាត់**លីប៉ោ**ហើយឃាត់ហាមថា អ្នកកុំពោលពាក្យដូច្នោះ ក្រែងនាំខ្ញុំឲ្យខុសមានទោសទៅផង។ **លីប៉ោ**ឆ្លើយថា ខ្លួនខ្ញុំកើតមកជាប្រុសតែម្តងសម្គាល់ថា ខ្លួនមានថ្វីដៃខ្លាំងពូកែ មិនត្រូវនៅក្រោមបង្គាប់អ្នកណា។ **អងអ៊ុន**តបថា គំនិតចេះដឹងនិងថ្វីដៃនៃអ្នកនោះ មិនគួរនៅក្រោមអំណាចឲ្យ**តាំងតុះ**ប្រើប្រាស់សោះ ឧបមាដូចជាកែវមានតម្លៃ បានទៅដល់ដៃពានរកាន់។

**លីប៉ោ**ឆ្លើយថា ខ្ញុំមានសេចក្តីតូចចិត្តពេក គិតនឹងសម្លាប់អាសត្រូវកញ្ចាស់ឲ្យបានជាងមួយខែប្លាយមកហើយ តែគិតរារែកសង្កត់ចិត្តព្រោះបានជាហៅវាជាបិតា បើនឹងសម្លាប់ចេញវេលាណាខ្លាចគេគរហានិន្ទាបាន។

**អងអ៊ុន**តបថា ខ្លួនអ្នកជា**សែលី** **តាំងតុះ**ជា**សែតាំង**នឹងរាប់ថាជាអាពុកកូនយ៉ាងម៉េច បើ**តាំងតុះ**រាប់អ្នានអ្នកជាកូនប្រាកដ ចុះកាលកាន់ទូនដេញកាប់នោះ តើនឹកថាជាកូនដែរឬទេ? ដែលអ្នកនឹងខ្លាចគេនិន្ទានោះមិនគួរទេ ។ **លីប៉ោ**បានស្តាប់ស្រាប់តែភ្ញាក់គំនិតគិតឃើញឡើង ទើបឆ្លើយតបថា សេចក្តីខនេះកុំបានតែលោករំឭកទាន់ ខ្ញុំគ្មានជីវ័ននឹងគិតឃើញសោះ ។

**អងអ៊ុន**គិតឃើញថា **លីប៉ោ**ប្រាកដជាប្រែចិត្តចេញពី**តាំងតុះ**ពិតណាស់ ក៏ដាស់សតិ**លីប៉ោ**ថា សព្វថ្ងៃនេះ**តាំងតុះ**ជាសត្រូវនឹងរាជសម្បត្តិ អ្នកក៏ល្មមដឹងច្បាស់

ប្រាកដក្នុងចិត្តហើយ ដែលអ្នកបានមកនៅធ្វើរាជការជាមួយនឹង**តាំងតុះ**នេះ ក៏មានសេចក្ដីគាប់ប្រសើរបានច្រើនដង តើ**តាំងតុះ**បានឲ្យបំណាច់រង្វាន់ឡើងយសស័ក្ដិជានាហ្មឺនតំណែងអ្វីខ្លះដែរឬទេ? បើអ្នកតាំងចិត្តសុចរិតត្រង់នឹងព្រះមហាក្សត្រជាម្ចាស់ផែនដីវិញ សូម្បីអ្នកនឹងយកចិត្តទុកដាក់ជួយទំនុកបម្រុងផែនដីតែម្ដង គឺកម្ចាត់ពួកសត្រូវរាជសម្បត្តិចេញបាន អ្នកនឹងឡើងទីជានាហ្មឺនធំ មានកេរ្តិ៍ឈ្មោះឧដុង្គឧត្ដមជាប់ក្នុងព្រះរាជពង្សាវតារតទៅ។

**លីប៉ោ**បានឮដូច្នោះ ក៏លុតជង្គង់គំនាប់**អងអ៊ុន**ហើយថា ខ្ញុំបាទនឹងសូមយកអាសាផែនដីសងសឹកសម្លាប់អា**តាំងតុះ**ចេញឲ្យបាន លោកកុំមានសេចក្ដីសង្ស័យនឹងខ្ញុំបាទឡើយ។ **អងអ៊ុន**តបថា អ្នកគិតទំនុកបម្រុងដល់ផែនដីដូច្នេះ ក៏ជាការគាប់ប្រសើរហើយ តែក្រែងអ្នកនិងខ្ញុំមិនរួមគំនិតគ្នាទៅមិនបានយូរ បែរជានាំគ្នាស្លាប់ចោលបង្បៀតទៅវិញទេដឹង! **លីប៉ោ**ទាញគ្រប៊ីមកចាក់កដៃ សម្រក់លោហិតដាក់ក្នុងពែងស្រា ហើយស្បថស្បាន់ថា "បើខ្ញុំមិនបានសម្លាប់**តាំងតុះ**ចេញ ដូចពាក្យថានេះទេ សូមឲ្យទេវតាបណ្ដាលឲ្យអាវុធផ្សេងៗប្រហារខ្លួនខ្ញុំបាទឲ្យវិនាសចុះ" ហើយលើកពែងស្រានោះផឹកអស់ទៅ។ **អងអ៊ុន**ឃើញដូច្នេះក៏ក្រោកឡើងគំនាប់**លីប៉ោ**ហើយថា ពេលនេះព្រះមហាក្សត្រ និងអាណាប្រជានុរាស្ត្របានសេចក្ដីសុខក្សេមក្សាន្តព្រោះសតិបញ្ញារបស់អ្នក បើអ្នកនឹងចាប់ផ្ដើមធ្វើការនេះវេលាណាខ្ញុំនឹងពន្យល់ឲ្យដឹង។ **លីប៉ោ**ក៏លា**អងអ៊ុន**ត្រឡប់ទៅផ្ទះវិញ។

ចំណែក**អងអ៊ុន**បង្គាប់ឲ្យហៅ**ស៊ុនស៊ុយ** និង**អ៊ុយអ្វ៊ិន**ដែលជាទីប្រឹក្សា មកប្រាប់ហេតុដែលបានគិតនឹង**លីប៉ោ**ឲ្យសម្លាប់**តាំងតុះ**។ **អ៊ុយអ្វ៊ិន**ជម្រាបថា ព្រះចៅ**ហៀនតេ**ទ្រង់ព្រះឈួននោះ **តាំងតុះ**ក៏បានដឹងច្បាស់ដែរ តែឥឡូវព្រះអាពាធធូរស្រាលបានពីរថ្ងៃហើយ **តាំងតុះ**មិនទាន់បានដឹងដំណឹងនេះទេ បើដូច្នេះសូមលោក

រកអ្នកមានសតិបញ្ញាទៅអញ្ជើញ**តាំងតុះ**ថា “មានព្រះរាជឱង្ការ ឲ្យហៅទៅគាល់នឹងបានប្រឹក្សារាជការធំ” ហើយឲ្យតែងសំបុត្រសម្ងាត់ទៅឲ្យ**លីប៉ោ** ជាសេចក្ដីព្រះតម្រាស់ ឲ្យ**លីប៉ោ**លើកទាហានទៅបង្កប់នៅទីស្ដេចចេញ បើ**តាំងតុះ**ចូលមក ឲ្យសញ្ញាគ្នា ទើបការដែលគិតនោះនឹងធ្វើបានដោយស្រួល។ **ស៊ុនស៊ុយ**ឆ្លើយថា ដែលគិតដូច្នេះក៏ត្រូវហើយ តែនឹងរកនរណាជាបម្រើកាន់សំបុត្រព្រះតម្រាស់ចេញទៅដល់**តាំងតុះ**នោះ? **អ៊ុយអ៊ួន**តបថា **លីសុក**ធ្វើរាជការមានសេចក្ដីគាប់ប្រសើរល្អ **តាំងតុះ**មិនបានពិតទូលឲ្យឡើងយសស័ក្ដិឡើយ។ **លីសុក**ក៏មានសេចក្ដីទោមនស្សតូចចិត្តពន់ពេក បើ**លីសុក**កាន់ព្រះតម្រាស់ទៅឲ្យប្រហែល**តាំងតុះ**មិនមានសេចក្ដីសង្ស័យ។ **អងអ៊ុន**ក៏យល់ព្រមតាមពាក្យ**អ៊ុយអ៊ួន** ហើយឲ្យហៅ**លីប៉ោ**ទៅជួប ហើយប្រាប់សេចក្ដីដែលប្រឹក្សាគ្នានោះឲ្យស្ដាប់គ្រប់ប្រការ។ **លីប៉ោ**យល់ព្រមហើយនិយាយថា **លីសុក**នោះបានទៅនិយាយល្បួងលួងបញ្ចុះបញ្ចូលខ្ញុំបាទ កាលដែលនៅធ្វើការជាមួយគ្នានឹង**តេងងួន** បើ**លីសុក**មិនព្រមទៅ ហើយបែកការណ៍ដែលយើងគិតនេះទៅថ្ងៃមុខ ខ្ញុំនឹងធានាសម្លាប់**លីសុក**ចេញ។ **អងអ៊ុន**និង**លីប៉ោ**បង្គាប់ឲ្យទៅហៅ**លីសុក**មកជួប ហើយ**លីប៉ោ**និយាយថា កាលដែលខ្ញុំនៅនឹង**តេងងួន**នោះ អ្នកបានទៅល្បួងបញ្ចុះបញ្ចូលខ្ញុំ ឲ្យខ្ញុំសម្លាប់**តេងងួន**យកក្បាលមកឲ្យ**តាំងតុះ** ឥឡូវនេះខ្ញុំឃើញ**តាំងតុះ**ធ្វើអាក្រក់ក្បត់ផែនដី ទើបព្រមព្រៀងគ្នាគិតរំលាង**តាំងតុះ**ចេញ វេលានេះ យើងត្រូវការប្រើអ្នកឲ្យកាន់ព្រះតម្រាស់ទៅហៅ**តាំងតុះ**ឲ្យចូលមកគាល់ ហើយយើងនឹងសម្លាប់**តាំងតុះ**ចេញ តើអ្នកនឹងព្រមទៅឬមិនទៅ?

**លីសុក**បានស្ដាប់ហើយឆ្លើយតបថា សព្វថ្ងៃនេះខ្ញុំគិតរកឧបាយនឹងសម្លាប់**តាំងតុះ**ជាដរាប តែថាខ្ញុំនៅបារម្ភអ្នកជារូបមួយ ចិត្តមួយនឹង**តាំងតុះ** ទើបគិតធ្វើការនោះមិនបានសម្រេច ឥឡូវបើអ្នកប្រាកដជាប្រើខ្ញុំទៅហៅ**តាំងតុះ**ឲ្យចូលមកគាល់

ដោយឧបាយមែន ខ្ញុំមានសេចក្ដីពេញចិត្តណាស់ សុំទទួលយកអាសាទៅហៅ**តាំងតុះ**ឲ្យចូលមកបាន។ ពេលនោះ**លីសុក**យកព្រួញធ្នូមកកាច់ជាពីរកំណាត់ ហើយស្បថស្បាន់តម្រង់ខ្លួនថា បើខ្ញុំមិនបានធ្វើតាមពាក្យប្ដេជ្ញានេះទេ នឹងត្រឡប់នាំសេចក្ដីនេះទៅបំបែកឲ្យ**តាំងតុះ**ដឹងការណ៍នេះវិញនោះ សូមឲ្យខ្លួនខ្ញុំដាច់ជាពីរកំណាត់ដូចព្រួញដែលកាច់នេះចុះ។ **អងអ៊ុន**បានស្ដាប់**លីសុក**និយាយដូច្នោះ ក៏អស់សេចក្ដីសង្ស័យ ហើយបែរជាមានសេចក្ដីត្រេកអរជាពន្លឹក ទើបក្រោកឡើងគំនាប់**លីសុក**ហើយថា អ្នកតាំងចិត្តសុចរិតត្រង់នឹងផែនដីដូច្នេះ បើសម្រេចសេចក្ដីប្រាថ្នាកាលណា អ្នកនឹងបានជានាហ្មឺនធំតទៅ។

លុះដល់ព្រឹកឡើង **អងអ៊ុន**តែងសំបុត្រព្រះតម្រាស់ ហើយឲ្យកេណ្ឌទាហានសេះម្ភៃប្រគល់ឲ្យ**លីសុក** ៗក៏ចេញទៅដល់ទីក្រុងថ្មី ទាហានម្នាក់នាំយកសេចក្ដីជម្រាប**តាំងតុះ** ៗបានដឹងចេញមកទទួលព្រះតម្រាស់ ហើយនាំ**លីសុក**ចូលទៅក្នុងក្រុងថ្មី។ **លីសុក**ជម្រាប**តាំងតុះ**ថា ឥឡូវនេះព្រះចៅ**ហៀនតេ**ទ្រង់ព្រះឈ្មួនជាទម្ងន់នឹងរកអ្នកឯណានិយាយការរាជការគ្មាន នាហ្មឺនទាំងពួងប្រឹក្សាគ្នាយល់ថា ព្រមឲ្យមកអញ្ជើញមហាឧបរាជចូលទៅនឹងប្រគល់ជូនរាជសម្បត្តិ។ **តាំងតុះ**សួរ**លីសុក**ថា ដែលនាហ្មឺនទាំងពួងប្រឹក្សាគ្នាដូច្នេះ អ្នកបានឮ**អងអ៊ុន**និយាយដូចម្ដេចខ្លះ? **លីសុក**ឆ្លើយថា ដែលនឹងប្រគល់រាជការនូវរាជសម្បត្តិជូនដល់លោកនេះ **អងអ៊ុន**ជាដើមគំនិតស្នើនឹងមន្ត្រីទាំងពួងៗក៏យល់ព្រម ឥឡូវនេះ**អងអ៊ុន**ចាត់ចែងត្រាសម្រាប់រាជ្យទុកជូនលោកជាស្រេចហើយ។ **តាំងតុះ**បានស្ដាប់ដូច្នោះ ក៏មានចិត្តសោមនស្សហើយប្រាប់**លីសុក**ថា កាលពីយប់មិញយើងមានសុបិននិមិត្តឃើញថា មានសត្វម្ករមួយ មករុំព័ទ្ធជុំវិញខ្លួនយើង ដល់ព្រឹកឡើងស្រាប់តែមានដំណឹងនេះមកដល់យើង បើដូច្នេះចាំយើងនឹងទៅស្រុកក្រុង ដែលអ្នកបានកាន់ព្រះតម្រាស់មកនេះ យើងក៏

មានសេចក្ដីត្រេកអរណាស់ហើយ បើបានរាជសម្បត្តិពិតប្រាកដមែន យើងនឹងតាំងអ្នកធ្វើជានាហ្មឺនធំ គឺទីអគ្គមហាសេនា។ **លីសុក**ធ្វើហាក់ដូចទទួលប្រសាសន៍**តាំងតុះ**ជាប្រាកដណាស់ ទើបបង្គាប់ឲ្យ**លីឈុយ, គុយគី, តៀវចេ** និង**ហួនតៀវ** កេណ្ឌកងសេនាទាហានបានបីពាន់ឲ្យទៅរក្សាក្រុងថ្មី។ ឯ**តាំងតុះ**ចូលទៅរកមាតាហើយជម្រាបថា ឥឡូវនេះខ្ញុំនឹងទទួលរាជសម្បត្តិហើយ អ្នកម្ដាយមុខជានឹងបានជា**ហងថៃហ** គឺជាស្ដេចព្រះវររាជជននី។ មាតាតបថា ខ្លួនម្ដាយក៏ចាស់ជរាអាយុដល់កៅសិបប្លាយហើយ ម្ដាយបានពឹងបុណ្យកូនក៏ល្មមបានសេចក្ដីសុខប៉ុណ្ណេះហើយ ពេលនេះមាតាមានសេចក្ដីពិភាល់ក្នុងចិត្តណាស់ ព្រោះចេះតែកម្រើកញ័រទូទាំងសព៌ាង្គកាយ ហើយក្នុងចិត្តក៏ចេះតែភ្ញាក់តក់ស្លុតមកជាច្រើនវេលាហើយ បើកូនឹងចូលទៅក្រុងនោះ ត្រូវគិតប្រយ័ត្នរវាំងខ្លួនឲ្យល្អកុំធ្វេសប្រហែល។

**តាំងតុះ**តបថា “ដែលអ្នកម្ដាយមានអាភេទក្នុងខ្លួននោះ ព្រោះបុណ្យកូននឹងដល់ហើយ បានជាបណ្ដាលឲ្យកើតមានអាភេទដូច្នេះ” ហើយលាមាតាចូលទៅរក**តៀវសៀន**ហើយនិយាយដំណាលសេចក្ដីទាំងនោះឲ្យនាងស្ដាប់ថា បើយើងបានគ្រងរាជសម្បត្តិវេលាណា យើងនឹងលើកនាងឲ្យធ្វើជាអគ្គមហេសីខាងឆ្វេង។ នាង**តៀវសៀន**បានស្ដាប់ក៏គិតឃើញថា ប្រហែលជានាហ្មឺនទាំងពួងឲ្យមកនិយាយដូច្នេះប្រាថ្នានឹងសម្លាប់**តាំងតុះ**ជាប្រាកដ។ នាង**តៀវសៀន**គំនាប់ហើយធ្វើជាអររួសរាយ។

**តាំងតុះ**ឲ្យចាត់ចែងសេនាទាហាន ហើយឡើងជិះរថលើកក្បួនហែចេញទៅតាមផ្លូវប្រមាណបានសាមសិបសិន ភ្លៅរថដែល**តាំងតុះ**ជិះនោះបាក់ដាច់ជាពីរកំណាត់ **តាំងតុះ**ឡើងជិះសេះតទៅទៀតបានប្រមាណមួយរយសិន ស្រាប់តែសេះផ្អើលដាច់បង្ហៀរពីដៃ។ **តាំងតុះ**ងាកមកសួរ**លីសុក**ថា ដែលបាក់ភ្លៅរថនិងសេះផ្អើលដាច់បង្ហៀរដូច្នេះ អ្នកយល់ឃើញថា ល្អអាក្រក់ប្រការម្ដេច? **លីសុក**ជម្រាប

ថា ដែលកើតហេតុទាំងពីរនេះ ជាបុព្វត្រូវមហាឧបរាជនឹងបានគ្រងរាជសម្បត្តិ ហើយនឹងបានទ្រង់រថប្រដាប់ដោយគ្រឿងចម្លាក់រចនា ព្រមទាំងសេះព្រះទីនាំង។ **តាំងតុះ**បានស្តាប់ក៏ជឿជាក់ក្នុងចិត្ត ព្រោះមិនបានដឹងកលឧបាយដោយប្រការផ្សេងៗ លុះទៅដល់ទ្វារក្រុង បណ្តានាហ្មឺនតូចធំ ចេញទៅគំនាប់ទទួល**តាំងតុះ**ឈូឆរ។ ឯ**លីយូ**មានជំងឺឈឺមិនសប្បាយ មិនបានចេញទៅទទួល។ **តាំងតុះ**ក៏ចូលទៅក្នុងទីលំនៅរបស់ខ្លួន ពេលនោះ**លីប៉ោ**ក៏ឈរគំនាប់**តាំងតុះ** ៗនិយាយថា បើយើងបានរាជសម្បត្តិ យើងនឹងតាំងអ្នកឲ្យធ្វើជាធំត្រួតសេនាទាហានទាំងអស់។ **លីប៉ោ**ធ្វើជាត្រេកអរទទួលពាក្យ**តាំងតុះ** ហើយលាថយមកវិញ។

លុះដល់ពេលយប់ក្នុងខែមិគសិរ ពួកកូនក្មេងអ្នកស្រុកសាមសិបនាក់បបួលគ្នាទៅលេងមុខផ្ទះ**តាំងតុះ** ហើយច្រៀងរាយទំនុកថា “ស្មៅទាំងអស់មានស្លឹកខៀវស្រស់ ដុះលេចឡើងមិនបានយូរប៉ុន្មាន ប្រាំបួនឬដប់ថ្ងៃក៏នឹងស្លាប់”។ **តាំងតុះ**បានឮសំឡេងក្មេងច្រៀងដូចគេយំ ក៏សំងំចាំស្តាប់ នឹកប្លែកក្នុងចិត្តណាស់ ទើបឲ្យទៅ**លីសុក**ទៅសួរថា ដែលក្មេងច្រៀងឮសំឡេងរបៀងដូចយំនេះ តើអ្នកនឹងយល់ឃើញប្រការម្តេច? **លីសុក**តបថា សំឡេងក្មេងដូច្នេះជាបុព្វនិមិត្តរបស់លោកធំវិសេសណាស់ ព្រោះសែឡៅនឹងសាបសូន្យ ហើយសែតាំងនឹងរុងរឿងតទៅ។ **តាំងតុះ**ក៏មានសេចក្តីត្រេកអរណាស់ លុះព្រឹកឡើងក៏តែងខ្លួនពេញយសហើយឡើងរថនឹងចូលទៅក្នុងព្រះរាជវាំង។

លុះទៅដល់កណ្តាលផ្លូវ ទទួលជួបនឹង**តូយិន**ៗនោះពាក់អាវខៀវ មួកស ដៃកាន់ឈើច្រត់ ហើយយកសំពត់ស្តើងប្រវែងប្រាំបីហត្ថចងធ្វើទង់ មានអក្សរនៅដើមទង់មួយតួថា “ខៅ” ចុងទង់មួយតួថា “ខៅ” ទាំងពីរនោះផ្សំគ្នាហៅថា “លី” ប្រែថា “សែលី”។ សំពត់នោះភាសាចិនហៅថា “ប៉ោ”។ ប្រស្នាដែល**តូយិន**ធ្វើនេះបាន

សេចក្ដីថា **លីប៉ោ**នឹងសម្លាប់**តាំងតុះ**។ ឯ**តាំងតុះ**មិនយល់សេចក្ដីក្នុងប្រស្នានោះ ក៏មានសេចក្ដីសង្ស័យទើបសួរទៅ**លីសុក**ថា ដែល**តូយិន**ធ្វើដូច្នេះ តើអ្នកណានឹងយល់ឃើញដូចម្ដេច? **លីសុក**ដឹងច្បាស់ក្នុងប្រស្នា តែក្លែងប្រាប់**តាំងតុះ**ថា “**តូយិន**ធ្វើដូច្នោះព្រោះខូចចរិតទេ នឹងកាន់យកថាល្អឬអាក្រក់នោះមិនបាន” ហើយ**លីសុក**ក៏ប្រើទាហានបណ្ដេញ**តូយិន**ចេញឆ្ងាយពីផ្លូវ។ លុះ**តាំងតុះ**ចូលដល់ទ្វារវាំង **លីសុក**ប្រើឧបាយឲ្យ**តាំងតុះ**ឃាត់ទាហានទុកខាងក្រៅ ហើយ**លីសុក**នាំរថ**តាំងតុះ**ចូលទៅក្នុងកំបាំងពីទីគាល់។ **តាំងតុះ**ក្រឡេកឃើញនាហ្មឺនកាន់គ្រប៊ីឈរតម្រៀបគ្នា ក៏មានសេចក្ដីភ័យបារម្ភ ហើយសួរ**លីសុក**ថា ហេតុដូចម្ដេចបានជាពួកនាហ្មឺនឈរកាន់គ្រប៊ីដូច្នេះ? **លីសុក**មិនបានតបសោះ បង្ខំឲ្យបររថចូលទៅក្នុងទីព្រះរាជវាំងរម្យ។

**អងអ៊ុន**ឃើញដូច្នោះ ក៏ស្រែកប្រកាសថា សត្រូវរាជសម្បត្តិមកដល់ហើយ ចុះទាហានយើងហេតុម្ដេចក៏មិនពិឃាតបង់ទៅ! ឯទាហានដែលបង្កប់នៅទីនោះ ក៏ស្ទុះស្រចេញមកយកទួនចាក់**តាំងតុះ**ៗក៏ក្រាបនៅក្នុងរថ ហើយស្រែកហៅ**លីប៉ោ**ឲ្យជួយ។ **លីប៉ោ**ស្ទុះចេញមក ហើយស្រែកថា ខ្លួនជាសត្រូវរាជសម្បត្តិ ហេតុម្ដេចស្រែកឲ្យយើងជួយ? ថាហើយក៏យកទួនចាក់ត្រូវត្រង់ក**តាំងតុះ** ធ្លាក់ពីលើរថស្លាប់។ **លីសុក**ក៏កាត់ក្បាល**តាំងតុះ** ហើយស្រែកប្រកាសថា អាសត្រូវរាជសម្បត្តិស្លាប់ហើយ។ បណ្ដានាហ្មឺនតូចធំទាំងអស់ ដល់បានឃើញដូច្នោះ ក៏មានចិត្តត្រេកអរគ្រប់គ្នា។ **លីប៉ោ**ស្រែកថា ដែល**តាំងតុះ**ធ្វើការអាក្រក់ដូច្នេះ ព្រោះស្ដាប់ពាក្យ**លីយូ** នរណានឹងអាចយកអាសាទៅចាប់**លីយូ**ឲ្យយើងបាន? **លីសុក**ឆ្លើយទទួលយកអាសា ហើយក៏នាំទាហានទៅព័ទ្ធចាប់**លីយូ** និងពួកបក្សបងប្អូនមកទាំងអស់។ **អងអ៊ុន**បង្គាប់ឲ្យនាំបុត្រភរិយា និងបក្សពួក ព្រមទាំងខ្លួន**លីយូ**ទៅសម្លាប់គ្មានសល់។ សម័យនោះអាណាប្រជានុរាស្ត្រទាំងពួងក្នុងទីក្រុង ដែលមានចិត្តស្អប់**តាំងតុះ**

បបួលគ្នាទៅជេរប្រទេចខ្មោច ហើយយកដៃចង្កុលត្បូកក្បាលខ្លះ យកជើងធាក់ច្រំខ្លះ ទាល់តែសពនោះខ្ទេចខ្ទីពុះពោរទៅ។ **អងអ៊ុន**បានឱ្យនាំសពនោះទៅបោះចោលក្រៅព្រំខេត្ត ដោតក្បាលផ្ដាលទុកត្រង់ផ្លូវបែកឱ្យមានមនុស្សនៅចាំរក្សា។ ឯអ្នកចាំនោះវះពន្លះយកសាច់**តាំងតុះ**ចេញ ហើយដាក់ប្រឆេះប្រេងក្នុងលលាដក្បាល យកភ្លើងអុជជួសតាងចង្កៀងរៀងរាល់ថ្ងៃតទៅ។

ចំណែក**អងអ៊ុន**ឱ្យ**លីប៉ោ**, **លីសុក** និង**ហង់ហូកោ** ទាំងបីនាយនេះលើកទាហានប្រាំម៉ឺន ទៅសម្លាប់បក្សពួក**តាំងតុះ**ឯស្រុកក្រុងថ្មីទាំងប្រុសស្រីអស់គ្មានសល់ ហើយរឹបយកទ្រព្យរបស់នាំមកដាក់ឃ្លាំង។ ឯ**លីឈុយ**, **គុយគី**, **តៀវចេ** និង **ហ្វូនតៀវ** ដែល**តាំងតុះ**ឱ្យនៅរក្សាស្រុកក្រុងថ្មី កាលដឹងសេចក្ដីដូច្នោះហើយ ក៏នាំទាហានបីពាន់រត់ទៅនៅស្រុកសៀងសៃ។

កាល**លីប៉ោ**, **លីសុក**, **ហង់ហូកោ** សម្លាប់បក្សពួក**តាំងតុះ**និងមាតាសាច់ញាតិអស់ហើយ **លីប៉ោ**ក៏ចូលទៅយកនាង**តៀវសៀន**មកទុកនឹងខ្លួន។ ឯពួកស្រីប្រាំបីរយនាក់ក៏ចាត់ឱ្យមាតាបិតានាំយកខ្លួនទាំងអស់ទៅវិញ។ បណ្ដារបស់ទ្រព្យទាំងប៉ុន្មានក៏ឱ្យទាហានជញ្ជូនដាក់រទេះ នាំទៅឱ្យ**អងអ៊ុន**ក្នុងទីក្រុង។ **អងអ៊ុន**ក៏យករបស់ទាំងនោះចែករំលែកឱ្យទាហានតាមសមគួរ ហើយប្រជុំអស់នាហ្មឺនមុខមន្ត្រីតូចធំប្រឹក្សាថា “ឥឡូវនេះ សត្រូវរាជសម្បត្តិស្លាប់បាត់អស់ហើយ ផែនដីក៏បានសេចក្ដីសុខក្សេមក្សាន្ត យើងត្រូវបបួលគ្នាលេងឱ្យសប្បាយចុះ” ថាហើយចាត់ចែងរៀបលៀងភោជនាហារនាហ្មឺនទាំងពួង។

ពេលនោះមានបម្រើមកប្រាប់**អងអ៊ុន**ថា មាននាហ្មឺនម្នាក់ឈ្មោះ **ស្ហួយ៉ុង** មកអង្គុយយំស្រណោះខ្មោច**តាំងតុះ**។ **អងអ៊ុន**ខឹងណាស់ឱ្យទាហានទៅចាប់យកខ្លួនមកសួរពិចារណាថា ហេតុអ្វីខ្លួនជានាហ្មឺនក្នុងរាជការមកសោកាអាឡោះអាល័យ**តាំងតុះ**

ក្រែងខ្លួនចូលគំនិតនឹង**តាំងតុះ**ជាសត្រូវរាជសម្បត្តិឬ? **ស្លយ៉ុង**គំនាប់ហើយឆ្លើយថា ខ្ញុំបាទនឹងបានចូលគំនិតដោយគិតខុសដូច្នោះទេ តែបានជាមកយំសោកស្រណោះនោះ ពីព្រោះនឹករឮកដល់គុណ**តាំងតុះ** ដែលបានយកខ្លួនខ្ញុំបាទមកធ្វើជានាហ្មឺនក្នុងរាជការ ទោសខ្ញុំបាទខុសត្រង់នេះ សូមជីវិតនៅឱ្យរស់នឹងបានជួយធ្វើការរក្សាផែនដីតទៅ។ នាហ្មឺនទាំងពួងដែលបានស្គាល់ជា**ស្លយ៉ុង** ទៀងទ្រង់សុចរិត ក៏បបួលគ្នាសុំទោសទាំងអស់។ **ម៉ាយឺត**ឱនខ្សឹប**អងអ៊ុន**ថា **ស្លយ៉ុង**នេះជាមនុស្សសុចរិតពិតត្រង់ណាស់ តម្រិះប្រាជ្ញាក៏មាន មានមនុស្សស្រឡាញ់រាប់អានក៏ច្រើន ទោសដែលល្មើសនោះ បើនឹងសម្លាប់ចេញក៏គួរ តែថាក្រែងបណ្ដារាស្ត្រនឹងមានពាក្យគរហានិន្ទា។ **អងអ៊ុន**តបថា ស្រុកទេសកើតចលាចលទើបនឹងស្ងប់រាបទាបក្នុងថ្ងៃនេះ ព្រះចៅ**ហៀនតេ**ក៏នៅទ្រង់ព្រះកុមារណាស់ ទោះបី**ស្លយ៉ុង**ជាមនុស្សមានសតិបញ្ញាក៏ពិត តែខ្ញុំមិនត្រូវការនឹងយកឱ្យធ្វើជានាហ្មឺនទីប្រឹក្សាយើងបានទេ ដោយហេតុថា បើយើងនឹងបណ្ដោយឱ្យមនុស្សធ្វើល្មើសនឹងព្រះរាជសម្បត្តិហើយ ចេះតែលើកទោសទៅនោះ ច្បាប់សម្រាប់ផែនដីនឹងត្រឡប់ត្រឡិនខូចទៅ។ **ម៉ាយឺត**បានឮដូច្នោះ ក៏ថយចេញទៅហើយនិយាយនឹងនាហ្មឺនទាំងពួងថា ធម្មតាផែនដីនីមួយៗបើមិនរកមនុស្សជាអ្នកមានសតិបញ្ញាទុកទេ ប្រទេសនោះក៏មិនឋិតថេរចេរកាលទៅទៀតបាន។

គ្រានោះ **អងអ៊ុន**បង្គាប់ឱ្យចាប់យកខ្លួន**ស្លយ៉ុង**ទៅដាក់គុក ហើយលបបង្គាប់ឱ្យនាយភូឃុំដាក់ច្រវាក់ខ្នោះឃ្នាបរឹតរួតត្រាតែស្លាប់។ បណ្ដានាហ្មឺនទាំងអស់ដែលបានដឹងថា**ស្លយ៉ុង**ស្លាប់ហើយ ក៏មានសេចក្ដីបរិវេទនាការគ្រប់គ្នា។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៨

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំងពី**លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ** ធ្វើសំបុត្រទៅជម្រាប **អងអ៊ុន** រហូតដល់**តៀវយី**លើកទាហានទៅសម្លាប់**ចូកូ**ជាឪពុក**ចូឆូ**)*

ឯ**លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ**ជាសេនា**តាំងតុះ** ដែលរត់ទៅនៅស្រុកសៀងសៃនោះ ប្រឹក្សាគ្នាធ្វើជាសំបុត្រចាត់បម្រើឲ្យកាន់ចូលមកជម្រាប**អងអ៊ុន** សេចក្ដីថា "យើងខ្ញុំបាទទៅនៅជាពួកបក្ស**តាំងតុះ**នោះ ដោយសេចក្ដីទាល់គំនិត មិនបានគិតយកជាទីពឹងអស់ហើយទេ ទោសយើងទាំងបួននាក់ដែលយើងធ្វើទៅហើយ សូមលោកអភ័យចុះ ឥឡូវនេះយើងខ្ញុំសូមសំអាងខ្លួននឹងចូលមកនៅធ្វើរាជការនឹងលោកតទៅ"។

**អងអ៊ុន**ទទួលសំបុត្រមើលដឹងសេចក្ដីហើយនិយាយនឹងបម្រើថា ដែល**តាំងតុះ**ធ្វើការអាក្រក់ពីព្រោះតែ**លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ** ឥឡូវនេះបើមានព្រះតម្រាស់ឲ្យលើកទោសមនុស្សទាំងអស់បាន យើងត្រូវព្រមតាម តែឯ**លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ**នោះ យើងនឹងទៅសុំអញ្ញាតឲ្យយកខ្លួនមកសម្លាប់ចេញឲ្យបាន។ បម្រើកាន់សំបុត្រក៏លាត្រឡប់ទៅប្រាប់**លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ**តាមពាក្យនោះ។ ឈ្មោះទាំងបួននាក់ប្រឹក្សាគ្នាថា ដែលយើងនឹងទៅចុះចូលនឹង**អងអ៊ុន**នោះ មិនសម្រេចតាមប្រាថ្នាទេ បើដូច្នេះត្រូវតែយើងដោះខ្លួនរៀងខ្លួនឲ្យរួចទៅចុះ។

ឯ**ការសៀង**ជាទីប្រឹក្សាឆ្លើយឡើងថា យើងនឹងគិតរត់ចៀសចេញទៅនោះក៏មិនផុត សុំឲ្យគិតបញ្ចុះបញ្ចូលអ្នកស្រុកសៀងសែបានជាពួកហើយ លើកកងទ័ពទៅវាយយកស្រុកទៀងហាន់វិញ បើបានស្រុកនោះហើយត្រូវតែចាប់សម្លាប់**អងអ៊ុន**ចេញ លោកទាំងប្អូននាក់នឹងបានធ្វើរាជការក្នុងស្រុកក្រុងតទៅ បើគិតដូច្នេះហើយមិនសម្រេចដូចគំនិតទេ សុំនាំគ្នារត់ចៀសចេញទៅចុះ។ **លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ**ស្ដាប់ហើយឃើញត្រូវផង ក៏ទៅចាត់ចែងរើសទាហាន ដែលមានសតិបញ្ញាឲ្យចេញទៅបញ្ចុះបញ្ចូលពួកអ្នកស្រុកសៀងសែថា ឥឡូវនេះ**អងអ៊ុន**បានជាធំក្នុងស្រុកក្រុងហើយ ប៉ងនឹងលើកទាហានមកសម្លាប់អ្នកស្រុកនេះ ដែលជាអ្នកគ្មានកំហុសឲ្យអស់ ដោយឃើញកំហុសដូច្នេះ ទើប**លីឈុយ**, **គុយគី**ឲ្យយើងមកបញ្ចុះបញ្ចូលអ្នកស្រុកនិងក្រៅស្រុកទាំងអស់គ្នា បើអ្នកឯណាស្រឡាញ់ជីវិតខ្លាច**អងអ៊ុន**នឹងសម្លាប់ ត្រូវប្រញាប់ឲ្យចូលមកនឹងយើងទើបរួចភ័យអន្តរាយ។ ឯអ្នកស្រុកសៀងសែកាលបានដឹងសេចក្ដីដូច្នោះ ក៏ភ័យបារម្ភខ្លាចស្លាប់ ទើបនាំគ្នាប្រញាប់ចុះចូលមកជាពួក**លីឈុយ**, **គុយគី**, **តៀវចេ** និង**ហួនតៀវ**លើកទៅជាប្អូនកង លុះទៅដល់កណ្ដាលផ្លូវប្រទះនឹង**ងីវហ៊ូ**ជាកូនប្រសា**តាំងតុះ** លើកទាហានប្រាំរយនឹងចូលទៅសងសឹក**អងអ៊ុន**។ នាយទ័ពទាំងប្អូនកងចាត់ឲ្យ**ងីវហ៊ូ**ជាមេទ័ពស្រួចហើយលើកទៅជិតដល់ស្រុកទៀងហាន់។

ឯ**អងអ៊ុន**កាលបើបានដឹងដំណឹង ជាមានកងទ័ពលើកទៅជិតទីក្រុងហើយ ប្រឹក្សានឹង**លីប៉ោ**ថា ដែល**លីឈុយ**, **គុយគី** លើកទ័ពមកគ្រានេះ តើយើងនឹងគិតការដូចម្ដេច? **លីប៉ោ**តបថា "**លីឈុយ**, **គុយគី**លើកមកនេះ លោកកុំវិតក្កឡើយ ការនេះជាធុរៈលើខ្លួនខ្ញុំ" ហើយឲ្យ**លីសុក**លើកទាហានចេញទៅតទល់។ កាល**លីសុក**លើកទ័ពទៅនោះបានជួបប្រទះនឹងទ័ព**ងីវហ៊ូ** បានតយុទ្ធគ្នាជាមាំមួន។ **ងីវហ៊ូ**ឃើញកម្លាំង

នឹងតទល់ពុំបាន ក៏នាំទាហានថយទ័ពត្រឡប់ទៅក្រោយវិញ។ **លីសុក**ក៏មានចិត្តកំរើបឲ្យទាហានទៅនៅប្រជុំគ្នា មិនបានបំបែកឲ្យត្រួតត្រាតាមរបៀបទ័ព។ **ងីវហ៊្វ**ឃើញ**លីសុក**ប្រហែសការ ដល់ពេលយប់យាមពីរក៏លើកទាហានវាយបំបែកទ័ព**លីសុក** សម្លាប់ទាហានបានជាច្រើន។ **លីសុក**ក៏រត់រួចទៅបាន ទើបនាំយកសេចក្ដីដែលបានធ្វើសង្គ្រាមនោះប្ដឹងចូលទៅដល់**លីប៉ោ** ៗដឹងហើយខឹងណាស់ ក៏បង្គាប់ឲ្យយកខ្លួន**លីសុក**ចូលទៅកាត់ក្បាលដោតនៅមាត់ទ្វារស្រុក។

លុះវេលាព្រឹកឡើង **លីប៉ោ**លើកទាហានទៅតយុទ្ធនឹង**ងីវហ៊្វ** ៗបែកទ័ពត្រឡប់រត់រួចទៅ។ **ងីវហ៊្វ**ក៏ប្រឹក្សានឹង**អៅសុកយី**ថា **លីប៉ោ**នេះមានកម្លាំងខ្លាំងពូកែណាស់ យើងតស៊ូនឹងគេពុំបានទេ បើដូច្នេះត្រូវតែគិតរត់ទៅទៀត។ **អៅសុកយី**បានស្ដាប់ហើយក៏យល់ព្រមផង ដល់ពេលអាធ្រាត្រស្ងាត់ **ងីវហ៊្វ**រៀបប្រមូលយកទ្រព្យរបស់ផងខ្លួនដែលមានតម្លៃហើយនាំ**អៅសុកយី** និងទាហានដែលស្និទ្ធប្អូនប្រាំនាក់រត់ទៅដល់មាត់ស្ទឹង។ **អៅសុកយី**ប្រែចិត្តក្បត់សម្លាប់**ងីវហ៊្វ**ស្លាប់ ហើយយកទ្រព្យរបស់ទាំងអស់នោះ នាំពួកទាហានប្អូនប្រាំនាក់និងក្បាល**ងីវហ៊្វ**ទៅឲ្យ**លីប៉ោ**ក្នុងក្រុងទៀតហាន់។ **លីប៉ោ**ឃើញដូច្នោះក៏នឹកសង្ស័យនឹង**អៅសុកយី**ណាស់ ក៏លបសួរមនុស្សដែលទៅជាមួយថា កើតហេតុទាស់ទែងគ្នាដូចម្ដេចបានជា**អៅសុកយី**សម្លាប់**ងីវហ៊្វ**? មនុស្សពួកនោះឆ្លើយឲ្យការតាមដំណើរសព្វគ្រប់។ **លីប៉ោ**បានស្ដាប់ហើយក៏ខឹងណាស់ថា “**អៅសុកយី**ជាមនុស្សលោភ មិនមានសេចក្ដីសុចរិតពិតត្រង់ នឹងចិញ្ចឹមទុកជាគ្នាក៏ពុំបាន” ទើបបង្គាប់ឲ្យទាហានចាប់**អៅសុកយី**នាំទៅសម្លាប់។ ឯ**លីប៉ោ**ចាត់ចែងទាហានកងទ័ពលើកទៅប្រទះនឹងទ័ព**លីឈុយ, គុយគី, តៀវចេ** និង**ហ្វួនតៀវ** ក៏បរសេះនាំពលទាហានចូលច្បាំងតគ្នា។ កងទ័ព**លីឈុយ, គុយគី, តៀវចេ** និង**ហ្វួនតៀវ**មិនទាន់បានត្រៀមខ្លួនក៏បែកខ្ចាត់ខ្ចាយអស់ទៅ រត់តាមផ្លូវប្រហែលប្រាំ

រយសិន (២០ គ.ម) ដល់ភ្នំមួយក៏បង្គាប់ឲ្យកបន្ទាយយ៉ាងមាំមួននៅទីនោះ **លីឈុយ** ទើបប្រឹក្សានឹង**គុយគី**, **តៀវចេ** និង**ហួនតៀវ**ថា "**លីប៉ោ**នោះមានថ្វីដៃខ្លាំងពូកែណាស់ តែជាអ្នកមិនមានតម្រិះប្រាជ្ញាឆ្លាត យើងនឹងគិតឧបាយឲ្យ**គុយគី**ឃុំទាហានទៅចាំស្កាត់ផ្លូវដែលនឹងចូលទៅក្នុងស្រុក បើកាលណាឃើញទ័ព**លីប៉ោ**យើងត្រូវតយុទ្ធជាកលបញ្ឆោត បើបានឮសំឡេងគងឃ្មោះវេលាណាឲ្យបរពលចូលច្បាំង បើឮសំឡេងស្គរឡើងទៀតឲ្យថយទាហានទៅក្រោយ ឯ**តៀវចេ**, **ហួនតៀវ**ឲ្យលើកទាហានបំបែកគ្នាទៅវាយទម្លាយស្រុកទៀងហាន់ជាពីរផ្លូវ បើធ្វើដូច្នេះឃើញថា **លីប៉ោ**នោះនឹងច្បាំងតទល់មុខក្រោយមិនទាន់ការ នឹងខូចអសារដល់ពួកយើងជាប្រាកដ។ **គុយគី**, **តៀវចេ** និង**ហួនតៀវ**យល់ឃើញត្រូវ ក៏លើកទាហានចេញទៅតាមពាក្យ**លីឈុយ**។

គ្រានោះ **លីប៉ោ**លើកទ័ពទៅដល់ប្រហាកច្រកភ្នំប្រទះនឹងកងទ័ព**លីឈុយ**ចូលប្រយុទ្ធគ្នាជាកោលាហល។ **លីឈុយ**ឲ្យវាយស្គររាថយទ័ពត្រឡប់ឡើងទៅលើភ្នំ **លីប៉ោ**បង្ខំដេញចូលទៅ ស្រាប់តែទាហាន**លីឈុយ**បាញ់ធ្នូចោលដុំថ្មទម្លាក់ចុះមកដូចគ្រាប់ភ្លៀង **លីប៉ោ**ក៏ឲ្យទាហានថយមកក្រោយវិញ។

ឯទ័ព**គុយគី**ដែលនៅពីក្រោយបានឃើញដូច្នោះ ឲ្យវាយគងឃ្មោះលើកទាហានបង្រុះចូលទៅទៀត **លីប៉ោ**ឲ្យប្រែមុខទ័ពត្រឡប់មកតទល់ **គុយគី**វាយស្គរពីលើភ្នំហើយនាំទាហានចុះមកវិញ ដេញទាហានឲ្យវាយពីខាងក្រោយបណ្ដោយទៅ ទ័ព**លីប៉ោ**ក៏នៅជាកណ្ដាល។ តាំងពីកងទ័ព**លីឈុយ**, **គុយគី**ខ្ទប់ទ័ព**លីប៉ោ**នៅទីនោះចំនួនបីថ្ងៃ។ **លីប៉ោ**ក៏បែរតទល់ទាំងមុខទាំងក្រោយវិលនៅជុំវិញ មិនដឹងជានឹងវាយទម្លុះទៅខាងណាបាន ទទួលមានបម្រើសេះចេះជ្រៀតជ្រែកដែងចូលទៅប្រាប់ **លីប៉ោ**ថា ឥឡូវមានកងទ័ព**តៀវចេ** និង**ហួនតៀវ**លើកចូលទៅច្បាំងទម្លាយយកទី

ក្រុងទៀងហាន់ ហើយសុំឲ្យ**លីប៉ោ**លើកទ័ពទៅជួយជាប្រញាប់។ **លីប៉ោ**គិតនឹងទៅជួយខាងស្រុកក្រុង ទើបឃុំនាំទាហានស្ទុះបំពានវាយទម្លាយចេញទៅបាន។ ឯ**លីឈុយ, គុយគី**លើកទ័ពតាមទៅទៀត **លីប៉ោ**មិនបានញញើតដៃសោះ បែរមកតទល់ទ័ពទាំងអស់ពីក្រោយហើយស្រូតទៅមុខ លុះទៅដល់ជិតស្រុកក្រុងឃើញទាហាន**តៀវចេ** និង**ហួនតៀវ**ឡោមព័ទ្ធ ឯ**លីប៉ោ**នោះមិញចូលទៅប្រយុទ្ធឥតរួញរា តែថាទាហាន**លីប៉ោ**វិនាសស្លាប់ជាច្រើនណាស់ ខ្លះរត់ចូលទៅនៅខាងកងទ័ព**តៀវចេ, ហួនតៀវ**ជាច្រើន។ **លីប៉ោ**ឃើញដូច្នោះនឹកតូចចិត្តណាស់ ទើបនាំទាហានដែលសល់នៅវិលវល់ក្នុងចំណោមទ័ពគ្រប់ពីរបីថ្ងៃ។

ឯ**លីបង, អងហាង**ទាំងពីរនាក់ជាបក្សពួក**តាំងតុះ**នៅស្រុកក្រុងទៀងហាន់កំណាន់ចិត្តគិតស្អប់**អងអ៊ុន**ណាស់ គិតឧបាយជាកលសឹកលើកទាហានរបស់ខ្លួនទៅពួនបើកមាត់ទ្វារទាំងបួនទិស ទទួលយកកងទ័ព**លីឈុយ, គុយគី, តៀវចេ** និង**ហួនតៀវ**ឲ្យចូលទៅបាន។ **លីប៉ោ**ក៏ស្ទុះបំពានល្បឿនទៅមុខតាំងតែចាក់កាប់សម្លាប់កងទ័ព**លីឈុយ, គុយគី**ស្លាប់ពិការជាច្រើនណាស់ ហើយត្រឡប់លើកទាហានរបស់ខ្លួនប្រហែលមួយរយប្លាយ ពារទម្លាយចូលទៅដល់ទ្វារព្រះរាជវាំង ជួបនឹង**អងអ៊ុន** ហើយនិយាយថា សង្គ្រាមម្តងនេះធំលើសលុបពេកណាស់ បើយើងនឹងនៅតទល់នោះ ឃើញលើសហួសកម្លាំង សូមលោកស្រូតប្រញាប់ឡើងសេះរត់ឲ្យរួចតែខ្លួនទៅសិនចុះ ក្រោយពីនោះសឹមគិតការតទៅ។

**អងអ៊ុន**តបថា ពីដើមខ្ញុំនិងអ្នកគិតគ្នានឹងទំនុកបម្រុងផែនដីឲ្យបានសេចក្តីសុខក្សេមក្សាន្ត សេចក្តីដែលគិតនោះបានសមដូចប្រាថ្នាហើយ តែឥឡូវកើតហេតុឡើងទៀតព្រោះពួក**តាំងតុះ** ដែលយើងនឹងលះបង់ចោលស្រុកក្រុងរត់យករួចតែខ្លួននោះមិនគួរសោះ ទោះនឹងស្លាប់ក៏គួរយកសេចក្តីត្រូវទុកជាខាងមុខ ចំណែកលោក

បើនឹងទៅក៏ទៅចុះ តែត្រូវជួយយកសេចក្តីទៅប្រមាណប្រាប់ដល់បណ្តាចៅហ្វាយខេត្តខាងក្រៅថា យើងសូមគំនាប់មក ដ្បិតសម័យនេះកើតហេតុក្នុងស្រុកក្រុងជាចលាចល ឱ្យចៅហ្វាយខេត្តទាំងអស់យកចិត្តទុកដាក់ជួយទំនុកបម្រុងផែនដី លើកកងទ័ពមកជួយកម្ចាត់សត្រូវរាជសម្បត្តិឱ្យអស់ចេញ។ **លីប៉ោ**បានឮដូច្នោះ ក៏និយាយបញ្ចុះបញ្ចូលបបួល**អងអ៊ុន**ជាច្រើនដង **អងអ៊ុន**ក៏មិនព្រមទៅ ទទួលក្រឡេកឃើញពន្លឺភ្លើងឆេះឡើងគ្រប់តំបន់ដែលសត្រូវចូលទៅដុត **លីប៉ោ**ភ័យរន្ធត់រត់ចោលអស់គ្រួសារ ឡើងជិះសេះនាំសេនាទាហានប្រហែលមួយរយប្លាយចេញទៅដល់**អ្នូនសុត** នៅស្រុកឡាំយ៉ុង ឯ**អងអ៊ុន**ក៏ចូលទៅក្នុងព្រះរាជវាំង។

ខណៈនោះ **លីឈុយ, គុយគី, តៀវចេ, ហ្វូនតៀវ** ដែលហែកទ្វារស្រុកចូលទៅក្នុងទីក្រុងនោះ កាប់សម្លាប់នាហ្មឺនមុខមន្ត្រីនូវអាណាប្រជានុរាស្ត្ររបួសពិការស្លាប់ជាច្រើន ហើយលើកទាហានចូលទៅក្នុងព្រះរាជវាំង ។ ខន្ទីទាំងពួងឃើញដូច្នោះ ស្ទុះចូលទៅអញ្ជើញស្តេចព្រះចៅ**ហៀនតេ** និង**អងអ៊ុន** ឡើងទៅគង់លើដំណាក់ថ្នាក់លើ។ **លីឈុយ, គុយគី** និងសេនាទាហានទាំងពួង ក៏ឱនគំនាប់ថ្វាយបង្គំពីខាងក្រោមទៅ។ ព្រះចៅ**ហៀនតេ**ទតព្រះនេត្រមកឃើញហើយ មានព្រះតម្រាស់ត្រាស់សួថា ដែលខ្លួនបង្អាចពុំខ្លាចព្រះចេស្តា លើកសេនាទាហានពានព្រះរាជវាំងចូលមកនេះ នឹងប្រាថ្នារបស់អ្វី? **លីឈុយ, គុយគី**ក្រាបទូលថា ទូលព្រះបង្គំទាំងឡាយ ធ្វើការទាំងនេះនឹងបានគិតក្បត់ព្រះអង្គក៏ទេ កាលពីដើម**តាំងតុះ**ជាមហាឧបរាជបានទំនុកបម្រុងផែនដី ថ្វាយព្រះករុណាជាសុខរៀងមក តែ**អងអ៊ុន** និង**លីប៉ោ**គប់គិតគ្នាសម្លាប់មហាឧបរាជចេញដោយអំណាចចិត្ត ទូលព្រះបង្គំជាខ្ញុំឈឺចិត្តណាស់ ចូលមកនេះប្រាថ្នានឹងសម្លាប់**អងអ៊ុន**ចេញឱ្យអស់កំហឹង បើព្រះអង្គទ្រង់ព្រះមេត្តាប្រគល់ខ្លួន**អងអ៊ុន**ឱ្យហើយ ទូលព្រះបង្គំជាខ្ញុំនឹងនាំទាហានចេញទៅ។

**អងអ៊ុន**បានស្តាប់ក៏ក្រាបទូលព្រះចៅ**ហៀនតេ**ថា “ទូលព្រះបង្គំជាខ្ញុំមានសេចក្តីពិតត្រង់នឹងផែនដីជាប្រាកដ ទើបសម្លាប់**តាំងតុះ**ដែលក្បត់នឹងព្រះករុណានោះចេញ ឥឡូវ**លីឈុយ, គុយគី**គិតចង់សម្លាប់ទូលព្រះបង្គំជាខ្ញុំវិញ។ បើទូលព្រះបង្គំជាខ្ញុំនៅស្រឡាញ់ជីវិតគិតតែជ្រកពួនដូច្នេះ នឹងកើតអន្តរាយក្នុងព្រះរាជឋានច្រើនឡើងទៀត ហេតុនេះសូមយកជីវិតទៅឲ្យ**លីឈុយ, គុយគី**សម្លាប់ចេញចុះ ចំពោះជាទីតបស្នងឆ្លងព្រះតេជព្រះគុណព្រះករុណា” ថាហើយក៏លោតចុះទៅតាមផ្លូវជើងជណ្តើរព្រះដំណាក់ស្រែកថា “ខ្លួនអញនៅឯណេះ ឯងនឹងចង់ធ្វើប្រការម្តេចក៏ធ្វើឲ្យស្រេចទៅចុះ”។ **លីឈុយ, គុយគី**ឆ្លើយថា មហាឧបរាជមានទោសកំហុសពីព្រោះអ្វី បានជាឯងគប់គិតចូលគំនិតនឹង**លីប៉ោ**សម្លាប់ចេញ? **អងអ៊ុន**តបថា **តាំងតុះ**ជាសត្រូវរាជសម្បត្តិ ធ្វើការអាក្រក់នឹងរាជសម្បត្តិច្រើនណាស់ បានជាអញសម្លាប់វាចេញ នាហ្មឺននិងបណ្តារាស្ត្រទាំងអស់មានសេចក្តីត្រេកអរ ហេតុម្តេចឯងមានចិត្តគំនុំគុំគួនជួសពួកអាក្បត់នោះ?

**លីឈុយ, គុយគី**តបថា មហាឧបរាជប្រព្រឹត្តបទកំហុស ឯងក៏ចុះទោសប្រហារជីវិតទៅហើយ តែយើងទាំងបួននាក់មានសំបុត្រមកអង្វរលន់តួខ្លួនសុំចូលមកធ្វើការជាមួយវិញ ហេតុអ្វីខ្លួនមិនព្រមលើកទោសសន្តោសប្រណី ត្រឡប់មានសេចក្តីព្យាបាទឲ្យចាប់យើងសម្លាប់ទៀត តើយើងខុសព្រោះហេតុអ្វី? **អងអ៊ុន**ស្រែកគំហកថា ដែលអញមិនទទួលយកឯងទាំងបួននាក់ទុកធ្វើរាជការផងនោះ ព្រោះឯងជាបក្សពួកអាក្បត់ផែនដី អញក្រែងឯងធ្វើបំភ្លាត់ឲ្យអន្តរាយផែនដីទៀត ឥឡូវឯងប្រាថ្នាចង់ធ្វើអ្វីក៏ធ្វើឆាប់ទៅចុះ អញមិនមែនខ្លាចស្លាប់ទេ។ **លីឈុយ, គុយគី**ខឹងខ្លាំងណាស់ ក៏ហ្វូតគ្រប៊ីកាប់**អងអ៊ុន**ស្លាប់ ហើយឲ្យទាហានទៅចាប់ភរិយាបុត្រញាតិសន្តានសម្លាប់អស់ទៅទៀត។ ឯអាណាប្រជានុរាស្ត្រក្នុងស្រុកក្រុងវេលានោះ

លុះដឹងថា**អងអ៊ុន**ស្លាប់ហើយ ទើបនាំគ្នាទួញយំដំឱរាដោយសារអាល័យស្រឡាញ់**អងអ៊ុន**ពន់ប្រមាណណាស់។

**លីឈុយ, គុយគី**គិតគ្នាថា យើងធ្វើការចូលមកដល់ទីនេះហើយ នឹងលះបង់ទៅវិញមិនបានទេ ត្រូវតែគិតយករាជសម្បត្តិហើយសម្លាប់ព្រះចៅ**ហៀនតេ**ចេញទើបស្រួល។ **តៀវចេ, ហ្សួនតៀវ**ឃាត់ថា លោកនឹងធ្វើឲ្យចលាចលដល់ព្រះចៅ**ហៀនតេ**នោះ យើងមិនបានយល់ព្រមផងទេ ព្រោះចៅហ្វាយខេត្តៗក្រៅទាំងអស់ និងអាណាប្រជានុរាស្ត្រមិនមែនចូលចិត្តនឹងឲ្យធ្វើដូច្នេះឡើយ បើយើងធ្វើហើយគង់នឹងលើកកងទ័ពពីគ្រប់តំបន់ ចូលមកតតាំងច្បាំងនឹងយើងយ៉ាងអធិកអធមមិនខាន យើងមុខជានឹងរកទីបង្អែកទប់ទល់ពុំបាន។ បើដូច្នេះត្រូវតែយើងបបួលគ្នាក្រាបសំពះគាល់ព្រះចៅ**ហៀនតេ** ទូលសុំធ្វើរាជការជានាហ្មឺនធំក្នុងក្រុង នឹងបានគិតអែបព្រះតម្រាស់ឲ្យហៅចៅហ្វាយខេត្តចូលមក ហើយកាប់សម្លាប់ចេញ រាជសម្បត្តិគង់នឹងបានមកយើងដោយងាយ។ **លីឈុយ, គុយគី**លុះបានស្តាប់ហើយឃើញថាត្រូវ ទើបនាំ**តៀវចេ, ហ្សួនតៀវ**ចូលទៅគាល់។

ព្រះចៅ**ហៀនតេ**ទ្រង់ត្រាស់សួរ**លីឈុយ, គុយគី**ថា ពីថ្ងៃមុនខ្លួនប្រាប់យើងថា នឹងសុំយកខ្លួន**អងអ៊ុន** បើបានហើយនឹងត្រឡប់លើកទ័ពទៅវិញ ឥឡូវខ្លួនសម្លាប់**អងអ៊ុន**បានហើយ ហេតុម្តេចមិញទើបមិនលើកទ័ពចេញទៅ ឯងចង់នៅប្រាថ្នាអ្វីទៀត? **លីឈុយ, គុយគី**ក្រាបទូលថា កាលពីថ្ងៃមុនទូលព្រះបង្គំជាខ្ញុំបានធ្វើរាជការមានបំណាច់នឿយហត់ក្នុងផែនដីព្រះករុណា តែមិនមាននរណានឹងពិតទូលព្រះអង្គឲ្យទ្រង់ជ្រាប ទើបព្រះអង្គមិនប្រទានយសស័ក្តិដល់យើងខ្ញុំ។ ឥឡូវនេះ យើងខ្ញុំទាំងបួននាក់ សូមចូលមកស្វាមីភក្តិធ្វើរាជការជានាហ្មឺនក្រោមល្អងធូលីព្រះបាទ។ បើ

ព្រះអង្គទ្រង់ព្រះរាជានុញ្ញាតប្រោសព្រះរាជទានតាមប្រាថ្នាហើយ ទូលព្រះបង្គំជាខ្ញុំនឹងលើកទាហានចេញពីព្រះរាជវាំងទៅវិញ។

ព្រះចៅ**ហៀនតេ**មានព្រះរាជឱង្ការត្រាស់ថា ដែលខ្លួនទាំងបួននាក់ចូលចិត្តចង់ធ្វើនាហ្មឺននោះ តើចង់ធ្វើតំណែងអ្វីឲ្យថាមកចុះ? **លីឈ្មុយ**, **គុយគី**, **តៀវចេ**, **ហ្វួនតៀវ**ប្រឹក្សាគ្នាហើយ ទើបសរសេរសំបុត្រថ្វាយព្រះចៅ**ហៀនតេ** ៗទតឃើញសេចក្ដីសំបុត្រនោះថា **លីឈ្មុយ**សុំជាទី "គីចុងគុន" គឺសុំជានាយទាហានធំខាងក្នុង ហើយជាអ្នកសម្រេចរាជការផង។ **គុយគី**សុំជាទី "ហាចុងគុន" គឺជានាយទាហានធំខាងក្រោយ ហើយជាទីចាងហ្វាយនាហ្មឺនទាំងពួងផង **តៀវច** និង**ហ្វួនតៀវ**ជានាយទាហានឆ្វេងស្ដាំ។ ព្រះចៅ**ហៀនតេ**ក៏ទ្រង់ប្រោសប្រទានតាមសុំ។ ឯ**លីឈ្មុយ**, **គុយគី** លុះបានទទួលតម្រាស់ហើយ ក៏ចេញមកនៅក្រៅព្រះរាជវាំង ទើបប្រឹក្សាគ្នាថា "ស្រុកហាងឡុងនេះ ជាស្រុកមុខគយ នឹងទុកចិត្តដល់ពួកសត្រូវមិនបាន" ទើបចាត់ឲ្យ**តៀវចេ** និង**ហ្វួនតៀវ** លើកទាហានទៅនៅរក្សា។ ឯ**លីបង** និង**អងហាង**ដែលបើកទ្វារស្រុកឲ្យកងទ័ពចូលទៅនោះ ក៏តាំងឲ្យឡើងជាទីនាហ្មឺនតាមតំណែងក្នុងរាជការ បណ្ដាទាហានដែលមានសតិបញ្ញា ក៏តាំងឡើងជានាហ្មឺនទាំងអស់ ហើយឲ្យទាហានទៅស៊ើបពិនិត្យរើសយកឆ្អឹង**តាំងតុះ** មកតែងការសពរបៀបមហាឧបរាជ ហើយឲ្យហែចេញទៅនិងកប់សពទុកតាមទំនៀម។ ក្នុងខណៈកំពុងរៀបបញ្ចុះសពនោះ ក៏បណ្ដាលឲ្យកើតខ្យល់ព្យុះសង្ឃរាជាខ្លាំងណាស់ កើតជាផ្គររន្ទះ ភ្លៀងធ្លាក់ទឹកជោរជន់លិចផែនដីជម្រៅប្រហែលពីរហត្ថ ហើយថែមទាំងមានរន្ទះបាញ់ច្រស់លើសព ឯឆ្អឹងដែលកាប់ខ្ទាតខ្ទាត់ចេញអស់ លុះភ្លៀងស្ងប់ហើយ **លីឈ្មុយ**ក៏ឲ្យរើសមកបញ្ចុះទៀតជាច្រើនគ្រា ភ្លៀងក៏បង្អុរចុះមកលិចផែនដី អសនីរន្ទះក៏បាញ់ច្រស់ឆ្អឹង**តាំងតុះ**នោះ ទាល់តែខ្ទេចខ្ទីជាធូលីអស់ទៅ នឹងរើសយកមកទៀតពុំបាន។ ដែល

កើតហេតុទាំងនេះ ព្រោះ**តាំងតុះ**ធ្វើអាក្រក់ក្បត់ផែនដី សម្លាប់មនុស្សប្រុសនិងស្រីជាច្រើនណាស់។ **លីឈុយ**, **គុយគី**អស់តម្រិះប្រាជ្ញា ក៏នាំគ្នាត្រឡប់ចូលទៅក្រុងវិញ។ តាំងពីនោះមក **លីឈុយ**, **គុយគី** រឹតតែធ្វើការកំរើបតាមអំពើចិត្ត អាណាប្រជានុរាស្ត្រក៏មានសេចក្តីក្តៅក្រហាយខ្លាំង។ **លីឈុយ**, **គុយគី**យកមាសប្រាក់ទៅសូកចិត្តខន្ទីដែលរក្សាព្រះចៅ**ហៀនតេ**ហើយផ្តាំថា បើឮព្រះចៅ**ហៀនតេ**ត្រាស់ពីសេចក្តីល្អអាក្រក់ប្រការម្តេច សុំឲ្យនាំសេចក្តីនោះទៅប្រាប់ឲ្យដឹងផង។

ក្នុងសម័យនោះ ព្រះចៅ**ហៀនតេ**នៅជាព្រះកុមារណាស់ នឹងត្រាស់បង្គាប់ការអ្វីជាផ្លូវរាជការក៏ពុំស្រេចដាច់សោះ រាជការផែនដីក៏ត្រឡប់ត្រឡិនភ័ន្តប្រែទៅ បណ្តានាហ្មឺនមុខមន្ត្រីក្នុងក្រុង ក៏សឹងនៅក្រោមបង្គាប់បញ្ជា**លីឈុយ**, **គុយគី**ទាំងអស់។ ឯ**លីឈុយ**, **គុយគី**ក៏ឲ្យយក**ជូហ៊ី** ដែលជានាហ្មឺនរាជការនោះ មកតាំងជានាហ្មឺនក្នុងរាជការជាទីប្រឹក្សាវិញ។

ចំណែក**ម៉ាថេង**ចៅហ្វាយស្រុកសេលៀង និង**ហាន់ស៊ុយ**ចៅហ្វាយស្រុកប៉េងជីវប្រឹក្សាគ្នាថា “ឥឡូវនេះ **លីឈុយ** និង**គុយគី**បានជានាហ្មឺនធំក្នុងស្រុកក្រុង ធ្វើការទុច្ចរិតប្រព្រឹត្តអាក្រក់ដូចគ្រាតាំងតុះ បើដូច្នោះចាំយើងនឹងកម្ចាត់វាចេញ ទើបនឹងបានសេចក្តីសុខតទៅ” គិតហើយក៏ធ្វើសំបុត្រមួយច្បាប់ទៅដល់**ម៉ាហ៊្វ** មួយច្បាប់ទៅដល់**តុងសៀង** មួយច្បាប់ទៅដល់**ឡៅឈៀវ** អ្នកទាំងបីនេះជានាហ្មឺនខ្ញុំរាជការចាស់នៅក្នុងក្រុង។ សេចក្តីសំបុត្រនោះថា “**លីឈុយ**, **គុយគី** ធ្វើការទុច្ចរិតប្រព្រឹត្តអំពើអាក្រក់ សព្វថ្ងៃអាណាប្រជានុរាស្ត្រខេត្តក្រៅក្តៅក្រហាយដូចគ្រា**តាំងតុះ** បើដូច្នេះសុំឲ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ឲ្យទ្រង់ជ្រាបថា យើងនឹងលើកកងទ័ពមកព័ទ្ធចាប់**លីឈុយ**, **គុយគី**សម្លាប់ចេញ ឯអ្នកទាំងបីក៏ត្រូវនៅគិតការខាងក្នុងឲ្យមាំមួនចុះ”។

ឯ**ម៉ាហ៊ូ, តុងសៀវ, ឡៅឈៀវ** លុះបានដឹងសេចក្តីក្នុងសំបុត្រនោះហើយ ទើបចូលទៅក្រាបបង្គំទូលព្រះចៅ**ហៀនតេ** ៗទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ទ្រង់ត្រាស់យកក្រដាសទឹកខ្មៅ មកទ្រង់ព្រះសុភអក្សរជាសេចក្តីថា “ដែល**ម៉ាថេង**និង**ហាន់ស៊ុយ**គិតការដូច្នោះ យើងត្រេកអរណាស់ បើបានសម្រេចដូចសេចក្តីប្រាថ្នាហើយ យើងនឹងតាំងឲ្យធ្វើជានាហ្មឺនធំតទៅ” ស្រេចហើយប្រគល់ឲ្យបម្រើ**ម៉ាថេង, ហាន់ស៊ុយ**កាន់ត្រឡប់មកវិញ។

**ម៉ាថេង, ហាន់ស៊ុយ**ទទួលសុភអក្សរលាមើលឃើញព្រះហត្ថលេខា ក៏មានសេចក្តីត្រេកអរណាស់ ទើបរៀបចាត់ចែងកេណ្ឌទាហានទាំងពីរខេត្តបានប្រមាណដប់មួយដប់ពីរម៉ឺន លើកទៅដាក់កណ្តាលផ្លូវ ហើយឲ្យទាហានស្រែកប្រកាសប្រាប់បណ្តារាស្ត្រគ្រប់ភូមិស្រុកថា យើងលើកទ័ពមកនេះ ដើម្បីនឹងធ្វើការកម្ចាត់សត្រូវរាជសម្បត្តិចេញ។

បម្រើសេះបានឮច្បាស់ ក៏នាំសេចក្តីនោះទៅប្រាប់**គុយគី** ៗឲ្យរក**តៀវចេ, ហួនតៀវ**មកប្រឹក្សាថា **ម៉ាថេង, ហាន់ស៊ុយ**លើកទ័ពមកនេះយើងនឹងគិតប្រការណា? **កាសៀង**ទីប្រឹក្សាតបថា **ម៉ាថេង, ហាន់ស៊ុយ**លើកទ័ពមកនេះអស់រយៈផ្លូវឆ្ងាយដាច់ស្រយាលណាស់ យើងត្រូវរក្សានាទីទុកឲ្យគេឡោមព័ទដល់ជើងកំពែងចុះ បើកាលណាខាងគេដាច់ស្បៀងអាហារហើយ សឹមយើងលើកទាហានចេញទៅវាយទម្លាយកងទ័ព យើងនឹងចាប់**ម៉ាថេង** និង**ហាន់ស៊ុយ**បានដោយងាយ។ **លីបង** និង**អងហាង**ឆ្លើយថា ដែល**កាសៀង**ថានោះ ខ្ញុំមិនយល់ផងសោះ ខ្ញុំសុំទាហានមួយម៉ឺនលើកទៅចាប់**ម៉ាថេង** និង**ហាន់ស៊ុយ** កាត់យកក្បាលជូនលោកឲ្យបាន។ **កាសៀង**តបថា នឹងឲ្យ**លីបង, អងហាង**លើកទ័ពទៅនោះ មុខជានឹងចាញ់ប្រៀបគេជាប្រាកដ។ **លីបង, អងហាង**ឆ្លើយថា បើយើងចេញទៅហើយមិនបានក្បាល**ម៉ាថេង** និង**ហាន់ស៊ុយ**

មកជូនទេ អ្នកចូរកាត់ក្បាលយើងជាជំនួសចុះ បើយើងបានក្បាលយនាយទ័ពទាំងពីរចូលមក អ្នកចូលកាត់ក្បាលអ្នកឲ្យយើងវិញ។

**កាសៀង**ជម្រាបទៅ**លីឈុយ** និង**គុយគី**ថា បើ**លីបង** និង**អងហាង**សុំយកអាសាចេញទៅច្បាំងក៏ឲ្យទៅចុះ តែភ្នំចៀវចិតនោះ ចម្ងាយផ្លូវពីស្រុកក្រុងនេះប្រហែលពីរពាន់សិន ពីខាងលិចមានតែផ្លូវចំពោះដើរបានច្រកភ្នំចង្អៀតណាស់ បើដូច្នេះសុំឲ្យ**តៀវចេ** និង**ហួនតៀវ**លើកទាហានទៅបង្កប់នៅតំបន់នោះឲ្យច្រើន បើកាលណា**លីបង** និង**អងហាង**ចាញ់ប្រៀបគេថយមកប្រការម្តេចក៏នឹងបានជួយគ្នា។

**លីឈុយ, គុយគី**ឆ្លើយថា "ដែលនឹងឲ្យ**តៀវចេ, ហួនតៀវ**លើកទាហានទៅតាំងនៅច្រកភ្នំនោះ យើងមិនយល់ព្រមផងទេ" ហើយប្រគល់ទាហានមួយម៉ឺនប្រាំពាន់ឲ្យ**លីបង** និង**អងហាង** លើកចេញទៅតាមផ្លូវប្រហែលពីរពាន់សិន (៨0 គ.ម) ទទួលជួបកងទ័ព**ម៉ាថេង** និង**ហាន់ស៊ុយ**លើកមកប្រទល់គ្នានៅទីនោះ ។ លុះព្រឹកឡើងនាយទ័ពទាំងសងខាងបញ្ចេញទាហានមកខាងក្រៅបន្ទាយ **ម៉ាថេង** និង**ហាន់ស៊ុយ**ស្រែកថា **អាលីបង, អាអងហាង** ជាសត្រូវរាជសម្បត្តិ នរណានឹងទទួលអាសាចេញទៅចាប់វាឲ្យយើងបាន? **ម៉ាឈៀវ**ជាកូន**ម៉ាថេង**អាយុដប់ប្រាំបីឆ្នាំ សម្បុរមុខដូចពណ៌ថ្មយក់ កិរិយារហ័សរហួនកាន់ទួនជិះសេះ បំពារទាហានចេញទៅទទួលយកអាសា។ **អងហាង**ឃើញ**ម៉ាឈៀវ**នៅក្មេងណាស់ ក៏មើលងាយមិនសូវប្រយ័ត្ន ឡើងសេះរំដាវចេញមកតយុទ្ធនឹង**ម៉ាឈៀវ**បានប្រាំស្នៀត **ម៉ាឈៀវ**យកទួនចាក់**អងហាង**ធ្លាក់ពីលើសេះស្លាប់ ហើយ**ម៉ាឈៀវ**កន្ត្រាក់សេះប្រុងនឹងត្រឡប់មកវិញ **លីបង**ខឹងណាស់ក៏បរសេះរំដាវចេញកាប់**ម៉ាឈៀវ**ពីក្រោយ **ម៉ាឈៀវ**ក្រឡេកមើលធ្វើជាមិនឃើញ **ម៉ាថេង**ស្រែកប្រាប់**ម៉ាឈៀវ**ថា "សត្រូវតាមពីក្រោយមកជិតហើយឲ្យប្រយ័ត្ន" **លីបង**ដេញជិតជិតនឹងទាន់យកដាវកាប់**ម៉ាឈៀវ** ៗរងជាប់

ត្រឡប់ញាក់សេះបែរទៅវិញ លោតចាប់**លីបង**បាន ក៏នាំមកជូន**ម៉ាថេង**ជាបិតា បណ្ដាទាហាន**ម៉ាថេង**ទាំងប៉ុន្មានបានចំណាប់ ក៏ព្រួតគ្នាដេញកាប់ទាហាន**លីបង** ស្លាប់ជាច្រើន។ **ម៉ាថេងនិងហាន់ស៊ុយ** ក៏លើកទាហានចូលទៅតាំងបន្ទាយនៅជិត កំពែងស្រុកទៀងហាន់ ហើយឲ្យយក**លីបង**ទៅសម្លាប់កាត់ក្បាលដោតទុកនៅមុខ បន្ទាយ។

បម្រើសេះចូលទៅប្រាប់**លីឈុយ, គុយគី**ថា **លីបង** និង**អងហាង**បរាជ័យ ក្ស័យទាំងពីរនាក់ទៅហើយ។ **លីឈុយ, គុយគី**ប្រឹក្សាគ្នាថា **កាសៀង**ថានោះត្រូវ ណាស់ យើងមិនធ្វើតាមពាក្យគាត់បានជាខូចខាតទាហាន់អស់ទៅដូច្នេះ។ តាំងពី នោះមក **លីឈុយ, គុយគី**ក៏សរសើរជឿស្រឡាញ់**កាសៀង**ទុកជាទីប្រឹក្សា ហើយឲ្យ ចាត់ចែងបែងទាហានកបន្ទាយរាយរបាំង តាំងជីកគូលើកកំពែងយ៉ាងមាំមួន រួច កេណ្ឌទាហានឲ្យឡើងលើសើនក្រវើនចាំគយល្បាតប្រយ័ត្នការគ្រប់បន្ទាយ។

ឯ**ម៉ាថេង** និង**ហាន់ស៊ុយ**លើកទាហានទៅសន្ធប់ ផ្ទាប់ជើងកំពែងស្រុកជុំ បរិវេណប្រហែលពីរខែ។ ឯទាហានក្នុងកងទ័ពនោះក៏ដាច់ស្បៀងអាហារជាយូរថ្ងៃ មានសេចក្ដីស្រេកឃ្លានពន់ប្រមាណណាស់។ **ម៉ាថេងនិងហាន់ស៊ុយ**លើកទាហាន របស់ខ្លួនដាច់ស្បៀងអាហារដូច្នោះ ក៏ប្រឹក្សាគ្នានឹងឲ្យលើកកងទ័ពត្រឡប់ទៅវិញ នៅកំពុងជជែគ្នា។

ខណៈនោះមានបម្រើស្និទ្ធរបស់**ម៉ាហ៊្វូ** លបនាំព័ត៌មានទៅប្រាប់**លីឈុយ, គុយគី**ថា **ម៉ាហ៊្វូ**ជានាយខ្ញុំបាទគប់គិតនឹង**តុងសៀវ, ឡៅឈៀ**ទទួលធ្វើជាកលសឹក ទើប**ម៉ាថេង**លើកពលមកធ្វើសង្គ្រាម។ **លីឈុយ, គុយគី**ឮដូច្នោះខឹងណាស់ ទើបឲ្យ ទាហានទៅចាប់**ម៉ាហ៊្វូ, តុងសៀវ** និង**ឡៅឈៀ**ហើយនិងភរិយាបុត្រញាតិសន្តាន បានហើយឲ្យនាំយកទៅសម្លាប់ទាំងអស់ កាត់ក្បាលមេទាំងបីនាក់ដោយផ្ចាលទុក

នៅមុខសើន ឲ្យសត្រូវក្រឡេកឃើញ។ **ម៉ាថេង** និង**ហាន់ស៊ុយ**ឃើញដូច្នោះក៏ប្រឹក្សាគ្នាថា “កលសឹកក្នុងស្រុកក្រុងបែកខ្ចាត់ខ្ចាយហើយ ទាហានក្នុងកងទ័ពក៏ដាច់ស្បៀងអាហារទៀត បើនឹងឡោមព័ទ្ធក្រុងទុកដូច្នេះ មុខជានឹងខូចខាតទាហានច្រើនណាស់” លុះប្រឹក្សាព្រមព្រៀងគ្នាហើយ ទើបលើកទ័ពត្រឡប់ទៅវិញ។

**លីឈុយ, គុយគី**ឃើញដូច្នោះ ទើបឲ្យ**តៀវចេ**លើកទាហានទៅតាម**ម៉ាថេង**មួយកង ឲ្យ**ហួនតៀវ**លើកទាហានទៅតាម**ហាន់ស៊ុយ**មួយកង លុះទៅដល់ភ្នំតាន់ឆង **ហាន់ស៊ុយ**ក្រឡេកមកឃើញ**ហួនតៀវ**ក៏ស្រែថា អ្នកនិងយើងជាមនុស្សនៅស្រុកជាមួយគ្នាមកពីតូច ហេតុម្តេចក៏ភ្លេចសេចក្តីមេត្រីសោះ ត្រឡប់មកធ្វើអន្តរាយដល់យើង។ **ហួនតៀវ**តបថា សព្វថ្ងៃនេះ រាជការក្នុងស្រុកក្រុងជាកម្មសិទ្ធិលើ**លីឈុយ, គុយគី** បានប្រើយើងលើកទាហានមកតាមអ្នកគ្រានេះ ប្រយោជន៍នឹងប្រហារជីវិតអ្នក ដែលយើងនឹងយល់មុខអ្នកជាអ្វីនោះមិនបានទេ។ **ហាន់ស៊ុយ**តបថា យើងលើកទាហានមកធ្វើសង្គ្រាមគ្រានេះ ក៏ព្រោះតែនឹងជួយទំនុកបម្រុងផែនដីឲ្យបានសេចក្តីសុខ បើអ្នកមិនគិតដល់យើងក៏វាហីទៅចុះ តែត្រូវគិតដល់ព្រះចៅ**ហៀនតេ**ជាម្ចាស់ផែនដី ព្រោះអ្នកជាមន្ត្រីស្តេចដូចគ្នា។ **ហួនតៀវ**បានឮ**ហាន់ស៊ុយ**និយាយដូច្នោះ ក៏នឹកឃើញសេចក្តីកតញ្ញូឡើង ក្នុងចិត្តនឹកអាណិត**ហាន់ស៊ុយ** ទើបឲ្យទាហានបង្អង់ឈប់នៅទីនោះ ឯ**ហាន់ស៊ុយ**ក៏ស្រូតលើកទាហានទៅស្រុកប៉េងជីវ។

ឯ**តៀវចេ**ដែលលើកទាហានទៅតាម**ម៉ាថេង**នោះ លុះមិនទាន់ហើយក៏ត្រឡប់ទាហានមកតាំងនៅជាមួយនឹង**ហួនតៀវ**។ ឯ**លីបៀត**ដែលជាក្មួយ**លីឈុយ**នៅជាមួយនឹងកងទ័ព**ហួនតៀវ** លុះឃើញ**ហួនតៀវ**មិនបានចាប់**ហាន់ស៊ុយ**ដូច្នោះ ក៏នាំយកសេចក្តីនោះចូលទៅប្រាប់**លីឈុយ**ជាមា។ **លីឈុយ**ឮហើយក៏នឹកខឹងណាស់ គិតនឹងប្រើទាហានឲ្យទៅចាប់**ហួនតៀវ**។ **កាសៀង**ដឹងដូច្នោះ ក៏ឃាត់**លីឈុយ**ថា

ឥឡូវស្រុកទេសកំពុងវឹកវរចលាចល ដែលនឹងប្រើកលទៅចាប់**ហ្លួនតៀវ**នោះ ឃើញថា**ហ្លួនតៀវ**មិនមែនព្រមឲ្យចាប់ដោយងាយទេ មុខជានឹងកើតសឹកសាម សង្គ្រាមជ័យនឹងគ្នាមិនខាន សូមឲ្យចាត់មនុស្សចេញទៅប្រាប់**ហ្លួនតៀវ, តៀវចេ** ដោយល្អវិញថា ដែលលើកទៅតាម**ម៉ាថេង, ហាន់ស៊ុយ**មិនទាន់នោះក៏វាហើទៅចុះ ឥឡូវត្រូវយើងរៀបលៀងអាហារ អញ្ជើញនាហ្មឺនទាំងអស់មកបរិភោគជាសប្បាយ ហើយឲ្យបម្រើទៅហៅ**ហ្លួនតៀវ, តៀវចេ** ចូលមកបរិភោគអាហារជាមួយ កាលបើចូលមកហើយសឹមយើងឲ្យចាប់**ហ្លួនតៀវ**សម្លាប់ចេញ កាលបើដូច្នោះទើបមិនមានភ្ញាក់ផ្អើលជ្រួលច្របល់។ **លីឈ្យុយ**បានស្ដាប់យល់ឃើញថាស្រួលហើយ ក៏រៀបចំអាហារភោជន ចាត់មនុស្សឲ្យចេញទៅហៅ**ហ្លួនតៀវ** និង**តៀវចេ**ចូលមកបរិភោគអាហារ។ ឯ**ហ្លួនតៀវ** និង**តៀវចេ** មិនបានដឹងកលឧបាយសោះ ក៏លើកទាហានត្រឡប់ចូលមកកាន់ក្រុងវិញ ហើយចូលទៅបរិភោគអាហារជាមួយនឹង**លីឈ្យុយ, គុយគី**។ កាលកំពុងផឹកស្រា **លីឈ្យុយ**និយាយនឹង**ហ្លួនតៀវ**ថា យើងឲ្យលើកទាហានទៅតាមចាប់**ហាន់ស៊ុយ** ហេតុម្ដេចខ្លួនមិនធ្វើតាមពាក្យយើង ត្រឡប់ប្រែចិត្តទៅអាណិត**ហាន់ស៊ុយ**វិញ ខ្លួននឹងគិតគំនិតអាក្រក់ស្អប់យើងឬ? **ហ្លួនតៀវ**ឮដូច្នោះភ័យណាស់ មិនទាន់ឆ្លើយថាប្រការម្ដេច ពេជ្ឈឃាដស្ទុះទៅចោមចាប់ខ្លួន**ហ្លួនតៀវ**យកទៅមួយរំពេច ហើយកាត់យកក្បាលមកជូន**លីឈ្យុយ**មើល។

**តៀវចេ**ឃើញដូច្នោះ មិនដឹងជាមានហេតុអ្វី ភ័យណាស់ក៏ឱនមុខក្រាបនៅគែមតុ។ **លីឈ្យុយ**ក៏ទៅគ្រាហ៍លើកឡើងហើយប្រាប់ថា **ហ្លួនតៀវ**ប្រែចិត្តក្បត់ហើយ បែរទៅចូលគំនិតគ្នានឹង**ហាន់ស៊ុយ**គិតប្រទូសរាយយើងវិញ បានជាយើងធ្វើដូច្នេះ។ ឯចំណែកខ្លួនអ្នកមិនមានរឿងខុសពីអ្វីទេ កុំឲ្យភ័យបារម្ភ។ ថាហើយ

ប្រគល់ពលទាហានដែល**ហួនតៀវ**នាំមកនោះឲ្យទៅ**តៀវចេ**ទាំងអស់ ហើយចាត់ប្រើ**តៀវចេ**ឲ្យលើកពលទៅរក្សាស្រុកហាងឡុងដូចដើម។

ក្នុងសម័យនោះ មនុស្សម្នាបណ្ដាដែលមាននៅក្នុងក្រុងទៀងហាន់ ក៏កាន់តែមានសេចក្ដីកោតញញើតខ្លាច**លីឈុយ, គុយគី**។ ឯ**កាសៀង**នោះ ក៏ចេះតែនិយាយពន្យល់**លីឈុយ, គុយគី**ឲ្យយកចិត្តអាណិតស្រឡាញ់នាហ្មឺន និងរាស្ត្រក្នុងស្រុកក្រុងឲ្យផ្លុងចិត្តគិតរាប់អានមកវិញ បណ្ដានាហ្មឺន និងរាស្ត្រសឹងនៅក្រោមអំណាច**លីឈុយ, គុយគី**ទាំងអស់។

គ្រានោះ មានសំបុត្រមកពីស្រុកសៀងជីវថា មានពួកចោរជួតក្បាលលឿងប្រមាណសាមឬសែសិបម៉ឺន ត្រាច់រង្កាត់ធ្វើទុក្ខបុកម្នេញអាណាប្រជានុរាស្ត្រជាចលាចល។ **លីឈុយ, គុយគី**បានឃើញសំបុត្រហើយក៏ប្រឹក្សានឹងនាហ្មឺនទាំងពួងថា ដែលកើតចោរអន្តរាយគ្រប់ខេត្តខណ្ឌដូច្នេះ យើងត្រូវគិតយ៉ាងណាទើបនឹងកម្រាបពួកចោរទាំងនោះបាន? **ជូហ៊ី**ឆ្លើយថា ដែលកើតចោរកម្មប្រជុំនៅក្នុងស្រុកសៀងជីវនោះ ខ្ញុំបាទឃើញតែ**ចូឆូ**មួយនាក់ដែលមានថ្វីដៃខ្លាំងពូកែ បើនឹងចាត់ឲ្យទៅប្រាបប្រាមពួកអាចោរ ដែលនៅខាងទិសឯកើតនោះ មុខជានឹងបានសម្រេចដូចបំណង។ **លីឈុយ, គុយគី**សួរតបទៅវិញថា **ចូឆូ**នោះសព្វថ្ងៃនៅឯណា? **ជូហ៊ី**ឆ្លើយថា **ចូឆូ**នោះបានមកធ្វើទ័ពជាមួយនឹង**អួនសៀវ**កាលគ្រាចម្បាំងនឹង**តាំងតុះ** ឥឡូវត្រឡប់ទៅនៅស្រុកចុងគុនមានសេនាទាហានជាច្រើន បើលោកត្រូវការសុំឲ្យមានសំបុត្រព្រះតម្រាស់ព្រះចៅ**ហៀនតេ**ចេញទៅ បង្គាប់ឲ្យ**ចូឆូ**លើកកងទ័ពទៅបង្ក្រាបពួកចោរក្នុងស្រុកសៀងជីវចុះ។ **លីឈុយ, គុយគី**យល់ឃើញថាត្រូវ ក៏តែងសំបុត្រព្រះតម្រាស់ពីរច្បាប់ មួយច្បាប់ប្រាប់ទៅ**ប៉ៅស៊ិន**ចៅហ្វាយស្រុកប៉ាក់ប៉េង សំបុត្រមួយ

ច្បាប់ទៀតប្រាប់ទៅ**ចូឆ្វ** ឲ្យលើកទាហានរួមគ្នាទៅបង្ក្រាបពួកចោរក្នុងដែនស្រុកសៀងជីវ។

ឯ**ប៉ៅស៊ិន** ដល់បានទទួលព្រះតម្រាស់ហើយ ក៏ចាត់ចែងកេណ្ឌទាហានលើកទៅរក**ចូឆ្វ** ៗទទួលសំបុត្រព្រះតម្រាស់មកមើលដឹងហើយ មានសេចក្ដីត្រេកអរណាស់ តាំងតែកេណ្ឌសេនាទាហានបានជាច្រើន ហើយនាំ**ប៉ៅស៊ិន**លើកពលទៅតំបន់ស៊ីវស៊ិនក្នុងដែនស្រុកសៀងជីវ បានជួបប្រទះពួកចោរជូតក្បាលលឿងមួយពួកតាំងភ្ជុំគ្នាជាច្រើន **ប៉ៅស៊ិន**សុំយកអាសាចេញទៅតតាំងច្បាំងនឹងពួកចោរ ៗក៏តទល់គ្នាជារបឹងរបាញណាស់ ទាហានចោរលើកគ្នាចោមព័ទ្ធសម្លាប់**ប៉ៅស៊ិន**ស្លាប់ក្នុងទីនោះ។

**ចូឆ្វ**ឃើញ**ប៉ៅស៊ិន**ស្លាប់នឹកខឹងណាស់ លើកទាហានចូលទៅកាប់សម្លាប់ពួកចោរស្លាប់ជាច្រើន ហើយដេញទាហានទន្ទ្រានចូលទៅទៀតដល់ស្រុកចេប៉ាក់ ស្ទាក់ចាប់បានពួកចោរ ៗត្រឡប់ចុះចូលមកនៅនឹង**ចូឆ្វ**វិញប្រហែលបួនប្រាំម៉ឺននាក់ ហើយ**ចូឆ្វ**ឲ្យពួកចោរឈ្លើយនោះជាកងមុខ លើកទៅសង្កត់សង្កិនពួកចោរគ្រប់តំបន់។ **ចូឆ្វ**លើកទ័ពទៅបង្ក្រាបពួកចោរយូរប្រមាណពីរខែ ពួកចោរក៏ចុះចូលមកជាស្ម័គ្របក្សពួក**ចូឆ្វ**ទាំងចាស់ទាំងថ្មីបានប្រហែលសាមសិបម៉ឺន។

បណ្ដាស្រីប្រុសចាស់ក្មេង ដែលចោរចាប់ទុកជាពួកម៉ាកគ្រប់តំបន់ប្រហែលមួយរយម៉ឺននាក់ **ចូឆ្វ**ជ្រើសរើសយកតែរូបណា ដែលកាចសាហាវខ្លាំងពូកែទុកជាសេនាទាហានបានប្រហែលម្ភៃម៉ឺន រូបណាដែលចាស់ជរាពិការនិងស្រី គឺឲ្យត្រឡប់ទៅរកស៊ីធ្វើការតាមទីលំនៅរៀងខ្លួនវិញ។

**ចូឆ្វ**បកសំបុត្រចូលទៅក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ថា “ទូលព្រះបង្គំជាខ្ញុំបានបង្ក្រាបពួកចោរកំណាចរាបទាបអស់ហើយ”។ **លីឈុយ**, **គុយគី**ទទួលសំបុត្រ

ហើយនាំឡើងក្រាបបង្គំទូលព្រះចៅ**ហៀនតេ** ៗទ្រង់មានព្រះតម្រាស់ថា "**ចូឆ្វ**គ្រានេះមានសេចក្ដីគាប់ប្រសើរក្នុងរាជការណាស់" រួចទ្រង់ត្រាស់ឲ្យមានព្រះរាជប្រកាសតាំង**ចូឆ្វ**ជាទីមន្ត្រីធំ ជាចៅហ្វាយខេត្តទិសខាងកើតទាំងអស់។ **លីឈុយ, គុយគី**មិនបានគិតវែងឆ្ងាយ ក៏ធ្វើសំបុត្រតាំង**ចូឆ្វ**តាមក្រសែព្រះរាជឱង្ការ។ កាល**ចូឆ្វ**បានជាធំតាមព្រះតម្រាស់ហើយ ក៏លើកទ័ពទៅតាំងនៅស្រុកគុនជីវ ហើយបញ្ចុះបញ្ចូលពួកម៉ាក និងរើសរកអ្នកមានតម្រិះប្រាជ្ញាទុកជាទីប្រឹក្សា។ បណ្ដាមនុស្សក្នុងអាណាខេត្តទាំងនោះ សឹងតែចុះចូលមូលមកជាពួកម៉ាក**ចូឆ្វ**ច្រើនណាស់។

មានថ្ងៃមួយ **ស៊ុនហុក**ជាមា**ស៊ុនស៊ីវ**ដែលនៅនឹង**អ្វួនសៀវ**នោះប្រឹក្សាគ្នាថា **អ្វួនសៀវ**ជាមនុស្សទុច្ចរិតអាក្រក់ យើងនឹងជ្រកនៅតទៅទៀតមិនបានទេ ឥឡូវអាណាខេត្តទិសខាងកើតទាំងអស់ **ចូឆ្វ**បានជាធំត្រួតត្រាអស់ហើយ បណ្ដាមនុស្សក៏សឹងចុះចូលជាច្រើន យើងត្រូវតែចូលទៅនៅទីពឹង**ចូឆ្វ**វិញស្រួលជាង។ **ស៊ុនស៊ីវ** ជាក្មួយយល់ឃើញត្រូវផង ក៏នាំគ្នារត់ចេញពី**អ្វួនសៀវ**ទៅនៅនឹង**ចូឆ្វ**ឯស្រុកគុនជីវ។ **ចូឆ្វ**ឃើញ**ស៊ុនហុក, ស៊ុនស៊ីវ**អង់អាចមុតមាំណាស់ ទំនងដូចជាមានសតិបញ្ញាខ្លាំងពូកែ ហៅចូលទៅសួរហើយតាំងទុកជាទីប្រឹក្សា។ **ស៊ុនហុក**ជម្រាប**ចូឆ្វ**ថា ខ្ញុំបាទបានឮគេនិយាយថា **ឆៀយ៉ុក**ជាពួកស្រុកតុងគុននោះមានសតិបញ្ញាណាស់ ឥឡូវនេះមកនៅស្រុកគុនជីវនេះ ហេតុម្ដេចក៏លោកមិនល្បួងយកមកផង? **ចូឆ្វ**ថា "យើងក៏បានឮគេនិយាយល្បីល្បាញមកជាយូរហើយ តែយើងមិនទាន់ដែលឃើញខ្លួនសោះ" ថាហើយក៏ប្រើមនុស្សឲ្យទៅស៊ើបរកខ្លួន**ឆៀយ៉ុក**នាំបានមក។ **ចូឆ្វ**បានឃើញ**ឆៀយ៉ុក**ក៏មានចិត្តស្រឡាញ់ជាពន្លឹក ទើបតាំង**ឆៀយ៉ុក**ទុកជាទីប្រឹក្សា។

ឯ**ឆៀយ៉ុក**ដឹងថា **ស៊ុនហុក**ស្នើសេចក្ដីគុណគាប់របស់ខ្លួនឲ្យ**ចូឆ្វ**ដឹងដូច្នោះ ក៏មានសេចក្ដីអរគុណនឹង**ស៊ុនហុក**ច្រើនហើយថា ខ្លួនខ្ញុំនេះមានសតិបញ្ញាតិចណាស់

បើ**គុយកែ** ដែលនៅស្រុកជាមួយនឹងអ្នកនោះ ទើបមានសតិបញ្ញាច្រើន ហេតុម្ដេចអ្នកមិនស្នើឲ្យយកខ្លួន**គុយកែ**មកធ្វើរាជការផង? **ស៊ុនហុក**ឆ្លើយថា ខ្ញុំភ្លេចទៅហើយទាល់តែអ្នកនាំនឹក ឥឡូវនេះខ្ញុំក៏រឭកឡើងបាន។ **ស៊ុនហុក**បានយកសេចក្ដីនោះទៅជម្រាប**ចូវឆូ** ៗឲ្យទៅយកខ្លួន**គុយកែ**មក។ **គុយកែ**ជម្រាប**ចូវឆូ**ថា **ឡៅហ៊្វី**ជាពូជព្រះរាជវង្ស**ហាន់កងប៊ូ១**, **ប៊ូកចុក**ពួកអ្នកស្រុកសាន់យ៉ុង១, **លីគៀន**ពួកអ្នកស្រុកប៊ូសេង១, **ម៉ាកាយ**ពួកអ្នកស្រុកតាន់លីវ១, ទាំងបួននាក់នេះមានសតិបញ្ញាច្រើន។ **ចូវឆូ**ចាត់ឲ្យទៅបញ្ចុះបញ្ចូលឈ្មោះទាំងបួននាក់នោះមកបានទៀត ហើយតាំងទុកជាទីប្រឹក្សា។

ឯ**អ៊ីគឹម**ពួកអ្នកស្រុកគីប៉េង ដែលជាចោរមានបក្សពួកច្រើន ក៏នាំយកបក្សពួកចូលមកនៅជាទាហាន**ចូវឆូ**ទាំងអស់។ **ហែហ្គូទុន**នាំ**តៀនអ៊ុយ**មកនៅជាពួក**ចូវឆូ**ទៀត ហើយជម្រាបថា **តៀនអ៊ុយ**នេះពួកអ្នកស្រុកតាន់លីវ មានកម្លាំងខ្លាំងពូកែណាស់ សម្លាប់បាវព្រាវ**តៀវម៉ៅ**អស់ជាច្រើន ហើយរត់ទៅនៅព្រៃ ខ្ញុំបាទចេញទៅដើរលេងឃើញ**តៀនអ៊ុយ**វាយខ្លាស្លាប់ ហើយហែលឆ្លងសមុទ្រមកជួបនឹងខ្ញុំបាទ ៗឃើញសមគួរជាទាហានណាស់ ក៏ល្បួងលួងលោមឲ្យមកនៅនឹងលោក។ **ចូវឆូ**បានស្ដាប់ពិនិត្យមើលរូបភាព**តៀនអ៊ុយ**ឃើញរូបរាងធំមាំមួនសមគួរជាទាហាន ទើបសួរបញ្ជាក់**តៀនអ៊ុយ**ថា បើខ្លួនធ្វើទាហាននោះតើនឹងចូលចិត្តកាន់ប្រដាប់អ្វីជាអាវុធ? **តៀនអ៊ុយ**ឆ្លើយថា ខ្ញុំបាទធ្លាប់ចំណានខាងកាន់ទួនផ្លែពីរ ទម្ងន់ប៉ែតសិបជញ្ជីងចិន មានសម្រាប់ខ្លួនខ្ញុំបានហើយ។ **ចូវឆូ**បានឮចាត់ឲ្យរកសេះជំនិះមួយ មានថ្វីជើងពូកែ ឲ្យ**តៀនអ៊ុយ**ឡើងជិះរាំទួនល្បងមើល។ **ចូវឆូ**ឃើញ**តៀនអ៊ុយ**ជិះសេះរាំទួនរហ័សរហួនយ៉ាងចំណាប់ ក្រឡេកមើលទៅឃើញដងទង់ជ័យសម្រាប់ទ័ព ដែលលើកទុកនៅមុខទ្វារស្រុកត្រូវខ្យល់ព្យុះទ្រេតចុះនឹងរលំ មានទាហានម្ភៃប្រាំនាក់កំពុង

ប្រានលើកឡើងក៏មិនទាន់កម្រើក **ចូឆូ**ប្រើ**តៀនអ៊ុយ**ឲ្យទៅជួយលើក។ **តៀនអ៊ុយ**លោតចុះពីលើសេះ រត់ទៅដេញទាហានទាំងនោះឲ្យដើរចេញ។ **តៀនអ៊ុយ**ចូលទៅលើកដងទង់នោះតម្រង់ឈរឡើងដូចដើម។ **ចូឆូ**ឃើញដូច្នោះ ក៏សរសើរ**តៀនអ៊ុយ**ថាមានកម្លាំងដូចមនុស្សពីបុរាណ ហើយចាត់គ្រឿងក្រោះដែកមួយប្រដាប់ឲ្យ**តៀនអ៊ុយ** តាំងជានាយទាហានសម្រាប់រក្សាខ្លួន**ចូឆូ**។

*ចប់សៀវភៅទីមួយ*

*សូមរង់ចាំអានសៀវភៅទីពីរ បន្តទៀត។*

*សូមអរគុណ។*

*ណុល ដារ៉ា*